ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

ដើម្បីកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព

ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

ជានិច្ចកាល រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច សង្គម ជាមួយនឹងស្មារតីសាមគ្គីជាតិមួយរឹងមាំតាមរយៈការប្រមូលកម្លាំងប្រជាជាតិទាំងមូលពីគ្រប់មជ្ឈដ្ឋាន គ្រប់និន្នាការនយោបាយ ទាំងក្នុងទាំងក្រៅប្រទេសឱ្យទៅជាផ្លូងមួយក្រោមបាវចនា "**ជាតិ សាសនា ព្រះមហាក្សត្រ** " ដើម្បីធានាឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី សុខសន្តិភាព ភាពសុខដុម ប្រជាធិបតេយ្យ និងវឌ្ឍនភាពដ៏ចុំថ្កើងរុងរឿង។ ជាក់ស្តែង ដូចបានកំណត់ច្បាស់លាស់ក្នុង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**(ផ.យ.អ.ជ.) **២០១៩-២០២៣** ដែលបានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា សមិទ្ធផលធំៗជាច្រើនត្រូវបានបង្កើតឡើងក្នុងរយៈពេលពីរឆ្នាំកន្លះដំបូងនៃការអនុវត្ត**ផ.យ.អ.ជ. ២០១៩-២០២៣** ទោះបីជាត្រូវប្រឈមជាមួយបញ្ហាចម្បងៗជាច្រើនក៏ដោយ ជាពិសេសការរីករាលដាលនៃជំងឺកូវីដ-១៩។ ការរីករាលដាលនៃជំងឺកូវីដ-១៩ នេះ មិនត្រឹមតែបានរារាំងដល់ការសម្រេចបានគោលដៅអភិវឌ្ឍន៍ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានគំរាមបំផ្លាញសមិទ្ធផលដែលយើងសម្រេចបានក្នុងរយៈពេលកន្លងមកទៀតផងដែរ។

ទោះបីជាបានជួបនូវបញ្ហាប្រឈមយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវជោគជ័យធំៗគួរជាទីមោទនៈ ក្នុងរយៈពេលពាក់កណ្តាលអាណត្តិនៃ**ផ.យ.អ.ជ. ២០១៩-២០២៣** នេះ ក្នុងការនាំប្រទេសជាតិទាំងមូលឱ្យបានឆ្លងផុតស្ថានភាពដ៏លំបាកទាំងនេះ តាមរយៈការផ្តល់អន្តរាគមន៍បន្ទាន់និងការព្យាបាលជំងឺកូវីដ-១៩ និងការស្វែងរកវ៉ាក់សាំងកូវីដ-១៩ចាក់ជូនប្រជាជនដោយមិនគិតថ្លៃ និងក្នុងការបង្កឱ្យមានបរិយាកាសអំណោយផលសម្រាប់ការធានាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការស្តារនិងជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនឡើងវិញ និងការសម្រេចបាននូវវឌ្ឍនភាពក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ក្រោយរួចចាកផុតពីផលប៉ះពាល់នៃការរីករាលដាលនៃជំងឺកូវីដ-១៩។

ទោះជាដូចនេះក្តី ការងារដែលយើងទាំងអស់គ្នាត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយនោះ គឺការកំណត់យុទ្ធសាស្ត្រនិងគោលនយោបាយឱ្យបានត្រឹមត្រូវនិងសមស្របតាមបរិការណ៍សេដ្ឋកិច្ច សង្គម ជាក់ស្តែងរបស់យើង និងការអនុវត្តយុទ្ធសាស្ត្រនិងគោលនយោបាយទាំងនោះប្រកបដោយសក្តិសិទ្ធិភាព សំដៅធានាឱ្យបាននូវសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមដែលជាបុព្វបទសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាពនិងសមធម៌។ ក្នុងន័យនេះ វឌ្ឍនភាពត្រូវតែជំរុញឱ្យលឿនជាងមុន មានមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុននៅក្នុងវិស័យសំខាន់ៗ ហើយបញ្ហាប្រឈម

ទាំងឡាយដែលកំពុងកើតមាននិងមានពីមុន ត្រូវដោះស្រាយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ កំណែទម្រង់ជាច្រើនក្នុងការងារអភិបាលកិច្ច ត្រូវតែជំរុញល្បឿនបន្ថែមទៀត ដែលក្នុងនោះ រួមមានការបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ការលើកកម្ពស់សមត្ថភាពជំនាញ និងការធ្វើឱ្យប្រសើរឡើងនូវការងារសម្របសម្រួលក្នុងចំណោមក្រសួង ស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង ការបន្តផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើតំបន់ជនបទ គឺជាការងារចាំបាច់ដែលនឹងជួយប្រែក្លាយតំបន់ទាំងនោះឱ្យទៅជាមជ្ឈមណ្ឌលដែលមានការអភិវឌ្ឍលឿនជាងមុន សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ហើយដែលនឹងជួយផងដែរដល់ការកាត់បន្ថយភាពក្រីក្រដែលភាគច្រើននៅមានកម្រិតខ្ពស់នៅតំបន់នោះ។ លើសពីនេះ ការបន្តលើកកម្ពស់បន្ថែមទៀតលើវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំនិងវិស័យសុខាភិបាលជាការងារអាទិភាពផងដែរ សម្រាប់ការរួមចំណែកធ្វើឱ្យសម្រេចបានកំណើនសេដ្ឋកិច្ច។

ការវិវឌ្ឍដូចបានពោលពីខាងដើម មិនមែនគ្រាន់តែជាបញ្ហាចម្បងធំៗដែលត្រូវប្រឈមនៅពេលខាងមុខនោះទេ ប៉ុន្តែក៏ផ្តល់ផងដែរនូវកាលានុវត្តភាពដ៏មានតម្លៃសម្រាប់ការកែប្រែទ្រង់ទ្រាយមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព ដោយមិនពឹងផ្អែកតែលើវិស័យតែពីរឬបីដែលអាចងាយរងផលប៉ះពាល់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់លើវិស័យរួមចំណែកជំរុញកំណើនប្រកបដោយបរិយាបន្ន ប៉ុន្តែមិនទាន់បានប្រើប្រាស់អស់លទ្ធភាព និងលើការអភិវឌ្ឍនៅតំបន់ជនបទ សំដៅពង្រីកមូលដ្ឋានសេដ្ឋកិច្ចនិងដើម្បីធ្វើឱ្យកំណើននេះមានចីរភាពក្នុងរយៈ-ពេលវែង ព្រមទាំងរួមចំណែកកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទឱ្យបានកាន់តែឆាប់រហ័ស។ លទ្ធផលនឹងអាចទទួលបានតាមរយៈការបង្កើនផលិតភាពកសិកម្មនិងការបង្កើនចំណូលរបស់ប្រជាជននៅតំបន់ជនបទនោះ។

ខ្ញុំមានសេចក្តីរីករាយនឹងដាក់ចេញនូវ**របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ ស្តីពីការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣** ដែលគ្របដណ្តប់ការវិវឌ្ឍទាំងអស់ដែលបានកើតមានឡើងចាប់តាំងពីខែមករា ឆ្នាំ២០១៩មក តាមរបៀបមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានគុណភាពផ្អែកខ្លឹមសារដោយមិនលម្អៀងទៅផ្នែកណាមួយ។ ឯកសារនេះបង្ហាញពីទិដ្ឋភាពរួមនៃស្ថានភាពរបស់កម្ពុជាទាំងមូល ហើយផ្តល់នូវការណែនាំសម្រាប់ការអនុវត្តនៅពេលខាងមុខ។ របាយការណ៍នេះបានសង្កត់ធ្ងន់លើការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស តាមរយៈគោលនយោបាយនិងសកម្មភាពគាំទ្រដល់ប្រជាជនក្រីក្រនិងងាយរងគ្រោះ។ ដើម្បីសម្រេចបានគោលដៅនេះ ទាមទារឱ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ចរឹងមាំដែលមានមូលដ្ឋានទូលាយជាងមុន មានសមត្ថភាពប្រកួតប្រជែងជាងមុន ព្រមទាំងមានមូលដ្ឋានប្រកបដោយពិពិធភាពនៅតំបន់ជនបទ និងដែលផ្អែកលើការបង្កើនផលិតភាពកសិកម្មរួមគ្នាជាមួយនឹងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងដីធ្លីនិងការជំរុញការអភិវឌ្ឍជនបទ។ **របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ ស្តីពីការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣** គឺជាឯកសារមួយយ៉ាងសំខាន់និងជារបៀបវារៈការងារមួយសម្រាប់ឈានទៅសម្រេចបានអាទិភាពជាតិនានាក្នុងរយៈពេលខ្លីខាងមុខនេះ។

ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍរបស់យើងទាំងអស់ ឱ្យផ្តោតការយកចិត្តទុកដាក់លើលទ្ធផលដោយលើកកម្ពស់ប្រសិទ្ធភាពធនធានអភិវឌ្ឍន៍ដ៏មានកម្រិត ទាំងពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍទាំងពីប្រភព

ថវិកាជាតិ ដើម្បីរួមគ្នាឈានទៅសម្រេចបានអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និង **ផ.យ.អ.ជ. ២០១៩-២០២៣។**

ថ្ងៃ ចន្ទ ៨កើត ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ២០២២

**ហ៊ុន សែន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា






# កម្ពុជា : សូចនាករសេដ្ឋកិច្ច សង្គមកិច្ចសំខាន់ៗ

## ព័ត៌មានទូទៅ

| | |
|---|---|
| ផ្ទៃដីសរុប : (គម$^2$ ) | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៤ |
| ចំនួនក្រុង | ២៧ |
| ចំនួនខណ្ឌ | ១៤ |
| ចំនួនស្រុក | ១៦២ |
| ចំនួនសង្កាត់ | ២៤១ |
| ចំនួនឃុំ | ១ ៤០៥ |
| ចំនួនភូមិ | ១៤ ៣៨៣ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល(៛) |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| **១.00** | **អត្រានៃភាពក្រីក្រ** | | | | | | |
| ១.0១ | សរុបទូទាំងប្រទេស | %នៃប្រជាជន | | ១៧,៨ | ២១,៥ | | ១៩,0 |
| | | | | | | | |
| **២.00** | **ប្រជាជន**[1] | | | | | | |
| ២.0១ | ប្រជាជនសរុប | លាននាក់ | ១៦,១ | ១៦,៣ | ១៦,៦ | ១៦,៨ | ១៧,0 |
| ២.0២ | ដង់ស៊ីតេប្រជាជន | ក្នុងមួយគម$^2$ | ៩0,៣ | ៩១,៨ | ៩៣,២ | ៩៤,៦ | ៩៦,0 |
| ២.0៣ | បុរសធៀបនឹងស្ត្រី | ស្ត្រី១00នាក់ | ៩៤,៨ | ៩៥,0 | ៩៥,២ | ៩៥,៤ | ៩៥,៦ |
| ២.0៤ | អាយុ0-១៤ឆ្នាំ | % នៃប្រជាជន | ២៩,៦ | ២៩,២ | ២៨,៦ | ២៨,0 | ២៧,៤ |
| ២.0៥ | អាយុ១៥-៦៤ឆ្នាំ | % នៃប្រជាជន | ៦៤,៥ | ៦៤,៨ | ៦៥,៣ | ៦៥,៧ | ៦៦,១ |
| ២.0៦ | អាយុ៦៥ឆ្នាំឡើង | % នៃប្រជាជន | ៥,៨ | ៦,0 | ៦,២ | ៦,៣ | ៦,៦ |
| ២.0៧ | ជនបទ | % នៃប្រជាជន | ៦0,៦ | ៦0,៩ | ៦0,៧ | ៦0,៨ | ៦0,៨ |
| ២.0៨ | ទីប្រជុំជន | % នៃប្រជាជន | ៣៩,៤ | ៣៩,១ | ៣៩,៣ | ៣៩,២ | ៣៩,២ |
| ២.0៩ | អត្រាកំណើនប្រចាំឆ្នាំ | % | ១,៤ | ១,៦ | ១,៥ | ១,៥ | ១,៥ |
| ២.១0 | អត្រាបង្កើតកូនសរុប(ក្នុងស្ត្រីម្នាក់) | កំណើតរស់ | ២,៥ | ២,៤ | ២,៤ | ២,៣ | ២,៣ |
| ២.១១ | អាយុកាលមធ្យមសង្ឃឹមរស់ពីកំណើត ប្រុស | ឆ្នាំ | ៧៤,៣ | ៧៥,0 | ៧៥,៧ | ៧៦,៤ | ៧៧,១ |
| | ស្ត្រី | ឆ្នាំ | ៧៦,៨ | ៧៧,៣ | ៧៧,៩ | ៧៨,៦ | ៧៩,២ |
| | | | | | | | |
| **៣.00** | **ម៉ាក្រូសេដ្ឋកិច្ច** | | | | | | |
| ៣.0១ | ផ.ស.ស. ថ្លៃបច្ចុប្បន្ន | ប៊ីលានរៀល | ១១0 0១៤ | ១0៩ 0៦២ | ១១៥ ២១៣ | ១២៤ ១៦២ | ១៣៤ ៩៩៧ |
| ៣.0២ | ផ.ស.ស. ថ្លៃបច្ចុប្បន្ន | លានដុល្លារ | ២៧ ១៣0 | ២៦ ៧៣១ | ២៨ ៣៤៣ | ៣0 ៥៤៤ | ៣៣ ២១0 |

[1] ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ៣.០៣ | អត្រាកំណើនផ.ស.ស.ពិត | % | ៧,១ | -៣,១ | ២,៤ | ៤,៨ | ៦,២ |
| ៣.០៤ | កសិកម្ម | % | -០,៥ | ០,៥ | ១,៤ | ១,១ | ១,២ |
| ៣.០៥ | ឧស្សាហកម្ម | % | ១១,៣ | -១,២ | ៥,៧ | ៧,៧ | ៩,២ |
| ៣.០៦ | សេវា | % | ៦,២ | -៦,៧ | ០,៣ | ៤,១ | ៥,៦ |
| ៣.០៧ | ផ.ស.ស.សម្រាប់ប្រជាជនម្នាក់ៗ | ពាន់រៀល | ៦ ៨៩៤ | ៦ ៧៤៥ | ៧ ០៣៤ | ៧ ៤៨៧ | ៨ ០៤៤ |
| ៣.០៨ | ផ.ស.ស.សម្រាប់ប្រជាជនម្នាក់ៗ | ដុល្លារ | ១ ៧០០,១ | ១ ៦៥៣,១ | ១ ៧៣០,៤ | ១ ៨៤២,៨ | ១ ៩៧៩,៨ |
| ៣.០៩ | អតិផរណា(ការប្រែប្រួលមធ្យមប្រចាំឆ្នាំ) | % | ១,៨ | ២,៩ | ៣,៤ | ២,៨ | ៣,០ |
| ៣.១០ | ប្រាក់រៀលធៀបនឹងដុល្លារ(មធ្យមប្រចាំឆ្នាំ) | រៀល/ដុល្លារ | ៤ ០៥៥ | ៤ ០៨០ | ៤ ០៦៥ | ៤ ០៦៥ | ៤ ០៦៥ |
| ៣.១១ | ទុនបម្រុងបរទេសដុល | ចំនួនខែនាំចូល | ៨,៨ | ១៣,៤ | ១០,៩ | ១០,១ | ៩,៣ |
| ៣.១២ | ទុនបម្រុងបរទេសដុល | លានដុល្លារ | ១៨ ៧៦៣ | ២១ ៣៣៤ | ២១ ៦១៧ | ២២ ១១៨ | ២២ ៧៣២ |
| ៣.១៣ | ការវិនិយោគផ្ទាល់បរទេស | លានដុល្លារ | ៣ ៥៦១,២ | ៣ ៤៩៧,៦ | ៣ ៤៥១,៧ | ៣ ៨៥៧,៧ | ៤ ៣៤៥,០ |
| | | | | | | | |
| **៤.០០** | **សារពើពន្ធ** | | | | | | |
| ៤.០១ | ចំណូលថវិកាសរុប | %នៃផ.ស.ស. | ២៥,២ | ២១,៨ | ១៩,២ | ២០,៦ | ២០,២ |
| ៤.០២ | ចំណាយថវិកាសរុប | %នៃផ.ស.ស. | ២៥,៩ | ២៨,១ | ៣០,៥ | ២៨,០ | ២៩,១ |
| ៤.០៣ | អតិរេកចរន្ត | %នៃផ.ស.ស. | ៧,២ | ៤,១ | ០,០ | ២,៨ | ២,០ |
| | | | | | | | |
| **៥.០០** | **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | |
| ៥.០១ | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | ៣,៣៣៥ | ៣,៣៤៥ | ៣,៣៣ | ៣,២១ | ៣,២៣ |
| ៥.០២ | ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | ៣,៣៤ | ៣,៤០ | ៣,៣ | ៣,២ | ៣,២ |
| ៥.០៣ | បរិមាណផលស្រូវ | លានតោន | ១០,៨៩ | ១០,៩៤ | ១០,០ | ១០,២ | ១០,៥ |
| ៥.០៤ | ផលិតផលស្រូវផលិតលើស | លានតោន | ៥,៨៣ | ៥,៩២ | ៥,៤១ | ៥,៦០ | ៥,៧៩ |
| ៥.០៥ | ផ្ទៃដីដាំដុះដំណាំគ្រប់មុខ | លានហ.ត. | ៤,៨៨ | ៤,៩១ | ៤,៩៦ | ៥,០១ | ៥,០៦ |
| ៥.០៦ | ចំនួនសហគមន៍កសិកម្ម(បង្កើត) | ចំនួន | ១១៩០ | ១ ២០០ | ១ ២០៥ | ១ ២១០ | ១ ២១៥ |
| ៥.០៧ | ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | ៤៥,៨៥ | ៥៣,៩០ | ៣៨,០ | ៣៩,១ | ៤០,៣ |
| ៥.០៨ | សត្វដែលទទួលបានវ៉ាក់សាំង | ភាគរយ | ៤០ | ៤៣,៣៦ | ១៥ | ១៧ | ២០ |
| ៥.០៩ | ចំនួនសត្តឃាតដ្ឋានដែលអនុវត្ត អនាម័យល្អតាមស្តង់ដាបច្ចេកទេស | ចំនួនកន្លែង | ២៤ | ២៩ | ៧៥ | ១០០ | ១២៥ |
| ៥.១០ | ផ្ទៃដីដាំដុះកៅស៊ូ | ហ.ត. | ៤០៥ ៦០០ | ៤០៤.០០០ | ៣៣៤.៥០០ | ៣៦២.៥០០ | ៣៨៤.៥០០ |
| ៥.១១ | ទិន្នផលជ័រកៅស៊ូ | គ.ក្រ/ហ.ត/ឆ្នាំ | ១ ១៤៨ | ១ ១៩៤ | ១.២៨២ | ១.៣១១ | ១.៣៧៣ |
| ៥.១២ | ផលិតកម្មកៅស៊ូ | ពាន់តោន | ២៨៧ ៦០០ | ៣៤៩ ៣០០ | ១៨១.៥៦០ | ២៤០.៨០០ | ៣០០.៨០០ |
| ៥.១៣ | ផលិតកម្មវារីវប្បកម្មកើន១៥% | តោន | ៣០៧ ៤០៨ | ៤០០ ៤០០ | ១១២ ៥០០ | ១២៩ ៤០០ | ១៤៨ ៨០០ |
| ៥.១៤ | បរិមាណផលិតកម្មនេសាទ(ទឹកសាប សមុទ្រ និងវារីវប្បកម្ម) | ពាន់តោន | ៩០៩ | ៩៣៦ | ៧៩០ | ៨២៩ | ៨៧០ |
| ៥.១៥ | ចំនួនសហគមន៍នេសាទ | សហគមន៍ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ |
| ៥.១៦ | ផ្ទៃដីអភិរក្សសត្វព្រៃនិងព្រៃការពារ(បរិស្ថាន) | ហ.ត. | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ | ៥០ ០០០ |
| ៥.១៧ | ផ្ទៃដីដាំព្រៃឡើងវិញ | ហ.ត. | ១ ៤៨៧ | ២ ១៧៩ | ២៥ ០០០ | ២៥ ០០០ | ២៥ ០០០ |
| ៥.១៨ | ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើត | ចំនួន | ៤៩៤ | ០ | ៣០ | ១០ | ១០ |
| | | | | | | | |
| **៦.០០** | **ការអភិវឌ្ឍជនបទ** | | | | | | |
| ៦.០១ | ការស្តារនិងសាងសង់ផ្លូវជនបទ (លើប្រវែងសរុប៤៥ ២០០គ.ម.) | គ.ម. | ២៩ ៦៣៤ | ៣០ ៣១២ | ៣០ ៤០២ | ៣៩ ៦០៩ | ៤៣ ៥៧០ |
| ៦.០២ | ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ | គ.ម. | ២៦១ | ១៨៨ | ១៤៧ | ២០៧ | ២៤៨ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| | (DBST)ឬបេតុង | | | | | | |
| ៦.០៣ | ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការគែលម្ អប្រកបដោយនិរន្តរភាព | % | ៧៥ | ៧៧ | ៨៤ | ៨៥ | ៩០ |
| ៦.០៤ | ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យដែលមានការគែលម្អប្រកបដោយនិរន្តរភាព | % | ៧៤,៦០ | ៧៦,៩ | ៧៧ | ៨៤ | ៩១ |
| ៦.០៥ | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | ក្រុម | ១៥៤ | ១៥៥ | ១៥៦ | ១៦១ | ១៦៥ |
| ៦.០៦ | ចំនួនភូមិដែលបានបណ្តុះបណ្តាល គ.អ.ភ.ស្តីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | ២០០ | ២១០ | ២២០ | ២៣០ | ២៤០ |
| ៦.០៧ | សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ៤៥០គ.ម.ដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ១០០% | គ.ម. | ៣៣០ | ៣៥៤ | ៣៨២ | ៤១៧ | ៤៥៨ |
| ៦.០៨ | កសាងសមត្ថភាពគ.អ.ភ. ស្តីពីជម្រើសនៃបន្ស៊ាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | ៣០ | ៣៥ | ៤០ | ៤៥ | ៥០ |
| | | | | | | | |
| **៧.០០** | **ដឹកជញ្ជូន** | | | | | | |
| ៧.០១ | ផ្លូវជាតិនិងផ្លូវខេត្ត : សរុប | គ.ម. | ១៦ ៥៧០ | ១៨ ១២៥ | ១៨ ៨០៣ | ១៩ ៥២៩ | ២០ ២២៥ |
| ៧.០២ | ក្នុងនោះ ផ្លូវបេតុងនិងកៅស៊ូ | គ.ម. | ៩ ២១០ | ៩ ៦៧៣ | ១០ ២៨១ | ១០ ៨៣៤ | ១១ ៣៨៧ |
| ៧.០៣ | ផ្លូវដែក | គ.ម. | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ | ៦៥២ |
| ៧.០៤ | កំពង់ផែអន្តរជាតិ | ចំនួន | ២ | ២ | ២ | ៤ | ៤ |
| | | | | | | | |
| **៨.០០** | **សុខាភិបាល** | | | | | | |
| | **១- កម្មវិធីសុខភាពបន្តពូជ មាតា ទារកនិងកុមារ និងអាហារូបត្ថម្ភ** | | | | | | |
| ៨.០១ | អត្រាមរណភាពមាតា | ក្នុង១០០ ០០០ កំណើតរស់ | ១៤១ | | CDHS | | ១០០ (២០២៥) |
| ៨.០២ | អត្រាស្លាប់ទារក | ក្នុង១០០០ កំណើតរស់ | ១៨ | | CDHS | | ១៤ (២០២៥) |
| ៨.០៣ | អត្រាស្លាប់កុមារអាយុក្រោម៥ឆ្នាំ | ក្នុង១០០០ កំណើតរស់ | ២៨ | | CDHS | | ២៥ (២០២៥) |
| ៨.០៤ | អត្រាស្គមស្គាំងលើកុមារអាយុក្រោម៥ឆ្នាំ | % | ១០ (២០១៤) | | CDHS | | ៩ |
| ៨.០៥ | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ(១៥-៤៩ឆ្នាំ) ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្តនឹងមធ្យោបាយពន្យារកំណើតទំនើប | % | | | CDHS | | ៦២ |
| ៨.០៦ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ២០,៤៧ | ២០,១២ | ២២,១៥ | ២២ | ២៣ |
| ៨.០៧ | ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល | % | ៧៧,៨១ | ៧៤,១៤ | ៥៨,៦៨ | ៩០ | >៩០ |
| ៨.០៨ | ស្ត្រីមានគភ៌បានទទួលជីវជាតិដែក ហ្វូលីក | % | ៩១,០៥ | ៨៩,៤៧ | ៧៧,៤០ | ៨៩ | ៩០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| | អាស៊ីត៩០គ្រាប់ | | | | | | |
| ៨.០៩ | ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យថែទាំក្រោយសម្រាលលើកទី១(មុន៤៨ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល | % | ៦៦,៤១ | ៦៧,៨៣ | | ៩២ | ៩៣ |
| ៨.១០ | សមាមាត្រនៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ | % | ៨៦,៧៥ | ៨៩,១៦ | ៧៧,៥៦ | ៩២ | ៩៣ |
| ៨.១១ | ការសម្រាលដោយវះកាត់ | % | ៧,១៣ | ៧,៦៧ | ៧,៥៧ | ១០,៤ | ១០,៦ |
| ៨.១២ | ភាគរយនៃទារកបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងកំឡុងមួយម៉ោងដំបូងនៃកំណើត | % | ៦៥,៣៦ | ៧១,១៤ | ៧២,៧៦ | ៦៩ | ៦៩,៥ |
| ៨.១៣ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹលស្ទួចដូសទី១ | % | ១០២ | ១០៧,៣ | ១០១,៤ | ៩៥ | >៩៥ |
| ៨.១៤ | ការពិនិត្យពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ១,៦១ | ១,២៨ | ១,១០ | ១,៦៥ | ១,៦៧ |
| ៨.១៥ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូសបង្ការជំងឺខាន់ស្លាក់ ស្អិតដៃជើង តេតាណូស រលាកសួត | % | ៩៩,០ | ១០៦,៦ | ៩៦,៧៩ | >៩៥ | >៩៥ |
| ៨.១៦ | ភាគរយនៃកុមារអាយុ១២-៥៩ខែ បានទទួលថ្នាំទម្លាក់ព្រូនមេបង់ដាហ្សូលក្នុងអំឡុងពេល៦ខែ ចុងក្រោយនៃឆ្នាំ | % | ៧៥,១៥ | ៧៦,០ | | ៩០ | ៩០ |
| | **២- បង្ការនិងគ្រប់គ្រងជំងឺឆ្លង** | | | | | | |
| ៨.១៧ | ករណីឆ្លងថ្មីនៃមេរោគអេសដ៏ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍១ ០០០នាក់ | % | ០,០៣ | ០,០៧ | | ០,០៣ | ០,០៣ |
| ៨.១៨ | ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressedក្នុងរយៈពេល១២ខែកន្លងមក | % | ៩៦,០ | ៩៧,០ | ៩៧,០ (៦ខែ) | ៩០ | ៩៦ |
| ៨.១៩ | អាំងស៊ីដង់នៃជំងឺរបេងគ្រប់សណ្ឋានលើប្រជាជន | ១០០ ០០០ នាក់ | ២៨៧ | ២៧៤ | | ២៤៣ | ២២៦ |
| ៨.២០ | អត្រាស្លាប់ដោយជំងឺរបេងក្នុងចំណោមប្រជាជន | ១០០ ០០០ នាក់ | ១៧ | ២០ | | ១៤ | ១៣ |
| ៨.២១ | អត្រាព្យាបាលជោគជ័យនៃជំងឺរបេង | % | ៩៤ | ៩៤ | ៩៦ | >៩០ | >៩០ |
| ៨.២២ | អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់រាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈលើប្រជាជន១០០ ០០០នាក់ | ១០០ ០០០ នាក់ | ០,០០ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ៨.២៣ | អាំងស៊ីដង់នៃជំងឺគ្រុនចាញ់(ករណីថ្មី) លើប្រជាជន | ១០០០នាក់ | ១,៩ | ០,៦៥ | ០,២១ (១០ខែ) | ០,៦៥ | ០,៤០ |
| ៨.២៤ | អត្រាស្លាប់ដោយជំងឺគ្រុនឈាម | % | ០,០៧ | ០,០១ | ០,៣ | <០,២ | <០,២ |
| | **៣- បង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈ** | | | | | | |
| ៨.២៥ | ភាគរយនៃប្រជាជនអាយុពី២៥-៦៩ឆ្នាំមានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល | % | ២៣,១២ | ២៩,០៧ | | ៤៥ | ៥០ |
| ៨.២៦ | ភាគរយនៃប្រជាជនអាយុពី២៥-៦៩ឆ្នាំមានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល | % | ២៨,៦ | ៤៣,១៩ | | ២៤ | ២៦ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ៨.២៧ | ភាគរយនៃស្ត្រីអាយុ៣០ទៅ៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនយ៉ាងតិចមួយលើក | % | ០,៣១ | ០,៥៤ | | ១០ | ១២ |
| ៨.២៨ | អត្រារះកាត់ជំងឺភ្នែកឡើងបាយក្នុងចំណោមប្រជាជន១លាននាក់ | ១លាននាក់ | ២.៥៦២ | ២.៣៣៤ | ១.៣៤០ | ៣.២០០ | ៣.៣០០ |
| ៨.២៩ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់៖<br>- អាយុលើសពី១៥ឆ្នាំ<br>- អាយុពី១៣-១៥ឆ្នាំ | % | ប:៣៥,៣<br>ស:១១,៦<br>ប:២,៩<br>ស:១,៩<br>(២០១៦) | | | ១៧,៨<br>២,០ | ១៦,៨<br>១,៩ |
| ៨.៣០ | ប្រេវ៉ាឡង់នៃការប្រើប្រាស់សារជាតិអាល់កុលក្នុងចំណោមមនុស្សពេញវ័យចាប់ពីអាយុ១៨ឆ្នាំ | % | ៤៥,៥<br>(២០១៦) | | | ៤៥,១ | ៤៥,០ |
| ៨.៣១ | ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល | % | ២,២ | ១,៩ | ១,៣ | ៦ | ៧ |
| ៨.៣២ | ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល | % | ៤៥ | ៥០ | ២២,៩ | ៨០ | >៨០ |
| | **៤- ពង្រឹងប្រព័ន្ធសុខាភិបាល** | | | | | | |
| ៨.៣៣ | ភាគរយនៃមូលដ្ឋានសុខាភិបាលដែលមានស្តុកឱសថសារវន្តនិងឧបករណ៍បរិក្ខារពេទ្យចាំបាច់ដែលបានកំណត់១៥មុខ | % | ៧៣ | n.a | n.a | ៨៧ | ៨៨ |
| ៨.៣៤ | ភាគរយនៃការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្ត | % | ២១,៧ | ១៣,២ | ៦,៩៥<br>(១០ខែ) | ២១ | ២២ |
| ៨.៣៥ | ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីរបស់ប្រជាជនមួយនាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ០,៧២ | ០,៦៧ | ០,៥០ | ០,៨៧ | ០,៨៩ |
| ៨.៣៦ | អត្រាស្លាប់នៅមន្ទីរពេទ្យ | % | ០,៦២ | ០,៧៥ | ១,៣៤ | <១ | <១ |
| ៨.៣៧ | ភាគរយនៃប្រជាជនដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម(មូលនិធិសមធម៌និងធានារ៉ាប់រងសុខភាព) | % | ៣៨,៥ | ៣៩,៥ | n.a | ៤៣ | ៤៥ |
| ៨.៣៨ | ចំណាយចរន្តនៃថវិកាជាតិលើសុខភាពគិតជា%នៃផលិតផលសរុបក្នុងស្រុក | % | n.a | n.a | n.a | ២,២ | ២,៣ |
| ៨.៣៩ | សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | % | ៩៣,៨៧ | ៩៥,១៣ | ៩៤,៦៩ | ៩៨ | >៩៧ |
| ៨.៤០ | ភាគរយនៃមណ្ឌលសុខភាពដែលមានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដំណើរការពេញលេញ | % | ៨៧,១២ | ៩០,៩៥ | ៨៥,៦២<br>(៦ខែ) | >៨៥ | ៩០ |
| | | | | | | | |
| | | | | | | | |
| **៩.០០** | **អប់រំ** | | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ |
| ៩.០១ | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ គ្រប់រូបភាព (មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៥៨,១ | ៦២,៩ | ៦១,១ | ៦៣,២ | ៦៤,៥ |
| ៩.០២ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា<br>សរុប | % | ៩៨,០ | ៩៧,៣ | ៩១,៩ | ៩៨,៤ | ៩៨,៥ |
| ៩.០៣ | ប្រុស | % | ៩៧,៥ | ៩៦,៨ | ៩១,០ | ៩៨,៣ | ៩៨,៥ |
| ៩.០៤ | ស្រី | % | ៩៨,៥ | ៩៧,៩ | ៩២,៣ | ៩៨,៨ | ៩៩,០ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ៩.០៥ | ទីប្រជុំជន | % | ១០៤,៦ | ១០៥,៣ | ៩៦,៤ | ៩៧,៩ | ១០០ |
| ៩.០៦ | ជនបទ | % | ៩៦,៦ | ៩៥,៦ | ៩០,៩ | ៩៧,៦ | ៩៨,០ |
| | អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | |
| ៩.០៧ | សរុប | % | ១១៣,៥ | ១១៩,៩ | ១០៩,០ | ១០៩,៨ | ១០៨,០ |
| ៩.០៨ | ប្រុស | % | ១១៤,៤ | ១១២,៤ | ១០៩,៣ | ១១០,៨ | ១០៩,០ |
| ៩.០៩ | ស្រី | % | ១១២,៥ | ១១១,១ | ១០៨,១ | ១០៨,៩ | ១០៧,០ |
| | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | |
| ៩.១០ | សរុប | % | ៨៦,២ | ៨៨,២ | ៨៧,៤ | ៨៥,៥ | ៨៦,២ |
| ៩.១១ | ប្រុស | % | ៨២,៣ | ៨៤,១ | ៨៣,៤ | ៨៣,៨ | ៨៥,០ |
| ៩.១២ | ស្រី | % | ៩០,៤ | ៩២,៧ | ៩១,៦ | ៩០,១ | ៩១,០ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | |
| ៩.១៣ | សរុប | % | ៥៩,១ | ៥៩,៩ | ៦០,៧ | ៦៥,២ | ៦៦,៧ |
| ៩.១៤ | ប្រុស | % | ៥៤,៩ | ៥៥,១ | ៥៥,៣ | ៦៣,០ | ៦៥,០ |
| ៩.១៥ | ស្រី | % | ៦៣,៨ | ៦៥,១ | ៦៦,៦ | ៧០,៣ | ៧២,០ |
| ៩.១៦ | ទីប្រជុំជន | % | ៦៦,៩ | ៧០,១ | ៧២,៧ | ៧២,៦ | ៧៤,០ |
| ៩.១៧ | ជនបទ | % | ៥៧,៣ | ៥៧,៤ | ៥៧,៨ | ៦៣,៨ | ៦៥,៤ |
| | អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | |
| ៩.១៨ | សរុប | % | ៤៧,៦ | ៤៧,៣ | ៤៨,១ | ៥១,៤ | ៥២,៦ |
| ៩.១៩ | ប្រុស | % | ៤២,៩ | ៤២,៤ | ៤៣,១ | ៤៨,៥ | ៥០,០ |
| ៩.២០ | ស្រី | % | ៥២,៦ | ៥២,៥ | ៥៣,៤ | ៥៥,៣ | ៥៦,៣ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | |
| ៩.២១ | សរុប | % | ២៩,៧ | ៣០,៩ | ៣២,២ | ៣៦,១ | ៣៨,០ |
| ៩.២២ | ប្រុស | % | ២៦,៧ | ២៧,១ | ២៨,៥ | ៣៤,១ | ៣៦,១ |
| ៩.២៣ | ស្រី | % | ៣២,៩ | ៣៥,១ | ៣២,៣ | ៣៨,២ | ៤០,០ |
| ៩.២៤ | ចំនួនវិទ្យាល័យបច្ចេកទេស | ចំនួន | ១៤ | ១៦ | ១៧ | ១៦ | ១៩ |
| ៩.២៥ | ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | ចំនួន | ២ ១០៣ | ២ ៧១៧ | ៣ ៣២៤ | ២ ៦៩៤ | ៣ ០០០ |
| | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ) | | | | | | |
| ៩.២៦ | សរុប | % | ១១,៦ | ១២,០ | ១៣,៣ | ១៥,១ | ១៦,០ |
| ៩.២៧ | ប្រុស | % | ១៣,២ | ១២,២ | ១៥,៥ | ១៦,៩ | ១៨,៣ |
| ៩.២៨ | ស្រី | % | ១១,៣ | ១១,៨ | ១១,៩ | ១២,៧ | ១៣,០ |
| | ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលផ្នែកស្ទែម | | | | | | |
| ៩.២៩ | សរុប | % | ២៧,១ | ២៨,៣ | ៣០,៤ | ៣១,០ | ៣២,០ |
| ៩.៣០ | ប្រុស | % | ៣៦,៧ | ៤០,១ | ៤៥,៤ | ៤៦,១ | ៤៦,៨ |
| ៩.៣១ | ស្រី | % | ១៧,៤ | ១៦,៩ | ១៧,៥ | ២១,៥ | ២២,៥ |
| ៩.៣២ | អត្រាអក្ខរជនពេញវ័យ(១៥ឆ្នាំឡើង) | % | ៨២,៥ | ៨២,៥ | ៨៧,៨ | ៨៦,៩ | ៨៨,០ |
| | | | | | | | |
| **១០.០០** | **កម្មវិធីសម្អាតមីន** | | | | | | |
| ១០.០១ | ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ(ស្លាប់/របួស) | នាក់ | ៧៧ | ៦៥ | ៤៤ | ៣៨ | ៣៤ |
| ១០.០២ | ចំនួនជនរងគ្រោះដោយសារការលេងនិងថ្វៃគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ(ស្លាប់/របួស) | នាក់ | ៤៨ | ៣០ | ២១ | ១៩ | ១៧ |

| | សូចនាករសំខាន់ៗ | ឯកតា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ១០.០៣ | ផ្ទៃដីសរុបបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម(ផ្តែកលើលទ្ធផលពីការស្រាវជ្រាវមូលដ្ឋាន) | ហ.ត. | ១២ ៦៧៦ | ១៥ ៣២៨ | ១៦ ៧៦៤ | ២១ ៤០០ | ២១ ៤០០ |
| ១០.០៤ | ផ្ទៃដីបោសសម្អាតមីន | ហ.ត. | ៩ ១៣៧ | ៩ ៤៧៨ | ១០ ០៩៩ | ១៧ ៤០០ | ១៧ ៤០០ |
| ១០.០៥ | ផ្ទៃដីបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. | ៣ ៥៣៩ | ៥ ៨៥០ | ៥ ៦៦៥ | ៤ ០០០ | ៤ ០០០ |
| | | | | | | | |

# មាតិកា

ទំព័រ

**អារម្ភកថា** .................................................. i

**សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា** .................................................. iv

**កម្ពុជា : សូចនាករសេដ្ឋកិច្ច សង្គមកិច្ចសំខាន់ៗ** .................................................. V

**មាតិកា**.................................................. vii

**បញ្ជីនៃតារាង រូបភាព និងឧបសម្ព័ន្ធ**.................................................. xvi

**ជំពូកទី១ សេចក្តីផ្តើម** .................................................. ១

១- សារៈការ .................................................. ១

២- គោលបំណង.................................................. ២

៣- វិធីសាស្ត្រ.................................................. ២

៤- បរិបទព្រះរាជាណាចក្រកម្ពុជា.................................................. ៣

៥- ទម្រង់នៃរបាយការណ៍.................................................. ៤

**ជំពូកទី២ ការអនុវត្តម៉ាក្រូសេដ្ឋកិច្ច**.................................................. ៥

**២.១- វឌ្ឍនភាពសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច**.................................................. ៥

**២.២- គោលនយោបាយសារពើពន្ធនិងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**.................................................. ៨

ក- កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៤-២០២៥.................................................. ៨

ខ- យុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ២០១៩-២០២៣.................................................. ៩

គ- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥.................................................. ១០

ឃ- យុទ្ធសាស្ត្រគ្រប់គ្រងបំណុល ឆ្នាំ២០១៩-២០២៣.................................................. ១០

**២.៣- វឌ្ឍនភាពវិស័យរូបិយវត្ថុនិងវិស័យហិរញ្ញវត្ថុ**.................................................. ១១

**២.៤- វឌ្ឍនភាពជញ្ជីងទូទាត់កម្ពុជា**.................................................. ១២

**ជំពូកទី៣ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ** .................................................. ១៥

១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ.................................................. ១៥

១.១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន.................................................. ១៥

១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ........ ២៤

១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ ........ ២៨

១.៤- ពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន ........ ៣៣

២- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំងមូល........ ៣៤

២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ........ ៣៤

២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ........ ៣៦

២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ........ ៤០

២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក........ ៤៥

៣- ការអភិវឌ្ឍធនធានមនុស្ស........ ៤៧

៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា........ ៤៧

៣.២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស........ ៥០

៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ........ ៥១

៣.៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម........ ៥៩

៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច........ ៦៧

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល........ ៦៧

៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ........ ៧៦

៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤........ ៨១

៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ........ ៨៥

៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ........ ៨៩

៥.១- ការអភិវឌ្ឍទីផ្សារការងារ........ ៨៩

៥.២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព........ ៩២

៥.៣- ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន........ ៩៤

៥.៤- ការពង្រឹងការប្រកួតប្រជែង........ ៩៥

៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន........ ៩៥

៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ........ ៩៥

៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព............................................ ១០៦

៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម.................................................................. ១១៥

៦.៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ.................. ១១៦

**ជំពូកទី៤ ជំហានបន្ទាប់ ..................................................................................... ១១៩**

១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ................................ ១១៩

១.១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន........................................................ ១១៩

១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ...................................................... ១២១

១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ ....................................................................... ១២៤

១.៤- ពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន ....................................................................... ១២៥

២- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំងមូល........................................ ១២៥

២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ................................ ១២៥

២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ.............................. ១២៦

២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ................. ១២៧

២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់និង ពិភពលោក.................................................................................................. ១២៨

៣- ការអភិវឌ្ឍធនធានមនុស្ស.................................................................................. ១២៨

៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា........................................ ១២៨

៣.២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស................................................................... ១៣២

៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ.............................................. ១៣៣

៣.៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម......................................................... ១៣៧

៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច.................................................................................. ១៣៩

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល..... ១៤០

៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ......................................................... ១៤២

៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤................. ១៤៤

៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ......................................................... ១៤៦

៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ....................................................................... ១៤៨

៥.១- ការអភិវឌ្ឍទីផ្សារការងារ........ ១៤៨

៥.២- ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព........ ១៤៩

៥.៣- ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន........ ១៥០

៥.៤- ការពង្រឹងការប្រកួតប្រជែង........ ១៥១

៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន........ ១៥១

៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ........ ១៥១

៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព........ ១៥៣

៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម........ ១៥៥

៦.៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ........ ១៥៦

**ជំពូកទី៥ តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ**........ **១៥៨**

**ជំពូកទី៦ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**........ ១៦១

១- សេចក្តីផ្តើម........ ១៦១

២- សមិទ្ធផល........ ១៦១

៣- បញ្ហាប្រឈម........ ១៦២

៤- ជំហានបន្ទាប់........ ១៦៣

**ជំពូកទី៧ សេចក្តីសន្និដ្ឋាន**........ ១៦៤

**ឧបសម្ព័ន្ធ**........ ១៦៦

# បញ្ជីនៃតារាង រូបភាព ប្រអប់ និងឧបសម្ព័ន្ធ

## តារាង


| | | |
|---|---|---|
| តារាង២.១ | សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ឆ្នាំ២០១៨ - កក្កដា ២០២១ | ៦ |
| តារាង២.២ | ចំណូល ចំណាយ និងសន្ទស្សន៍បំណុល | ៨ |
| តារាង២.៣ | សូចនាករសំខាន់ៗវិភាគពីចីរភាពបំណុល | ១០ |
| តារាង៣.១ | ការបណ្ដុះបណ្ដាលនិងអភិវឌ្ឍសមត្ថភាពមន្ត្រី ឆ្នាំ២០១៩-២០២១ | ២២ |
| តារាង៣.២ | បៀវត្សអប្បបរមាសម្រាប់មន្ត្រីនៅថ្នាក់ក្រោមជាតិ | ២២ |
| តារាង៣.៣ | បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកម្លាំងប្រដាប់អាវុធ | ២២ |
| តារាង៣.៤ | លទ្ធផលសម្រេចបាន ឆ្នាំ២០១៩-២០២១ | ២៨ |
| តារាង៣.៥ | សូចនាករនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១ | ៣០ |
| តារាង៣.៦ | បញ្ជីអង្គការមិនមែនរដ្ឋាភិបាលបរទេស ឆ្នាំ២០១៩-២០២១ | ៤១ |
| តារាង៣.៧ | បញ្ជីជួយសង្គ្រោះពលរដ្ឋខ្មែររងគ្រោះដោយការជួញដូរខុសច្បាប់ ឆ្នាំ២០១៩-២០២១ | ៤២ |
| តារាង៣.៨ | បញ្ជីស្ថានបេសកកម្មកម្ពុជានិងបរទេស ឆ្នាំ២០១៩-២០២១ | ៤២ |
| តារាង៣.៩ | សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម ឆ្នាំ២០១៩-២០២១ | ៤៦ |
| តារាង៣.១០ | លទ្ធផលនៃការប្រកួតកីឡាលក្ខណៈអន្តរជាតិ | ៤៩ |
| តារាង៣.១១ | លទ្ធផលនៃសុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ | ៥២ |
| តារាង៣.១២ | លទ្ធផលនៃការបង្ការនិងគ្រប់គ្រងជំងឺឆ្លង | ៥៣ |
| តារាង៣.១៣ | លទ្ធផលនៃការបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង | ៥៤ |
| តារាង៣.១៤ | លទ្ធផលនៃការផ្ដល់សេវាសុខាភិបាលនិងពង្រឹងប្រព័ន្ធសុខាភិបាល | ៥៤ |
| តារាង៣.១៥ | ចំណូលបានពីការផ្ដល់សេវាកម្មនាំផ្លូវហោះហើរ | ៧០ |
| តារាង៣.១៦ | អាកាសយានដ្ឋានអន្តរជាតិសាងសង់ថ្មី | ៧០ |
| តារាង៣.១៧ | សូចនាករវិស័យថាមពល | ៧៣ |
| តារាង៣.១៨ | សូចនាករវិស័យប្រៃសណីយ៍និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១ | ៧៤ |
| តារាង៣.១៩ | អត្រាអ្នកប្រើប្រាស់សេវាទូរសព្ទនិងសេវាអ៊ិនធឺណិតសរុប ឆ្នាំ២០១៩-២០២១ | ៧៤ |
| តារាង៣.២០ | សូចនាករវិស័យប.គ.ព.និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១ | ៧៥ |
| តារាង៣.២១ | សូចនាករការកសាងសមត្ថភាពនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១ | ៧៦ |
| តារាង៣.២២ | សូចនាករវិស័យទេសចរណ៍និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១ | ៧៨ |
| តារាង៣.២៣ | ចំណូលមិនមែនសារពើពន្ធដែលប្រមូលបានពីវិស័យប្រេងកាត | ៨០ |

| | | |
|---|---|---|
| តារាង៣.២៤ | សូចនាករវិស័យព័ត៌មាន ឆ្នាំ២០១៩-២០២១.......... | ៨៣ |
| តារាង៣.២៥ | សូចនាករគោលនយោបាយរូបិយវត្ថុនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១.......... | ៨៧ |
| តារាង៣.២៦ | សូចនាករវិស័យធនាគារនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១.......... | ៨៨ |
| តារាង៣.២៧ | សូចនាករវិស័យមីក្រូហិរញ្ញវត្ថុនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១.......... | ៨៨ |
| តារាង៣.២៨ | សូចនាករវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២១.......... | ៩៧ |
| តារាង៣.២៩ | សូចនាករវិស័យសកម្មភាពមីននិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១.......... | ១០០ |
| តារាង៣.៣០ | ចំណូលមិនមែនសារពើពន្ធក្នុងវិស័យរ៉ែ ឆ្នាំ២០១៩-២០២១.......... | ១០៧ |
| តារាង៣.៣១ | សមិទ្ធផលសម្រេចបានក្នុងវិស័យបរិស្ថាន ឆ្នាំ២០១៩-២០២៣.......... | ១១២ |
| តារាង៣.៣២ | សមិទ្ធផលសម្រេចបានក្នុងវិស័យដីធ្លី ឆ្នាំ២០១៩-២០២១.......... | ១១៦ |
| តារាង៤.១ | សូចនាករនិងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣.......... | ១២៤ |
| តារាង៤.២ | សូចនាករសំខាន់និងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣.......... | ១៤៧ |
| តារាង៤.៣ | សូចនាករវិស័យធនាគារនិងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣.......... | ១៤៧ |
| តារាង៤.៤ | សូចនាករវិស័យមីក្រូហិរញ្ញវត្ថុនិងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣.......... | ១៤៧ |
| តារាង៥.១ | ការវិនិយោគមូលធនចាំបាច់ ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុកនិងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់.......... | ១៥៨ |


**រូបភាព**


| | | |
|---|---|---|
| រូបភាព២.១ | សមាសធាតុនៃរូបិយវត្ថុទូទៅនិងកំណើន.......... | ១២ |
| រូបភាព២.២ | គណនីចរន្ត .......... | ១៣ |

# ជំពូកទី១

# សេចក្តីផ្តើម

## ១- សាវតារ

១.១- ក្រោមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣ ត្រូវបានរៀបចំឡើងជាផែនទីបង្ហាញផ្លូវមួយសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា និងឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ ២០៣០។

១.២- ផ.យ.អ.ជ. ២០១៩-២០២៣ គឺជាឧបករណ៍សម្រាប់អនុវត្តដើម្បីសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) ២០១៦-២០៣០ និងចូលរួមចំណែកក្នុងការសម្រេចបានរបៀបវារៈឆ្នាំ២០៣០របស់អង្គការសហប្រជាជាតិ ព្រមទាំងការប្តេជ្ញាចិត្តថ្នាក់ជាតិ និងអន្តរជាតិផ្សេងៗទៀត។ អាទិភាពជាយុទ្ធសាស្ត្រសំខាន់នៅក្នុងផ.យ.អ.ជ. ២០១៩-២០២៣ បានតម្រង់ទិសការអភិវឌ្ឍប្រទេសកម្ពុជា ឱ្យក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១នៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ នេះ នឹងបង្ហាញអំពីសូចនាករអភិវឌ្ឍន៍ ពេលវេលា ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃដោយផ្អែកលើលទ្ធផលនិងការប៉ាន់ស្មានថវិកាតាមវិស័យនីមួយៗ។

១.៣- ដោយផ្អែកលើសារៈសំខាន់នៃផែនការអភិវឌ្ឍន៍និងការប្រើប្រាស់ធនធានរបស់ប្រទេស រាជរដ្ឋាភិបាលកម្ពុជាត្រូវរៀបចំរបាយការណ៍វាយតម្លៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣។ ក្រសួងផែនការមានតួនាទីដឹកនាំការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ រួមមានការរៀបចំ ការសម្របសម្រួល ការតាមដាន និងរាយការណ៍ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិ។

១.៤- ក្នុងឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាមានភារកិច្ចរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ ដែលនឹងរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ ចាប់ពីឆ្នាំ២០១៩ រហូតដល់ខែមិថុនាឆ្នាំ២០២១ និងស្នើឡើងនូវសកម្មភាពនិងចំណុចដៅដែលត្រូវបន្តអនុវត្តសម្រាប់រយៈពេលដែលនៅសល់របស់ផែនការនេះ។ ដំណើរការនៃការរៀបចំរបាយការណ៍នេះមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទាំងអស់ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល។ ក្នុងដំណើរការនៃការវាយតម្លៃនេះ ការសម្រេចបានជាក់ស្តែងត្រូវបានវាស់វែងធៀប នឹងសូចនាករនិងចំណុចដៅដែលបានកំណត់។

១.៥- ដោយមានស្ថានភាពដូចគ្នាទៅនឹងប្រទេសនានានៅក្នុងពិភពលោក ជំងឺកូវីដ-១៩ បានជះឥទ្ធិពលមកលើប្រទេសកម្ពុជាចាប់ពីចុងឆ្នាំ២០១៩ ដូចនេះរបាយការណ៍នេះនឹងបង្ហាញអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើលទ្ធផលនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ និងស្នើឡើងនូវ

វិធានការនិងអន្តរាគមន៍នានា ដើម្បីដោះស្រាយស្ថានភាពនេះសម្រាប់រយៈពេលដែលនៅសល់របស់ផែនការ។

## ២- គោលបំណង

១.៦- គោលបំណងនៃការរៀបចំ**របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣** គឺដើម្បីវាយតម្លៃសមិទ្ធផលនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ ព្រមទាំងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលមានអាទិភាពចំនួន៤ គឺ (១)**ការអភិវឌ្ឍធនធានមនុស្ស** (២)**ការធ្វើពិពិធកម្មសេដ្ឋកិច្ច** (៣)**ការអភិវឌ្ឍវិស័យឯកជននិងការងារ** និង(៤) **កំណើនប្រកបដោយចីរភាពនិងបរិយាបន្ន ហើយមានការកែទម្រង់អភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រ**។

១.៧- របាយការណ៍នេះ ក៏មានគោលបំណងបង្ហាញអំពីវឌ្ឍនភាពធៀបនឹងផែនការដោយពិនិត្យមើលខ្សែច្រវាក់លទ្ធផលនិងកត្តាពាក់ព័ន្ធផ្សេងៗ ដែលជាការវាស់វែងដោយផ្អែកលើភស្តុតាងនិងប្រើប្រាស់ជាប្រភពទិន្នន័យសំខាន់សម្រាប់ការរៀបចំផែនការនិងកម្មវិធីផ្សេងៗ។ របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣នេះ បានវាយតម្លៃការអនុវត្តធៀបនឹងចំណុចដៅដែលមានចែងក្នុងផ.យ.អ.ជ. ២០១៩-២០២៣។

១.៨- គោលបំណងជាក់លាក់នៃការរៀបចំរបាយការណ៍នេះមានដូចខាងក្រោម៖

- វាយតម្លៃសមិទ្ធផលសំខាន់ៗធៀបនឹងសូចនាករនិងចំណុចដៅតាមវិស័យនីមួយៗ រួមទាំងការស្នើឡើងនូវវិធានការកែតម្រូវមួយចំនួន
- វិភាគនិងរាយការណ៍អំពីការប្រែប្រួលតាមក្រសួង ស្ថាប័ន ក្នុងការសម្រេចបានសមិទ្ធផលពាក់កណ្ដាលអាណត្តិនេះដោយប្រើប្រាស់ការវិនិច្ឆ័យវាយតម្លៃ ដើម្បីឆ្ពោះទៅរកការសម្រេចចិត្តផ្អែកគោលនយោបាយដោយផ្អែកលើភស្តុតាង
- កំណត់វិធានការយុទ្ធសាស្ត្រកែតម្រូវនិងសកម្មភាពនានាដែលចាំបាច់ ដើម្បីជំរុញការសម្រេចបានលទ្ធផលនានាផ្អែកលើភាពប្រឈមដែលបានជួបក្នុងការអនុវត្ត
- កំណត់ការកែសម្រួលនានាដើម្បីសម្រេចបានលទ្ធផលដែលគ្រោងទុកក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ និងសុខដុមនីយកម្មផែនការ កម្មវិធី និងចំណុចដៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និង
- កំណត់អំពីរបៀបវារៈដែលត្រូវអនុវត្តសម្រាប់ពេលវេលាដែលនៅសល់របស់ផ.យ.អ.ជ. ២០១៩-២០២៣ ដើម្បីសម្រេចបានគោលដៅរបស់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងចំណុចដៅរបស់គ.អ.ច.ក. នៅឆ្នាំ២០៣០។

## ៣- វិធីសាស្ត្រ

១.៩- ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍ ព្រមទាំងសង្គមស៊ីវិលត្រូវបានធ្វើការពិគ្រោះយោបល់ដើម្បីផ្ដល់របាយការណ៍វឌ្ឍនភាពទៅតាមការស្នើសុំរបស់ក្រសួងផែនការ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន

ត្រូវរាយការណ៍អំពីសមិទ្ធផលសម្រេចបានសម្រាប់ឆ្នាំ២០១៩ ឆ្នាំ២០២០ និងត្រឹមខែមិថុនា ឆ្នាំ ២០២១ រួមទាំងបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងការអនុវត្តដែលធ្វើឱ្យមិនសម្រេចបានចំណុចដៅដែលបានគ្រោងទុក និងស្នើឡើងនូវការកែតម្រូវគោលនយោបាយនានាដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះនិងបញ្ហាប្រឈមដែលកើតចេញពីការរីករាលដាលនៃជំងឺកូវីដ-១៩។

១.១០- ដោយអនុលោមតាមទម្រង់របាយការណ៍នៃផ.យ.អ.ជ. ២០១៩-២០២៣ ការវាយតម្លៃត្រូវបានធ្វើឡើងដោយផ្អែកលើគោលការណ៍វាយតម្លៃចំនួន៤ គឺ (១)**ភាពទាក់ទង** (២)**ភាពសក្តិសិទ្ធិ** (៣)**ប្រសិទ្ធភាព** **និង**(៤)**ចីរភាព**។ ការវាយតម្លៃភាពទាក់ទងវាយតម្លៃលទ្ធផលដែលរំពឹងថា មានភាពស៊ីគ្នាជាមួយនឹងអាទិភាពជាតិដែរឬទេ និងថា តើការរៀបចំផែនការមានលក្ខណៈសមរម្យដើម្បីសម្រេចបានលទ្ធផលរំពឹងទុកឬទេ។ ភាពសក្តិសិទ្ធិ វាយតម្លៃថា លទ្ធផលរំពឹងទុកសម្រេចបានដែរឬទេ នៅពេលធ្វើការវាយតម្លៃធៀបជាមួយចំណុចដៅ។ ប្រសិទ្ធភាព វាស់វែងលើការប្រើប្រាស់ធនធានដើម្បីសម្រេចបានធាតុចេញ។ ចីរភាព វាយតម្លៃលើការបន្តនិរន្តរភាពនៃធាតុចេញ និងលទ្ធផលដែលកើតចេញពីការអនុវត្តផែនការ។ ការវាយតម្លៃពីចីរភាព ត្រូវគិតគូរពីហានិភ័យផ្នែកនយោបាយ សេដ្ឋកិច្ច ស្ថាប័ន បច្ចេកទេស សង្គម បរិស្ថាន និងហិរញ្ញវត្ថុ និងគិតគូរពីវិធានការសម្រាប់ដោះស្រាយ។

## ៤- បរិបទព្រះរាជាណាចក្រកម្ពុជា

១.១១- ជាង២ទសវត្សចុងក្រោយនេះ ប្រទេសកម្ពុជាមានការវិវត្តគួរឱ្យកត់សម្គាល់ ដោយបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងឈានទៅក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដោយសារមានកំណើនខ្ពស់ក្នុងវិស័យកាត់ដេរនិងទេសចរណ៍ សេដ្ឋកិច្ចកម្ពុជាបានរក្សាកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧,៧% ចាប់ពីឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០១៩ ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតមួយក្នុងពិភពលោក(ធនាគារពិភពលោក ឆ្នាំ២០២១)។

១.១២- ក្នុងឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវទស្សនវិស័យរយៈពេលវែងមួយគឺ*កម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* សម្រាប់ការផ្តួចផ្តើមដំណើរការស្តារនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាតិ សង្គម វប្បធម៌ និងស្ថាប័នឡើងវិញ។ ផ្អែកលើទស្សនវិស័យនេះ *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច(ផ.អ.ស.ស.)៥ឆ្នាំលើកទី១ ១៩៩៦-២០០០* និង *ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច (ផ.អ.ស.ស.) ៥ឆ្នាំលើកទី២ ២០០១-២០០៥* ត្រូវបានរៀបចំឡើង។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០០៦-២០១០ ត្រូវបានធ្វើបច្ចុប្បន្នភាពជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដើម្បីមានសង្គតិភាពជាមួយអាណត្តិរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និង គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។

១.១៣- ផ.យ.អ.ជ. ២០១៤-២០១៨ និង ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលនយោបាយជាតិដែលនឹងប្រែក្លាយប្រទេសកម្ពុជាជាប្រទេសដែលចំណូលមធ្យមកម្រិតខ្ពស់ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងដំណាក់កាលទី៤។ យុទ្ធសាស្ត្រ

ចតុកោណ ដំណាក់កាលទី៤ គឺជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងមានមុំចំនួន៤ គឺ(១)**ការអភិវឌ្ឍធនធានមនុស្ស** (២)**ការធ្វើពិពិធកម្មសេដ្ឋកិច្ច** (៣)**ការអភិវឌ្ឍវិស័យឯកជននិងការងារ** និង(៤)**ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន** ហើយមានការកែទម្រង់អភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រ។

## ៥- ទម្រង់នៃរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១

១.១៤- របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានរៀបចំឡើងជា៦ជំពូក។ ជំពូកទី១ បង្ហាញអំពីសេចក្តីផ្តើម។ ជំពូកទី២ បង្ហាញអំពីការអភិវឌ្ឍផ្នែកម៉ាក្រូសេដ្ឋកិច្ច។ ជំពូកទី៣ បង្ហាញដោយសង្ខេបអំពីសមិទ្ធផលសំខាន់ៗនិងបញ្ហាប្រឈម នៅក្នុងអំឡុងពេលនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣។ ជំពូកទី៤ បង្ហាញអំពីវិធានការនិងសកម្មភាពអាទិភាពសំខាន់ៗដែលនឹងត្រូវបន្តអនុវត្តសម្រាប់អាណត្តិដែលនៅសល់របស់ផ.យ.អ.ជ. ២០១៩-២០២៣។ ជំពូកទី៥ បង្ហាញអំពីការប៉ាន់ស្មានតម្លៃដែលរួមទាំងចំណាយប្រភពធនធាននិងការកំណត់កម្មវិធីចំណាយ។ ជំពូកទី៦ បង្ហាញពីការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ និងនៅចុងបញ្ចប់ ជំពូកទី៧ បង្ហាញអំពីសេចក្តីសន្និដ្ឋាន។

# ជំពូកទី២

# ការអនុវត្តម៉ាក្រូសេដ្ឋកិច្ច

២.១- កម្ពុជាសម្រេចបានគួរឱ្យកត់សម្គាល់នូវស្ថិរភាពនយោបាយនិងម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ៧%ក្នុងមួយឆ្នាំ បន្ទាប់ពីកម្ពុជាទទួលបានសន្តិភាពពេញលេញជាលើកដំបូងនៅក្នុងឆ្នាំ១៩៩៨ ក្រោយពីជម្លោះផ្ទៃក្នុងចាប់តាំងពីឆ្នាំ១៩៧០មក។ អតិផរណាមានកម្រិតទាប ប៉ុន្តែមានឱនភាពថវិកាប្រមាណ១៥%នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩។ បំណុលសាធារណៈ មានកម្រិតទាបប្រមាណ២៨,២%នៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ២០១៩[1]។

២.២- តាមរយៈការបើកចំហជើងមេឃ ពាណិជ្ជកម្មអន្តរជាតិនិងការវិនិយោគបានជំរុញដល់ការវិនិយោគផ្ទាល់ពីបរទេសនិងហិរញ្ញប្បទានក្រៅប្រទេស សម្រាប់គាំទ្រដល់វិស័យកម្មន្តសាល សំណង់ និងទេសចរណ៍។ ផ្អែកលើធនាគារពិភពលោកនិងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា កម្ពុជាទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ឆ្នាំ២០១៩ ទំហំប្រមាណ១ ៩៨១ លានដុល្លារអាម៉េរិក ដែលអាចចាត់ទុកថាមានកម្រិតខ្ពស់ ប្រៀបធៀបជាមួយជំនួយអភិវឌ្ឍន៍ផ្លូវការមធ្យមដល់បណ្ដាប្រទេសចំនួន១៣១ ដែលមានចំនួន៨៤០,០២លានដុល្លារអាម៉េរិក។ ដោយសារស្ថិរភាពកំណើន បានធ្វើឱ្យកម្ពុជាមានចំណូលមធ្យមសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំមានកម្រិតខ្ពស់ជាង១ ០៤៥ដុល្លារ ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥។

២.៣- ទោះជាដូចនេះក្ដី ដោយសារការរីករាលដាលជាសាកលនៃជំងឺកូវីដ-១៩ កំណើនសេដ្ឋកិច្ចមិនអាចបន្តទទួលបានដូចកម្រិតដែលបានរំពឹងទុកទេ ដោយសារសកម្មភាពពាណិជ្ជកម្មមានការថយចុះ ការវិនិយោគផ្ទាល់ពីបរទេសបានកាត់បន្ថយ និងក្នុងពេលជាមួយគ្នា មានតម្រូវការធាតុចូលបន្ថែមទៀតសម្រាប់គាំទ្រដល់ការផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា។ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាក៏មានផលប៉ះពាល់ជាអវិជ្ជមាន បន្ថែមលើសម្ពាធក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ។ វិស័យទាំងនោះ មានដូចជាការនាំចេញសម្លៀកបំពាក់ ការមកដល់នៃភ្ញៀវទេសចរណ៍បរទេស សំណង់ និងការវិនិយោគផ្ទាល់ពីបរទេសជាដើម ដែលបានជួបប្រទះនឹងការធ្លាក់ចុះមិនធ្លាប់មានពីមុនមក។

២.៤- ផ្នែកដូចខាងក្រោមនេះ នឹងបង្ហាញពីលទ្ធផលសំខាន់ៗនៃការសម្រេចបានម៉ាក្រូសេដ្ឋកិច្ចនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៩-២០២៣ ព្រមជាមួយនឹងការពណ៌នាពីលក្ខណៈសំខាន់ៗនៃគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុ។ ជាមួយគ្នានេះ ក៏នឹងផ្ដល់ជូននូវជំហានដែលត្រូវអនុវត្តបន្ត បន្ទាប់ពីការពិនិត្យមើលពីបញ្ហាប្រឈមនិងឧបសគ្គនានាដែលជួបប្រទះក្នុងពេលអនុវត្ត។

## ២.១- ទន្សានភាពសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

[1] ធនាគារជាតិនៃកម្ពុជា កម្រិតនៃបំណុលបរទេសសរុប តាមវិស័យ

២.៥- ទោះបីជាសម្រេចបានកំណើនសេដ្ឋកិច្ចរឹងមាំប្រមាណ៧,១% នៅក្នុងរយៈពេលកន្លងទៅក្តី កម្ពុជាបានជួបប្រទះនូវកំណើនសេដ្ឋកិច្ចអវិជ្ជមានលើកដំបូងក្នុងរយៈពេលមួយទសវត្ស ក្នុងកម្រិត -៣,១% ក្នុងឆ្នាំ២០២០ ដែលមូលហេតុចម្បងបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ដោយសារកិច្ចខិតខំប្រឹងប្រែងនិងការផ្តល់អន្តរាគមន៍ជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជាត្រឹមតែរយៈពេលខ្លី នៅដើមឆ្នាំ២០២១ សេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញមកត្រឹម២,៤% និងតាមការព្យាកររបស់ធនាគារអភិវឌ្ឍន៍អាស៊ី សេដ្ឋកិច្ចកម្ពុជារំពឹងទុកថានឹងកើនឡើងដល់៥,៥% នៅក្នុងឆ្នាំ២០២២។ នៅមុនពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសត្រូវបានជំរុញលើសលប់ដោយវិស័យកម្មន្តសាល សំណង់ និងទេសចរណ៍។ ផ្អែកលើរបាយការណ៍ប្រចាំឆ្នាំ ២០១៩របស់ធនាគារជាតិនៃកម្ពុជា ការរួមចំណែករបស់វិស័យឧស្សាហកម្មក្នុងផលិតផលក្នុងស្រុកសរុបមានកម្រិត៣៨,៣% និងវិស័យសេវាកម្មមានកម្រិត៣៨,១% ដែលបង្ហាញថា វិស័យទាំងពីរនេះនាំមុខគេក្នុងសេដ្ឋកិច្ចកម្ពុជា។ ទោះជាដូចនេះក្តី ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩នៅតែបន្ត សេដ្ឋកិច្ចតាមវិស័យមានការធ្លាក់ចុះយ៉ាងខ្លាំង រួមទាំងវិស័យទេសចរណ៍ វិស័យកម្មន្តសាល សំណង់ និងវិស័យពាក់ព័ន្ធផ្សេងទៀត។ ដូចមានបញ្ជាក់ក្នុងរបាយការណ៍វាយតម្លៃពីស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២០ ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា ការមកដល់នៃភ្ញៀវទេសចរបរទេសបានថយចុះ៨០,២% ទន្ទឹមនឹងនេះ ការនាំចេញផលិតផលសម្លៀកបំពាក់បានថយចុះ៩,៧% និងផលិតផលស្បែកជើងថយចុះប្រមាណ១១,៦%។

២.៦- ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ដែលវាស់វែងដោយការគណនាផលិតផលសរុបជាមធ្យមក្នុងមនុស្សម្នាក់ នៅក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ មានប្រមាណ១ ៧០០ដុល្លារអាម៉េរិក ទន្ទឹមនឹងនេះ អតិផរណារក្សាបានស្ថិរភាពនៅក្នុងកម្រិត ៣%ក្នុងឆ្នាំ២០២១ ដែលធ្វើឱ្យកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបតាំងពីឆ្នាំ២០១៥មក។ ដូចមានបង្ហាញជូនក្នុងតារាង២.១ កម្រិតអតិផរណាក្នុងប្រទេសបានកើនឡើងដល់៣,៤% ក្នុងត្រីមាសទី២ ឆ្នាំ២០២១ ប៉ុន្តែនៅតែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ មូលហេតុនៃការកើនឡើងអតិផរណានេះ គឺត្រូវបានសន្មតថា ការរាលដាលនៃជំងឺកូវីដ-១៩ ជាមូលហេតុធ្វើឱ្យថ្លៃទំនិញកើនឡើង ជាមួយនឹងការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការសេដ្ឋកិច្ចសរុប។

### តារាង២.១ : សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ឆ្នាំ២០១៨ - កក្កដា ឆ្នាំ២០២១

| | ២០១៨ | ២០១៩ | ២០២០ | កក្កដា ២០២១ |
|---|---|---|---|---|
| កំណើនផលិតផលក្នុងស្រុកសរុបពិត(%) | ៧,៥ | ៧,១ | -៣,១ | ២,៤ |
| ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់(ដុល្លារអាម៉េរិក) | ១ ៥៦៣ | ១ ៧០០ | ១ ៦៥៣ | ១ ៧៣០ |
| ការវិនិយោគធៀបនឹងផលិតផលក្នុងស្រុកសរុប(%) | ៣១,១ | ៣២,៦ | ៣៥,៩ | ៣៥,៨ |
| អតិផរណា(%) | ២,៥ | ១,៨ | ២,៩ | ៣,៤ |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាម៉េរិក) | ៤ ០៤៥ | ៤ ០៥៥ | ៤ ០៨០ | ៤ ០៦៥ |

*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**ចំណូល ចំណាយ និងចំណុលសាធារណៈ(ឆ្នាំ២០១៨ - គម្រោង ឆ្នាំ២០២១)**

២.៧- នៅមុនពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ការគ្រប់គ្រងហិរញ្ញវត្ថុទទួលបានផលល្អប្រសើរ ដោយរក្សាបានឱនភាពថវិកាក្នុងកម្រិតទាបជាង២%(តារាង២.២)។ ដោយសារផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ចំណាយសាធារណៈមានចំនួនលើសចំណូលរបស់រដ្ឋក្នុងកម្រិត៧,២% និង១១,៣% រៀងគ្នា។ ការចំណាយរបស់រាជរដ្ឋាភិបាល មានសារៈសំខាន់ណាស់ក្នុងការបង្កើនតម្រូវការសរុប ខណៈពេលដែលមានការប្រើប្រាស់ធនធានដើម្បីបង្កើនទិន្នផល ជាពិសេសក្នុងកាលៈទេសៈដែលសកម្មភាពមានផលប៉ះពាល់ពីការបិទខ្ទប់ប្រទេស ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាមួយនឹងការធ្លាក់ចុះនៃប្រាក់ចំណូលក្នុងស្រុករំពឹងទុកក្នុងការប្រៀបធៀបនឹងការចំណាយសាធារណៈដែលមិនអាចជៀសវាងបាន ឱនភាពនៃចំណូលពីសារពើពន្ធមានការកើនឡើង។ ទោះបីជាមានការវិភាជថវិកាមូលធនក៏ដោយ ក៏ការរីករាលដាលនៃកូវីដ-១៩បានធ្វើឱ្យប្រតិបត្តិការមូលធនអនុវត្តបានតែក្នុងកម្រិតមួយប៉ុណ្ណោះ និងធ្វើឱ្យប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចទាំងមូល។ អ្នកជំនាញបានទាញយកមេរៀនពីការរាំងស្ទះដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ហើយបានគ្រោងទុកនូវវិធានការសមស្របតាមរយៈការធ្វើអន្តរាគមន៍រយៈពេលវែងដើម្បីជំរុញផលិតកម្ម។

២.៨- សន្ទស្សន៍បំណុលធៀបនឹងផលិតផលក្នុងស្រុកសរុបដែលវាស់វែងពីភាគរយនៃបំណុលសាធាណៈជាមួយនឹងផលិតផលក្នុងស្រុកសរុប ឬធៀបជាមួយនឹងលទ្ធផលប្រចាំឆ្នាំនៃសកម្មភាពសេដ្ឋកិច្ច ត្រូវបានរក្សាឱ្យនៅក្នុងកម្រិតស្ថិរភាព គឺក្រោម៣០%[2]។ ផ្អែកលើគេហទំព័រwww.tradingeconomics.com បំណុលសាធារណៈធៀបនឹងផលិតផលក្នុងស្រុកសរុបរបស់ប្រទេសថៃមានកម្រិត៥០,៥% ប្រទេសវៀតណាមមានកម្រិត៤៦,៧% ប្រទេសឡាវមានកម្រិត៥៥,៦៦%។ តាមការសិក្សាបង្ហាញថា បំណុលសាធារណៈបានផ្ដល់នូវឥទ្ធិពលវិជ្ជមានដល់កំណើនផលិតផលក្នុងស្រុកសរុបពិតសម្រាប់មនុស្សម្នាក់ ដោយផ្ដល់នូវហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាពសម្រាប់ការវិនិយោគសាធារណៈ ការជំរុញកំណើនសេដ្ឋកិច្ចនិងសុខុមាលភាពសង្គមក្នុងរយៈពេលវែង។

២.៩- ប្រហាក់ប្រហែលគ្នាដែរ សន្ទស្សន៍បំណុលធៀបនឹងការនាំចេញរបស់កម្ពុជានៅក្នុងរយៈពេលពាក់កណ្ដាលអាណត្តិនៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ មានកម្រិតចន្លោះពី២៥% ដល់៣៥%(តារាង២.២)។ រង្វាស់នៃបំណុលរបស់ប្រទេសមួយធៀបនឹងផលិតផលក្នុងស្រុកសរុបរបស់ខ្លួនគិតជាភាគរយ បានផ្ដល់នូវការព្យាករដ៏ល្អអំពីសមត្ថភាពក្នុងការសងបំណុលរបស់ខ្លួន។ យោងតាមរបាយការណ៍វិភាគរួមគ្នាមួយរបស់ធនាគារពិភពលោកនិងមូលនិធិរូបិយវត្ថុអន្តរជាតិឆ្នាំ២០១៩

[2] ផ្អែកលើធនាគារពិភពលោក សន្ទស្សន៍បំណុលដែលលើសពី៧៧% អាចបណ្ដាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់កំណើនសេដ្ឋកិច្ច។ ម្យ៉ាងទៀត ផ្អែកតាមធនាគារអភិវឌ្ឍន៍អាស៊ី សេដ្ឋកិច្ចនៅទ្វីបអាស៊ីមានសន្ទស្សន៍បំណុលធៀបនឹងផលិតផលក្នុងស្រុកសរុបក្នុងកម្រិត៦៣,៥% ក្នុងឆ្នាំ២០២០ គឺមានកម្រិតទាបខ្លាំងជាងសន្ទស្សន៍បំណុលធៀបផលិតផលក្នុងស្រុកសរុបរបស់សេដ្ឋកិច្ចសាកលលោកដែលមានកម្រិត១០៥,៤%។

ស្ដីពីចីរភាពបំណុល បង្ហាញថាវិបត្តិបំណុលខាងក្រៅរបស់កម្ពុជាត្រូវបានចាត់ថ្នាក់ថាមិនត្រឹមតែមានកម្រិតហានិភ័យទាបប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញផងដែរពីសមត្ថភាពខ្លាំងរបស់ប្រទេសក្នុងការគ្រប់គ្រងបំណុលនេះ ផ្អែកតាមកម្រិតកំណត់នៃសូចនាករសន្ទុស្សន៍សមាសភាគ។

**តារាង២.២ : ចំណូល ចំណាយ និងសន្ទុស្សន៍បំណុល**

| | ២០១៨ | ២០១៩ | ២០២០ | កក្កដា ២០២១ |
|---|---|---|---|---|
| ចំណូល | ២១,៩% | ២៥,២% | ២១,៨% | ១៩,២% |
| ចំណាយ | ២៣,៤% | ២៥,៩% | ២៩,០% | ៣០,៥% |
| បំណុលធៀបនឹងផលិតផលក្នុងស្រុកសរុប | ២១,៤% | ២០,៩% | ២៤,០៤% | |
| បំណុលធៀបនឹងការនាំចេញ | ២៨,៤% | ២៦,៧% | ៣២,៨% | |

ប្រភព : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.២- គោលនយោបាយសារពើពន្ធនិងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

២.១០- គោលនយោបាយសារពើពន្ធ គឺជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងចំណាយសាធារណៈនិងការប្រមូលចំណូល ជាមួយនឹងការទទួលខុសត្រូវក្នុងការជំរុញតម្រូវការសរុប។ ផ្នែកបន្ទាប់នេះ នឹងពណ៌នាពីសមិទ្ធផលមួយចំនួនដែលទទួលបានពីការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព។

### ក- កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៤-២០២៥

២.១១- ការសម្រេចបានកំណើនសេដ្ឋកិច្ច ក៏នឹងចូលរួមធ្វើឱ្យសម្រេចបានគោលដៅទី៨នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដ៏រឹងមាំនឹងធ្វើឱ្យការប្រើប្រាស់ធនធានថវិកាសាធារណៈកាន់តែប្រសើរឡើងនិងបង្កើនគណនេយ្យភាពនិងប្រសិទ្ធភាពប្រតិបត្តិការ។ ដើម្បីសម្រេចបានគោលបំណងនេះ រាជរដ្ឋាភិបាលកម្ពុជាបានសហការជាមួយដៃគូអភិវឌ្ឍ ក្នុងការរៀបចំកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បី (១)កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា (២)ទទួលយកឧត្តមានុវត្តន៍អន្តរជាតិក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីការរៀបចំថវិកា គណនេយ្យភាព សវនកម្ម និងការត្រួតពិនិត្យ។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់លើកកម្ពស់កំណើន ការងារ និងការកាត់បន្ថយភាពក្រីក្រ ត្រូវការការចំណាយសាធារណៈច្រើនសម្រាប់ការអភិវឌ្ឍនៅជនបទ ជាមួយនឹងការគ្រប់គ្រងចំណាយ។ ការសិក្សាមួយ[3] ដែលបានធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញពីការសន្សំថវិកាប្រមា១២០

3 ការវិភាគរបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្ដីពីអនុវិស័យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់កម្មវិធីអភិវឌ្ឍន៍ជនបទ អនុកម្មវិធីទី២ (RRP CAM 4137302)។

លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដោយសារការផ្លាស់ប្តូរ៥០%នៃលទ្ធកម្មទៅជាការប្រកួតប្រជែងតាមរយៈការដេញថ្លៃវិញ។ ទោះជាដូចនេះក្តី ការអនុវត្តពេញលេញនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងនៅដំណើរការវែងឆ្ងាយបន្តទៀតរួមទាំងការអភិវឌ្ឍធនធានមនុស្សផងដែរសម្រាប់ដំណើរការពេញលេញនៃកម្មវិធី។

២.១២- ដំណាក់កាលទី១នៃកម្មវិធីគឺ ភាពជឿជាក់នៃថវិកា ដែលសំដៅលើសមត្ថភាពរបស់រាជ-រដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តថវិកានិងការសម្រេចឱ្យបាននូវលទ្ធផលតាមតម្រូវការ បានសម្រេចលើសពីកំណើននៃគោលដៅចំណូលចរន្តប្រមាណ១,៤៧%នៃផលិតផលក្នុងស្រុកសរុប(General Secretariat 2018 et al)។ ចំណុចសំខាន់របស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏បានបង្ហាញក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ផងដែរ ដោយរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកំណែទម្រង់មួយចំនួនដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនិងលើកកម្ពស់ភាពជឿជាក់លើថវិកា។

## ខ- យុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ២០១៩-២០២៣

២.១៣- រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តួចផ្តើមគៀរគរចំណូល តាមរយៈគោលនយោបាយចំណូលថ្មីនិងក្របខ័ណ្ឌស្ថាប័ន ដោយធ្វើការពង្រឹងការគ្រប់គ្រងចំណូល សវនកម្មពន្ធ និងធ្វើឱ្យប្រសើរឡើងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រគៀរគរចំណូល ជាមួយនឹងកម្មវិធីធ្វើទំនើបកម្មប្រព័ន្ធចំណូលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងនូវគុណភាពសេវាកម្ម ការជានាសមធម៌សង្គម និងចីរភាពប្រាក់ចំណូល។ បញ្ហានេះបានកំណត់ឱ្យរាជរដ្ឋាភិបាលពង្រឹងគោលនយោបាយសារពើពន្ធនិងគោលនយោបាយមិនមែនសារពើពន្ធក្នុងវិស័យសំខាន់ៗ។

២.១៤- ពន្ធប្រយោលបាននាំមុខលើប្រាក់ចំណូលពន្ធសរុប គឺមានកម្រិត៨៩,៣%នៃចំណូលពន្ធសរុបក្នុងឆ្នាំ២០១៩ ដែលរួមមានពន្ធលើតម្លៃបន្ថែមក្នុងស្រុក ពន្ធលើតម្លៃបន្ថែមនាំចូល និងពន្ធគយ។ ពន្ធផ្ទាល់ដែលមានការប្រមូលផ្តុំជាចម្បងលើពន្ធលើប្រាក់ចំណេញ មានភាពប្រសើរឡើងដោយកើនឡើងពី១៦%នៃប្រាក់ចំណូលសរុបក្នុងឆ្នាំ២០១០ ដល់១៩,២%ក្នុងឆ្នាំ២០១៩។

២.១៥- ការប្រមូលពន្ធក្នុងឆ្នាំ២០២០មានភាពរឹងមាំ នៅពេលដែលពន្ធលើប្រាក់ចំណេញត្រូវបានដាក់ឱ្យដំណើរការ។ ផ្អែកលើរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០២១ បានបញ្ជាក់ថាប្រាក់ចំណូលក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២១ មានចំនួន៣,១៨ទ្រីលានរៀល មានការធ្លាក់ចុះប្រមាណ១០,៦%ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ ដោយសារតែការធ្លាក់ចុះនៃពន្ធលើទំនិញនិងសេវាដែលការប្រើប្រាស់មានការធ្លាក់ចុះ។ នៅក្នុងរយៈពេលពីរខែដើមឆ្នាំ២០២១នេះចំណូលពន្ធមានប្រមាណ២,៦៨ទ្រីលានរៀល មានការថយចុះ៨,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ។ ប្រហាក់ប្រហែលគ្នានេះដែរ ចំណូលមិនមែនពន្ធធ្លាក់ចុះមកត្រឹម០,៦៩ទ្រីលានរៀលដែលមានការថយចុះប្រមាណ១៩,៨%ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ។

### គ- យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

២.១៦- សមត្ថភាពក្នុងការរៀបចំនិងអនុវត្តថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យ លទ្ធកម្ម សវនកម្មផ្ទៃក្នុងនិងខាងក្រៅ និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ កំពុងត្រូវបានពង្រឹង។ បញ្ហានេះ ត្រូវបានបន្ថែមដោយសំណុំនៃការគ្រប់គ្រងខាងក្នុងដ៏ទូលំទូលាយ និងស្មុគស្មាញ(ការសន្យាផ្តល់និងដំណើរការការបញ្ជាទិញ ការទូទាត់) ដែលបច្ចុប្បន្នកំពុងដាក់ឱ្យអនុវត្ត។ រតនាគារជាតិបានធ្វើសមតុល្យគណនីរាជរដ្ឋាភិបាលដែលកាន់កាប់នៅធនាគារពាណិជ្ជ ហើយផ្ទេរសមតុល្យទៅគណនីតែមួយរបស់រតនាគារ។ បន្ថែមលើនេះ ការទូទាត់របស់រាជរដ្ឋាភិបាល រួមទាំងការគ្រប់គ្រងប្រាក់បៀវត្សតាមរយៈប្រព័ន្ធធនាគារមានការកើនឡើង ដោយកាត់បន្ថយចំនួនប្រតិបត្តិការផ្អែកលើសាច់ប្រាក់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ បានប្រកាសដល់ក្រសួង ស្ថាប័ន ដើម្បីជួយសម្រួលដំណើរការទូទាត់ដោយរលូន ប៉ុន្តែមានការគ្រប់គ្រងបានល្អ និងដើម្បីគាំទ្រដល់ការរៀបចំកាន់តែប្រសើរឡើងនូវការសន្យាផ្តល់មុខងារចំណាយ និងការផ្សះផ្សារ (ធនាគារពិភពលោកឆ្នាំ២០១៣)។

២.១៧- ដូចគ្នាដែរ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ភាពត្រឹមត្រូវនិងភាពទូលំទូលាយនៃរបាយការណ៍ហិរញ្ញវត្ថុ កំពុងត្រូវបានកែលម្អជាប្រព័ន្ធតាមរយៈការចាត់ថ្នាក់ថវិកាស្តង់ដាអន្តរជាតិ តារាងគណនី និងការរួមបញ្ចូលនៃការចំណាយមូលធន។ រតនាគារជាតិ ជាអ្នកគ្រប់គ្រងគណនីធនាគាររបស់រាជរដ្ឋាភិបាលនៅធនាគារជាតិនៃកម្ពុជា។ រតនាគារជាតិ ធ្វើឱ្យស៊ីគ្នារវាងគណនីទាំងនេះជាមួយនឹងសៀវភៅសាច់ប្រាក់ដែលត្រូវគ្នាប្រចាំខែក្នុងរយៈពេល៤សប្តាហ៍ចាប់ពីចុងខែ។

### ឃ- យុទ្ធសាស្ត្រគ្រប់គ្រងបំណុលឆ្នាំ២០១៩-២០២៣

២.១៨- ដូចបានបង្ហាញក្នុងតារាង២.៣ ការវិភាគពីចីរភាពបំណុលដែលបានកត់ត្រាសម្រាប់ឆ្នាំ ២០២០ ជាមួយនឹងសូចនាករបំណុលសំខាន់ៗទាំងអស់ គឺស្ថិតនៅក្រោមកម្រិតកំណត់។ បំណុលសាធារណៈសរុបធៀបនឹងផលិតផលក្នុងស្រុកសរុបមានកម្រិត២៤% ធៀបនឹងកម្រិតកំណត់៥៥%។ បំណុលសាធារណៈពីក្រៅប្រទេសធៀបនឹងផលិតផលក្នុងស្រុកសរុបមានកម្រិត២៤% ធៀបនឹងកម្រិតកំណត់៤០%។ បំណុលសាធារណៈពីក្រៅប្រទេសធៀបនឹងការនាំចេញ មានកម្រិត៣២,៨% ធៀបនឹងកម្រិតកំណត់១៨០% និងបំណុលសាធារណៈពីក្រៅប្រទេសធៀបនឹងចំណូល មានកម្រិត ៦,៣% ធៀបនឹងកម្រិតកំណត់១៨%។

**តារាង២.៣ : សូចនាករសំខាន់ៗវិភាគពីចីរភាពបំណុល(%)**

| | Threshold | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|
| **បំណុលសាធារណៈសរុប ធៀបនឹង** | | | | |
| ផលិតផលក្នុងសរុប | ៥៥ | ២១,៤ | ២០,៧៨ | ២៤,០៤ |
| **បំណុលសាធារណៈនិងបំណុលសាធារណៈធានាបំណុលក្រៅប្រទេស ធៀបនឹង** | | | | |

| | | | | |
|---|---|---|---|---|
| ផលិតផលក្នុងសរុប | ៤០ | ២១,៤៦ | ២០,៧៨ | ២៤,០៤ |
| ការនាំចេញ | ១៨០ | ២៨,៤ | ២៦,៧ | ៣២,៨ |
| **បំណុលសាធារណៈនិងបំណុលសាធារណៈធានាសេវាបំណុលក្រៅប្រទេស ធៀបនឹង** | | | | |
| ការនាំចេញ | ១៥ | ១,៤ | ១,៥ | ១,៨ |
| ចំណូល | ១៨ | ៤,៩ | ៤,៥ | ៦,៣ |

**ប្រភព :** ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈរបស់កម្ពុជា ជុំទី១១ ទំព័រ១២ ខែមីនា ឆ្នាំ២០២១។

**សម្គាល់ :** កម្រិតកំណត់ត្រូវបានកំណត់តាមស្តង់ដារបស់ធនាគារពិភពលោកនិងមូលនិធិរូបិយវត្ថុអន្តរជាតិ។

## ២.៣- ចង្ខ្សនភាពចិស័យរូបិយចត្ថុនិងចិស័យហិរញ្ញចត្ថុ

២.១៩- ទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជាបង្ហាញថា រូបិយវត្ថុទូទៅ(M2)បានកើនឡើងពី ១០០,២ទ្រីលានរៀល(១០១%នៃផ.ស.ស)នៅឆ្នាំ២០១៨ ដល់ប្រមាណ១៤៨ទ្រីលានរៀល (១៣៩,៧%នៃផ.ស.ស.)ឆមាសទី១ ឆ្នាំ២០២១។ ជារួម រូបិយវត្ថុទូទៅមានកំណើនប្រចាំឆ្នាំក្នុងកម្រិតប្រមាណ២០% នៅក្នុងអំឡុងពេលនៃវដ្តផែនការ(រូបភាព៣.១) ដែលកំណើននេះត្រូវបានគាំទ្រដោយកំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធនិងទ្រព្យសកម្មបរទេសសុទ្ធ។ នៅឆមាសទី១ ឆ្នាំ២០២១ រូបិយវត្ថុទូទៅ(M2)បានកើនឡើង១៩,២%(ឆ្នាំលើឆ្នាំ) ខ្ពស់ជាងកំណើនក្នុងគ្រាដូចគ្នាឆ្នាំមុន(១២,៣%) ប៉ុន្តែមានកំណើនប្រហាក់ប្រហែលនឹងកំណើនមធ្យមរយៈពេល៥ឆ្នាំចុងក្រោយមុនពេលមានវិបត្តិកូវីដ-១៩(២០,៦%)។ កំណើននេះជាចម្បងបណ្តាលមកពីកំណើនប្រាក់បញ្ញើសរុប របស់អតិថិជន (ទាំងជាប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀល) ក្នុងអត្រា១៩,៥%ធៀបនឹងកំណើន១០,៨% ខណៈដែលកំណើនរូបិយវត្ថុក្នុងចរាចរណ៍បានថយល្បឿនមក១៦,៨% ធៀបនឹង២៨% គ្រាដូចគ្នាឆ្នាំមុន។ កំណើនប្រាក់បញ្ញើសរុបរបស់អតិថិជន ត្រូវបានគាំទ្រដោយបញ្ញើរបស់អតិថិជនចាស់ដែលបានដាក់ផ្ញើក្នុងទំហំទឹកប្រាក់ច្រើនៗ និងមួយផ្នែកដោយការបង្កើតគណនីសន្សំឆ្លាតវៃ(Smart Saving account) និងធនាគារចល័ត(Mobile Banking) ដោយសារការបន្តកើនឡើងនៃប្រាក់ចំណូលនិងសន្សំរបស់សាធារណជន ការបន្តទទួលបានលំហូរមូលធនចូលមកក្នុងសេដ្ឋកិច្ចតាមរយៈប្រព័ន្ធធនាគារនិងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។ កំណើនទាបនៃរូបិយវត្ថុក្នុងចរាចរណ៍ អាចបណ្តាលមកពីការគ្រប់គ្រងរូបិយវត្ថុដោយប្រុងប្រយ័ត្នដើម្បីជៀសវាងសម្ពាធលើអត្រាប្តូរប្រាក់និងការងាកមកប្រើប្រាស់ប្រព័ន្ធធនាគារច្រើនជាងមុនក្នុងការទូទាត់ទំនិញប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចមានការថមថយ។

២.២០- រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា បាននិងកំពុងកសាងទំនុកចិត្តមកលើប្រាក់រៀលនិងលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុតាមរយៈការអនុវត្តសកម្មភាពផ្សេងៗ ដូចជា (១)តម្រូវឱ្យប្រតិបត្តិការរបស់រាជរដ្ឋាភិបាលទាំងអស់ធ្វើឡើងជាប្រាក់រៀល (២)ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ (៣)ការកែលម្អគុណភាពក្រដាសប្រាក់ និង(៤)ការចែកចាយប្រាក់រៀលដើម្បីបំពេញតាមតម្រូវការនៅក្នុងតំបន់និងវិស័យទាំងអស់។ ជាលទ្ធផល ការប្រើប្រាស់ប្រាក់រៀលបានកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់

បញ្ញើជារូបិយបណ្ណធៀបនឹងរូបិយវត្ថុទូទៅ(FCD/M2) និងប្រាក់បញ្ញើជារូបិយបណ្ណធៀបនឹងប្រាក់បញ្ញើសរុប ដោយបានថយចុះពីកម្រិតប្រមាណ៨៦%និង៩៤%រៀងគ្នាក្នុងឆ្នាំ២០១៨ មកត្រឹម ៨២,៧%និង៩២% រៀងគ្នាត្រឹមឆមាសទី១ ឆ្នាំ២០២១។

២.២១- យុទ្ធសាស្ត្ររបស់ធនាគារជាតិនិងរាជរដ្ឋាភិបាលខាងលើ ក៏បានធ្វើឱ្យប្រាក់រៀលមានស្ថិរភាពក្នុងកម្រិត៤ ០៥០រៀល/ដុល្លារអាម៉េរិកផងដែរ ដោយអនុញ្ញាតឱ្យមានការប្រែប្រួលតិចតួច។

**រូបភាព២.១ : សមាសធាតុនៃរូបិយវត្ថុទូទៅ និងកំណើន**
(ឆ្នាំ២០១៨ ដល់ឆមាសទី១ ឆ្នាំ២០២១)




*ប្រភព : ធនាគារជាតិនៃកម្ពុជា*

## ទីផ្សារភាគហ៊ុននិងផ្សេងទៀត

២.២២- ទីផ្សារភាគហ៊ុនក្នុងប្រទេសកម្ពុជាកំពុងមានសន្ទុះ ដោយមានក្រុមហ៊ុនចំនួន៧បានចុះបញ្ជីដែលមានមូលធនបត្រទីផ្សារកើនឡើងពី១,២៣ប៊ីលានរៀលក្នុងឆ្នាំ២០១៧ ដល់១,៧៧ប៊ីលានរៀលក្នុងឆ្នាំ២០១៨ ស្មើនឹងកំណើន៤៤%(ធនាគាជាតិនៃកម្ពុជាឆ្នាំ២០២០ ទំព័រ២៩)។ អនុក្រឹត្យថ្មីមួយពាក់ព័ន្ធនឹងទីផ្សារភាគហ៊ុននេះដែលត្រូវបានបង្កើតក្នុងឆ្នាំ២០១៩ បានផ្តល់នូវការលើកទឹកចិត្តគួរឱ្យទាក់ទាញបន្ថែមទៀត ដោយផ្តល់ឱ្យក្រុមហ៊ុនដែលចុះបញ្ជីទទួលបានការកាត់បន្ថយលើពន្ធលើប្រាក់ចំណូល៥០% ក្នុងរយៈពេលបីឆ្នាំ និងការលុបបំបាត់បំណុលពន្ធទាំងអស់។

## ២.៤- ចន្លោះភាពជញ្ជីងទូទាត់កម្ពុជា

២.២៣- ស្ថានភាពជញ្ជីងទូទាត់មានអតិរេកជាមធ្យមប្រមាណ៤% ធៀបនឹងផ.ស.ស.រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ(ឆ្នាំ២០១៩ ដល់ឆមាសទី១ ឆ្នាំ២០២១)។ អតិរេកជញ្ជីងទូទាត់បានថយចុះពី

៥,៩នៃផ.ស.ស.ក្នុងឆ្នាំ២០១៨ មក១%នៃផ.ស.ស.ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាចម្បងដោយសារការកើនឡើងឱនភាពគណនីចរន្តនិងសេវា។

២.២៤- គណនីចរន្តមានឱនភាព១១,៨% នៃផ.ស.ស.ក្នុងឆ្នាំ២០១៨ និង១៥%នៃផ.ស.ស.ក្នុងឆ្នាំ២០១៩ ដែលបណ្ដាលមកពីការកើននៃឡើងឱនភាពពាណិជ្ជកម្មទំនិញនិងចំណូលបឋម។ នៅឆ្នាំ២០២០ ឱនភាពគណនីចរន្តបានថយចុះដល់៨%នៃផ.ស.ស. ជាចម្បងដោយសារការថយចុះនៃឱនភាពពាណិជ្ជកម្មទំនិញ ខណៈដែលគណនីសេវាបានផ្លាស់ប្ដូរពីអតិរេកសុទ្ធទៅជាឱនភាពសុទ្ធ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ ឱនភាពគណនីចរន្តបន្តកើនឡើងដោយសារការកើនឡើងឱនភាពពាណិជ្ជកម្មទំនិញនិងចំណូលបឋម ស្របពេលដែលគណនីសេវាសុទ្ធបន្តមានឱនភាព ដែលអាចត្រូវបានផាត់ទាត់មួយផ្នែកដោយការកើនឡើងនូវអតិរេកគណនីចំណូលបន្ទាប់បន្សំ។

**រូបភាព២.២ : គណនីចរន្ត**

(%នៃផ.ស.ស. ពីឆ្នាំ២០១១ ដល់ឆមាសទី១ ឆ្នាំ២០២១)




ប្រភព : ធនាគារជាតិនៃកម្ពុជា

២.២៥- សមតុល្យពាណិជ្ជកម្មទំនិញ បានបង្ហាញឱនភាព២៣,៨%នៃផ.ស.ស.ក្នុងឆ្នាំ២០១៨ និង២៦,៧%នៃផ.ស.ស.នៅឆ្នាំ២០១៩ ហើយបានធ្លាក់ចុះមកត្រឹម៩,៥%នៃផ.ស.ស.នៅឆ្នាំ២០២០។ ការធ្លាក់ចុះនេះ ជាចម្បងដោយសារការថយចុះនៃការនាំចូល ខណៈដែលការនាំចេញបន្តកើនឡើង ជាពិសេស ការនាំចេញផលិតផលកម្មន្តសាលក្រៅពីវិស័យកាត់ដេរ ដូចជាគ្រឿងអេឡិចត្រូនិក ទោចក្រយាន និងផលិតផលកសិកម្ម រួមមានអង្ករនិងកៅស៊ូ ស្របពេលដែលការនាំចេញផលិតផលកាត់ដេរបានថយចុះ។ ក្នុងឆមាសទី១ ឆ្នាំ២០២១ ឱនភាពពាណិជ្ជកម្មទំនិញបានកើនឡើងដល់៤២,៧%នៃផ.ស.ស. ដែលបណ្ដាលមកពីការនាំចូលកើនឡើងលឿនជាងការនាំចេញ។ សេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានឆ្លុះបញ្ចាំងក្នុងការធ្លាក់ចុះតម្រូវការក្នុងស្រុកនិងការថយចុះការនាំចេញផលិតផលក្នុងវិស័យកាត់ដេរ។ ការនាំចូលវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ សម្ភារៈនិងបរិក្ខារសំណង់ យានយន្ត និងប្រេងឥន្ធនៈបានថយចុះតិចតួច ស្របពេលដែលការនាំចេញសម្លៀកបំពាក់និងស្បែកជើងក៏បានថយចុះដែរ។

២.២៦- ទុនបម្រុងអន្តរជាតិបានកើនឡើងពី១៤,៦ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨ ដល់២១,៣ប៊ីលានដុល្លារអាម៉េរិកនៅឆ្នាំ២០២០ រួចបានថយចុះប្រមាណ៥%មក២០,២ប៊ីលានដុល្លារអាម៉េរិកនៅចុងខែមិថុនា ឆ្នាំ២០២១នេះ ដោយសារការអូសបន្លាយនិងការរីករាលដាលនៃជំងឺកូវីដ-១៩និងភាពមិនអំណោយផលនៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ប៉ុន្តែ នៅតែអាចធានាបានការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ប្រមាណ៩ខែ និងអាចអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអត្រាប្តូរប្រាក់និងការផ្គត់ផ្គង់តម្រូវការសន្ទនីយភាពនិងរក្សាបានភាពធន់នៃវិស័យហិរញ្ញវត្ថុនៅពេលមានការប៉ះទង្គិចពីវិបត្តិសេដ្ឋកិច្ចជាយថាហេតុ។ ទុនបម្រុងអន្តរជាតិត្រូវបានគ្រប់គ្រងយ៉ាងហ្មត់ចត់និងប្រុងប្រយ័ត្នខ្ពស់ដោយគោរពតាមគោលការណ៍លំដាប់អាទិភាព (១)ការរក្សាដើមទុន (២)សន្ទនីយភាព និង(៣)ចំណូល។ ជាងនេះទៀត ហានិភ័យថ្មីៗដែលអាចកើតមានត្រូវបានកំណត់និងតាមដានយ៉ាងយកចិត្តទុកដាក់ ជាពិសេសលើការវិនិយោគប្រកបដោយការទទួលខុសត្រូវខ្ពស់លើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ។



# ជំពូកទី៣

# សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ

## ១- ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ : ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

### ១.១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន

៣.១- ក្រសួងមហាផ្ទៃ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

**លើកកម្ពស់គុណភាពសេវាសាធារណៈ និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- កិច្ចសហការនិងការរៀបចំដាក់ចេញលិខិតបទដ្ឋាននានា
  - បានរៀបចំអនុក្រឹត្យចំនួន៣ពាក់ព័ន្ធនឹងមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌក្នុងគោលដៅដើម្បីរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលខណ្ឌធានាបានការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន
  - បានផ្ទេរការគ្រប់គ្រងបុគ្គលិកទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
  - បានរៀបចំនូវលិខិតបទដ្ឋានគតិយុត្តិចំនួន៥ច្បាប់ សេចក្តីណែនាំចំនួន២ ប្រកាសចំនួន ៣ ពាក់ព័ន្ធការចូលសញ្ជាតិខ្មែរ ការផ្តល់សៀវភៅស្នាក់នៅ ការចុះបញ្ជី និងការគ្រប់គ្រងការស្នាក់នៅ និងការណែនាំការអនុវត្តយន្តការច្រកចេញចូលតែមួយរបស់សេវាអត្តសញ្ញាណកម្មនៅឃុំ សង្កាត់
- ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ត្រីថ្នាក់ជាតិ
  - ការលើកកម្ពស់សមត្ថភាពស្ថាប័ន បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញសវនកម្មនិងជំនាញពាក់ព័ន្ធចំនួន៥មុខវិជ្ជាចំនួន២លើក ដែលមានសិក្ខាកាមចូលរួមចំនួន២៦០រូប
  - បានរៀបចំផ្សព្វផ្សាយតាមបណ្តាញសង្គមនូវគោលនយោបាយរាជរដ្ឋាភិបាលពាក់ព័ន្ធនឹងអភិបាលកិច្ចបានចំនួន២៨លើក ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលនិងមន្ត្រីនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីការផ្តល់សេវាសាធារណៈឈរលើគោលការណ៍អភិបាលកិច្ចល្អចំនួន១៧លើក
- បង្កើតនិងដាក់ឱ្យដំណើរការជាផ្លូវការនូវអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋទាំង២៥រាជធានី ខេត្ត
- រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពជាគោលការណ៍អនុញ្ញាតតាមការស្នើសុំរបស់ក្រសួងមហាផ្ទៃលើការដំឡើងកម្រិតច្រកទ្វារតំបន់ព្រំដែនចំនួន១ច្រក ស្ថិតក្នុងឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ទៅជាច្រកទ្វារព្រំដែនអន្តរជាតិក្នុងឆ្នាំ២០១៩បន្ថែមទៀត បន្ទាប់ពីដំឡើងកម្រិតច្រកទ្វារតំបន់ព្រំ ច្រកទ្វារតំបន់ព្រំដែនទៅជាច្រកទ្វារព្រំដែនអន្តរ

ជាតិចំនួន១ក្នុងឆ្នាំ២០១៥ ដំឡើងកម្រិតច្រកទ្វារព្រំដែនទ្វេភាគីទៅជាច្រកទ្វារព្រំដែនអន្តរជាតិចំនួន១ច្រក ក្នុងឆ្នាំ២០២១ និងដំឡើងកម្រិតច្រកទ្វារតំបន់ព្រំដែនទៅជាច្រកទ្វារព្រំដែនទ្វេភាគីចំនួន៤ច្រកពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧

- បានបង្កើតយន្តការការនៃផ្តល់បណ្ណព្រំដែនដល់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែនសម្រាប់ចេញចូលប្រទេសជិតខាងក្នុងការប្រកបរបរទទួលទាន
- បានពង្រឹងគណនេយ្យភាពរវាងក្រុមប្រឹក្សានិងប្រជាពលរដ្ឋ រវាងក្រុមប្រឹក្សានិងមន្ត្រីរបស់ខ្លួន និងរវាងក្រុមប្រឹក្សានិងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន
- បានធ្វើកំណែទម្រង់ការគ្រប់គ្រងពន្ធនាគារ។

**សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

- កងកម្លាំងនគរបាលការពារព្រំដែនបាននិងបន្តសហការកៀកស្មាគ្នាយ៉ាងជិតស្និទ្ធជាមួយកងយោធពលខេមរភូមិន្ទ ការពារយ៉ាងគង់វង្សនូវបូរណភាពទឹកដីនិងអធិបតេយ្យជាតិ រក្សាបាននូវព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងមានការអភិវឌ្ឍ។ ទន្ទឹមនេះ កងកម្លាំងនគរបាលការពារព្រំដែនបានជួបប្រជុំជាមួយសមភាគីនៃប្រទេសជិតខាងចំនួន ១ ១៧៧៥លើក ដើម្បីផ្លាស់ប្តូរបទពិសោធរួមគ្នាដោះស្រាយបាតុភាពនានា និងសហការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងព្រំដែនប្រកបដោយប្រសិទ្ធភាព
- ក្នុងបរិបទប្រយុទ្ធប្រឆាំងការឆ្លងរាតត្បាតជំងឺកូវីដ-១៩ចាប់តាំងពីឆ្នាំ២០២០មក កងកម្លាំងនគរបាលការពារព្រំដែនបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអនុវត្តវិធានការគ្រប់គ្រង បិទខ្ទប់ព្រំដែន ដោយបានដាក់ពង្រាយកម្លាំងនៅតាមតំបន់ព្រំដែនចំនួន៩៦២ គោលដៅ។ ជាក់ស្តែងកម្លាំងបានបង្ក្រាបសកម្មភាពនាំពលករចេញចូលឆ្លងដែនគេចចេញពីការធ្វើចត្តាឡីស័កចំនួន១៨០ករណី សកម្មភាពជនបរទេសជ្រៀតឆ្លងដែនខុសច្បាប់ចំនួន ៣៥ករណី
- បានការបន្តដោះស្រាយបញ្ហាព្រំដែនគោកនិងទឹកជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំនិងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែនជាព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឱ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង
- បានបញ្ចៀសអំពើភេរវកម្មមិនឱ្យកើតមានឡើងនៅកម្ពុជា ក្នុងខណៈពេលដែលការវាយប្រហារដោយភេរវកម្មអន្តរជាតិកើតឡើងចំនួន២ ២៦៤លើក៤៤ប្រទេស/
- បានទប់ស្កាត់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ទប់ស្កាត់រាល់សកម្មភាពប្រមូលផ្តុំធ្វើបាតុកម្ម កូដកម្ម និងការចាត់វិធានការរដ្ឋបាលនិងការវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ចំពោះមុខសញ្ញាដែលធ្វើសកម្មភាពញុះញង់ វាយប្រហារប្រមាថដល់ព្រះកិត្តិយសព្រះមហាក្សត្រ កិត្តិយសថ្នាក់ដឹកនាំ និងស្ថាប័នកំពូលៗរបស់ជាតិ ជាពិសេស

ការចុះស្រាវជ្រាវបង្ក្រាបមុខសញ្ញាពាក់ព័ន្ធពួកឧទ្ទាមនិងបានអប់រំពលរដ្ឋដែលចាញ់កលឃោសនារបស់ពួកឧទ្ទាម

- បានបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្មនិងហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរនិងប្រើប្រាស់គ្រឿងញៀន ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងៗទៀត
- បានបន្តជំរុញអនុវត្ត "គោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព"
- បានដាក់ចេញវិធានការរឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោករបស់រាជរដ្ឋាភិបាល ក៏ដូចជាគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលជាលទ្ធផលមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ពិសេសការចូលរួមគោរពនិងអនុវត្តច្បាប់យ៉ាងផុសផុលរបស់អ្នកប្រើប្រាស់ផ្លូវ បានធ្វើឱ្យស្ថានភាពចរាចរណ៍មានការប្រែប្រួលប្រកបដោយភាពវិជ្ជមាន
- បានយកចិត្តទុកដាក់រៀបចំក្រុមពន្លត់អគ្គិភ័យកាតព្វកិច្ចនិងក្រុមពន្លត់អគ្គិភ័យដោយស្ម័គ្រចិត្ត ដោយរៀបចំជាលិខិតបទដ្ឋានក្នុងគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងគាំទ្រ
- បានពង្រឹងការអនុវត្តច្បាប់សញ្ជាតិនិងច្បាប់អន្តោប្រវេសន៍ តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍នៅតាមព្រំដែនគោក អាកាសយានដ្ឋាន និងព្រំដែនទឹក ជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់តាមរយៈការអនុវត្តនូវកិច្ចការមួយចំនួនដូចខាងក្រោម៖
    - ពង្រឹងការគ្រប់គ្រងច្រកទ្វារគ្រប់ប្រភេទ បំផុសការចូលរួមសហការពីមហាជននិងសមត្ថកិច្ចពាក់ព័ន្ធក្នុងការបង្ការទប់ស្កាត់បទល្មើសនិងការឆ្លងដែនខុសច្បាប់
    - លើកកម្ពស់ការគ្រប់គ្រងនិងការផ្តល់សេវាទិដ្ឋាការគ្រប់ប្រភេទ សំដៅបម្រើនយោបាយបើកចំហជើងមេឃ ការងារអន្តោប្រវេសន៍និងការងារសន្តិសុខ
    - ពង្រឹងការគ្រប់គ្រងវត្តមានស្នាក់នៅនិងការប្រកបមុខរបររបស់ជនបរទេសអន្តោប្រវេសន៍ឱ្យបានម៉ឺងម៉ាត់
    - ចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសនៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថាននានាដោយសហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
    - សិក្សាកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធជនបរទេសអន្តោប្រវេសន៍កាន់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ រៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការប្រើប្រាស់ហត្ថពលកម្មនៅតាមតំបន់ព្រំដែនដើម្បីផ្សព្វផ្សាយដល់ម្ចាស់ទីតាំងអាជីវកម្ម និងរៀបចំគំរូប្រកាសទទួលស្គាល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍និងឯកសារធ្វើដំណើរសម្រាប់ជនបរទេសជាអ្នកវិនិយោគឯកជននិងសហព័ទ្ធ

- អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឆ្លើយតបបាននូវគ្រប់សំណូមពរជំនាញអន្តោប្រវេសន៍
- ចាត់វិធានការស៊ើបអង្កេត ស្វែងរកជនបរទេសដែលលួចជ្រៀតចូលមកស្នាក់នៅខុសច្បាប់ ជនបរទេសពាក់ព័ន្ធការប្រព្រឹត្តបទល្មើសនានា ដោយអនុវត្តច្បាប់ម៉ឺងម៉ាត់
- ពង្រីកចំណងមិត្តភាព សហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ដើម្បីផ្តល់នូវការគាំទ្រគ្នាទៅវិញទៅមក ការផ្លាស់ប្តូរព័ត៌មាន ការដោះស្រាយបញ្ហាអន្តោប្រវេសន៍ ការលើកកម្ពស់សមត្ថភាពជំនាញ និងជំនួយសម្ភារៈបច្ចេកទេស
- ពង្រឹងសមត្ថភាពអង្គភាពស្ថាប័នដោយធ្វើការកែសម្រួលរចនាសម្ព័ន្ធ ការគ្រប់គ្រង ការអភិវឌ្ឍធនធានមនុស្ស ការបំពាក់សម្ភារៈបច្ចេកទេស ការលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តថវិការបស់អង្គភាពស្ថាប័ន

- ពង្រឹងការអនុវត្តច្បាប់និងកសាងសមត្ថភាពដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាជាក់ស្តែង បទល្មើសឆបោកដោយប្រើប្រព័ន្ធបច្ចេកវិទ្យា និងការក្លែងបន្លំឆបោកតាមប្រព័ន្ធ VOIP ល្បែងស៊ីសងតាមប្រព័ន្ធអ៊ិនធឺណិត ត្រូវបានបើកប្រតិបត្តិការបង្ក្រាបយ៉ាងសកម្មដោយបានឃាត់ខ្លួនជនសង្ស័យដើម្បីបញ្ជូនទៅតុលាការនិងអនុវត្តច្បាប់អន្តោប្រវេសន៍ដោយធ្វើការបណ្តេញចេញពីប្រទេសកម្ពុជា
- កសាងផែនការមេនិងផែនការសកម្មភាពបម្រើឱ្យព្រឹត្តិការណ៍នយោបាយនិងព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ រួមមានផែនការការពារកិច្ចប្រជុំASEMទី១៣ ឆ្នាំ២០២១ កិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២ ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ និងកសាងសេចក្តីព្រាងផែនការសម្រាប់ការពារយុទ្ធនាការឃោសនាបោះឆ្នោតនិងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ក្នុងឆ្នាំ២០២២ និងជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ ឆ្នាំ២០២៣។ ទន្ទឹមនេះ បានកសាងផែនការស្តីពីកិច្ចការពារសុវត្ថិភាពសម្រាប់ជនភៀសខ្លួនស្នាក់នៅបណ្តោះអាសន្ននៅកម្ពុជាផងដែរ។

៣.២- ទន្ទឹមនឹងវឌ្ឍនភាពជាទីមោទនភាពខាងលើ ក្រសួងនៅបន្តជួបបញ្ហាប្រឈមសំខាន់ ដូចខាងក្រោម៖

- ការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំមានភាពច្បាស់លាស់ស្របតាមការគ្រប់គ្រងតាមប្រព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការផ្ទេរមុខងារនិងធនធានពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានភាពយឺតយ៉ាវនិងអនុវត្តមិនបានពេញលេញ
- សាលាជាតិរដ្ឋបាលមូលដ្ឋានដែលជាគ្រឹះស្ថានសម្រាប់អភិវឌ្ឍសមត្ថភាព ពុំទាន់អាចដំណើរការបានពេញលេញ
- សមត្ថភាពស្ថាប័ននិងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ឆ្លើយតបបានពេញលេញ

- ខ្វះការគាំទ្របច្ចេកទេសនិងធនធានក្នុងការចុះតាមដាននិងគាំទ្រសម្រុះសម្រួលបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋ
- សេវារដ្ឋបាលដែលបានផ្ដល់ដោយមន្ទីរ អង្គភាពមួយចំនួនពុំទាន់បានផ្ទេរមកអនុវត្តនៅអង្គភាពច្រកចេញចូលតែមួយនៅឡើយ
- បែបបទនិងនីតិវិធីនៃការផ្ដល់សេវារដ្ឋបាលនានានៅមានភាពស្មុគស្មាញ
- ទទួលរងភាពអវិជ្ជមានជាអន្លើៗ ដូចជាការផ្ទេរមុខងារនិងធនធានពីក្រសួង ស្ថាប័ន ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋានកំណើត ការចុះបញ្ជីគ្រប់គ្រងការស្នាក់នៅបណ្ដោះអាសន្ន និងការចុះបញ្ជីគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋនៅតាមតំបន់ខុនដូ បុរី ឧស្សាហកម្ម និងតំបន់សេដ្ឋកិច្ចពិសេស មិនទាន់បានអនុវត្តឱ្យបានពេញលេញនិងម៉ឺងម៉ាត់ ដោយសារកត្តាប្រឈមពាក់ព័ន្ធនឹងសមត្ថភាពមន្ត្រីទាំងនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន
- ការបង្កើតឬដំឡើងកម្រិតច្រកទ្វារព្រំដែនជាមួយប្រទេសជិតខាងក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖
    - ប្រទេសជិតខាងមិនព្រមបង្កើតឬដំឡើងកម្រិតច្រកទ្វារព្រំដែន តាមស្មារតីដែលបានឯកភាពគ្នា
    - ការចរចារវាងមន្ត្រីជំនាញក្រសួងមហាផ្ទៃជាមួយមន្ត្រីជំនាញនៃបណ្ដាក្រសួង ស្ថាប័នជំនាញដែលទទួលបន្ទុកក្នុងការបង្កើតឬដំឡើងកម្រិតច្រកទ្វារព្រំដែន មានភាពស្មុគស្មាញ
    - ការរីករាតត្បាតនៃការឆ្លងជំងឺកូវីដ-១៩ បានធ្វើឱ្យក្រុមការងារចម្រុះស្ដីពីច្រកទ្វារព្រំដែនគោក កម្ពុជា វៀតណាម ខកខានក្នុងការចុះសិក្សា ពិនិត្យវាយតម្លៃរួមគ្នានៅទីតាំងជាក់ស្ដែងដើម្បីរៀបចំផែនការបង្កើតនិងដំឡើងកម្រិតច្រកទ្វារព្រំដែនរួមគ្នា
    - ពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ការចុះសិក្សា ពិនិត្យ វាយតម្លៃក្នុងការបង្កើតឬដំឡើងកម្រិតច្រកទ្វារព្រំដែន
- ការគំរាមកំហែងដោយការរីករាលដាលនៃជំងឺកូវីដ-១៩និងមេរោគបំប្លែងថ្មី ការគំរាមកំហែងដោយភេរវកម្មអន្តរជាតិនិងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ បទល្មើសបច្ចេកវិទ្យា គួបផ្សំនឹងការបន្តកើតឡើងនូវបទល្មើសព្រហ្មទណ្ឌ ការជួញដូរប្រើប្រាស់គ្រឿងញៀន អំពើជួញដូរកេងប្រវញ្ចពលកម្មនិងផ្លូវភេទ បញ្ហាក្មេងទំនើង ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ សុទ្ធតែជាកម្មវត្ថុដែលត្រូវប្រមូលផ្ដុំគិតគូរបន្តដោះស្រាយសំដៅពង្រឹងស្ថិរភាព សុវត្ថិភាពសង្គម ដើម្បីរក្សាសេចក្ដីសុខជូនប្រជាពលរដ្ឋនិងសង្គមជាតិ
- ក្នុងការកសាងសមត្ថភាពកម្លាំងនគរបាលជាតិនិងមន្ត្រីពន្ធនាគារទូទាំងប្រទេស បានជួបបញ្ហាប្រឈមនិងខ្វះខាតកញ្ចប់ថវិកានៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជាអគារហ្វឹកហាត់ស៊ើបអង្កេតកើតហេតុបទល្មើសព្រហ្មទណ្ឌសិប្បនិម្មិតនិងមន្ទីរពិសោធន៍កោសលវិច័យ អគារហ្វឹកហាត់សម្រាប់ពហុជំនាញ អគារហ្វឹកហាត់រំដោះចំណាប់ខ្មាំងនិង

ពន្លត់អគ្គិភ័យ បន្ថែមអគារសិក្សា អគារស្នាក់នៅ ទីលានបាញ់គ្រាប់ពិត ទីលានឆ្លងកាត់ឧបសគ្គ អគារក្បាច់គុននៅតាមបណ្ដាសាលានគរបាលជាតិភូមិភាគ តាមតម្រូវការអាទិភាព និងខ្វះខាតសម្ភារៈហ្វឹកហាត់សម្រាប់ជំនាញមួយចំនួន

- វគ្គបណ្ដុះបណ្ដាលបំប៉នជំនាញរយៈពេលខ្លីនិងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូ ដូចជាដំណើរការទស្សនកិច្ចសិក្សា ការចូលរួមក្នុងវេទិកាអន្តរជាតិផ្សេងៗ ដែលត្រូវបានផ្អាកទាំងស្រុងដោយសារជំងឺកូវីដ-១៩។

៣.៣- រាជរដ្ឋាភិបាលអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការប្រកបដោយប្រសិទ្ធភាព ដោយបានផ្ដល់អំណាចដល់ប្រជាពលរដ្ឋឱ្យមានការចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋាននិងលើកកម្ពស់សុខមាលភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ចាប់ផ្ដើមពីឆ្នាំ២០០០ គោលនយបាយនេះបានបន្តផ្ដល់សេវាដែលមានលក្ខណៈឆ្លើយតបនិងគណនេយ្យភាពតាមរយៈការពង្រឹងស្ថាប័នប្រជាធិបតេយ្យមូលដ្ឋាន ដែលជំរុញដល់ការសម្រេចបានអាទិភាពនានានៅមូលដ្ឋាន។ គោលនយោបាយនេះ បានជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញតួនាទីរបស់ខ្លួនកាន់តែមានប្រសិទ្ធភាពនិងជំរុញមន្ត្រីរាជការនិងតំណាងរាស្ត្របំពេញតួនាទីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនិងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព។ ក្នុងដំណើរការអនុវត្តគោលនយោបាយនេះ ក្រសួងស្ថាប័នថ្នាក់ជាតិបានផ្ទេរអំណាចបន្តិចម្ដងៗដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ សេវានានាដែលផ្ដល់ដោយថ្នាក់រាជធានី ខេត្តត្រូវបានផ្ទេរទៅក្រុង ស្រុក ខណ្ឌ រួមមានការអប់រំកម្រិតបឋមសិក្សា សុខាភិបាល ការគ្រប់គ្រងធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងការផ្សព្វផ្សាយកសិកម្ម។ បច្ចុប្បន្ន អភិបាលកិច្ចថ្នាក់ឃុំសង្កាត់បានផ្សារភ្ជាប់ប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់លើ។ ផែនការយុទ្ធសាស្ត្រនិងការវិនិយោគបានដំណើរការដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់រាជធានីខេត្ត។

៣.៤- សមត្ថភាពនិងការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានលើកកម្ពស់ក្នុងការដឹកនាំនិងគាំទ្រដល់តួនាទីផ្ដល់សេវាថ្មីៗ។ រាជរដ្ឋាភិបាលបានរៀបចំរចនាសម្ព័ន្ធអង្គភាពឡើងវិញនិងគោលការណ៍ណែនាំកម្រិតបច្ចេកទេសដើម្បីគាំទ្រដល់ការងារកំណែទម្រង់នេះ។ ឧទាហរណ៍ វគ្គបណ្ដុះបណ្ដាលស្ដីពីអភិបាលកិច្ចមូលដ្ឋាននិងការអភិវឌ្ឍសេដ្ឋកិច្ច គណនេយ្យសង្គម ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយមានអ្នកចូលរួមចំនួន ៦៤ ០០០នាក់ តាមរយៈសាលាជាតិរដ្ឋបាលថ្នាក់ក្រោមជាតិ(ធនាគារពិភពលោក ឆ្នាំ២០១៨)។ បច្ចុប្បន្ន ឃុំ សង្កាត់ដំណើរការការងារដោយអភិបាលកិច្ចឯករាជ្យ ដោយកំណត់តម្រូវការមូលដ្ឋានតាមរយៈមេភូមិឬក្រុមប្រឹក្សាឃុំសង្កាត់។ លើសពីនេះទៀត សេវារដ្ឋបាលជាច្រើនត្រូវបានផ្ទេរទៅថ្នាក់ក្រុង ស្រុក ខណ្ឌ តាមរយៈការិយាល័យច្រកចេញចូលតែមួយ ដែលបានជួយកាត់បន្ថយថ្លៃចំណាយនិងពេលវេលា។

៣.៥- បញ្ហាប្រឈមសំខាន់ គឺការពង្រឹងសន្តិភាព ស្ថិរភាព សុវត្ថិភាព បូរណភាពទឹកដី និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។

៣.៦- ដើម្បីធានានូវគុណភាពនៃការផ្តល់សេវាសាធារណៈ ក្រសួងមុខងារសាធារណៈបានដាក់ចេញនូវប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងបានរៀបចំច្បាប់ស្តីពីសេវាសាធារណៈ ដោយមានអនុក្រឹត្យស្តីពី ១)ការវាយតម្លៃនិងការទទួលស្គាល់ការផ្តល់សេវាសាធារណៈល្អ ការទទួលស្គាល់សាលារៀនមធ្យមសិក្សាចំនួន១០ និងមន្ទីរពេទ្យបង្អែកចំនួន៣០។ គោលការណ៍ណែនាំរបស់អាស៊ានស្តីពីប្រព័ន្ធផ្តល់សេវាសាធារណៈត្រូវបានអនុម័ត។ ក្រសួងបានអភិវឌ្ឍនិងលើកកម្រិតប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ដោយធ្វើសមាហរណកម្មថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ វគ្គបណ្តុះបណ្តាលជំនាញនិងចំណេះដឹង ត្រូវបានរៀបចំដោយមានមន្ត្រីជាន់ខ្ពស់ថ្នាក់អគ្គនាយកនិងអគ្គាធិការចំនួន៧៧៣នាក់ចូលរួម។ មន្ត្រីរាជការដែលចូលរួមវគ្គបណ្តុះបណ្តាលមានចំនួន១៧ ៧៧៨នាក់។ ក្រសួងក៏បានរៀបចំឯកសារជាតិសម្រាប់កម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈនិងក្របខ័ណ្ឌនិងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់អនុវត្តកំណែទម្រង់នេះ។ ២)ការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីលេខ១ ឆ្នាំ២០១៩ ៣)ការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ ៤)ការវាយតម្លៃនិងទទួលស្គាល់អ្នកដឹកនាំគំរូក្នុងរដ្ឋបាលសាធារណៈ ៥)ច្បាប់ស្តីពីសេវាសាធារណៈ ៦)អនុក្រឹត្យស្តីពីការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ៧)ឯកសារណែនាំអាស៊ានស្តីពីការផ្តល់សេវាសាធារណៈ ប្រព័ន្ធនិងការអនុវត្តក្នុងប្រទេសជាសមាជិកអាស៊ាននិងការផ្តល់សេវាសាធារណៈក្រោមហិរញ្ញប្បទានរបស់មូលនិធិអាស៊ានបូកបី ៨)កម្រងព័ត៌មានស្តីពីសេវាសាធារណៈក្នុងកម្មវិធីទូរសព្ទនិងគេហទំព័រ ដូចខាងក្រោម៖

- បានដាក់ឱ្យអនុវត្តអនុក្រឹត្យ ១)ការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដើម្បីជំរុញចលនាប្រឡងប្រណាំង ការកែលម្អការផ្តល់សេវាអប់រំនិងសុខាភិបាលសាធារណៈនៅថ្នាក់មូលដ្ឋាន
- បានគាំទ្រទាំងបច្ចេកទេសនិងឯកសារផ្នែកសេវាសាធារណៈជាមួយ ១)ក្រសួងបរិស្ថាន ២)ក្រសួងសាធារណការ និងដឹកជញ្ជូន ៣)សាលារាជធានីភ្នំពេញ ៤)អង្គការUNICEF ប្រចាំកម្ពុជា ៥)ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង ៦)កម្មវិធីអភិវឌ្ឍសហប្រជាជាតិ
- បានសហការលើការបណ្តុះបណ្តាលនវានុវត្តន៍សម្រាប់អ្នកគ្រងគ្រងក្នុងវិស័យសាធារណៈ វិស័យអប់រំ វិស័យសុខាភិបាល ផ្នែកសេវាសាធារណៈ និងទស្សនកិច្ចសិក្សាជាមួយ ១) កម្មវិធីអភិវឌ្ឍសហប្រជាជាតិប្រចាំកម្ពុជា ២) សាលាភូមិន្ទរដ្ឋបាល ៣) ក្រសួងអប់រំ យុវជន និងកីឡា ៤) ក្រសួងសុខាភិបាល ៥) គណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរពេទ្យ និងនាយកវិទ្យាល័យចំនួន៩៥០នាក់(ស្ត្រីចំនួន១៩៧នាក់)។

## តារាង៣.១ : ការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពមន្ត្រី ឆ្នាំ២០១៩-២០២១

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | | ២០២០ | | ៦ខែ ដើមឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ក. វគ្គបណ្តុះបណ្តាលដំបូង | | នាក់ | ៨៦៦ | ៣២២ | ៣៩៦ | ១៦៦ | ៥០៣ | ១៧៨ |
| ១ | សិស្សមន្ត្រីជាន់ខ្ពស់ | នាក់ | ៦០ | ១៥ | ០ | ០ | ៩១ | ២៨ |
| ២ | សិស្សមន្ត្រីក្រមការ | នាក់ | ១១៩ | ៣២ | ០ | ០ | ១២១ | ៤៣ |
| ៣ | សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មី | នាក់ | ៦៨៧ | ២៧៥ | ៣៩៦ | ១៦៦ | ២០៥ | ៧១ |
| ៤ | មន្ត្រីក្រមការ រដ្ឋបាលក្របខ័ណ្ឌថ្មី | នាក់ | ០ | ០ | ០ | ០ | ៨៦ | ៣៦ |
| ខ. វគ្គបណ្តុះបណ្តាលបន្ត | | នាក់ | ០ | ០ | ៣៥២ | ៥៥ | ៨៦៨ | ២២២ |
| ១ | វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ | នាក់ | ០ | ០ | ១០៦ | ១២ | ១៥៥ | ៣៨ |
| ២ | វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល | នាក់ | ០ | ០ | ១៦៤ | ២៦ | ៥៣៥ | ១៣៤ |
| ៣ | វគ្គវិក្រឹត្យការមន្ត្រីមធ្យម | នាក់ | ០ | ០ | ៣៩ | ១១ | ៩០ | ២៦ |
| ៤ | វគ្គវិក្រឹត្យការមន្ត្រីក្រមការ | នាក់ | ០ | ០ | ៤៣ | ៦ | ៨៨ | ២៤ |
| គ. វគ្គបណ្តុះបណ្តាលខ្លី | | នាក់ | ១ ៤៧៩ | ៤៣៣ | ៨០ | ១៩ | ១៥១ | ២២ |
| ឃ. កម្មវិធីសិក្ខាសាលានិងកម្មវិធីផ្សេងៗទៀត | | នាក់ | ៣ ២៩៤ | ៩៤៣ | ២ ៨៤២ | ៨៤៤ | ៦ ៩៤៧ | ២ ០៤៥ |

## តារាង៣.២ : បៀវត្សអប្បបរមាសម្រាប់មន្ត្រីនៅថ្នាក់ក្រោមជាតិ (គិតជាប្រាក់រៀល)

| បរិយាយ | ឯកតា | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|
| | | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា |
| មន្ត្រីជាប់កិច្ចសន្យា | រៀល | ៦០០ ០០០ | | ៦៥០ ០០០ | | ៦៧០ ០០០ | | ៦៧០ ០០០ | |
| ក្រុមប្រឹក្សារាជធានី ខេត្ត | រៀល | ១ ០៨៥ ០០០ | ១ ៣៦០ ០០០ | ១ ១៣៥ ០០០ | ១ ៤៤០ ០០០ | ១ ៣៥០ ០០០ | ១ ៤៤០ ០០០ | ១ ៣៥០ ០០០ | ១ ៤៤០ ០០០ |
| ក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ | រៀល | ៨៦០ ០០០ | ១ ០៧៥ ០០០ | ៩១០ ០០០ | ១ ១៥៥ ០០០ | ៩១០ ០០០ | ១ ១៥៥ ០០០ | ៩១០ ០០០ | ១ ១៥៥ ០០០ |
| ក្រុមប្រឹក្សា ឃុំ សង្កាត់ | រៀល | ៧០០ ០០០ | ១ ០៣០ ០០០ | ៧៤០ ០០០ | ១ ១១០ ០០០ | ៨៧០ ០០០ | ១ ១១០ ០០០ | ៨៧០ ០០០ | ១ ១១០ ០០០ |
| មន្ត្រីភូមិ | រៀល | ១៨០ ០០០ | ២៥០ ០០០ | ២៥០ ០០០ | ៤០០ ០០០ | ២៨០ ០០០ | ៤៣០ ០០០ | ២៨០ ០០០ | ៤៣០ ០០០ |

ប្រភព : ក្រសួងមុខងារសាធារណៈ

៣.៧- បច្ចុប្បន្ន រាជរដ្ឋាភិបាលបានកែសម្រួលក្នុងការបើកបៀវត្សជូនមន្ត្រីរាជការដោយផ្ទេរផ្ទាល់ចូលគណនីរបស់មន្ត្រីរាជការពីរដងក្នុង១ខែ និងដំឡើងបៀវត្សជូនមន្ត្រីរាជការពីមួយឆ្នាំទៅមួយឆ្នាំ។

## តារាង៣.៣ : បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកម្លាំងប្រដាប់អាវុធ
(គិតជាពាន់រៀល)

| បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|---|
| | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា | អប្បបរមា | អតិបរមា |
| វិស័យរដ្ឋបាល | ១ ០១៤,៥ | ៣ ០០១,៥ | ១ ១០០,១ | ៣ ១១៧,០ | ១ ១៧២,៥ | ២ ៤៧៥,០ | ១ ១៧២,៥ | ២ ៤៧៥,០ |
| វិស័យអប់រំ | ១ ១១៤,៥ | ៣ ០០១,៥ | ១ ២០០,១ | ៣ ១១៧,០ | ១ ២៧២,៥ | ៣ ២០៥,០ | ១ ២៧២,៥ | ៣ ២០៥,០ |
| វិស័យសុខាភិបាល | ១ ១១៤, ៥ | ២ ១៣១,៥ | ១ ២០០,១ | ២ ២៩៧,០ | ១ ២៧២,៥ | ២ ៤០៥,០ | ១ ២៧២,៥ | ២ ៤០៥,០ |
| នគរបាលជាតិ | ១ ០៩៨,៩ | ៣ ១៨៥,៩ | ១ ១៨៤,៦ | ៣ ៣០១,៥ | ១ ២៥៦,៩ | ៣ ២០៥,០ | ១ ២៥៦,៩ | ៣ ២០៥,០ |
| យោធិន | ១ ០៣៥,០ | ៣ ១៨៥,៩ | ១ ១៤៣,៤ | ៣ ៣០១,៥ | ១ ១៨១,៩ | ៣ ២០៥,០ | ១ ១៨១,៩ | ៣ ២០៥,០ |

ប្រភព : ក្រសួងមុខងារសាធារណៈ

៣.៨- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងមុខងារសាធារណៈបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តមិនទាន់បានអនុវត្តឱ្យទូលំទូលាយ
- ការផ្ដល់សេវាសាធារណៈនិងនីតិវិធីមួយចំនួននៅមានភាពស្មុគស្មាញនិងមានកម្រិត
- ខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុលើការរៀបចំប្រព័ន្ធព័ត៌មានវិទ្យាដើម្បីគ្រប់គ្រងទិន្នន័យរួមមន្ត្រីរាជការ ព្រោះប្រព័ន្ធនេះទាមទារនូវការវិនិយោគទាំងលើផ្នែករឹងនិងផ្នែកទន់
- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការស៊ីវិល នៅមិនទាន់បានពេញលេញ
- មានការលំបាកក្នុងការធ្វើការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសារ ព្រមទាំងការរៀបចំបៀវត្សជូនមន្ត្រីរាជការស៊ីវិល ដោយសារការផ្ដល់ឯកសារពាក់ព័ន្ធពីក្រសួង ស្ថាប័នមិនគ្រប់គ្រាន់ឬយឺតយ៉ាវ
- ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ធ្វើឱ្យនីតិវិធីនៃការកសាងផែនការនិងការជ្រើសរើសក្របខ័ណ្ឌប្រចាំឆ្នាំមានភាពយឺតយ៉ាវ រីឯគម្រោងផែនការសកម្មភាពនានាដែលមានលក្ខណៈប្រមូលផ្ដុំមនុស្សត្រូវបានផ្អាក។

៣.៩- ក្រសួងការពារជាតិសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បាននិងកំពុងបំពេញសកម្មភាពក្នុងកិច្ចការពារព្រំដែន ដោយផ្អែកលើមូលដ្ឋានឆ្នាំអន្តរជាតិ
- បាននិងកំពុងអនុវត្តចក្ខុវិស័យរបស់ខ្លួនដោយប្រែក្លាយតំបន់ប្រយុទ្ធមកជាតំបន់អភិវឌ្ឍ
- បានទទួលសិទ្ធិក្នុងការធ្វើធុរកិច្ចដើម្បីស្វែងរកប្រភពចំណូល
- បាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់និងការពារការរីករាលដាលនៃជំងឺកូវីដ-១៩ ការចូលរួមយុទ្ធនាការចាក់វ៉ាក់សាំងជូនកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និង ប្រជាពលរដ្ឋទូទាំងប្រទេស ការរៀបចំតំបន់ចត្តាឡីស័កនិងទីកន្លែងព្យាបាលអ្នកមានផ្ទុកជំងឺកូវីដ-១៩ ការរៀបចំតំបន់បិទខ្ទប់ ការដឹកជញ្ជូនពលករចំណាកស្រុកទៅតំបន់ធ្វើចត្តាឡីស័កឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ដែលនៅជិតបំផុត
- បានកសាងមជ្ឈមណ្ឌលស្ដារនីតិសម្បទាយោធិនពិការនិងលំនៅឋានគ្រួសារកងទ័ពនិងនិវត្តជន
- បានបង្កើតវិទ្យាស្ថានជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពនិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម និង
- បានបង្កើតសមាគមអតីតយុទ្ធជនកម្ពុជាផងដែរ ដើម្បីបម្រើសេវាកម្មសុខុមាលភាពក្នុងសហគមន៍កងទ័ព។

៣.១០- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងការពារជាតិបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- កត្តាឆ្លងរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ សង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិន និងការរឹតត្បិតការនាំចូលទំនិញរបស់សហគមន៍អឺរ៉ុបបានធ្វើឱ្យការស្វែងរកប្រភពទុនវិនិយោគលើធនធានរូបវន្តកងទ័ពជួបការលំបាក
- ពុំទាន់មានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងវិស័យអភិវឌ្ឍសមស្រប ដើម្បីពង្រឹងសមត្ថភាពកងទ័ពលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិជ្ជាជីវៈជារបស់កងទ័ពនៅឡើយ

- ការគ្រប់គ្រងនិងប្រើប្រាស់ធនធានរូបវន្តរបស់កងទ័ព នៅពុំទាន់ប្រើប្រាស់ឱ្យអស់សក្តានុពលប្រកបដោយប្រសិទ្ធភាព ដើម្បីទាញប្រយោជន៍ឱ្យបានជាអតិបរមាសម្រាប់បង្កើនកម្រិតជីវភាពរស់នៅនិងការអភិវឌ្ឍរបស់អង្គភាព។

## ១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

៣.១១- សមិទ្ធផលការងារប្រឆាំងអំពើពុករលួយដែលរដ្ឋាភិបាលកម្ពុជា សម្រេចបានពីឆ្នាំ២០១៩-២០២១ដូចខាងក្រោម៖

ការងារប្រឆាំងអំពើពុករលួយដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានតាមរយៈការរួមគ្នាប្រយុទ្ធប្រឆាំងអំពើពុករលួយស្របទៅតាមអភិក្រមទាំង៥ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ និងវិធានការស្នូលទាំង៣ រួមមាន(១)ការពង្រឹងការអប់រំមិនឱ្យប្រព្រឹត្តអំពើពុករលួយ (២)ការបង្ការទប់ស្កាត់កុំឱ្យអាចប្រព្រឹត្តអំពើពុករលួយ និង(៣)ការបង្ក្រាបបទល្មើសពុករលួយទៅតុលាការកុំឱ្យហ៊ានប្រព្រឹត្តអំពើពុករលួយ គឺបានជំរុញឱ្យសង្គមកម្ពុជាមានការវិវឌ្ឍមួយជំហានយ៉ាងសំខាន់បន្ថែមទៀតក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

**១- ការពង្រឹងការអប់រំ**

ចាប់តាំងពី**សម្តេចតេជោនាយករដ្ឋមន្ត្រី**បានដាក់ចេញនូវអភិក្រមទាំង៥ : ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ក្រសួងស្ថាប័ននីមួយៗហាក់បីដូចជាងាយយល់ ងាយធ្វើ ងាយដាក់ចេញនូវការអប់រំដល់មន្ត្រីរបស់ខ្លួនឱ្យកែលម្អនូវចំណុចខ្វះខាតនិងបង្កើនស្មារតីក្នុងការអនុវត្តការងារប្រកបដោយតម្លាភាព សុចរិតភាព នៅតាមក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក នៅតាមស្ថាប័នសិក្សាទាំង៣កម្រិត(បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា) ក្រសួងអប់រំ យុវជន និងកីឡា នៅតែបានពង្រឹងការបណ្តុះនូវគំនិតប្រយុទ្ធប្រឆាំងអំពើពុករលួយ ស្អាតស្អំ តាមរយៈការបង្រៀនមុខវិជ្ជាប្រយុទ្ធប្រឆាំងអំពើពុករលួយផង និងមុខវិជ្ជាមួយចំនួនផ្សេងទៀតផង។

ស្ថាប័នរដ្ឋនិងរដ្ឋបាលថ្នាក់ក្រោមជាតិ បានលើកកម្ពស់ឆន្ទៈបង្ហាញសាធារណជននូវការប្តេជ្ញាចិត្តក្នុងការប្រឆាំងអំពើពុករលួយតាមរយៈការថ្លែងនូវសុន្ទរកថា ឧទ្ទេសនាម ការឃោសនាការបំភ្លឺបាតុភាព ការកែលម្អបាតុភាពខុសឆ្គងជូនសាធារណជនបានគ្រប់គ្នា ការលើកបដាប្រឆាំងអំពើពុករលួយ ការបិទផ្សាយពីតម្លៃសេវា បានធ្វើឱ្យថ្នាក់ក្រោម និងមហាជនឃើញច្បាស់នូវឆន្ទៈរបស់គ្រប់ក្រសួងស្ថាប័នក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ស្ថាប័នសារព័ត៌មាន ទាំងបុរាណទាំងសម័យ តែងតែរួមចំណែកយ៉ាងសកម្មក្នុងការអប់រំ ផ្សព្វផ្សាយចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ។ យើងសង្កេតឃើញថា ប្រជាជនមានការភ្ញាក់រលឹកចូលរួមការប្រយុទ្ធប្រឆាំងអំពើពុករលួយច្រើនជាងមុនពីមួយឆ្នាំទៅមួយឆ្នាំ ដូចជាការបញ្ចេញមតិ ការប្តឹងបរិហារ ជាដើម។

**២- ការបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ**

ការបង្ការនិងការទប់ស្កាត់អំពើពុករលួយអមដោយអភិក្រមទាំង៥ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ បានធ្វើឱ្យស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិនិងមូលដ្ឋានបញ្ចេញសកម្ម

ភាពកាន់តែច្រើនក្នុងការបង្ការទុកជាមុននិងការបង្ការទប់ស្កាត់កុំឱ្យអំពើពុករលួយកើតឡើងបាន។ គ្រប់អង្គភាពនិងគ្រប់ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិនិងមូលដ្ឋានបានរួមគ្នាយ៉ាងស្អិតរមួតក្នុងការប្រកាសទ្រព្យសម្បត្តិនិងបំណុល ហើយតែងតែទទួលជោគជ័យ១០០% ជារៀងរាល់ឆ្នាំ ទោះបីជួបប្រទះស្ថានភាពធ្ងន់ធ្ងរនៃការរីករាលដាលជំងឺកូវីដ-១៩ក៏ដោយ។ ការប្រកាសទ្រព្យសម្បត្តិនិងបំណុលជាអំពើនៃការឆ្លុះកញ្ចក់មួយ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្ការនិងទប់ស្កាត់អំពើពុករលួយ និងកំពុងរួមចំណែកចូលរួមកសាងផ្នត់គំនិតថ្មីរបស់មន្ត្រីក្នុងជំនាញ ការងារនិងការរស់នៅ។

ការប្រឡងចូលក្របខ័ណ្ឌ ការប្រឡងផ្សេងៗទៀតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្ហាញនូវតម្លាភាព ភាពយុត្តិធម៌ ដែលនាំឱ្យសង្គមកាន់តែមានការជឿជាក់ច្រើនឡើងៗ បន្ថយបាននូវការរិះគន់យ៉ាងច្រើនជាទីបំផុត ឬការប្រឡងផ្នែកខ្លះ ការរិះគន់ស្ទើរតែលែងមានតែម្តង។

ឆ្នាំនេះ អង្គភាពប្រឆាំងអំពើពុករលួយបានចូលរួមសង្កេតលើការងារលទ្ធកម្មចំនួន២ ៨៨៨ គម្រោង របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន២៤០ក្រសួង ស្ថាប័ន ឃើញថាដំណើរបានល្អស្របទៅតាមគោលការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការអូសទាញវិស័យឯកជនដើម្បីឱ្យចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ យើងបានធ្វើចំនួន៧ដង។ អង្គភាពប្រឆាំងអំពើពុករលួយបានទទួលលិខិត ឯកសារចុះអនុស្សរណៈរួមគ្នាប្រឆាំងអំពើពុករលួយបានចំនួន៧អង្គភាពទៀត។ ការគាំទ្ររបស់វិស័យឯកជនក្នុងការប្រឆាំងអំពើពុករលួយ ក៏ទទួលបានការគាំទ្រគួរជាទីកត់សម្គាល់។

### ៣- ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ

ទោះបីការងារអប់រំនិងការងារបង្ការ ទប់ស្កាត់គ្របដណ្តប់ច្រើនលើសលប់នៃការងារប្រឆាំងអំពើពុករលួយរបស់អង្គភាពប្រឆាំងអំពើពុករលួយក៏ដោយ ក៏អង្គភាពប្រឆាំងអំពើពុករលួយនៅតែយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ បញ្ជូនករណីជាច្រើនទៅតុលាការផងដែរ។

ចាប់ផ្តើមពីប្រភពពាក្យបណ្តឹងទាំងអនាមិកនិងចេញឈ្មោះ រួមមានប្រភពព័ត៌មានចំហដែលមានចុះផ្សាយក្នុងសារព័ត៌មាននិងបណ្តាញសង្គម ពីប្រភពបណ្តឹងរបស់ក្រសួងស្ថាប័ននានានិងពីតុលាការ ករណីដែលតុលាការប្រគល់ឱ្យ និងចុងក្រោយពីប្រភពព័ត៌មានសម្ងាត់ក្នុងនិងក្រៅប្រទេស។

អង្គភាពប្រឆាំងអំពើពុករលួយ បានផ្អែកលើវិធានប្រតិបត្តិការដោយស្តង់ដា(SOP) របស់ខ្លួនដំណើរការស្រាវជ្រាវនិងស៊ើបអង្កេត។ រយៈពេលពីខែមករា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២១ ពាក្យបណ្តឹងសរុបចំនួន១ ៤៥៧ពាក្យបណ្តឹង ក្នុងនោះ អង្គភាពប្រឆាំងអំពើពុករលួយបានដោះស្រាយបញ្ចប់ជាមួយម្ចាស់បណ្តឹងចំនួន៧២៦ពាក្យបណ្តឹង បានដាក់វិន័យចំនួន៣៩ករណី បញ្ជូនទៅតុលាការចំនួន១២ពាក្យបណ្តឹង និងពាក្យបណ្តឹងកំពុងបន្តនីតិវិធីចំនួន៧១៩ពាក្យបណ្តឹងទៀត។ ដោយឡែកឆមាសទី១នៃឆ្នាំ២០២១ យើងបានទទួលពាក្យបណ្តឹងចំនួនតែ១៧១ករណី តិចជាងឆ្នាំមុនចំនួន

១៥៧ពាក្យប្ដឹង ដោយសារកត្តានៃការឆ្លងរីករាលដាលធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ហើយក៏បានបញ្ចប់នីតិវិធីជាមួយម្ចាស់បណ្ដឹងចំនួន១១៩ពាក្យប្ដឹង និងកំពុងបន្តនីតិវិធីចំនួន៥២ពាក្យប្ដឹង។

៣.១២- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ អង្គភាពប្រឆាំងអំពើពុករលួយក៏នៅមានការងារសេសសល់មួយចំនួនដូចខាងក្រោម៖

- ពិតមែនតែសម្រេចបានកិច្ចការងារជាច្រើនក្ដី ក៏ប៉ុន្តែអង្គភាពប្រឆាំងអំពើពុករលួយនៅមិនទាន់បានធ្វើអស់លទ្ធភាពកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋាននានា
- ការបូកសរុបនៃការងារអប់រំ បង្ការ និងទប់ស្កាត់ក៏ដូចជាការអនុវត្តនូវអភិក្រមទាំង៥ ឆ្លុះ កញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មូលដ្ឋាននានា អ.ប.ព.មិនទាន់បង្កើតយន្តការបូកសរុបឱ្យបាននៅឡើយ
- ការស៊ើបអង្កេត ដើម្បីរក្សាបាននូវភាពម៉ត់ចត់ ទាមទារឱ្យមានក្របខ័ណ្ឌច្រើនជាងនេះថែមទៀត និងធនធានហិរញ្ញវត្ថុ ក៏ដូចជាសម្ភារៈនានា។

៣.១៣- ក្រសួងមុខងារសាធារណៈ សម្រេចបានសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

- បានរៀបចំសេចក្ដីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០៣០
- បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈសម្រាប់ឆ្នាំ២០១៩និងឆ្នាំ២០២០ និងសេចក្ដីព្រាងរបាយការណ៍នៃការសិក្សាលើប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ
- បានរៀបចំក្របខ័ណ្ឌនិងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងនោះ មានសេចក្ដីព្រាងក្របខ័ណ្ឌលទ្ធផលនិងទម្រង់របាយការណ៍ស្ដីពីការអនុវត្តសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ និងសេចក្ដីព្រាងឯកសារគោលការណ៍ណែនាំស្ដីពីប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០២៣
- បានរៀបចំឯកសារទស្សនាទានស្ដីពីការរៀបចំកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ ២០១៩-២០៣០
- បានរៀបចំសេចក្ដីព្រាងរបាយការណ៍នៃការសិក្សាលើប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ រួមមានៈ ប្រទេសកម្ពុជា ថៃ វៀតណាម និងហ្វីលីពីន
- បានប្រមូលនិងចងក្រង ១)លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងនៃការកែទម្រង់រដ្ឋបាលសាធារណៈពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០២០ និង២)បានពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈផ្អែកលើយុទ្ធសាស្ត្រចំនួន៥ ដើម្បីកំណត់នូវសូចនាករគន្លឹះសម្រាប់តាមដានត្រួតពិនិត្យពីប្រសិទ្ធភាពនៃការអនុវត្ត
- បានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន២ សរុបអ្នកចូលរួមចំនួន១៤៥នាក់ ១)វិធីសាស្ត្រនៃការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និង២)ការរៀបចំតាក់តែងករណីសិក្សា។

៣.១៤- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងមុខងារសាធារណៈបានជួបប្រទះភាពប្រឈមមួយចំនួនដូចខាងក្រោម៖

- ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តមិនទាន់បានអនុវត្តឱ្យទូលំទូលាយ
- មន្ត្រីរាជការមួយចំនួននៅមានឥរិយាបថមិនល្អ ខ្វះមនសិការវិជ្ជាជីវៈ
- ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ធ្វើឱ្យនីតិវិធីនៃការកសាងផែនការនិងការជ្រើសរើសក្របខ័ណ្ឌប្រចាំឆ្នាំ មានភាពយឺតយ៉ាវ រីឯគម្រោងផែនការសកម្មភាពនានាដែលមានលក្ខណៈប្រមូលផ្តុំមនុស្សត្រូវបានផ្អាក
- មានការលំបាកក្នុងការធ្វើកែប្រែស្ថានភាពរដ្ឋបាលនិងគ្រួសារ ព្រមទាំងការរៀបចំបៀវត្សជូនមន្ត្រីរាជការស៊ីវិល ដោយសារការផ្តល់ឯកសារពាក់ព័ន្ធពីក្រសួងស្ថាប័នមិនគ្រប់គ្រាន់ ឬយឺតយ៉ាវ។

៣.១៥- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានរៀបចំសេចក្តីព្រាងច្បាប់អធិការកិច្ច
- បានចុះរៀបចំវេទិកាស្ទាបស្ទង់មតិការយល់ដឹងច្បាប់ នៅមុននិងក្រោយពេលផ្សព្វផ្សាយរួមមានច្បាប់ភូមិបាល ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅមូលដ្ឋានរាជធានី ខេត្ត ចំនួន១៣លើក ដោយមានអ្នកចូលរួមសរុបចំនួន ២ ១២២នាក់
- បានធ្វើសកម្មភាពផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរាជធានី ខេត្ត ទទួលបានចំណេះដឹងច្បាប់ ធ្វើឱ្យពួកគាត់យល់ដឹងពីសិទ្ធិនិងកាតព្វកិច្ចរស់នៅប្រចាំថ្ងៃជៀសផុតឬកាត់បន្ថយបទល្មើសផ្សេងៗ ដែលរួមមានច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីការបង្ការនិងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ភូមិបាល និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយមានអ្នកចូលរួមសរុបចំនួន៧៤ ៨៧៨នាក់
- បានរៀបចំវេទិកាសាធារណៈនៅមូលដ្ឋានរាជធានី ខេត្ត ដើម្បីទទួលមតិ សំណូមពរនិងកង្វល់របស់ប្រជាពលរដ្ឋ មកពិនិត្យពិចារណាសំណូមពរទាំងនោះនិងធ្វើការដោះស្រាយកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីសម្រួលជីវភាពរស់នៅកាន់តែប្រសើរឡើង។ ជាក់ស្តែងបានរៀបចំវេទិកាសាធារណៈចំនួន១០លើក ក្នុងនោះ មានអ្នកចូលរួមសរុបចំនួន២ ៦៥៦នាក់ និងទទួលសំណូមពរចំនួន២៧៣សំណូមពរ
- បានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានចំនួន១០៧១ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព

- បានចុះតាមដានអនុវត្តច្បាប់បានចំនួន៤៥៥ស្ថាប័ន អង្គភាព
- បានទទួលពាក្យបណ្តឹងសរុបចំនួន៣២៣បណ្តឹង
- បានធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញអធិការកិច្ច បានចំនួន៣៧នាក់។

**តារាង៣.៤ : លទ្ធផលសម្រេចបាន ឆ្នាំ២០១៩-២០២១**

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|
| **ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** | | | | |
| ១- ការងារស្ទង់មតិអំពីច្បាប់ | នាក់ | ១ ៥៣២ | ៥៩០ | ០ |
| ២- ការងារអប់រំផ្សព្វផ្សាយច្បាប់ | នាក់ | ៤៧ ៧២៤ | ២៥ ៣៤១ | ១ ៨១៣ |
| ៣- រៀបចំវេទិកាសាធារណៈមូលដ្ឋាន | នាក់ | ២ ៦៥៦ | | |
| **ការងារអធិការកិច្ច** | | | | |
| ១- ការងារអធិការកិច្ចគ្រប់គ្រងរដ្ឋបាល គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យរដ្ឋ | ស្ថាប័ន អង្គភាព | ៧៧២ | ២៩៩ | ០ |
| ២- ការងារតាមដានការអនុវត្តច្បាប់ | ស្ថាប័ន អង្គភាព | ៤៥៥ | ០ | ០ |
| ៣- ការងារទទួលពាក្យបណ្តឹង | ករណី | ១៣៥ | ១២៩ | ៥៩ |
| **ការងាររដ្ឋបាលកិច្ចការទូទៅ** | | | | |
| ១- បណ្តុះបណ្តាលជំនាញការងារអធិការកិច្ច | នាក់ | ៣៧២ | ០ | ០ |

ប្រភព : ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

៣.១៦- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព-ព្រឹទ្ធសភា និងអធិការកិច្ច បានជួបប្រទះភាពប្រឈមមួយចំនួន ដូចជាសមត្ថភាពមន្ត្រីរាជការមួយចំនួននៅមានកម្រិត ខ្វះមធ្យោបាយធ្វើដំណើរបំពេញការងារបេសកកម្ម តម្រូវការថវិកានៅមានកម្រិត មិនទាន់មានច្បាប់អធិការកិច្ច កិច្ចសហការតាមបណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត និងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។

## ១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

៣.១៧- ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការ ក្រសួងមុខងារសាធារណៈសម្រេចបានសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

- បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលារយៈពេលខ្លីនិងវែងដែលមានអ្នកចូលរួមសរុបចំនួន១៧ ៧៧៨នាក់(ស្ត្រីចំនួន៥ ២៤៩នាក់)
- បានអនុវត្តកំណែទម្រង់អន្តរវិស័យតាមរយៈការកែលម្អកិច្ចសម្របសម្រួលរវាងក្រសួង ស្ថាប័ន ថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍ។ ឧទាហរណ៍ ផែនការសកម្មភាពរួមគ្នាថ្មីនៃកម្មវិធីកំណែទម្រង់៣+១ សម្រាប់ឆ្នាំ២០២០ រួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់គ្រប់គ្រងហិរញ្ញ

វត្ថុសាធារណៈ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ កម្មវិធីកំណែទម្រង់នេះមានលេខាធិការដ្ឋានសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈនៅក្រសួងមុខងារសាធារណៈ

- បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ២០១៩-២០២១ និងធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការ ដោយបានរៀបចំធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ដើម្បីធ្វើសមាហរណកម្មជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានអនុវត្តការធ្វើអធិការកិច្ចលើការគ្រប់គ្រងមន្ត្រីរាជការនៅតាមក្រសួងស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន២៥លើកនិងការធ្វើអធិការកិច្ចនិងដោះស្រាយបញ្ហារបស់មន្ត្រីរាជការចំនួន៧ករណី
- បានអនុវត្តការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការងារអធិការកិច្ច ចំនួន៣៩លើក
- បានរៀបចំសេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីកែលម្អការផ្តល់សេវាសធារណៈ ដូចជាកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រព័ន្ធគ្រប់គ្រងការិយាល័យច្រកចេញចូលតែមួយ បានរៀបចំសូចនាករតាមដាន ចំណាត់ថ្នាក់ និងវគ្គបណ្តុះបណ្តាលនានា
- បានដំឡើងប្រាក់បៀវត្សនិងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា
- បានធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ដោយប្រើប្រាស់ប្រព័ន្ធវាយតម្លៃតាមអនឡាញតាមរយៈបច្ចេកវិទ្យាព័ត៌មាន
- បានរៀបចំផែនការសកម្មភាពរួមថ្មីនៃកម្មវិធីកែទម្រង់៣+១ សម្រាប់ឆ្នាំ២០២០ (កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌) ដែលទទួលបន្ទុកដោយលេខាធិការដ្ឋានគ.ក.វ និងក្រសួងមុខងារសាធារណៈ និងរៀបចំក្រុមជនបង្គោលកម្រិតបច្ចេកទេសសម្រាប់សម្របសម្រួលការអនុវត្តយន្តការកែទម្រង់៣+១
- បានរកឃើញប្រាក់បំណាច់ក្រុមប្រឹក្សាដែលបានបើកលើសចំនួន៦១១ ៥១៣ ១៨៧រៀល។

៣.១៨- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)បានរៀបចំតាក់តែងនិងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយផ្តោតលើកិច្ចការជាអាទិភាពនិងចំណុចដៅមួយចំនួន ដូចខាងក្រោម៖

- បន្តពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់
- បន្តពង្រឹងនិងកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- លើកកម្ពស់ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ
- បន្តជំរុញការផ្ទេរមុខងារក្នុងវិស័យអាទិភាពនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។

**តារាង៣.៥ : សូចនាករនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងលទ្ធផលនៃការអនុវត្តឆ្នាំ២០១៩-២០២១**

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|---|---|---|
| | **ការគ្រប់គ្រងការងារកំណែទម្រង់** | | | | |
| ១ | ចំនួនក្រសួង ស្ថាប័នដែលបានកែសម្រួលរចនាសម្ព័ន្ធស្របជាមួយវិមជ្ឈការ | ក្រសួងស្ថាប័ន | កំពុងដំណើរការ | ២០ | ២០ |
| ២ | ចំនួនថវិការដ្ឋប្រចាំឆ្នាំសម្រាប់គាំទ្រសកម្មភាពកំណែទម្រង់ស្នូល(លានដុល្លារអាម៉េរិក) | លានដុល្លារអាម៉េរិក | ១២,៥ | ៨,៥ | ៦,៥ |
| | **អភិបាលកិច្ចល្អ** | | | | |
| ៣ | ភាគរយក្រុង ស្រុក ខណ្ឌគោលដៅប្រើប្រាស់ប្រព័ន្ធព័ត៌មានក្នុងការគ្រប់គ្រង | % | ៧០ | ៦៤ | ១០០ |
| ៤ | ភាគរយស្ត្រីក្រុង ស្រុក ខណ្ឌកាន់មុខតំណែងគ្រប់គ្រង | % | ១៩ | ១៦,៨៧ | ១៧,៥ |
| | **ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស** | | | | |
| ៥ | ភាគរយរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើសបុគ្គលិកស្របតាមគោលការណ៍ បែបបទនិងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | % | ១០០ | ១០០ | ១០០ |
| ៦ | ភាគរយនាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌវាយតម្លៃដោយគណៈអភិបាលរបស់ខ្លួន | % | ១០០ | ១០០ | ១០០ |
| | **ការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន** | | | | |
| ៧ | ចំនួនសរុបនៃក្រសួងបានបញ្ចប់លិខិតបទដ្ឋានផ្ទេរមុខងារ | ក្រសួង | ២០ | ២០ | ២០ |
| ៨ | ចំនួនសរុបនៃផែនការផ្ទេរមុខងារដែលបានអនុវត្ត | ផែនការ | ២០ | ២០ | ២០ |
| | **វិមជ្ឈការហិរញ្ញវត្ថុ** | | | | |
| ៩ | ភាគរយផ្នែកអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុកធៀបនឹងចំណូលចរន្តនៃថវិកាជាតិ | % | ០,៥០ | ០,៥០ | ១,០ |
| ១០ | ចំនួនក្រុង ស្រុកទទួលបានមូលនិធិមានភ្ជាប់លក្ខខណ្ឌ | ក្រុង ស្រុក | ១៨ | ៤០ | ៤១ |
| ១១ | ភាគរយចំណូលសារពើពន្ធនៃគុណប្រយោជន៍ថវិកាខេត្តចែករំលែកទៅឱ្យក្រុង ស្រុក | % | ៣ | ៤ | ៤ |

៣.១៩- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ គ.ជ.អ.ប.បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំមានភាពច្បាស់លាស់ស្របតាមការគ្រប់គ្រងតាមប្រព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការផ្ទេរមុខងារនិងធនធានពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានភាពយឺតយ៉ាវនិងអនុវត្តមិនបានពេញលេញ
- សាលាជាតិរដ្ឋបាលមូលដ្ឋាន ដែលជាគ្រឹះស្ថានសម្រាប់អភិវឌ្ឍសមត្ថភាពពុំទាន់អាចដំណើរការបានពេញលេញ
- សមត្ថភាពស្ថាប័ននិងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់ឆ្លើយតបបានពេញលេញ
- ខ្វះការគាំទ្របច្ចេកទេសនិងធនធានក្នុងការចុះតាមដាននិងគាំទ្រសម្រុះសម្រួលបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ
- សេវារដ្ឋបាលដែលបានផ្តល់ដោយមន្ទីរ អង្គភាពមួយចំនួនពុំទាន់បានផ្ទេរមកអនុវត្តនៅអង្គភាពច្រកចេញចូលតែមួយនៅឡើយ។

៣.២០- ក្រសួងយុត្តិធម៌ សម្រេចបានសមិទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ការងារនីតិកម្ម**

- បានរៀបចំសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន រួមមានច្បាប់ដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាលើផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត តាមការស្នើសុំរបស់ក្រសួង ស្ថាប័ន
- គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃក្រសួងយុត្តិធម៌ បានពន្យល់និងអនុម័តមេពាក្យដែលដកស្រង់ចេញពីក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ បានចំនួន១៦១មេពាក្យ និងបានរៀបចំសេចក្តីព្រាងការពន្យល់មេពាក្យដែលបានដកស្រង់ចេញពីក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌបានចំនួន២១៣មេពាក្យ។

**ការងារអប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាល**

- បានចូលរួមបណ្តុះបណ្តាលសិស្សចៅក្រមជំនាន់ទី៨ ចំនួន៥៥នាក់(ស្រី១១នាក់) សិស្សចៅក្រមជំនាន់ទី៩ចំនួន៥៦នាក់(ស្រី១៣នាក់) សិស្សចៅក្រមជំនាន់ទី១០ចំនួន៥៥នាក់(ស្រី១០នាក់) សិស្សក្រឡាបញ្ជីជំនាន់ទី៦ចំនួន១០០នាក់(ស្រី៣៧នាក់) សិស្សក្រឡា

បញ្ជីជំនាន់ទី៧ ចំនួន១១៦នាក់(ស្រី៤៧នាក់) មន្ត្រីរាជការប្រឡងផ្ទៃក្នុងជាប់ថៅក្រមនិងព្រះរាជអាជ្ញាជំនាន់ទី១ចំនួន៣២នាក់(ស្រី៥នាក់) និងសិស្សសារការីជំនាន់ទី២ចំនួន២០នាក់(ស្រី៩នាក់)។

## ការងារព្រឹត្តិបត្រថ្កោលទោស ការលើកលែង និងការបន្ធូរបន្ថយទោស

- ប្រជាពលរដ្ឋទូទៅបានមកស្នើសុំព្រឹត្តិបត្រថ្កោលទោសពីក្រសួងយុត្តិធម៌ មានចំនួន១០៣ ១០០ច្បាប់
- តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ **ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានព្រះរាជទានព្រះរាជក្រឹត្យបន្ធូរបន្ថយនិងលើកលែងទោសដល់ទណ្ឌិត សរុប១ ៥៩២នាក់។

## ការងារជំនួយផ្នែកច្បាប់

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទទួលថវិកាប្រចាំឆ្នាំពីរាជរដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់ចំនួន៣ ៨០០លានរៀល ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ សម្រាប់ប្រើប្រាស់នៅក្នុងប្រតិបត្តិការការពារក្ដីនិងពិគ្រោះយោបល់ផ្លូវច្បាប់ជូនជនក្រីក្រទូទាំងប្រទេស។

## ការងារដោះស្រាយការកកស្ទះសំណុំរឿង

- បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះទាំងដំណាក់កាលអយ្យការ ទាំងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ សរុបជាង៣៧ ៩០០រឿង ស្មើនឹង៩៦%នៃសំណុំរឿងព្រហ្មទណ្ឌដែលកកស្ទះសរុបជាង៣៩ ៥០០រឿង(សំណុំរឿងដែលត្រូវបានជំនុំជម្រះរួចមានជាង១២ ៦០០រឿង ស្មើនឹង៩៧%នៃចំនួនសំណុំរឿងសរុបជាង១៣ ០០០រឿងក្នុងដំណាក់កាលជំនុំជម្រះ)។ បន្ថែមពីនេះ សាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស ក៏បានដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មីជាង៦២ ៨០០រឿង ស្មើនឹង៧៨%នៃចំនួនសំណុំរឿងចូលថ្មីសរុបជាង៨០ ៤០០រឿង។

## ការងារអធិការកិច្ច

- បានធ្វើចំណាត់ការលើសំណុំរឿងបានចំនួន៦២សំណុំរឿង ធ្វើអធិការកិច្ចតាមបណ្ដឹងតវ៉ាពីរូបវន្តបុគ្គលឬនីតិបុគ្គល លើថៅក្រម អយ្យការ ក្រឡាបញ្ជី និងអាជ្ញាសាលា បានចំនួន៣៤នាក់ ក្នុងសាលាដំបូងនិងអយ្យការអមសាលាដំបូងចំនួន៨ ចុះធ្វើអធិការកិច្ចជាប្រចាំលើការប្រព្រឹត្តទៅរបស់សាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ចំនួន២៤ខេត្ត(២៤លើក) ការចុះស្រាវជ្រាវប្រមូលព័ត៌មានអំពីស្ថានភាពនៃការអនុវត្តច្បាប់នៅតាមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់បានចំនួន១៧លើក។

## ការងារសន្ទានកម្មនិងយុត្តិធម៌មូលដ្ឋាន

- បានបង្កើតយន្តការផ្តល់ប្រឹក្សាពិគ្រោះយោបល់ផ្នែកច្បាប់និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរ ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាននិងសហគមន៍ តាមរយៈការ

បង្កើតឱ្យមានមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ក្រុង ស្រុក ខណ្ឌ ចំនួន៦៨ទូទាំង១០រាជធានី ខេត្ត ក្នុងនោះរួមមានចំនួន៩ក្រុង ចំនួន៤៥ស្រុក និងចំនួន១៤ខណ្ឌ

- បានផ្ទេរនិងធ្វើសមាហរណកម្មមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ក្រុង ស្រុក និងខណ្ឌទាំង ៦៨នេះ ឱ្យស្ថិតនៅក្រោមរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានឈ្មោះថា ការិយាល័យនីតិកម្មនិងសម្រុះសម្រួលវិវាទមូលដ្ឋាន។

### ការសាងសង់អគារសាលាជម្រះក្ដី

- បានសាងសង់អគារនិងដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ចំនួន៣ទៀត គឺសាលាឧទ្ធរណ៍ត្បូងឃ្មុំ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ព្រះសីហនុ។ ទន្ទឹមនឹងនេះ ក្រសួងយុត្តិធម៌ក៏បានសាងសង់និងដាក់ឱ្យប្រើប្រាស់អគារថ្មីនៃសាលាដំបូងចំនួន៣ រួមមានសាលាដំបូងខេត្តត្បូងឃ្មុំ សាលាដំបូងខេត្តស្ទឹងត្រែង និងសាលាដំបូងខេត្តកំពង់ស្ពឺ ព្រមទាំងបានបង្កើតនិងដាក់ឱ្យដំណើរការសាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្តកែបក្នុងឆ្នាំ២០២១។

៣.២១- ទន្ទឹមនឹងសមិទ្ធផលសម្រេចបានខាងលើ ក្រសួងយុត្តិធម៌ ជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ធនធានមនុស្សនៅមានកម្រិតនិងមានបរិមាណនៅមិនទាន់បានសមស្របទាំងបរិមាណនិងគុណភាពសម្រាប់គាំទ្រកិច្ចដំណើរការការងារក្នុងវិស័យយុត្តិធម៌
- ការយល់ដឹងនិងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌របស់មន្ត្រីរាជការនិងសាធារណជន នៅមានកម្រិត
- មធ្យោបាយបម្រើការងារនៅមានកម្រិត
- បន្ទប់សម្រាប់ចៅក្រម តំណាងអយ្យការ ក្រឡាបញ្ជី និងផ្នែករដ្ឋបាលបំពេញការងារមិនទាន់គ្រប់គ្រាន់តាមតម្រូវការ
- បន្ទប់សម្រាប់សវនាការ បន្ទប់ប្រជុំ ឃ្លាំងផ្ទុកវត្ថុតាង ឃ្លាំងសម្រាប់ទុកដាក់ឯកសារមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង
- ចំនួនចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីរដ្ឋបាលនិងមន្ត្រីជាប់កិច្ចសន្យាមិនទាន់ឆ្លើយតបតាមតម្រូវការ។
- ការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យយឺតយ៉ាវលើការងារមួយចំនួន។

## ១.៤- ពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន

៣.២២- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងនាមជាលេខាធិការដ្ឋានសម្រាប់បម្រើយន្តការវេទិការាជរដ្ឋាភិបាល ផ្នែកឯកជន និងជាស្ថាប័នសម្របសម្រួលធ្វើទំនាក់ទំនងអន្តរក្រុមការងារសម្រាប់ផ្នែករាជ-រដ្ឋាភិបាល បានរៀបចំវេទិការាជរដ្ឋាភិបាល ផ្នែកឯកជនលើកទី១៨ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី**។

ជាលទ្ធផល វេទិកាលើកទី១៨នេះបានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់សំដៅពង្រឹងភាពប្រកួតប្រជែងនិងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។

## ២- បរិស្ថានគ្រឹះបដណ្ដាប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

### ២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

៣.២៣- ក្រសួងមហាផ្ទៃ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ការការពារអធិបតេយ្យជាតិនិងបូរណភាពទឹកដី ព្រមទាំងការទប់ស្កាត់និងប្រឆាំងដាច់ខាតរាល់សកម្មភាពខុសច្បាប់ បង្កអស្ថិរភាពនយោបាយឬចលាចលក្នុងសង្គម ព្រមទាំងបញ្ចៀសបាននូវអំពើភេរវកម្មមិនឱ្យកើតមានឡើងនៅកម្ពុជា ក្នុងខណៈពេលដែលការវាយប្រហារដោយភេរវកម្មអន្តរជាតិកើតឡើង២ ២៦៤លើកក្នុងប្រទេសចំនួន៤៤
- ការទប់ស្កាត់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ដោយការពារបាននូវស្ថិរភាពសន្តិសុខផ្ទៃក្នុង រក្សាបាននូវប្រក្រតីកម្ម ជីវភាពនិងសកម្មភាពសង្គម ដោយបានចាត់វិធានការរដ្ឋបាល
- ការបន្តដោះស្រាយបញ្ហាព្រំដែនគោកនិងទឹកជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ រួមជាមួយនឹងការបន្តរៀបចំនិងជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ ទន្ទឹមនឹងការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍មិនអនុញ្ញាតឱ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង
- ការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ រួមទាំងការប្រយុទ្ធប្រឆាំងភេរវកម្មនិងហិរញ្ញប្បទានភេរវកម្ម ការប្រឆាំងការសម្អាតប្រាក់ ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជួញដូរនិងប្រើប្រាស់គ្រឿងញៀន ការប្រយុទ្ធប្រឆាំងសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទផ្សេងៗទៀត ព្រមជាមួយនឹងការបន្តជំរុញអនុវត្ត**គោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព**
- ការពង្រឹងសុវត្ថិភាពចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ
- ការពង្រឹងការអនុវត្តច្បាប់សញ្ជាតិនិងច្បាប់អន្តោប្រវេសន៍ តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍នៅតាមព្រំដែនគោក អាកាសយានដ្ឋាន និងព្រំដែនទឹក ជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ជូនចេញទៅប្រទេសដើមវិញ។

៣.២៤- ក្រសួងមហាផ្ទៃបានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជាការទម្លាក់ថវិកាមានការយឺតយ៉ាវដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបែងចែកមន្ត្រីចូលរួមក្នុងយុទ្ធនាការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តម្រូវឱ្យពន្យារពេលការអនុវត្តសកម្មភាពមួយចំនួន។

៣.២៥- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្រេចបានសមិទ្ធផលមួយចំនួនដូចខាង

ក្រោម៖

- បានផ្សព្វផ្សាយទិសស្លោក ៣កុំ ១រាយការណ៍ គឺ ១- កុំពាក់ព័ន្ធ ២- កុំអន្តរាគមន៍ ៣- កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀនទៅគ្រប់វេទិកានិងព្រឹត្តិការណ៍ផ្សេងៗក្នុងភូមិសាស្ត្រនៃដែនសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាព និងរាជធានី ខេត្ត
- ក្រសួង ស្ថាប័ន ជាសមាជិក អង្គភាពពាក់ព័ន្ធ អគ្គលេខាធិការដ្ឋានអ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្តបានចូលរួមផ្ដល់បទសម្ភាសពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនតាមប្រព័ន្ធផ្សព្វផ្សាយ ដូចជាវិទ្យុ ទូរទស្សន៍រដ្ឋនិងឯកជន **ជាដើម**
- បាននិងកំពុងជំរុញការចុះធ្វើអធិការកិច្ចនៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាស ដែលប្រើប្រាស់សារធាតុគីមីផ្សំ ដើម្បីពិនិត្យលើសៀវភៅបន្ទុកនិងវាយតម្លៃពីហានិភ័យនានាដែលអាចកើតមានដោយការបង្វែរសារធាតុគីមីផ្សំទៅផលិតគ្រឿងញៀនខុសច្បាប់
- ដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនិងផ្អែកលើសហគមន៍នៅខេត្តព្រះសីហនុ និងជំរុញបញ្ចប់គម្រោងសាងសង់ទាំងស្រុង
- បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយបណ្ដាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ អង្គការUNODC និងគម្រោងសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ ក៏ដូចគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project)។

៣.២៦- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ក្រុមឧក្រិដ្ឋជនអន្តរជាតិនៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់ប្រទេសកម្ពុជា ធ្វើជាទីកន្លែងផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់តាមគ្រប់រូបភាពទាំងផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍
- ការជួញដូរ ការប្រើប្រាស់គ្រឿងញៀននៅតែបន្តកើតមាន ទោះបីសេវាកម្មកម្សាន្តសប្បាយនានាត្រូវបានបិទ**ក្នុង**ដំណាក់កាលនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ គួបផ្សំនឹងកត្តាជាចំណុចខ្វះខាតដែលអាចបណ្ដាលមកពីភាពមិនស្មោះត្រង់នឹងវិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់មួយចំនួន ឬអនុវត្តមិនបានល្អតាមទិសស្លោក ៣កុំ ១រាយការណ៍ ដែលនាំឱ្យជះឥទ្ធិពលអាក្រក់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់
- ការគ្រប់គ្រងទណ្ឌិតដែលជាឧក្រិដ្ឋជនគ្រឿងញៀននៅក្នុងពន្ធនាគារ នៅពុំទាន់បានតឹងរ៉ឹងដែលជាហេតុធ្វើឱ្យពួកឧក្រិដ្ឋជនទាំងនោះមានឱកាសទាក់ទងបណ្ដាញនិងបញ្ជាសកម្មភាពជួញដូរគ្រឿងញៀនចេញមកក្រៅពន្ធនាគារ
- ការបំផ្លាញមូលដ្ឋានហិរញ្ញវត្ថុរបស់ក្រុមឧក្រិដ្ឋជនគ្រឿងញៀននៅមិនទាន់ធ្វើឱ្យដល់ឫសគល់
- លក់ទ្រព្យដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀននៅតែមានភាពយឺតយ៉ាវ មិនឆ្លើយតបទៅនឹងសំណូមពររបស់មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ការជួយគាំទ្រជាថវិកា មធ្យោបាយ និងសម្ភារៈពីបណ្ដាប្រទេសផ្ដល់ជំនួយក៏ដូចជាដៃគូអភិវឌ្ឍនានាលើសកម្មភាពត្រួតពិនិត្យគ្រឿងញៀន បានកាត់បន្ថយមកនៅក្នុងកម្រិតតិចតួចបំផុតដែលទាំងអស់នេះបានជះឥទ្ធិពលមិនល្អនិងធ្វើឱ្យសកម្មភាពត្រួតពិនិត្យគ្រឿងញៀនមានភាពអសកម្មដោយអន្លើទាំងនៅកម្ពុជានិងក្នុងតំបន់ទាំងមូល។

៣.២៧- ក្រសួងធម្មការនិងសាសនាបានដាក់ចេញយុទ្ធសាស្ត្រចំនួន៣ គឺពុទ្ធិកសិក្សា ការផ្សព្វផ្សាយសាសនានិងរក្សាសុខដុមនីយកម្មខាងជំនឿសាសនា និងការផ្ដល់សេវាគាំទ្រទូទៅ។ សាលាពុទ្ធិកសិក្សាត្រូវបានគ្រប់គ្រងបានយ៉ាងល្អ ដោយមានកំណើនសិស្សចូលរៀន។ សាលាពុទ្ធិកសិក្សាមានចំនួន១ ៤៧០ និងមានគ្រូចំនួន៤ ២០៣អង្គ/នាក់។ សិស្សដែលបានបញ្ចប់ការសិក្សាមានចំនួន៨៤%។ សកលវិទ្យាល័យពុទ្ធិកសិក្សាទាំង៣បានបណ្ដុះបណ្ដាល២ ៥៣២អង្គ/នាក់ដែលមានព្រះសង្ឃចំនួន៧០២អង្គបានបញ្ចប់ថ្នាក់ឧត្ដមសិក្សាលើផ្នែកពុទ្ធិកសិក្សា។ នៅកម្ពុជាមានព្រះសង្ឃចំនួន៧៧ ៦១០អង្គ ដោយមានព្រះសង្ឃថ្មីចំនួន៧៥អង្គ។ ក្រសួងបានរៀបចំកម្មវិធីនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គមចំនួន២៤លើក និងកម្មវិធីទស្សនាទានព្រះពុទ្ធសាសនាចំនួន១២លើក និងវគ្គបណ្ដុះបណ្ដាលមួយចំនួនទៀតទាក់ទងនឹងពុទ្ធសាសនា។ ក្រសួងរក្សាបាននូវសុខដុមនីយកម្មរវាងអ្នកកាន់សាសនាផ្សេងៗដែលមាននៅកម្ពុជា។

៣.២៨- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងធម្មការនិងសាសនាបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការអប់រំបណ្ដុះបណ្ដាលសមណសិស្ស និស្សិតនៅតាមសាលាពុទ្ធិកសិក្សា គឺមានការលំបាកដោយសារខ្វះធនធានថវិកា ធនធានមនុស្ស សម្ភារៈបរិក្ខារ សៀវភៅសិក្សា ព្រមទាំងមធ្យោបាយធ្វើដំណើរ
- ខ្វះលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងវត្តអារាម
- ចំណេះដឹងរបស់ព្រះសង្ឃ អាចារ្យ គណៈកម្មការ អ្នកគ្រប់គ្រងវត្តនៅមានកម្រិត។

## ២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

៣.២៩- ក្រសួងពាណិជ្ជកម្ម សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ការចុះបញ្ជីពាណិជ្ជកម្ម (១)បានរៀបចំសេចក្ដីប្រកាសរួមស្ដីពីការប្រើប្រាស់នាមករណ៍សហគ្រាស ក្រុមហ៊ុននៅលើលិខិត ឯកសារ និងស្លាកសញ្ញាសម្រាប់តាំងបង្ហាញឬផ្សព្វផ្សាយជាសាធារណៈ ប្រកាសស្ដីពីការគ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម កិច្ចការពារម៉ាកនិងពាណិជ្ជនាមសម្រាប់អាជ្ញាបណ្ណលើវិស័យព័ត៌មាននិងសោតទស្សន៍ ប្រកាសស្ដីពីការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុននិងប្រកាសស្ដីពីការផ្ដល់អនុញ្ញាតឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២)បានធ្វើកំណែទម្រង់ឱ្យមានភាពងាយស្រួលតាមរយៈផ្លាស់ប្ដូរបញ្ជរចុះបញ្ជីពាណិជ្ជកម្មថ្មី ដំឡើងប្រព័ន្ធទូរសព្ទស្វ័យប្រវត្តិកម្មដែល

អាចទទួលការហៅចូលប្រមាណ២៤ទូរសព្ទក្នុងពេលតែមួយ បង្កើតប្រព័ន្ធចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់រាជរដ្ឋាភិបាល(CamDX) កាត់បន្ថយកម្រៃសេវា ៤0% លើការចុះបញ្ជីក្រុមហ៊ុន សហគ្រាស និងការពិនិត្យនាមករណ៍ (៣)បានស្នើបង្កើតមជ្ឈមណ្ឌលទិន្នន័យថ្មីសម្រាប់ផ្ទុកព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម (៤)បានចូលរួមបំពេញសកម្មភាពក្នុងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង(៥)បានចុះផ្សព្វផ្សាយអំពីនីតិវិធីច្បាប់និងប្រកាសពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មដល់ស្ថាប័នពាក់ព័ន្ធនឹងអាជីវករនៅតាមបណ្តារាជធានី ខេត្ត

- កិច្ចការកម្មសិទ្ធិបញ្ញា (១)បានទទួលពាក្យស្នើសុំនិងចុះបញ្ជីម៉ាក ម៉ាកMadrid ចុះបញ្ជីម៉ាកសាជាថ្មី បញ្ជាក់ពីការប្រើប្រាស់ឬមិនប្រើប្រាស់ម៉ាក កត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក កត់ត្រាអាជ្ញាបណ្ណឬអាជ្ញាបណ្ណពិសេស ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ចុះបញ្ជិការការពារម៉ាកសមូហភាព ទទួលពាក្យស្នើសុំសម្រុះសម្រួលវិវាទ (២)បានរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា រួមមានៈ សេចក្តីព្រាងច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្មនិងព័ត៌មានមិនទម្លាយចេញ សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីរដ្ឋបាលអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា សហការរៀបចំផែនការសកម្មភាពកម្មសិទ្ធិបញ្ញាសម្រាប់ឆ្នាំ២០២១-២០២៣ សេចក្តីព្រាងគោលនយោបាយជាតិកម្មសិទ្ធិបញ្ញាឆ្នាំ២០២១-២០២៦ សហការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើត "គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា" ប្រកាសស្តីពីនីតិវិធីបញ្ជាក់និងកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក កិច្ចសន្យាអាជ្ញាបណ្ណនិងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម បង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់លើការកសាងម៉ាកយីហោនិងគំរូឧស្សាហកម្ម ចុះអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកម្មសិទ្ធិបញ្ញាជាមួយអង្គការកម្មសិទ្ធិបញ្ញានៃសាធារណរដ្ឋកូរ៉េ និងរដ្ឋបាលជាតិឧស្សាហកម្មនិងពាណិជ្ជកម្មចិន ប្រកាសស្តីពីនីតិវិធីដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ប្រកាសស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងគម្រោងថ្នាក់តំបន់លើការលើកកម្ពស់និងទទួលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានិងនីតិវិធីដោះស្រាយវិវាទជាភាសាអង់គ្លេស ចុះកិច្ចសន្យាភាពជាដៃគូអនុវត្តគម្រោងដើម្បីជំរុញនិងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ កម្ពុជា ឡាវ មីយ៉ាន់ម៉ា បញ្ចប់ការបកប្រែបញ្ជីមុខទំនិញនិងសេវា និងសៀវភៅណែនាំស្តីពីការប្រើប្រាស់ពិធីសារទីក្រុងម៉ាឌ្រីដ (៣)បានរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងព្រឹត្តិការណ៍ផ្សេងៗ ដើម្បីលើកកម្ពស់វិស័យកម្មសិទ្ធិបញ្ញា
- កិច្ចការនាំចេញ នាំចូល (១)បានចូលរួមចរចារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទ្វេភាគី តំបន់ ពហុភាគី និងកិច្ចប្រជុំនានាដែលពាក់ព័ន្ធនឹងវិធានដើមកំណើតទំនិញ (២)បាន

អនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ សម្រាប់ការចេញអាជ្ញាបណ្ណនាំចេញ នាំចូល និងវិញ្ញាបនបត្រតឹមប័រលើប្រូសេស ក្រោមប្រព័ន្ធបញ្ជរតែមួយជាតិ ភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ(ATIGA e-Form D)ទៅក្នុងបញ្ជរតែមួយជាតិ និងភ្ជាប់ទៅបញ្ជរតែមួយអាស៊ាន អនុវត្តគម្រោងចុះបញ្ជីអ្នកនាំចេញសម្រាប់នាំចេញទៅសហភាពអឺរ៉ុប បន្ថែមCO ទម្រង់ផ្សេងៗទៀត ស្របតាមវិធានប្រភពដើមទំនិញនៃប្រទេសនាំចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម(Form Annex សម្រាប់នាំចេញទៅជប៉ុន និងForm Chile សម្រាប់នាំចេញទៅប្រទេសឈីលី) តភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ ទៅតាមរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស (៣)បានចងក្រងសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិនានាស្តីពីវិធានដើមកំណើតទំនិញ ប្រកាសស្តីពីការកំណត់នីតិវិធីអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន រៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាល សមាគមរោងចក្រកាត់ដេរនិងអង្គការអន្តរជាតិខាងការងារ ស្តីពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

- ការត្រួតពិនិត្យទំនិញ ការពារអ្នកប្រើប្រាស់ និងកិច្ចការប្រកួតប្រជែង (១)ចុះត្រួតពិនិត្យផលិតផលនៅតាមបណ្តាផ្សារ ទីតាំងស្តុក សិប្បកម្មផលិត ស្ថានីយប្រេងឥន្ធនៈ ដោយបង្ក្រាបនិងដកហូតផលិតផលដែលខូចគុណភាព ក្លែងក្លាយ មិនអនុលោមភាពតាមច្បាប់ និងមិនស្របតាមស្តង់ដាតម្រូវ (២)ចុះអប់រំផ្សព្វផ្សាយពីសុវត្ថិភាពម្ហូបអាហារនៅតាមសាលារៀនទីសាធារណៈ ស្រាវជ្រាវនិងផ្សព្វផ្សាយពីអនាម័យ និងភូតគាមអនាម័យរបស់អង្គការពាណិជ្ជកម្មពិភពលោកជូនដល់ស្ថាប័នសាធារណៈនិងវិស័យឯកជន ចុះចែកបិទផ្ទាំងរូបភាពនិងខិត្តបណ្ណផ្សព្វផ្សាយនិងអប់រំ (៣)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងកសាងសមត្ថភាពមន្ត្រី តាមរយៈការកសាងអគាររដ្ឋបាលនិងមន្ទីរពិសោធន៍ខ្នាតតូចនៅតាមបណ្តារាជធានីខេត្ត សាងសង់អគារសម្រាប់ជាមន្ទីរពិសោធន៍ ដាក់ឱ្យដំណើរការរថយន្តពិសោធន៍ចល័តផ្នែកម្ហូបអាហារនិងប្រេងឥន្ធនៈ ពង្រឹងកម្មវិធីធានាគុណភាព និង(៤)រៀបចំនិងចូលរួមកសាងសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារនិងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៣.៣០- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងពាណិជ្ជកម្មជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យខកខានក្នុងការអនុវត្តផែនការសកម្មភាព និងការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំ ការចុះស្រង់ទិន្នន័យ និងការរៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម

- ក្រុមហ៊ុនមួយចំនួនពុំទាន់បានបង់ប្រាក់ពិន័យគ្រប់ចំនួន
- សមត្ថភាពនិងឧបករណ៍វិភាគរបស់មន្ទីរពិសោធន៍ នៅមានកម្រិត
- ការយល់ដឹងអំពីបញ្ហាសុវត្ថិភាពម្ហូបអាហារនិងការចូលរួមពីវិស័យឯកជននិងប្រជាពលរដ្ឋ នៅមានកម្រិត
- កិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត(កិច្ចសម្រួលពាណិជ្ជកម្ម សុវត្ថិភាពម្ហូបអាហារ និងកិច្ចការពារផលប្រយោជន៍អ្នកប្រើប្រាស់ ជាដើម) នាំឱ្យប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិជាធរមានមិនទាន់បានល្អប្រសើរ
- ច្បាប់និងលិខិតបទដ្ឋានសម្រាប់គាំទ្រដល់ដំណើរការអនុវត្តការងារ នៅមិនទាន់មានគ្រប់គ្រាន់ ក្នុងនោះ មានដូចជាយន្តការទទួលបណ្តឹងពីម្ចាស់សិទ្ធិនិងអ្នកប្រើប្រាស់ បទប្បញ្ញត្តិសម្រាប់គ្រប់គ្រងការផ្សព្វផ្សាយពាណិជ្ជកម្ម ការត្រួតពិនិត្យផលិតផលអគ្គិសនីនិងអេឡិចត្រូនិក និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រមូលត្រឡប់វិញនូវទំនិញខូចគុណភាពជាដើម។

៣.៣១- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានបញ្ចប់សេចក្តីព្រាងច្បាប់ថ្មីស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងបានដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាបាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស
- បានជំរុញ ផ្សព្វផ្សាយ និងទាក់ទាញវិនិយោគ តាមរយៈវេទិកានិងសិក្ខាសាលាពាក់ព័ន្ធចំនួន៦១លើក និងជួបពិភាក្សាជាមួយគណៈប្រតិភូវិនិយោគជាតិនិងអន្តរជាតិចំនួន៧១លើក
- បានផ្តល់កិច្ចសម្របសម្រួលថែទាំវិនិយោគនិងរៀបចំវេទិកានិងកិច្ចប្រជុំជាមួយអ្នកវិនិយោគក្នុងនិងក្រៅប្រទេសនានា ក្នុងនោះ មានដូចជាវេទិការាជរដ្ឋាភិបាល ផ្នែកឯកជនលើកទី១៨ កិច្ចប្រជុំនៃគណៈកម្មាធិការចម្រុះកម្ពុជា ជប៉ុនចំនួន៥លើក ពីលើកទី១៧ ដល់លើកទី២១ ក្រោមកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងជប៉ុនស្តីពីសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគ និងដំណើរទស្សនកិច្ចការងារទៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងក្រុងបាវិត ខេត្តស្វាយរៀង ដើម្បីជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសតាមតំបន់ជាយដែន
- បាននិងកំពុងសហការជាមួយចក្រភពអង់គ្លេស ក្នុងការអនុវត្តកម្មវិធីពន្លឿនការគាំទ្រសេដ្ឋកិច្ចក្នុងដំណាក់កាលជំងឺកូវីដ-១៩ ដើម្បីកំណត់វិស័យអាទិភាពសម្រាប់ការទាក់ទាញវិនិយោគ បញ្ហាប្រឈម សក្តានុពល និងយុទ្ធសាស្ត្រទាក់ទាញវិនិយោគចំគោលដៅ
- គម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅឆ្នាំ២០២០ មានការថយចុះធៀបនឹងឆ្នាំ២០១៩ ទាំងចំនួនគម្រោង ទាំងទុនវិនិយោគ។ ជាក់ស្តែងចំនួនគម្រោងវិនិយោគបានថយចុះ ៧៧គម្រោង ស្មើនឹង២៤% ពី៣១៥គម្រោងក្នុងឆ្នាំ២០១៩ មកត្រឹម ២៣៨គម្រោងក្នុងឆ្នាំ២០២០ ខណៈទំហំទុនវិនិយោគថយចុះប្រមាណជាង១ ១៤៧លាន

ដុល្លារអាមេរិក ស្មើនឹង១២% ពីប្រមាណ៩ ៣៩៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ មកត្រឹម៨ ២៥១លានដុល្លារអាមេរិកក្នុងឆ្នាំ២០២០។ យ៉ាងណាក្តី ការថយចុះនៃទុនវិនិយោគនេះស្ថិតនៅក្នុងកម្រិតមួយល្អប្រសើរនៅឡើយ បើធៀបនឹងការព្យាករបស់សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ ដែលថាលំហូរវិនិយោគផ្ទាល់ពីបរទេសថយចុះប្រមាណ៤០%នៅក្នុងពិភពលោក។

## ២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

៣.៣២- ក្នុងការរក្សាឱ្យបាននូវកិត្តិយស សេចក្តីថ្លៃថ្នូរ កិត្យានុភាព និងសិទ្ធិស្វ័យសម្រេចរបស់កម្ពុជាក្នុងនាមជារដ្ឋឯករាជ្យ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនិងស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស ក្នុងរយៈពេលពាក់កណ្តាលអាណត្តិនៃនីតិកាលទី៦ បានតស៊ូមតិយ៉ាងស្វិតស្វាញនៅលើសមរភូមិការទូតនិងសាធារណមតិ តបតទៅនឹងទង្វើជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា សកម្មភាពបំពានលើឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ដូចខាងក្រោម៖

- បានពន្យល់បកស្រាយជាច្រើនលើកក្នុងជំនួបរវាងថ្នាក់ដឹកនាំជាន់ខ្ពស់កម្ពុជា ជាមួយឥស្សរជនបរទេសនិងសហគមន៍ខ្មែរនៅបរទេស និងតាមរយៈសេចក្តីថ្លែងការណ៍នានាអំពីតថភាពនិងវឌ្ឍនភាពនៃស្ថានភាពប្រជាធិបតេយ្យនិងសិទ្ធិមនុស្សនៅកម្ពុជា រួមជាមួយនឹងជំហរដាច់ខាតមិនដោះដូរអធិបតេយ្យជាមួយនឹងជំនួយបរទេស និងការមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីកម្ពុជា។ ជាមួយគ្នានេះ ក្រសួងក៏បានឆ្លើយតបជាបន្តបន្ទាប់ទៅនឹងរបាយការណ៍ឬអត្ថបទស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលខ្វះភាពសត្យានុម័តនិងមិនគ្រប់ជ្រុងជ្រោយរបស់បុគ្គល អង្គការចាត់តាំង ឬប្រទេសមួយក្តាប់តូច ព្រមទាំងបានក្រើនរំលឹកដល់អ្នករាយការណ៍ពិសេសអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាឱ្យជៀសវាងការអនុវត្តស្តង់ដាពីរក្នុងការងារសិទ្ធិមនុស្ស
- បានចងក្រងនិងផ្សព្វផ្សាយឯកសារស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា វគ្គ១និងវគ្គ២ ដើម្បីឱ្យសាធារណជនទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីស្ថានភាពសិទ្ធិមនុស្សពិតប្រាកដនៅកម្ពុជា។ ទន្ទឹមនេះ ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅហ្ស៊ឺណែវបានចងក្រងព័ត៌មានអំពីការបំពានសិទ្ធិមនុស្សរបស់ប្រទេសលោកខាងលិចផងដែរ
- បានធ្វើចលនាបង្កើនសំឡេងវិជ្ជមានអំពីវឌ្ឍនភាពល្អប្រសើរនៃស្ថានភាពសិទ្ធិមនុស្សនិងប្រជាធិបតេយ្យនៅកម្ពុជា ជាពិសេសកាយវិការមនុស្សធម៌ ដោយបានអនុញ្ញាតឱ្យនាវាទេសចរណ៍អន្តរជាតិWesterdamចូលចតនៅកម្ពុជានិងបានផ្តល់ជំនួយមនុស្សធម៌ប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ដល់ប្រទេសឡាវ មីយ៉ាន់ម៉ា ទីម័រខាងកើត និងនេប៉ាល់ កាលពីចុងឆ្នាំ២០២០ និងដើមឆ្នាំ២០២១ ជាដើម
- បានបង្ហាញពីសុឆន្ទៈកម្ពុជាក្នុងការបង្កើនបរិយាកាសសុខដុមនីយកម្មចំពោះកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេសនានា ដោយក្រសួង (១)បានបន្តសុពល

ភាពអនុស្សរណៈនៃការយោគយល់គ្នាដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអ.ស.ប. ប្រចាំកម្ពុជារយៈពេល២ឆ្នាំ(២០២១-២០២២) និងស្វាគមន៍អ្នករាយការណ៍ពិសេស អ.ស.ប.ថ្មីទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (២)បានបញ្ជូនក្រុមបេសកកម្មសុឆន្ទៈទៅជួបពិភាក្សាជាមួយឥស្សរជនសំខាន់ៗនៃគណៈកម្មការអឺរ៉ុបនិងទទួលក្រុមបេសកកម្មស្វែងរកការពិតរបស់សហភាពអឺរ៉ុប ព្រមទាំងបានផ្តល់ចម្លើយតបទៅនឹងរបាយការណ៍ចុងក្រោយរបស់គណៈកម្មការអឺរ៉ុបស្តីពីនីតិវិធីដកប្រព័ន្ធអនុគ្រោះពន្ធEBA ផងដែរ (៣)បានរៀបចំកិច្ចពិគ្រោះយោបល់ចំនួនពីរលើកក្នុងឆ្នាំ២០១៩និងឆ្នាំ២០២០ រវាងរាជរដ្ឋាភិបាលកម្ពុជា និងតំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេសចំនួនជាង២០០អង្គការ និង(៤) បានផ្តល់ភាពស្របច្បាប់ដល់អង្គការមិនមែនរដ្ឋាភិបាលបរទេសឱ្យប្រតិបត្តិការនៅកម្ពុជាដូចបង្ហាញក្នុងតារាងខាងក្រោម៖

**តារាង៣.៦: បញ្ជីអង្គការមិនមែនរដ្ឋាភិបាលបរទេស ឆ្នាំ២០១៩-២០២១**

| អង្គការមិនមែនរដ្ឋាភិបាលបរទេស | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|---|
| ចំនួនអង្គការមិនមែនរដ្ឋាភិបាលបរទេសចុះបញ្ជីថ្មី | ៨៥ | ៤៣ | ៤២ |
| ចំនួនអង្គការមិនមែនរដ្ឋាភិបាលបរទេសបន្តអនុស្សរណៈនៃការយោគយល់ | ៣២៩ | ៣១៤ | ៣២១ |
| សរុប | ៤១៤ | ៣៥៧ | ៣៦៣ |

ប្រភព : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

៣.៣៣- ឈរលើស្មារតីជាអ្នកជិតខាងល្អនិងរួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង ក្រសួងបានសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា និងប្រទេសជិតខាង ក្នុងការដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ជាមួយប្រទេសជាប់ព្រំដែនទាំងអស់ តាមរយៈសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ជាមួយឡាវ ភាគីទាំងពីរសម្រេចបានការខណ្ឌសីមានិងបោះបង្គោលព្រំដែនចំនួន៨៦% ហើយតំបន់ព្រំដែនដែលមិនទាន់ឯកភាពគ្នាមានចំនួន១៤%
- ជាមួយវៀតណាម ភាគីទាំងពីរសម្រេចបានការខណ្ឌសីមានិងបោះបង្គោលព្រំដែនចំនួន ៨៤% ហើយតំបន់ព្រំដែនដែលមិនទាន់ឯកភាពគ្នាមានចំនួន១៦%
- ជាមួយថៃ កម្ពុជាបានធ្វើការវាស់វែងនិងរុករកបង្គោលព្រំដែនបានចំនួន២បន្ថែមទៀត គឺបង្គោលលេខ៧២និងលេខ៧៣ នៅឆ្នាំ២០១៩ ដែលរហូតមកដល់ពេលនេះ បានរកឃើញបង្គោលព្រំដែនសរុបទាំងអស់៧៣ ដែលបោះដោយបារាំងនិងសៀម។

៣.៣៤- ការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ គួបផ្សំនឹងសកម្មភាពជួញដូរមនុស្សខុសច្បាប់ឥតឈប់ឈរនៅជុំវិញពិភពលោក បានធ្វើឱ្យពលរដ្ឋខ្មែរនៅបរទេសប្រឈមយ៉ាងខ្លាំងនឹងការបាត់បង់ការងារ បាត់ប្រាក់ចំណូល ការផុតកំណត់ទិដ្ឋាការស្នាក់នៅឬធ្វើដំណើរ និងបញ្ហាផ្សេងៗទៀត។ល។ ប្រការនេះបានធ្វើឱ្យស្ថានតំណាងកម្ពុជាបង្កើនយកចិត្តទុកដាក់ចំពោះសន្តិសុខ

សុវត្ថិភាព និងសុខុមាលភាពពលរដ្ឋខ្មែរ ដោយសហការជាមួយសមត្ថកិច្ចរដ្ឋម្ចាស់ផ្ទះដើម្បីផ្ដល់សេវានិងជំនួយឧបត្ថម្ភនានា។

**តារាង៣.៧ : បញ្ជីជួយសង្គ្រោះពលរដ្ឋខ្មែររងគ្រោះដោយការជួញដូរខុសច្បាប់ ឆ្នាំ២០១៩-២០២១**

| ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|
| ៣៨ ៤៧៣ នាក់ | ១១ ៩៨១ នាក់ | ២ ៣២២ នាក់ |

ប្រភព : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

៣.៣៥- កម្ពុជាមានទំនាក់ទំនងការទូតជាមួយបណ្ដាប្រទេសសរុបចំនួន១៧៥ប្រទេស ដោយកម្ពុជាបានភ្ជាប់ទំនាក់ទំនងការទូតជាមួយប្រទេសចំនួន២ក្នុងឆ្នាំ២០១៩ គឺ បុរីក្សត្រម៉ូណាកូ កោះបាបាដុស និងប្រទេសអ៊ូហ្គង់ដា នៅដើមឆ្នាំ២០២០។ កម្ពុជាមានស្ថានបេសកកម្មនៅបរទេសចំនួន៦៦ និងស្ថានបេសកកម្មបរទេសដែលមាននិវេសនដ្ឋាននៅកម្ពុជាមានចំនួន៥៥។

**តារាង៣.៨: បញ្ជីស្ថានបេសកកម្មកម្ពុជានិងបរទេស ឆ្នាំ២០១៩-២០២១**

| ស្ថានបេសកកម្មកម្ពុជា និងបរទេស | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|---|
| ស្ថានទូត/ស្ថានបេសកកម្មកម្ពុជានៅបរទេស | ៣១ | ៣១ | ៣១ |
| ស្ថានអគ្គកុងស៊ុល | ១១ | ១២ | ១២ |
| កុងស៊ុលកិត្តិយស | ២១ | ២២ | ២៣ |
| **សរុប** | **៦៣** | **៦៥** | **៦៦** |
| ស្ថានបេសកកម្មបរទេសនៅកម្ពុជា | ៣២ | ៣២ | ៣២ |
| ស្ថានអគ្គកុងស៊ុល | ៣ | ៣ | ៣ |
| ការិយាល័យកុងស៊ុល | ៤ | ៤ | ៤ |
| កុងស៊ុលកិត្តិយស | ១០ | ១២ | ១៦ |
| **សរុប** | **៤៩** | **៥១** | **៥៥** |

ប្រភព : ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

ចាប់ពីឆ្នាំ២០១៩ ដល់ពាក់កណ្ដាលឆ្នាំ២០២១ កិច្ចព្រមព្រៀងចំនួន៤៦ ត្រូវបានចុះហត្ថលេខា សំដៅឆ្លុះបញ្ចាំងពីនយោបាយ សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងវប្បធម៌ជាដើម។ កម្ពុជាបានរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវរដ្ឋនិងផ្លូវការរបស់ថ្នាក់ដឹកនាំប្រទេសផ្សេងៗ រួមមានកូរ៉េខាងត្បូង ចិន ជប៉ុន វៀតណាម នេប៉ាល់ មីយ៉ាន់ម៉ា ស្រីលង្កា ឡាវ ម៉ាឡេស៊ី និងហុងគ្រី ដែលក្នុងឱកាសនោះ កិច្ចព្រមព្រៀងចំនួន៣០ រួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា ចិន ត្រូវបានចុះហត្ថលេខា។ កម្ពុជា ក៏បានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការជាមួយប្រទេសចំនួន៣៥ផងដែរ។

៣.៣៦- នៅក្នុងក្របខ័ណ្ឌពិភពលោក កម្ពុជាបានដើរតួនាទីយ៉ាងសកម្មជាអនុប្រធានមហាសន្និបាត អ.ស.បលើកទី៧៣(ឆ្នាំ២០១៩) សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម(ឆ្នាំ២០១៩) និងសមាជិកស្ថាប័នអន្តរជាតិជាច្រើនទៀត។ ក្នុងក្របខ័ណ្ឌអាស៊ាន កម្ពុជាបានធ្វើការយ៉ាងសកម្មជាមួយសមាជិកនិងដៃគូទាំងអស់ ដើម្បីសម្រេចឱ្យបានគោលដៅអាស៊ានជាសហគមន៍តែមួយដែលផ្អែកលើវិធានច្បាប់និងមជ្ឈភាពអាស៊ាន។ នៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការតំបន់

មេគង្គ កម្ពុជាបានទទួលគម្រោងចំនួន២០(ជាង៧លានដុល្លារអាម៉េរិក) តាមរយៈកិច្ចសហប្រតិបត្តិការមេគង្គ ឡានឆាង។ កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសន្តិភាពពិភពលោក តាមរយៈការបញ្ជូនកងកម្លាំងទៅបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ដែលគិតចាប់ពីឆ្នាំ២០០៦មកដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងចំនួន៧៥២៨នាក់ (ស្ត្រី៤៦៨នាក់) ក្នុងប្រទេសចំនួន៩ ដូចជាស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ សាធារណរដ្ឋអាហ្វ្រិកកណ្តាល លីបង់ ស៊ីប ស៊ីរី ម៉ាលី និងយេម៉ែន។

៣.៣៧- ក្រសួងនិងស្ថានតំណាងកម្ពុជាបាននិងកំពុងជំរុញការទូតសេដ្ឋកិច្ចយ៉ាងសកម្ម សំដៅកៀរគរវិនិយោគិនបរទេស ផ្សព្វផ្សាយអូសទាញភ្ញៀវទេសចរណ៍ ពង្រីកទីផ្សារសម្រាប់នាំចេញ ក៏ដូចជាការធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ជាមួយបណ្តាប្រទេសជាមិត្តនានា ដូចខាងក្រោម៖

- ដាក់ឱ្យអនុវត្តជាផ្លូវការនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣ ដែលជាឯកសារចង្អុលផ្លូវសម្រាប់អនុវត្តសកម្មភាពការងារការទូតសេដ្ឋកិច្ច និងចងក្រងសៀវភៅកេរដំណែលស្នាដៃម្ហូបខ្មែរ The Taste of Angkor សម្រាប់ជាឧបករណ៍ផ្សព្វផ្សាយទំនៀមទម្លាប់ វប្បធម៌ និងអរិយធម៌ខ្មែរលើឆាកអន្តរជាតិ
- ស្រាវជ្រាវនិងធ្វើអន្តរាគមន៍ចំពោះទំនិញបរទេសដែលបានក្លែងបន្លំស្លាកសញ្ញាកម្ពុជា
- សហការរៀបចំទស្សនកិច្ចសិក្សារបស់អង្គទូតនិងពាណិជ្ជករបរទេសមកកាន់កម្ពុជា ដើម្បីស្វែងយល់អំពីកាលានុវត្តភាពសេដ្ឋកិច្ចនិងវិនិយោគនៅកម្ពុជា
- ជួបពិភាក្សាជាមួយអាជ្ញាធររដ្ឋម្ចាស់ផ្ទះ និងតំណាងក្រុមហ៊ុនសហគ្រាសបរទេស ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពិភាក្សាគម្រោងវិនិយោគ និងផ្សព្វផ្សាយពីសក្តានុពលសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍នៅកម្ពុជា
- ជំរុញការទូតវប្បធម៌នៅលើឆាកអន្តរជាតិ ដូចជា (១)ត្រៀមដាក់បញ្ចូល "ល្បាច់គុនខ្មែរ" និង"នំបញ្ចុក" ទៅក្នុងបញ្ជីឆ្នើមនៃបេតិកភណ្ឌអរូបីរបស់UNESCO (២)សម្របសម្រួលទទួលនិងបញ្ជូនរូបចម្លាក់បុរាណខ្មែរចំនួន២៧អង្គ ពីសហរដ្ឋអាម៉េរិកត្រឡប់មកកម្ពុជាវិញ (៣)សម្រេចដាក់បេក្ខភាពកម្ពុជាជាសមាជិកនៃគណកម្មាធិការបេតិកភណ្ឌអរូបីសម្រាប់អាណត្តិឆ្នាំ២០២២-២០២៦។

៣.៣៨- ទោះបីសមិទ្ធផលខាងលើបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍនិងការពារកិត្តិយសនិងសេចក្តីថ្លៃថ្នូរជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិក៏ដោយ ក៏ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានជួបនូវបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅ ធ្វើឱ្យក្រសួងខិតខំយកចិត្តទុកដាក់ចំពោះបញ្ហានយោបាយសកលនិងតំបន់ ទីតាំងភូមិសាស្ត្រ ដើម្បីធានានូវស្ថិរភាព សន្តិសុខសង្គម ទីផ្សារសេរី ដូចជាការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ ពាណិជ្ជកម្ម និងសេដ្ឋកិច្ច ជាដើម

- ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជាពីបរទេស ដោយប្រកាន់យកសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យមកធ្វើជាលេសដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តច្បាប់ និងគោលការណ៍ប្រជាធិបតេយ្យនិងនីតិរដ្ឋយ៉ាងខ្ជាប់ខ្ជួន
- គម្រោងពង្រីកស្ថានតំណាងកម្ពុជាបន្ថែមនៅតាមតំបន់នានាត្រូវបានផ្អាកដោយសារវិបត្តិកូវីដ-១៩។

៣.៣៩- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(គ.ជ.នា/ក.អ.ក.) សម្រេចបានសមិទ្ធផលនិងវឌ្ឍនភាពសំខាន់ៗជាច្រើនដូចខាងក្រោម៖

- បានរៀបចំនិងអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣
- បានបន្តពង្រឹងយន្តការភាពជាដៃគូ តាមរយៈការអនុវត្តសេចក្តីណែនាំស្តីពីឧបករណ៍ និងយន្តការពិគ្រោះយោបល់នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ
- បានបន្តចូលរួមយ៉ាងសកម្មក្នុងវេទិកាសកលស្តីពីសក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍ និងបានបញ្ចូលគោលការណ៍និងសូចនាករសមស្របមួយចំនួនស្តីពីសក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍទៅក្នុងក្របខ័ណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ និងតាមដានជាប្រចាំតាមរយៈរបាយការណ៍ស្តីពីប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូនៅកម្ពុជា
- បាននិងកំពុងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា តាមរយៈការសម្របសម្រួលវឌ្ឍនភាពការអនុវត្តសូចនាករតាមដានរួមគ្នាឆ្នាំ២០១៩-២០២០ និងបញ្ជីសូចនាករតាមដានរួមគ្នាឆ្នាំ២០២១-២០២៣ របស់ក្រុមការងារបច្ចេកទេសចម្រុះ
- បានកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីគាំទ្រការងារអាទិភាពនិងវិធានការគន្លឹះនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ចាប់ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១ ទំហំហិរញ្ញប្បទានប្រមាណ៩១៨,៧លានដុល្លារអាម៉េរិក ត្រូវបានបើកផ្តល់សម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។ ធនធានភាគច្រើនប្រមាណ៦៣៤,២លានដុល្លារអាម៉េរិក បានគាំទ្រវិធានការគន្លឹះបួនជាក់ស្តែង។ ជាមួយគ្នានេះ ធនធានប្រមាណ១៤២,៣លានដុល្លារអាម៉េរិកបានគាំទ្រការសម្របសម្រួលគោលនយោបាយគាំទ្រ ខណៈដែលធនធានត្រឹមតែ៩៨លានដុល្លារអាម៉េរិកបានគាំទ្រការជំរុញការទាក់ទាញវិនិយោគ
- ជាលទ្ធផល ក្នុងការដឹកនាំកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការក្នុងឆ្នាំ២០២០ ហិរញ្ញប្បទានសរុបចំនួន១ ៨៩០លានដុល្លារអាម៉េរិក ត្រូវបានបើកផ្តល់សម្រាប់គាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងរង្វង់១១០% នៃតម្រូវការសរុបត្រឹមតែ១ ៦៩០លានដុល្លារអាម៉េរិក។ ធនធានទាំងនេះ ក៏បានដើរតួនាទីជាកាតាលីករក្នុងការជំរុញកម្ពុជាឱ្យមានវឌ្ឍនភាព

ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ស្របពេលដែលកំពុងរៀបចំចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច។ ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដែលបានគាំទ្រដល់វិស័យសាធារណៈចំនួន៨១% បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០១៩ ហើយបានកើនដល់៨៦% ក្នុងឆ្នាំ២០២០។ ជាមួយគ្នានេះ ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋមានវឌ្ឍនភាពល្អ ដែលស្ថិតក្នុងរង្វង់៩២%ក្នុងឆ្នាំ២០១៩ និង៩១%ក្នុងឆ្នាំ២០២០។

## ២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

៣.៤០- ក្រសួងពាណិជ្ជកម្មសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ពង្រឹងនិងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម (១)ការពារសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១នៃវិសោធនកម្មកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន និងទទួលបានការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (២)បានបញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា ចិន និងរវាងកម្ពុជាកូរ៉េ (៣)បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាចម្រុះនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគនិងពាណិជ្ជកម្មលើកទី៥រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលសហរដ្ឋអាម៉េរិក សម្របសម្រួលកិច្ចប្រជុំរវាងក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាម៉េរិក អាស៊ាន (៤)បានរៀបចំសិក្ខាសាលាស្តីពីមគ្គុទេសក៍នាំចេញទៅកាណាដា និងការសិក្សាពីការនាំចេញផលិតផល សក្តានុពលកម្ពុជាទៅកាន់ទីផ្សារកាណាដា (៥)បានស្វែងរកកិច្ចសហការពាណិជ្ជកម្មជាមួយសភាពាណិជ្ជកម្មអឺរ៉ុប (៦)បានរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី "កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា ស្វីស" (៧)បានផ្តល់ការឯកភាពលើខ្លឹមសារដែលកែសម្រួលដោយភាគីអាស៊ែបៃហ្សង់លើអនុស្សរណៈនៃការយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្មរវាងកម្ពុជា អាស៊ែបៃហ្សង់" (៨)បានប្រជុំនិងចរចា ក្នុងក្របខ័ណ្ឌពាណិជ្ជកម្មទ្វេភាគីនិងពហុភាគីជាច្រើនដងដទៃទៀត
- ពង្រឹងកិច្ចការពិព័រណ៍ (១)បានចូលរួមរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ "យុទ្ធនាការទិញផលិតផលខ្មែរ" នៅក្នុងព្រឹត្តិការណ៍នានា ដូចជាបុណ្យទន្លេជាដើម (២)បានដឹកនាំនិងសម្របសម្រួលពាណិជ្ជករកម្ពុជាទៅចូលរួមពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេសទៅតាមព្រឹត្តិការណ៍នៅតាមប្រទេសនិងពិព័រណ៍ពិភពលោក (៣)បានផ្សព្វផ្សាយរកក្រុមហ៊ុនសហគ្រាស ផលិតករ ពាណិជ្ជករ សេវាករចូលរួមពិព័រណ៍អនឡាញ ក្នុងព្រឹត្តិការណ៍តាមប្រទេសផ្សេងៗ(ថៃ ម៉ាឡេស៊ី ឥណ្ឌា កូរ៉េ ចិន ភូមា និងផ្សេងៗទៀត) រួមមាន ពិព័រណ៍គ្រឿងសង្ហារិម កសិកម្ម ឧស្សាហកម្ម សូត្រ ល្បែងកម្សាន្តសកល ផលិតផលប្រេងនិងគ្រាប់ធញ្ញជាតិ ឧបករណ៍ប្រើប្រាស់និងបច្ចេកវិទ្យា វាយនភណ្ឌ និងសម្ភារៈប្រើប្រាស់
- ពង្រឹងការអភិវឌ្ឍទីផ្សារ (១)បានរៀបចំវេទិកាធុរកិច្ចក្នុងស្រុក (២)បានរៀបចំការតាំងបង្ហាញ ផ្សព្វផ្សាយ និងប្រឹក្សាយោបល់លើផលិតផលខ្មែរសំខាន់ៗ (៣)បានរៀបចំសិក្ខា

សាលាស្តីពីការផ្សព្វផ្សាយនិងការបញ្ជូនផលិតផលសក្តានុពលកម្ពុជា អមដោយផលិតផលគំរូ នៅតាមបណ្តារាជធានី ខេត្ត រៀបចំសិក្ខាសាលាក្នុងប្រទេសស្តីពីផលិតផលនិងទីផ្សារផលិតផលរបស់កម្ពុជា ដោយសហការជាមួយមជ្ឈមណ្ឌលអាស៊ាន ជប៉ុន មជ្ឈមណ្ឌលអាស៊ាន កូរ៉េ មជ្ឈមណ្ឌលអាស៊ាន ចិន និងដៃគូផ្សេងៗ និង(៤)បានបង្កើតផ្សារគំរូព្រំដែនកម្ពុជា(ផ្សារដារខេត្តត្បូងឃ្មុំ)

- រៀបចំផែនទីបង្ហាញផ្លូវក្នុងដំណើរការសមាហរណកម្មពាណិជ្ជកម្មកម្ពុជា: (១)បានផ្សព្វផ្សាយឯកសារយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៩-២០២៣ (២) បានជំរុញការអនុវត្តយុទ្ធសាស្ត្រCTISU តាមរយៈការបំពេញព័ត៌មានសមិទ្ធកម្មស្តីពីការអនុវត្តម៉ាទ្រិកសសកម្មភាពរបស់អង្គភាពពាក់ព័ន្ធ
- អភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មកម្ពុជា (១)ប្រមូល រៀបចំ វិភាគ ចងក្រង និងផ្សព្វផ្សាយនូវទិន្នន័យ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ដល់អ្នកប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម និងសាធារណជនទូទៅ (២)បានបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម សម្រាប់បង្កភាពងាយស្រួលដល់ការសិក្សាស្រាវជ្រាវលើការអភិវឌ្ឍសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ
- កែលម្អក្របខ័ណ្ឌគតិយុត្តលើផ្នែកធុរកិច្ច ពាណិជ្ជកម្ម និងវិនិយោគ (១)បានផ្តល់ព័ត៌មានទៅអង្គការពាណិជ្ជកម្មពិភពលោករាល់ឯកសារបទប្បញ្ញត្តិនិងច្បាប់នានាដែលក្រសួងនិងស្ថាប័នពាក់ព័ន្ធបានរៀបចំ (២)បានផ្សព្វផ្សាយបច្ចុប្បន្នភាពពាណិជ្ជកម្មនិងវិនិយោគរបស់កម្ពុជាក្រោមក្របខ័ណ្ឌអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក (៣)បានសម្របសម្រួលនិងផ្តល់ចម្លើយលើកម្រងសំណួររបស់ប្រទេសដៃគូពាក់ព័ន្ធនឹងច្បាប់ឧបាស្រ័យពាណិជ្ជកម្ម ការងារផ្តួចផ្តើមរបស់ក្រុមប្រទេសG20 ក្នុងការគាំទ្រឧស្សាហូបនីយកម្មក្នុងប្រទេសអាហ្វ្រិកនិងប្រទេសអភិវឌ្ឍតិចតួច ផ្តល់ចម្លើយពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មឌីជីថលនិងដោយចីរភាព (៤)បានតាមដានវឌ្ឍនភាពការងារនៅក្នុងតារាងកម្មវិធីការងារអង្គការពាណិជ្ជកម្មពិភពលោក រួមមានច្បាប់ វិសោធនកម្ម អនុក្រឹត្យ បទប្បញ្ញត្តិលិខិតបទដ្ឋាន ពិនិត្យផ្តល់យោបល់ និងផ្តល់ព័ត៌មានជូនអង្គការពាណិជ្ជកម្មពិភពលោកស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ការឧបត្ថម្ភធនលើការនាំចេញ ការឧបត្ថម្ភគាំទ្រក្នុងស្រុក និងកិច្ចការក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោកសំខាន់ៗដទៃទៀត។

### តារាង៣.៩ : សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|
| តម្លៃនៃការនាំចេញ | លានដុល្លារអាម៉េរិក | ១៤ ៧៤៩ | ១៧ ២១៥ | ៧ ៤១៨ |
| តម្លៃនៃការនាំចូល | លានដុល្លារអាម៉េរិក | ២០ ១៧២ | ១៨ ៥៩០ | ១៤ ១៧៦ |

| | | | | |
|---|---|---|---|---|
| ចំនួនរោងចក្រនិងក្រុមហ៊ុនចុះបញ្ជីសុំសិទ្ធិនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ២៦៧ | ២៥៩ | ១០៧ |
| ចំនួនកម្មករបំពេញការងារក្នុងរោងចក្រនិងក្រុមហ៊ុនចុះបញ្ជីសុំសិទ្ធិនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ៤៤ ៧៦៩ | ៣៥ ៨៦៧ | ១២ ៩៥៨ |
| ក្រុមហ៊ុនបានស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | ចំនួន | ១៣ ២៥៩ | ៧ ៨៦០ | ៣ ៦៩០ |
| ម៉ាកបានស្នើសុំចុះបញ្ជីម៉ាក | ចំនួន | ៦ ៥៤៧ | ៦ ១១៦ | ៣ ៤៨៧ |
| ចំនួនមន្ត្រីរាជការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាលទាក់ទងនឹងវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម | នាក់ | ២ ២៥៦ | ៣០០ | ២៥៨ |
| ចំនួនសកម្មភាពចុះត្រួតពិនិត្យផលិតផល ដើម្បីធានាស្របតាមស្តង់ដាតម្រូវនៅតាមបណ្តាផ្សារទូទាំងប្រទេស | លើក | ៥៤៩ | ៧០២ | ២៧៦ |

ប្រភព : ក្រសួងពាណិជ្ជកម្ម

៣.៤១- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងពាណិជកម្មជួប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- លទ្ធភាពនៃការអនុវត្តការងារនិងការបញ្ជ្រាបការយល់ដឹងដល់សាធារណជន ពិសេសធុរជនស្តីពីស្ថានភាពនិងបរិបទនៃសកម្មភាពពាណិជ្ជកម្មក្នុងប្រទេស តំបន់ និងពិភពលោក នៅមានកម្រិត
- ភាពអាក់ខាននិងការលើកពេលវេលានៃកិច្ចប្រជុំពិភាក្សាលើកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកម្ពុជាជាមួយនឹងប្រទេសក្នុងតំបន់និងពិភពលោក
- សម្ភារៈបច្ចេកទេសមួយចំនួនមិនមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់។

## ៣- ការអភិវឌ្ឍធនធានមនុស្ស

### ៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣.៤២- សាលាមត្តេយ្យសិក្សាទូទាំងប្រទេស បានកើនពីចំនួន៧ ៧៨០សាលា/កន្លែងក្នុងឆ្នាំសិក្សា ២០១៨-២០១៩(រដ្ឋ៤ ៣០១ ឯកជន៥០៩ សហគមន៍២ ៩៧០) ដល់៨ ០១២ សាលា/កន្លែង (រដ្ឋ ៤ ៤៩៣ ឯកជន៥១៩ សហគមន៍៣ ០០០)ក្នុងឆ្នាំសិក្សា២០២០-២០២១។ ការចូលរៀននៅបឋមសិក្សាបានថយចុះបន្តិច ដោយអត្រាពិតនៃការសិក្សាមាន៩១,៩%(ប្រុស៩១,០% ស្រី៩២,៣%)នៅឆ្នាំសិក្សា២០២០-២០២១ ដែលមិនបានសម្រេចចំណុចដៅ៩៨,២%(ប្រុស៩៨,១% ស្រី៩៨,៦%) ក៏ប៉ុន្តែអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាសម្រេចបានលើសចំណុចដៅ ដោយមានអត្រា៨៧,៤%(ប្រុស៨៣,៤% ស្រី៩១,៦%)ក្នុងឆ្នាំសិក្សា២០២០-២០២១(ចំណុចដៅ៨៤,៨% ប្រុស៨២,៦% ស្រី៨៩,២%)។ សាលាបឋមសិក្សាមានស្ទើរគ្រប់ភូមិសាស្ត្រ ដោយបានកើនពីចំនួន ៧ ៧១៦(រដ្ឋ៧ ២២៨ ឯកជន៤៨៨) ឆ្នាំសិក្សា២០១៨-២០១៩ ដល់៧ ៨៤៣(រដ្ឋ៧ ៣០៤ ឯកជន ៥៣៩) ក្នុងឆ្នាំសិក្សា២០២០-២០២១ ហើយសិស្សសរុបទាំងសាលារដ្ឋនិងសាលាឯកជន មានចំនួន២ ១២៨ ៧៧២នាក់(ស្រី១ ០២២ ៦៣០នាក់)។ សម្រាប់ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេក

ទេសក្នុងរយៈពេល២ឆ្នាំកន្លះកន្លងមក ការចូលរៀននៅមធ្យមសិក្សាមានភាពប្រសើរឡើងដោយអត្រារួមនៃការសិក្សាកើន១,៦%សម្រាប់មធ្យមសិក្សាបឋមភូមិ និង២,៥%សម្រាប់មធ្យមសិក្សាទុតិយភូមិ។ អត្រានេះបានកើនដល់៦០,៧%នៅមធ្យមសិក្សាបឋមភូមិ និង៣២,២% នៅមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា២០២០-២០២១ ដែលស្ថិតនៅក្រោមចំណុចដៅ៦៣,៧% (មធ្យមសិក្សាបឋមភូមិ) និង៣៤,២%(មធ្យមសិក្សាទុតិយភូមិ)។ ឆ្នាំសិក្សា២០២០-២០២១ ចំនួនបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមាន៧២ ០១៦នាក់(ស្មើនឹង៦៥,៦៥%) ស្រី៤១ ៧៣៣នាក់(ស្មើនឹង៧១,២៦%) ក្នុងនោះនិទ្ទេសA កើនដល់១ ៧៥៧នាក់(ស្រី១ ០៥២ នាក់)។ គ្រឹះស្ថានមធ្យមសិក្សាបានកើនឡើងជាបន្តបន្ទាប់ ដោយមានចំនួន២ ០៤៩(អនុវិទ្យាល័យ១ ៣០៨ និងវិទ្យាល័យ៧៤១)នៅឆ្នាំសិក្សា២០២០-២០២១ ហើយសិស្សមធ្យមសិក្សាបឋមភូមិមានចំនួន៦៦៨ ៦៣៧នាក់(ស្រី៣៥៤ ៣១៣នាក់) និងសិស្សមធ្យមសិក្សាទុតិយភូមិមាន៣៧៦ ៦៩២នាក់(ស្រី២០៤ ៥៤៩នាក់)។

៣.៤៣- សម្រាប់ការអប់រំឧត្តមសិក្សា : វឌ្ឍនភាពនៃការចូលរៀននៅឧត្តមសិក្សាមានតិចតួច ដោយអត្រារួមនៃការសិក្សា(១៨-២២ឆ្នាំ)កើនបាន១,៧%។ បច្ចុប្បន្ន អត្រារួមនៃការសិក្សានៅឧត្តមសិក្សាមាន១៣,៣%(ប្រុស១៥,៥% ស្រី១១,៩%) ដែលស្ថិតនៅទាបជាងចំណុចដៅ១៤,២% (ប្រុស១៦,៦% ស្រី១២,៣%)។ និស្សិតកំពុងសិក្សានៅឧត្តមសិក្សាទាំងអស់មានចំនួន២០១ ៩០០នាក់ ស្រី១០២ ៥៩៩នាក់ ស្មើនឹង៥០,៨% ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន១៩ ៧៨២នាក់ ស្រី១០ ២៣៩នាក់ ស្មើនឹង៥១,៧៦% និស្សិតថ្នាក់បរិញ្ញាបត្រចំនួន១៧១ ១៨៣នាក់ ស្រី៩២ ២៣៧នាក់ ស្មើនឹង៥៣,៨៨% និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន៩ ៩៨៤នាក់ ស្រី៣ ០៣៥នាក់ ស្មើនឹង៣០,៤% និងថ្នាក់បណ្ឌិតចំនួន៩៦១នាក់ ស្រី៨៨នាក់ ស្មើនឹង៩,១៦%។ និស្សិតរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(ស្ទែម) ក្នុងកម្រិតបរិញ្ញាបត្រ បានកើនដល់៣០,៤%(ប្រុស៤៥,៤% ស្រី១៧,៥%) ដែលសម្រេចបានតាមចំណុចដៅ៣០,០%។ គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមានចំនួន១២៨ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ៤៨ និងឯកជន៨០ ដែលមានទីតាំងស្ថិតនៅចំនួន២០ខេត្តនិងរាជធានី។ ការអប់រំក្រៅប្រព័ន្ធមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយមានមជ្ឈមណ្ឌលសិក្សាសហគមន៍ ចំនួន៣៤៩កន្លែង ថ្នាក់ជំនាញមុខរបរ ចំនួន៥៨៤។

៣.៤៤- ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងដាក់ចេញនូវវិធានការចាំបាច់នានាឆ្លើយតបនឹង "គន្លងជីវិតថ្មីក្នុងវិស័យអប់រំ" ដើម្បីធានាឱ្យការរៀនសូត្ររបស់សិស្សបានពេញលេញ។ មធ្យោបាយក្នុងការអនុវត្តការអប់រំពីចម្ងាយ មានដូចជាទូរទស្សន៍ ទូរសព្ទ កុំព្យូទ័រ កុំព្យូទ័របន្ទះ សន្លឹកកិច្ចការ សៀវភៅសិក្សាគោល ឯកសារផ្សេងៗ កម្មវិធី Zoom, Telegram, Messenger, Facebook, Google Meet, Google Classroom, E-Learning App, ប៉ុស្តិ៍ទូរទស្សន៍...។

៣.៤៥- សម្រាប់អនុវិស័យការអភិវឌ្ឍយុវជន ពាក្យស្លោក **កុមារល្អ សិស្សល្អ មិត្តល្អ** មានឥទ្ធិពលវិជ្ជមានលើសិស្សនិងការគ្រប់គ្រងសាលារៀន។ ក្នុងអនុវិស័យអប់រំកាយនិងកីឡា កម្ពុជាទទួលបានមេដាយមាស

ចំនួន៤ មេដាយប្រាក់ចំនួន៦ និងមេដាយសំរឹទ្ធចំនួន៣៦ ក្នុងស៊ីហ្គេមទី៣០ នៅប្រទេសហ្វីលីពីន។ កម្ពុជាមានគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករ កីឡាការិនីថ្នាលសរុបចំនួន៥០៩នាក់(ស្រី១០៨នាក់) ដែលទទួលការហ្វឹកហាត់បង្កើនសមត្ថភាពបច្ចេកទេសត្រៀមលក្ខណៈឆ្ពោះទៅស៊ីហ្គេមឆ្នាំ២០២៣។

## តារាង៣.១០ : លទ្ធផលនៃការប្រកួតកីឡាលក្ខណៈអន្តរជាតិ

| ប្រភេទកីឡា | ប្រតិភូ | កីឡាករ | កីឡាការិនី | មេដាយ | | | សរុប |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | |
| ការប្រកួតជើងឯកពិភពលោក | ៥០ | ៧៨ | ៣៩ | ១៤ | ១៣ | ១៥ | ៤២ |
| ការប្រកួតជើងឯកអាស៊ី | ៣៩ | ៥២ | ៣៩ | ១២ | ០៨ | ១២ | ៣២ |
| ការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ | ១១ | ២០ | ១៦ | ០០ | ០០ | ០៧ | ០៧ |
| ការប្រកួតកីឡាបើកទូលាយ | ៣៥ | ៧៩ | ៣១ | ០៩ | ០២ | ០៥ | ១៦ |
| ការប្រកួតកីឡាជនពិការ | ០៩ | ៣៤ | ០២ | ០០ | ០១ | ០២ | ០៣ |
| ការប្រកួតកីឡាស៊ីហ្គេមលើកទី៣០ | ១២៣ | ២០៦ | ៧០ | ០៤ | ០៦ | ៣៦ | ៤៦ |
| សរុប | | | | ៣៩ | ៣០ | ៧៧ | ១៤៦ |

ប្រភព : ក្រសួងអប់រំ យុវជន និងកីឡា

៣.៤៦- ទោះបីជាការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ ក្នុងរយៈពេល២ឆ្នាំកន្លះមក ទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ក៏នៅមានបញ្ហាប្រឈមចម្បងៗមួយចំនួន ដែលជាការរាំងស្ទះដល់ការអនុវត្តឱ្យសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេសក្នុងដំណាក់កាលវិបត្តិកូវីដ-១៩ ដែលទាមទារត្រូវដោះស្រាយនិងអនុវត្តបន្តដូចខាងក្រោម៖

- ហេដ្ឋារចនាសម្ព័ន្ធមត្តេយ្យសិក្សាពុំទាន់ឆ្លើយតបនឹងស្តង់ដាសេវានិងតម្រូវឱ្យមានការពង្រីកសេវាអប់រំកុមារតូច
- សមត្ថភាពគ្រូបង្រៀននៅមានកម្រិតលើចំណេះដឹង វិធីសាស្ត្របង្រៀន បទពិសោធការគ្រប់គ្រងថ្នាក់រៀន
- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធនិងឧបករណ៍អេឡិចត្រូនិក
- គ្រឹះស្ថានមធ្យមសិក្សាមួយចំនួនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារៈឧបទេស និងរោងជាង
- ការអនុវត្តកម្មវិធីអប់រំស្វែម នៅតែជាបញ្ហាសម្រាប់សាលារៀន
- ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសមិនទាន់អាចអនុវត្តបានពេញលេញ
- ខ្វះមន្ត្រីជំនាញបច្ចេកទេសផ្នែកប្រព័ន្ធគ្រប់គ្រងការរៀនពីចម្ងាយ
- ប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សាមិនទាន់ឆ្លើយតបបានទាំងស្រុងនឹងស្តង់ដាតំបន់និងអន្តរជាតិ
- លទ្ធភាពទទួលនិស្សិតក្រីក្រ ជាពិសេសនិស្សិតស្រីនៅមជ្ឈមណ្ឌលអន្តេវាសិកដ្ឋាននារីនៅមានកម្រិត

- គ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយចំនួន ពុំទាន់ទទួលបានការវិនិយោគលើការស្រាវជ្រាវ ធនធានសាស្ត្រាចារ្យតាមការកំណត់
- កង្វះខាតធនធានមនុស្សផ្នែកជំនាញទំនាក់ទំនង វេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រកីឡា។

## ៣.២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

៣.៤៧- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រសកម្មភាពធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ គម្រោងសាកល្បងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ និងការបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈរយៈពេលវែងតាមវិស័យអាទិភាពទាំង៥ រួមមានសំណង់ អគ្គិសនី មេកានិករថយន្ត កម្មន្តសាល និងធុរកិច្ច ព័ត៌មានវិទ្យា ដើម្បីគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្មនិងដើម្បីពង្រឹងនិងពង្រីកការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈឱ្យកាន់តែឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។ ក្រសួងបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឱ្យប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កាន់តែមានភាពទាក់ទាញដល់យុវជនដើម្បីត្រៀមចូលទីផ្សារការងារឱ្យជ្រួតជ្រាបបន្ថែមទៀត
- បានបង្កើនការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ដោយបានបណ្តុះបណ្តាលបញ្ចប់សិក្ខាកាម សិស្ស និស្សិត សរុបចំនួន១១៣ ៥៩៥នាក់(ស្រី៥១ ១៣៥នាក់) និងបានហ្វឹកហ្វឺនកូនជាងចំនួន៥០ ៦០៦នាក់(ស្រី៣៧ ៥១៤នាក់)។ ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈផ្លូវការពីចម្ងាយ(អនឡាញ) ដើម្បីធានា"យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"និងការកែទម្រង់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ(TVET 4.0)
- បានអនុវត្តសាកល្បងវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋនិងឯកជន លើវិស័យអាទិភាពក្នុងនោះ បានធ្វើការពង្រីកការអនុវត្តបណ្តុះបណ្តាលនៅកន្លែងការងារ(ការហ្វឹកហ្វឺនកូនជាង) និងដាក់បញ្ចូលជំនាញទន់ក្នុងកម្មវិធីបណ្តុះបណ្តាលបានចំនួន១៣០ ៦៦៤នាក់(ស្រី៩៦ ៧៦០នាក់) និងបានរៀបចំការិយាល័យឬផ្នែកទំនាក់ទំនងឧស្សាហកម្មសម្រាប់ទំនាក់ទំនងឧស្សាហកម្ម ដើម្បីពង្រឹងការបណ្តុះបណ្តាលជំនាញឱ្យឆ្លើយតបនឹងតម្រូវការរបស់វិស័យឯកជន។ ក្រោមកម្មវិធីភាពជាដៃគូនេះ ក្រសួងបានសហការបង្កើតវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា ចិន នៅខេត្តព្រះសីហនុនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាលចាប់ពីឆ្នាំ២០១៨មកលើមុខជំនាញ រួមមានមេកានិករថយន្ត អគ្គិសនី សំណង់ ព័ត៌មានវិទ្យា ទេសចរណ៍ បដិសណ្ឋារកិច្ច
- បានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន៤ គឺវិស័យសំណង់នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ វិស័យអគ្គិសនីនៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ វិស័យមេកានិក

រថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងវិស័យកម្មន្តសាលនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ក្នុងគោលបំណងដើម្បីពិគ្រោះយោបល់លើផែនការសកម្មភាពក្នុងការផ្ដល់ជំបូន្មាន និងកំណត់ទិសដៅក្នុងការអភិវឌ្ឍសមត្ថភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣.៤៨- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈនៅមានកម្រិត មិនទាន់បានឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនិងសមត្ថភាពគ្រូបច្ចេកទេស និងធនធានមនុស្សក្នុងផ្នែកអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈនៅមានកម្រិត
- ប្រព័ន្ធព័ត៌មានទីផ្សារការងារមិនទាន់មានការអភិវឌ្ឍពេញលេញ ដែលនាំឱ្យកើតឡើងនូវកង្វះជំនាញនិងភាពមិនស៊ីគ្នានៃជំនាញក្នុងទីផ្សារការងារ
- ការផ្ដល់តម្លៃទៅលើបច្ចេកវិទ្យាឬវិទ្យាសាស្ត្រ សម្រាប់ការអនុវត្តនៅមិនទាន់ផុសផុលនៅឡើយ ដែលប្រការនេះជាបញ្ហាសម្រាប់ជំរុញទឹកចិត្តយុវជនឱ្យមានក្ដីស្រមៃ និងមានមោទនភាពក្នុងការចាប់យកបច្ចេកទេសឬវិទ្យាសាស្ត្រក្នុងការសិក្សា ដែលនេះ ទាមទារការពង្រឹងនិងបង្កើនការផ្សព្វផ្សាយ ជាពិសេស ការបន្តរៀបចំទិវាអ.ប.វ. និងកម្មវិធីតម្រង់ទិសវិជ្ជាជីវៈ
- ការទទួលស្គាល់សមត្ថភាពជំនាញស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាតាមវិស័យនីមួយៗនៅមានចំនួនតិចតួច ការកំណត់បន្ថែមនូវវិសាលភាពនៃវិស័យនិងអាទិភាពប្រភេទមុខជំនាញ ព្រមទាំងបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាព ហើយធ្វើការផ្ទៀងផ្ទាត់បន្សុីគ្នារវាងCQF និងក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន(AQRF)។

## ៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ

៣.៤៩- ស្ថានភាពសុខភាពនិងសុខមាលភាពរបស់ប្រជាជនកម្ពុជា ត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការពង្រឹងនិងពង្រីកប្រព័ន្ធផ្ដល់សេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាពប្រកបដោយសមធម៌ និងពង្រីកការគ្របដណ្ដប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ដោយសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- លើកស្ទួយសុខភាពបន្តពូជ កាត់បន្ថយមរណភាពមាតា ទារក កុមារ និងកែលម្អកង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រីនិងកុមារតូច ក្រសួងសុខាភិបាលបានធ្វើឱ្យសុខភាពមាតាទារក និងកុមារកាន់តែប្រសើរឡើង ដោយកាត់បន្ថយអត្រាមរណភាពមាតាធ្លាក់ចុះពី១៧០មក១៤១ ក្នុងចំណោមទារកកើតរស់១០០ ០០០នាក់ អត្រាស្លាប់ទារកពី២៨មក១៨ និងអត្រាស្លាប់កុមារអាយុក្រោម៥ឆ្នាំ ពី៣៥មក២៨ ក្នុងចំណោមទារកកើតរស់១ ០០០នាក់ រវាងឆ្នាំ២០១៤និង២០១៩

## តារាង៣.១១ : លទ្ធផលនៃសុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ២០,៤៧ | ២០,១២ | ១៨,៩៧ |
| ២ | សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល | % | ៨៦,៧៥ | ៨៩,១៦ | ៣៨,៤៨ |
| ៣ | អត្រាសម្រាលដោយវិធីវះកាត់ | % | ៧,១៣ | ៧,៦៧ | ៧,០៦ |
| ៤ | ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល | % | ៧៧,៨១ | ៧៤,១៤ | ៣០,៨២ |
| ៥ | ភាគរយនៃស្ត្រីសម្រាលទទួលការពិនិត្យ ថែទាំក្រោយសម្រាលលើកទី១(មុន៤៨ម៉ោងក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល | % | ៦៦,៤១ | ៦៧,៨៣ | ៣០,០៨ |
| ៦ | ភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងកំឡុងម៉ោងទីមួយនៃកំណើត | % | ៦៥,៣៦ | ៧១,១៤ | ៧១,៧១ |
| ៧ | ភាគរយស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ | % | ៩១,០៥ | ៨៩,៤៧ | ៤១,៤៧ |
| ៨ | ភាគរយនៃកុមារអាយុ៦-៥៩ខែបានទទួលគ្រាប់ថ្នាំជីវជាតិអា | % | ៧៣,០៤ (ជុំទី២) | ៧៤,០ (ជុំទី២) | ៦០,៧៤ (ជុំទី១) |
| ៩ | ភាគរយនៃកុមារអាយុ១២-៥៩ខែបានទទួលថ្នាំទម្លាក់ព្រូនមេបង់ដាហ្សុល | % | ៧៥,១៥ (ជុំទី២) | ៧៦,០ (ជុំទី២) | ៥៨,៣៥ (ជុំទី១) |
| ១០ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូស បង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកថ្លើមប្រភេទបេ រលាកសួត/រលាកស្រោមខួរ | % | ៩៩,០ | ១០៦,៦ | ៥០,៧១ |
| ១១ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូចដូសទី១ (នៅខែទី៩) | % | ១០២ | ១០៧,៣ | ៥០,៣២ |
| ១២ | ពិនិត្យពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ | ចំនួនលើក | ១,៦១ | ១,២៨ | ០,៦២ |

ប្រភព : ក្រសួងសុខាភិបាល

- កាត់បន្ថយការឈឺនិងស្លាប់ដោយជំងឺឆ្លង ជំងឺរាំរ៉ៃ ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាគ្រប់គ្រងនិងទប់ស្កាត់បានការចម្លងរាតត្បាតជំងឺកូវីដ-១៩ក្នុងសហគមន៍ ដោយគ្មានការដាក់ប្រទេសក្នុងគ្រាអាសន្ន គ្មានការបិទជាតំបន់ ឬប្រទេសទាំងមូល គ្មានករណីស្លាប់ និងគ្មានការចម្លងដល់គ្រូពេទ្យ បុគ្គលិកសុខាភិបាលជួរមុខ(គិតត្រឹមថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១)។ ក្រៅពីនេះ ប្រទេសកម្ពុជាបានទទួលជោគជ័យជាបន្តបន្ទាប់ ក្នុងការកាត់បន្ថយប្រេវ៉ាឡង់នៃការចម្លងមេរោគអេដស៍ អត្រាស្លាប់នៃជំងឺរបេង និងអត្រាស្លាប់នៃជំងឺគ្រុនចាញ់។

## តារាង៣.១២ : លទ្ធផលនៃការបង្ការនិងគ្រប់គ្រងជំងឺឆ្លង

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាល ឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | ករណីឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍១០០០នាក់ | % | ០,០៣ | ០,០៧ | |
| ២ | ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន(HIV Testing) | % | ៨៤,០ | ៨៤,០ | ៨៤,០ |
| ៣ | ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍(Anti-Retroviral Therapy) | % | ៩៩,០ | ៩៩,០ | ៩៩,០ |
| | ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) ដែលកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មានតេស្ត Viral Load Suppression ក្នុងរយៈពេល១២ខែកន្លងមក | % | ៩៦,០ | ៩៧,០ | ៩៧,០ |
| ៤ | អាំងស៊ីដង់នៃជំងឺរបេងគ្រប់ទម្រង់ | លើប្រជាជន ១០០ ០០០ នាក់ | ២៨៧ | ២៧៤ | ទិន្នន័យប្រចាំឆ្នាំ |
| ៥ | អត្រាស្លាប់ដោយជំងឺរបេង | ក្នុងប្រជាជន ១០០ ០០០ នាក់ | ១៧ | ២០ | ទិន្នន័យប្រចាំឆ្នាំ |
| ៦ | អត្រាព្យាបាលជោគជ័យនៃជំងឺរបេង | % | ៩៤ | ៩៤ | ៩៣ |
| ៧ | ចំនួនករណីស្រាវជ្រាវជំងឺរបេងដែលបានរាយការណ៍ | ចំនួន | ២៩.៤៥០ | ២៩.៦៨០ | ១២,៤៨៨ |
| ៨ | អាំងស៊ីដង់នៃជំងឺគ្រុនចាញ់(ករណីថ្មី) | ក្នុងប្រជាជន ១ ០០០នាក់ | ១,៩៥ | ០,៦៥ | ០,២១ (ទិន្នន័យ១០ខែ) |
| ៩ | អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែលសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | ក្នុងប្រជាជន ១០០ ០០០ នាក់ | ០,០ | ០,០ | ០,០ |
| ១០ | អត្រាស្លាប់ដោយជំងឺគ្រុនឈាម | % | ០,០៧ | ០,១ | ០,៣ |

ប្រភព : ក្រសួងសុខាភិបាល

- កាត់បន្ថយការឈឺនិងស្លាប់ដោយជំងឺមិនឆ្លងនិងបញ្ហាសុខភាពសាធារណៈ៖ អន្តរាគមន៍ក្នុងការបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លងនិងបញ្ហាសុខភាពសាធារណៈដទៃទៀត ក្រសួងសុខាភិបាលសម្រេចបានតាមសូចនាករស្នូលដូចបង្ហាញក្នុងតារាងខាងក្រោម៖

## តារាង៣.១៣ : លទ្ធផលនៃការបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | ភាគរយនៃប្រជាជនអាយុពី២៥-៦៩ឆ្នាំមានជំងឺលើសសម្ពាធឈាមបានទទួលការព្យាបាល | % | ២៣,១២ | ២៩,០៧ | ទិន្នន័យប្រចាំឆ្នាំ |
| ២ | ភាគរយនៃប្រជាជនអាយុពី២៥-៦៩ឆ្នាំមានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល | % | ២៨,៦ | ៤៣,១៩ | ទិន្នន័យប្រចាំឆ្នាំ |
| ៣ | ភាគរយនៃស្ត្រីអាយុ៣០-៤៩ឆ្នាំបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន | % | ០,៣១ | ០,៥៤ | ទិន្នន័យប្រចាំឆ្នាំ |
| ៤ | ចំនួននិងភាគរយនៃប្រជាជនពេញវ័យ មានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល | ចំនួន និង% | ២,១% (១១ ៨០៩នាក់) | ១,៩% (១០ ៥៣២នាក់) | ០,៧% (៤ ២១១នាក់) |
| ៥ | ចំនួននិងភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល | ចំនួន និង% | ២៤,១% (៥ ៣៩៦នាក់) | ២៨,៨% (៦ ៤៣៦នាក់) | ១០,៤% (២ ៣៣០ នាក់) |
| ៦ | អត្រាវះកាត់ជំងឺភ្នែកឡើងបាយ | ក្នុងប្រជាជន ១លាននាក់ | ២ ៥៦២ | ២ ៣៣៤ | ១ ៣៤០ |

ប្រភព : ក្រសួងសុខាភិបាល

- ប្រព័ន្ធសុខាភិបាលកាន់តែមានភាពធន់ ភាពឆ្លើយតប និងគណនេយ្យភាពចំពោះតម្រូវការផ្នែកសុខភាពរបស់ប្រជាជន អន្តរាគមន៍ជាអាទិភាពចំបងៗ លើការកែលម្អគុណភាពសេវា និងការបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ដើម្បីសម្រេចបានការគ្របដណ្តប់សេវាសុខភាពជាសកល ក្រសួងសុខាភិបាលសម្រេចសមិទ្ធផលដូចបង្ហាញក្នុងតារាងខាងក្រោម៖

## តារាង៣.១៤ : លទ្ធផលនៃការផ្តល់សេវាសុខាភិបាលនិងពង្រឹងប្រព័ន្ធសុខាភិបាល

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | ការពិនិត្យពិគ្រោះជំងឺករណីថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ចំនួនលើក | ០,៧២ | ០,៦៧ | ០,២៦ |
| ២ | អត្រាប្រើប្រាស់គ្រែ | % | ១០៦,៨ | ៨៧,៩៧ | ៦៣,៩ |
| ៣ | អត្រាស្លាប់នៅមន្ទីរពេទ្យ | % | ០,៦២ | ០,៧៥ | ១,០៧ |
| ៤ | ភាគរយនៃប្រជាជនដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម(មូលនិធិសមធម៌និងធានារ៉ាប់រងសុខភាព) | % | ៣៨,៥ | ៣៩,៥ | ទិន្នន័យប្រចាំឆ្នាំ |
| ៥ | ភាគរយនៃការផ្តល់ឈាមដោយស្ម័គ្រចិត្ត | % | ២១,៧ | ១៣,២ | ៨,៣ |
| ៦ | សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | % | ៩៣,៨៧ | ៩៥,១៣ | ៩៤,៨៣ |
| ៧ | %នៃមណ្ឌលសុខភាពនិងមន្ទីរពេទ្យផ្តល់របាយការណ៍ពេញលេញនិងរាយការណ៍ទាន់ពេល (មុនថ្ងៃ១៦មករា) | % | ៩៨,១៤ | ៩៩,០ | ៩៧,៨៨ |
| ៨ | ភាគរយនៃមណ្ឌលសុខភាពដែលមានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដំណើរការពេញលេញ | % | ៨៧,១២ | ៩០,៩៥ | ៨៥,៦២ |

ប្រភព : ក្រសួងសុខាភិបាល

៣.៥០- ទោះបីវិស័យសុខាភិបាល សម្រេចបានសមិទ្ធផលនិងវឌ្ឍនភាពគួរឱ្យកត់សម្គាល់រវាងឆ្នាំ ២០១៩ ដល់ពាក់កណ្តាលឆ្នាំ២០២១ ជារួមវិស័យសុខាភិបាលនៅតែប្រឈមនឹងបញ្ហាដូចខាងក្រោម៖

- **កំណើនប្រជាពលរដ្ឋនិងមនុស្សចាស់កាន់តែច្រើន** ប្រទេសកម្ពុជាកំពុងស្ថិតលើផ្លូវឆ្ពោះទៅកាន់សង្គមមានមនុស្សចាស់កាន់តែច្រើន ដោយសារនិន្នាការកើនឡើងនៃអាយុកាលរស់នៅរំពឹងទុក។ និន្នាការនេះ នឹងជំរុញឱ្យកើនឡើងតម្រូវការនៃសេវាថែទាំរយៈពេលវែង និងសេវាថែទាំព្យាបាលជំងឺមិនឆ្លង/ជំងឺរ៉ាំរ៉ៃ
- **សន្ទុះកើនឡើងនៃជំងឺមិនឆ្លងនិងឥរិយាបថប្រឈមហានិភ័យសុខភាព** ជំងឺមិនឆ្លងជាមូលហេតុនាំមុខនៃការស្លាប់និងពិការភាពរបស់ប្រជាជនកម្ពុជា ខណៈពេលដែលជំងឺឆ្លងចម្បងៗនៅតែជាបញ្ហាសុខភាពសាធារណៈនៅឡើយ។ ការព្យាបាលថែទាំជំងឺមិនឆ្លងរ៉ាំរ៉ៃត្រូវការសមត្ថភាពធ្វើរោគវិនិច្ឆ័យនិងបច្ចេកវិទ្យាវេជ្ជសាស្ត្រខ្ពស់ ហើយត្រូវចំណាយច្រើនដែលនាំមកនូវបញ្ហាប្រឈមដល់មន្ទីរពេទ្យ អ្នកជំងឺនិងគ្រួសារអ្នកជំងឺនិងប្រព័ន្ធគាំពារសុខភាពសង្គម
- **ការគំរាមកំហែងសុខភាពសាធារណៈ** ចំពោះមុខការរាតត្បាតនៃកូវីដ-១៩ ចាំបាច់បន្តពង្រឹងសមត្ថភាពស្នូលដែលតម្រូវដោយនិយ័តកម្មសុខភាពអន្តរជាតិ ជាពិសេសសមត្ថភាពបច្ចេកទេសទាក់ទងនឹងការស្វែងរក ការបង្ការ និងការឆ្លើយតបរហ័ស ចំពោះការផ្ទុះឡើងនៃជំងឺនិងភាពអាសន្ននៃសុខភាពសាធារណៈ។ ហានិភ័យសុខភាពបរិស្ថាន ការប្រែប្រួលអាកាសធាតុនិងនគរូបនីយកម្ម អាចគំរាមកំហែងដល់សុខភាពសាធារណៈ
- **គុណភាពសេវាថែទាំសុខភាពនៅមិនទាន់ឆ្លើយតបទៅនឹងការរំពឹងទុករបស់ប្រជាពលរដ្ឋ** ត្រូវការចំនួនបុគ្គលិកសុខាភិបាលតាមប្រភេទជំនាញគ្រប់ចំនួនតាមនិយាមនៃការផ្តល់សេវានៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ព្រមទាំងឧបករណ៍ពេទ្យនិងបច្ចេកវិទ្យាវេជ្ជសាស្ត្រ
- **ការងារគ្រប់គ្រងនិងនិយតកម្មទីផ្សារឱសថនិងសេវាសុខាភិបាលនៅចន្លោះប្រហោង** ការលុបបំបាត់ការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធ/បណ្តាញសង្គម ស្តីពីផលិតផលឱសថ អាហារបំប៉នសុខភាព ផលិតផលគ្រឿងសម្អាងដែលប្រាសចាកពីការពិតនៅមាន បើទុកណាជាក្រសួងសុខាភិបាលបានចាត់វិធានការទប់ស្កាត់ជាប្រចាំ។

៣.៥១- យោងលើគោលនយោបាយអាទិភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ និងយោងលើសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានសម្រេចនូវសមិទ្ធផលមួយចំនួនដូចខាងក្រោម៖

- បានដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិរាជធានី ខេត្ត និងនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បានដាក់បញ្ចូលអ្នកផ្ទុកមេរោគអេដស៍ក្រីក្រទៅក្នុងការទទួលបានមូលនិធិសមធម៌។ ចាប់តាំងពីឆ្នាំ២០១៩មក ចំនួនអ្នកផ្ទុកមេរោគអេដស៍ក្រីក្រចំនួន១ ៨៩៤គ្រួសារ ត្រូវបានទទួលនូវមូលនិធិសមធម៌

- បានអនុវត្តលិខិតលេខ២១៣ សជណ.សស របស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- បានធ្វើឱ្យសម្រេចគោលដៅចំនួន២(គោលដៅទី២ និងទី៣) នៃគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ ២០២១ និងកំពុងឈានទៅរកការសម្រេចគោលដៅទាំងស្រុងនៅឆ្នាំ២០២៥។

## សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

៣.៥២- ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទសម្រេចបានសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

- បានពង្រឹងយន្តការស្ថាប័នដើម្បីលើកកម្ពស់អភិបាលកិច្ចលើវិស័យសន្តិសុខស្បៀងនិង អាហារូបត្ថម្ភ ទាំងថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចូលរួមអនុវត្ត ផែនការសកម្មភាពនៃចលនាបង្កើនអាហារូបត្ថម្ភពិភពលោក ដំណើរការក្រុមការងារ បច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ វេទិកាសន្តិសុខស្បៀងនិង អាហារូបត្ថម្ភនិងវេទិកានានា និងការបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិ សុខស្បៀងនិងអាហារូបត្ថម្ភថ្នាក់ខេត្ត
- បានសម្របសម្រួលរៀបចំនិងអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ២០១៩-២០២៣ និងរៀបចំសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេក ទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- បានរៀបចំនិងអនុវត្តផែនទីបង្ហាញផ្លូវស្ដីពីសកម្មភាពសកលដើម្បីឆ្លើយតបភាពស្គមស្គាំង របស់កុមារឆ្នាំ២០៣០
- បានរៀបចំនិងអនុវត្តផែនទីបង្ហាញផ្លូវស្ដីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយ ចីរភាពនៅកម្ពុជាឆ្នាំ២០៣០
- បានពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្ដីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំលើគេហទំព័រwww.foodsecurity.gov.kh និងបានរៀបចំនិង ធ្វើបច្ចុប្បន្នកម្មជាប្រចាំលើ Facebook page: https://web.facebook.com/fsncu2016 និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានកសាងសមត្ថភាពដល់ក្រុមគ្រូបង្គោល មន្ត្រីថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ សង្កាត់ លើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- បានរៀបចំទិវាជាតិអាហារូបត្ថម្ភ និងទិវាអាហារូបត្ថម្ភថ្នាក់ក្រោមជាតិ នៅថ្ងៃទី៦ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ
- បានសហការជាមួយអង្គការFAO, WFP, UNICEF, WHO, GIZ , HKI និងស្ថានទូត សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់និងដៃគូអភិវឌ្ឍដទៃទៀត ដើម្បីលើកកម្ពស់វិស័យសន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ
- បានបង្កើតបណ្ដាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភនិងបណ្ដាញយុវជនជើងឯកអាហា រូបត្ថម្ភ។

៣.៥៣- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ជំងឺកូវីដ-១៩បានធ្វើឱ្យវិស័យសន្តិសុខស្បៀងមានបញ្ហាប្រឈម ដោយខ្សែច្រវាក់ផ្គត់ផ្គង់ស្បៀងមានការរំខានដែលនាំឱ្យតម្លៃស្បៀងមានការកើនឡើង ប្រាក់ចំណូលថយចុះ បញ្ហាបំណុលកើន ដែលជះឥទ្ធិពលដល់លទ្ធភាពទទួលបានស្បៀង
- ការប្រែប្រួលអាកាសធាតុ បរិស្ថានស្បៀង ចំណាកស្រុក និងរបៀបនៃការទទួលទានអាហារ បង្កឱ្យមានផលប៉ះពាល់ដល់ស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- នៅខ្វះទិន្នន័យសម្រាប់ស្វែងយល់ពីវឌ្ឍនភាព ការឆ្លើយតបអភិបាលកិច្ចអាហារូបត្ថម្ភនិងការសម្របសម្រួលពហុវិស័យនៅថ្នាក់ក្រោមជាតិ និងការចូលរួមពីវិស័យឯកជននិងយុវជនលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ នៅមានកម្រិត។

៣.៥៤- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចបានសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

- បានអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ ដោយសហការជាមួយកាកបាទក្រហមកម្ពុជានិងអង្គការនានា ផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាស្បៀងនិងសម្ភារៈផ្សេងៗដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនរងគ្រោះនិងងាយរងគ្រោះ ប្រជាជនក្រីក្រ ទុរគតជន សរុបចំនួន ១៤៩ ៩០៣គ្រួសារ
- ប្រជាជនក្រីក្រនិងងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ បានមកចុះឈ្មោះទទួលសេវាសរុបចំនួន៦៥២ ៤៨៤គ្រួសារ ដែលចំណាយថវិកាសរុបចំនួន១.៤០៧ប៊ីលានរៀល សម្រាប់សម្រួលជីវភាពរស់នៅនិងការថែទាំសុខភាព
- បានប្រកាសដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។ បើគិតត្រឹមដល់ពាក់កណ្តាលឆ្នាំ២០២១ រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះចំនួន៧១ ៦៣៥នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន៣៧ ៣៦៦នាក់ ដែលចំណាយថវិកាសរុបចំនួនជាង២១ប៊ីលានរៀល។

៣.៥៥- ក្រសួងផែនការសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានរៀបចំឱ្យមានគោលនយោបាយ គោលការណ៍ណែនាំបច្ចេកទេស លិខិតបទដ្ឋានគតិយុត្តស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារនៅកម្ពុជា អង្កេតមូលដ្ឋានស្តីពីការរកកម្រិតជាតិអ៊ីយ៉ូដក្នុងខ្លួនស្ត្រីមានផ្ទៃពោះនិងស្ត្រីក្នុងវ័យបន្តពូជនៅ៥រាជធានី ខេត្ត រាជធានីភ្នំពេញ ) ខេត្តកំពត បាត់ដំបង ក្រចេះ និងរតនគិរីអង្កេតមូលដ្ឋានស្តីពី (ការរកកម្រិតជាតិអ៊ីយ៉ូដក្នុងអំបិល ដែលចរាចរនៅលើទីផ្សារ ទាំង២៥រាជធានី ខេត្ត
- បានដាក់បញ្ចូលមីក្រូសារជាតិគ្រប់កម្រិតទៅក្នុងចំណីអាហារសមស្រប និងធានាបាននូវគុណភាពសុវត្ថិភាពនិងបរិមាណគ្រប់គ្រាន់តាមតម្រូវការទៅក្នុងបញ្ជីស្តង់ដាជាតិ ជំរុញផលិតករផលិតម៉ាស៊ីនលាយជាតិអ៊ីយ៉ូដបានចំនួន២២គ្រឿងនៅក្នុងរាជធានី ខេត្តចំនួន៩

- បានជំរុញផលិតករអំបិលអ៊ីយ៉ូដឱ្យប្រើប្រាស់ស្លាកសញ្ញាសម្គាល់អំបិលអ៊ីយ៉ូដថ្មីបានចំនួន ២២សិប្បកម្ម និងជំរុញផលិតករទឹកត្រី ទឹកស៊ីអ៊ីវចូលរួមបញ្ចូលជាតិដែកទៅក្នុងទឹកត្រី ទឹកស៊ីអ៊ីវ បានចំនួន៥សិប្បកម្មបន្ថែម។ ជាលទ្ធផល អំបិលប្រមាណ៨៨ពាន់តោន ត្រូវបានបញ្ចូលជាតិអ៊ីយ៉ូដ ហើយទឹកត្រី ទឹកស៊ីអ៊ីវ ប្រមាណ៤លានលីត្រត្រូវបានបញ្ចូលជាតិដែក។ អង្ករប្រមាណ៣ ០០០តោនត្រូវបានបញ្ចូលមីក្រូសារជាតិ
- បានផ្សព្វផ្សាយអំពីសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់នៅថ្នាក់ក្រោមជាតិបានចំនួន៩ខេត្ត
- បន្តការសិក្សាបញ្ចូលវីតាមីនបេ១ទៅក្នុងអំបិលអ៊ីយ៉ូដ ទាំងគុណភាពនិងភាពទទួលយកបានរបស់ប្រជាពលរដ្ឋ។

៣.៥៦- ក្រសួងផែនការបានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេស វិស័យឯកជននៅក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនៅមានកម្រិត
- ចំណេះ និងការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ (អំបិល អ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក អង្ករបញ្ចូលមីក្រូសារជាតិ) នៅមានកម្រិត
- ការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ(អំបិលអ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក អង្ករបញ្ចូលមីក្រូសារជាតិ) មិនទាន់បានទូលំទូលាយ
- វត្ថុធាតុដើមពុំមានលក់នៅក្នុងស្រុក មានតែនាំចូលពីក្រៅប្រទេស
- សហគមន៍អ្នកផលិតអំបិលប្រចាំខេត្តកំពត កែបត្រូវបានរំសាយ ក្រោយពីអត់មានសហគមន៍ផលិតករត្រូវទទួលខុសត្រូវរៀងៗខ្លួន ទាំងការបញ្ចូលជាតិអ៊ីយ៉ូដនិងរកទីផ្សារ ធ្វើឱ្យរយៈពេលចុងក្រោយនេះ ផលិតករមិនបញ្ចូលជាតិអ៊ីយ៉ូដក្នុងអំបិលមុនចែកចាយលើទីផ្សារ
- ពុំមានថវិកាគ្រប់គ្រាន់ដើម្បីពង្រីកនិងពង្រឹងសកម្មភាពលើការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារនៅកម្ពុជា។

## វិស័យទឹកស្អាត

៣.៥៧- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍សម្រេចបានសមិទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ក្រសួងបានយកចិត្តទុកដាក់អនុវត្តគោលនយោបាយឧបត្ថម្ភធនសម្រាប់ប្រជាពលរដ្ឋក្រីក្រដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានការប្រើប្រាស់ទឹកដែលមានតម្លៃថោកក្នុងកម្រិតអប្បបរមា ក្នុងនោះ ប្រជាពលរដ្ឋក្រីក្រចំនួន៣៥ ០០៦គ្រួសារបានទទួលនូវការឧបត្ថម្ភធនសម្រាប់ការតភ្ជាប់បណ្តាញទឹកស្អាត។ លើសពីនេះទៀត ក្រសួងបានកំណត់ថ្លៃលក់ទឹកស្អាតនិងចុះកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួល៧០០រៀល/ម៣ ហើយម្ចាស់ផ្ទះជួលលក់

ឱ្យកម្មករ កម្មការិនី សិស្ស និស្សិត ក្នុងតម្លៃ៨០០រៀល/ម³។ បច្ចុប្បន្ន សម្រេចតភ្ជាប់បណ្តាញទឹកស្អាតបានចំនួន៥ ៦៣០ផ្ទះ ដែលមានបន្ទប់ជួលចំនួន១២២ ២៩១បន្ទប់ សម្រេចបាន ១០០%

- បានបន្តពង្រឹងគុណភាពសេវាស្របតាមបុរេលក្ខខណ្ឌគោលចំនួន៤ គឺត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ
- បានបន្តការពិភាក្សាក្នុងក្របខ័ណ្ឌអន្តរក្រសួង ស្ថាប័ន ដើម្បីជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី"ការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា" ដែលបច្ចុប្បន្នកំពុងដាក់ឆ្លងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងការកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ និងតម្រូវការនៃកំណែទម្រង់លិខិតបទដ្ឋានគតិយុត្ត
- បានលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សលើវិស័យទឹកស្អាត ដោយមានវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីប្រតិបត្តិករនិងអាជីវករទឹកស្អាតឯកជន អំពីការគ្រប់គ្រងបច្ចេកទេសនិងជំនាញសំខាន់ផ្សេងៗទៀត ដូចជាជំនាញមេកានិកនិងអគ្គិសនី និងជំនាញគ្រប់គ្រងគម្រោង។

៣.៥៨- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ប្រភពទឹកនៅតំបន់មួយចំនួនទទួលរងនូវការបំពុល ដោយសារទឹកសំណល់ពីលំនៅឋាន វិស័យសេវាកម្ម កសិកម្មឧស្សាហកម្ម ។ល។
- កង្វះខាតមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងសិក្សាស្រាវជ្រាវលើវិស័យទឹកស្អាត
- ការងារមួយចំនួនដែលបានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ក្រោមជាតិនៅមិនទាន់បានបំពេញឱ្យរលូន ដោយសារកង្វះធនធានមនុស្សមានសមត្ថភាព ថវិកាមានកម្រិត និងមធ្យោបាយក្នុងការអនុវត្ត។

## ៣.៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

៣.៥៩- ក្រសួងកិច្ចការនារី សម្រេចបានសមិទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- យោងតាមលទ្ធផលនៃការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជា ឆ្នាំ២០១៩/២០២០ បានបង្ហាញថា អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីអាយុពី១៥-៦៤ឆ្នាំមាន៨៤,១% ហើយប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារអាយុពី១៥-៦៤ឆ្នាំ បែងចែកតាមវិស័យសេដ្ឋកិច្ច (១)ប្រាក់ឈ្នួលស្ត្រីក្នុងវិស័យកសិកម្ម៣៤,៥% (២)ប្រាក់ឈ្នួលស្ត្រីក្នុងវិស័យឧស្សាហកម្ម២៥,៩% និង(៣)ប្រាក់ឈ្នួលស្ត្រីក្នុងវិស័យសេវាកម្ម៣៩,៦%
- បានបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី ដោយផ្តោតលើការបណ្តុះបណ្តាលសហគ្រិនភាព ការចាប់ផ្តើមអាជីវកម្ម ការសិក្សាស្រាវជ្រាវ និងការពង្រឹងបណ្តាញសហគ្រិនស្ត្រី។ បច្ចុប្បន្ន មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី តាមរយៈភាពជាដៃគូជាមួយនឹង

សហគ្រិនសង្គមនិងភ្នាក់ងារបណ្ដុះបណ្ដាលកម្មវិធីចំនួន៣កំពុងអនុវត្ត (១)ការគាំទ្រដល់ស្ត្រីអាជីវករក្នុងការអភិវឌ្ឍអាជីកម្មមូលដ្ឋាន ចំណេះដឹងហិរញ្ញវត្ថុ និងឌីជីថល (២)ការសិក្សាស្រាវជ្រាវពីផលប៉ះពាល់យេនឌ័រ ជាពិសេស សហគ្រិនស្ត្រី ជាម្ចាស់ឬអ្នកគ្រប់គ្រងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ដែលទទួលរងផលប៉ះពាល់ពីកូវីដ-១៩ ដើម្បីកំណត់គោលនយោបាយគាំទ្រជាក់លាក់ (៣)គម្រោងស្ដីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីនិងសហគ្រិនភាពក្នុងភាពជាដៃគូជាមួយធនាគារជាតិនៃកម្ពុជា ក្នុងខេត្តគោលដៅចំនួន៤ គឺខេត្តស្ទឹងត្រែង ក្រចេះ ព្រះវិហារ និងសៀមរាប ជាពិសេសស្ត្រីនៅតាមសហគមន៍និងស្ត្រីជាសហគ្រិន

- បានអភិវឌ្ឍសមត្ថភាពលើជំនាញទំនាក់ទំនងជាមួយវិស័យឯកជននិងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានិងព័ត៌មាន ជំនាញការធ្វើអាជីវកម្ម ការគ្រប់គ្រងនិងចាត់ចែងថវិកា ការងារកសិកម្មចម្រុះ សិប្បកម្មតម្បាញរំពាក់ ផ្ដៅ ធ្វើអំបោស សេវាកម្មផ្ទះស្នាក់ ការសន្សំប្រាក់សហគ្រិនភាព ការកែច្នៃចំណីអាហារ អ៊ុតសក់ សម្អាងកាយ កាត់ដេរ ច្នៃម៉ូដ តម្បាញ ដល់មន្ត្រីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី មន្ទីរកិច្ចការនារី និងបន្តអភិវឌ្ឍសមត្ថភាពដល់សហគមន៍គោលដៅ រួមទាំងស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ក្មេងស្រីបោះបង់ចោលការសិក្សា និងស្ត្រីជនជាតិដើមភាគតិច សរុបចំនួន១៦ ៤២៥ នាក់ ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ
- បានសម្របសម្រួល បង្កើត និងដំណើរការបណ្ដាញសហគ្រិនស្ត្រីកម្ពុជា ជាតំណាងសហ-គ្រិនស្ត្រីប្រមូលផ្ដុំដោយតំណាងមកពីសមាគមនិងក្រុមស្ត្រីនៅក្នុងវិស័យធុរកិច្ចចំនួន៤ គឺសមាគមសហគ្រិនស្ត្រីកម្ពុជា សមាគមសហគ្រិនវ័យក្មេងកម្ពុជា សមាគមភ្នាក់ងារធ្វើដំណើរកម្ពុជា និងសភាឃុំពាណិជ្ជករកម្ពុជា។ សហគ្រិនស្ត្រីកម្ពុជា បានចូលរួមយ៉ាងសកម្មនៅក្នុងបណ្ដាញសហគ្រិនស្ត្រីអាស៊ាន ក្នុងនោះ ស្ត្រីជាសហគ្រិនកម្ពុជាចំនួន៤៣រូបទទួលបានពានរង្វាន់សហគ្រិនស្ត្រីឆ្នើមអាស៊ាន
- បានចុះកិច្ចព្រមព្រៀងភាពជាដៃគូរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៩-២០២៤) ជាមួយអង្គការវីឌូកម្ពុជាក្នុងការអនុវត្តគម្រោងស្ដីពីការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ក្មេងស្រី
- យុទ្ធសាស្ត្រនិងឯកសារបណ្ដុះបណ្ដាលស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន បានរៀបចំ និងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន៨(ខេត្តបាត់ដំបង សៀមរាប ព្រះសីហនុ រាជធានីភ្នំពេញ កណ្ដាល រតនគិរី ព្រៃវែង និងត្បូងឃ្មុំ)
- ឧបករណ៍ផ្សព្វផ្សាយ(កម្រិត១ កម្រិត២) ឧបករណ៍បណ្ដុះបណ្ដាលកំណត់គោលដៅនិងឧបករណ៍ឯកទេស(កម្រិត៣) ស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន បានបណ្ដុះបណ្ដាលដល់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបន្តផ្សព្វផ្សាយដល់សហគមន៍
- គោលការណ៍ណែនាំស្ដីពីដំណើរការទារកដ្ឋានរបស់ក្រសួងកិច្ចការនារី រៀបចំនិងដំណើការ
- ផែនការសកម្មភាពស្ដីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារនិងការមានផ្ទៃពោះវ័យជំទង់ បានអនុវត្តសាកល្បងនៅខេត្តរតនគិរី និងកំពុងពិនិត្យលទ្ធភាពពង្រីកនៅខេត្តផ្សេងទៀត(ខេត្តមណ្ឌលគិរី)

- កិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងសកលវិទ្យាល័យចំនួន៤ រួមមាន សកលវិទ្យាល័យភូមិន្ទភ្នំពេញ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សកលវិទ្យាល័យភូមិន្ទកសិកម្ម និងសកលវិទ្យាល័យកម្ពុជា បានបង្កើននិងដំណើរការ ប្រអប់ឯកសារនិងស្រាវជ្រាវស្តីពីយេនឌ័រ ដែលជាផ្នែកមួយនៃបណ្ណាល័យនិងការសិក្សា ស្រាវជ្រាវរបស់សកលវិទ្យាល័យ
- គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានយកចិត្ត ទុកដាក់ចំពោះការលើកកម្ពស់គុណតម្លៃនៃសីលធម៌សង្គម និងផ្តល់បទអន្តរាគមន៍រួម ចំណែកលើកកម្ពស់ការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិជនដែលមានពិការភាព និងសិទ្ធិ ដទៃទៀតក្នុងសង្គម
- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣(ឆ្នាំ២០១៩-២០២៣) បានអនុម័តនិងដាក់ឱ្យអនុវត្តជាផ្លូវការដោយរាជរដ្ឋាភិបាល និងមានការចូលរួមអនុវត្តពី គ្រប់ដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការផ្តល់សេវាការពារក្តីដល់ស្ត្រីនិងក្មេងស្រីក្រីក្រដែលរង គ្រោះដោយអំពើហិង្សា និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីក.ជ.ក.ស.មន្ត្រីភ្នាក់ងារនគរបាល យុត្តិធម៌ទាំង២៥រាជធានី ខេត្ត។ ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១ ក.ជ.ក.ស.បានពង្រីកការ ផ្តល់សេវាជំនួយផ្នែកច្បាប់នៅទូទាំង២៥រាជធានី ខេត្ត ដោយប្រើប្រាស់កញ្ចប់ថវិកាប្រចាំ ឆ្នាំនិងមិនគិតកម្រៃមានចំនួន២៨៩ករណី និងផ្តល់សេវាការពារក្តីតាមផ្លូវច្បាប់មានចំនួន ១៣០ករណី
- បានបង្កើតនិងកំពុងអនុវត្តសាកល្បងកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើ ហិង្សាទាក់ទងនឹងយេនឌ័រនៅមន្ទីរពេទ្យខេត្តចំនួន២ គឺខេត្តកំពង់ចាមនិងខេត្តស្ទឹងត្រែង
- បានរៀបចំយុទ្ធនាការ១៦ថ្ងៃ បំពាក់បូពណ៌សបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ទាំង ថ្នាក់ជាតិនិងទាំងថ្នាក់ក្រោមជាតិ ចំនួន៤១លើក
- សម្តេចតេជោនាយករដ្ឋមន្ត្រី បានជំរុញដល់ការផ្តល់សេវាជំនួយផ្នែកច្បាប់ដល់ស្ត្រីនិង ក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សានិងអំពើរំលោភសេពសន្ថវៈ តាមរយៈការផ្តល់ ប្រឹក្សា យោបល់ផ្លូវចិត្ត សេវាមេធាវីការពារក្តី និងសេវាផ្សេងៗ ក្រោមកិច្ចសហការ ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់កញ្ចប់ថវិការដ្ឋប្រចាំឆ្នាំ ចំនួន៥០០លាន រៀល ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះតាមផ្លូវច្បាប់
- បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវ ភេទ អំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ និងការកេងប្រវញ្ចនានា ព្រមទាំងការ ទប់ស្កាត់ការប្រើប្រាស់និងជួញដូរគ្រឿងញៀននៅថ្នាក់ភូមិនិងឃុំ ចំនួន៦៦លើក
- គ្រប់ក្រសួង ស្ថាប័ន បានយកចិត្តទុកដាក់បង្កើនចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រី និងតែង តាំងស្ត្រីក្នុងមុខតំណែងនិងរចនាសម្ព័ន្ធដឹកនាំទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបានកើន ឡើងជាបន្តបន្ទាប់ផ្អែកតាមការណែនាំរបស់ក្រសួងមុខងារសាធារណៈ និងអនុវត្តតាម

អនុសាសន៍គន្លឹះ១១ចំណុចរបស់រាជរដ្ឋាភិបាល សមាមាត្រស្ត្រីមានតួនាទីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈទាំងថ្នាក់ជាតិនិងក្រោមជាតិ(អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងប្រធានមន្ទីរ) មានការកើនឡើងពី១៣,២៥%ដល់១៤%នៅឆ្នាំ២០២០។ ចំណែកឯមន្ត្រីរាជការជាស្ត្រី បានកើនឡើងដល់៤១% នៅឆ្នាំ២០២០

- របាយការណ៍ជាតិស្តីពីវឌ្ឍនភាពការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង ក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីនៅកម្ពុជា(Beijing Declaration and Platform for Action) លើកទី២៥ បានរៀបចំនិងបានផ្ញើជូនអង្គការសហប្រជាជាតិដើម្បីដាក់បញ្ចូលទៅក្នុងធាតុចូលរួមក្នុងតំបន់
- ឯកសារប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាឆ្នាំ២០២១ បានរៀបចំនិងផ្សព្វផ្សាយ ដែលបានផ្តល់នូវព័ត៌មាននិងអនុសាសន៍គន្លឹះសម្រាប់អ្នកពាក់ព័ន្ធក្នុងការកំណត់វិធានការគោលនយោបាយ កិច្ចអន្តរាគមន៍និងកម្មវិធីនានា ដើម្បីបញ្ជ្រាបយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីតាមវិស័យ
- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ត្រូវបានតាក់តែងនិងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធនានា ដោយបញ្ចូលពីតម្រូវការថ្មីៗទាក់ទងនឹងយេនឌ័រក្នុងបរិបទកូវីដ-១៩
- ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ ត្រូវបានតាក់តែងនិងដាក់ឱ្យអនុវត្តសម្រាប់ក្រសួងនិងមន្ទីរកិច្ចការនារីរាជធានី ខេត្ត
- ក្រសួងកិច្ចការនារី បានផ្ទេរមុខងារចំនួន៣ (១)ការគ្រប់គ្រង និងប្រមូលទិន្នន័យស្ត្រី និងកុមារនៅតាមមូលដ្ឋាន (២)ការសម្របសម្រួលទប់ស្កាត់និងដោះស្រាយអំពើហិង្សាលើស្ត្រីនិងកុមារ និងការជួញដូរលើស្ត្រីនិងកុមារ និង(៣)ការអប់រំផ្សព្វផ្សាយអំពីសិទ្ធិស្ត្រីនិងកុមារ ដើម្បីលើកកម្ពស់សីលធម៌សង្គមនិងសមធម៌យេនឌ័រ ព្រមទាំងបានផ្ទេរមន្ត្រីសរុបចំនួន២៧៤រូប(បុរស១០រូប)ទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី តាមរយៈក្រសួង ស្ថាប័ន បានអភិវឌ្ឍសមត្ថភាពផ្សព្វផ្សាយនិងជំរុញការអនុវត្តអនុសញ្ញាស្តីពីការរើសអើងប្រឆាំងនឹងនារីភេទថ្នាក់តំបន់ ផ្តោតលើការអនុវត្តច្បាប់ជាតិពាក់ពន្ធ័នឹងស្ត្រី គោលនយោបាយជាតិ អនុសាសន៍គន្លឹះរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងអនុសញ្ញាCEDAW ដល់មន្ត្រីជំនាញ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។

៣.៦០- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងកិច្ចការនារីបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ដំណើរការរៀបចំ ផ្សព្វផ្សាយអំពីច្បាប់គោលនយោបាយ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានា មិនបានទៅតាមផែនការដែលបានគ្រោងទុក និងបានធ្វើឱ្យថយចុះនៃធនធានថវិកាប្រចាំឆ្នាំសម្រាប់ការអនុវត្តការងាររបស់ក្រសួងនិងមន្ទីរកិច្ចការនារី ទាំងថវិការដ្ឋ និងដៃគូអភិវឌ្ឍ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩

- ការចាប់យកជំនាញសម្រាប់ស្ត្រី ក្មេងស្រី និងផ្នត់គំនិតរបស់គ្រួសារនិងសង្គម ក្នុងការលើកទឹកចិត្តឱ្យស្ត្រីទទួលបានចំណេះដឹង ជំនាញពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម គណិតវិទ្យា និងតម្រូវការទីផ្សារការងារនិងសុវត្ថិភាពពាក់ព័ន្ធសេដ្ឋកិច្ចឌីជីថលមានកម្រិតទាបនៅឡើយ
- វិសមភាពយេនឌ័រក្នុងវិស័យសុខភាពនៅតែជាឧបសគ្គសម្រាប់ស្ត្រី ក្មេងស្រី និងស្ត្រីដែលស្ថិតក្នុងក្រុមជនងាយរងគ្រោះក្នុងការទទួលបានសេវាថែទាំសុខភាពមានគុណភាពសុវត្ថិភាព និងប្រសិទ្ធភាព នៅតាមមូលដ្ឋានសុខាភិបាល
- ផ្នត់គំនិតនិងឥរិយាបថគ្រួសារនិងសង្គមនៅបន្តរើសអើងលើតួនាទីស្ត្រី ក្នុងភាពជាអ្នកដឹកនាំ ដែលជាកត្តារារាំងដល់ការចូលរួមពេញលេញរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈនិងនយោបាយ។

៣.៦១- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ ដោយសហការជាមួយកាកបាទក្រហមកម្ពុជានិងអង្គការនានា ផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាស្បៀងនិងសម្ភារៈផ្សេងៗ ដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនរងគ្រោះនិងងាយរងគ្រោះ ប្រជាជនក្រីក្រ ទុរគតជន សរុបចំនួន១៤៩ ៩០៣គ្រួសារ
- ប្រជាជនក្រីក្រនិងងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ បានមកចុះឈ្មោះទទួលសេវាសរុបចំនួន៦៥២ ៤៨៤គ្រួសារ ដែលចំណាយថវិកាសរុបចំនួន១ ៤០៧ប៊ីលានរៀល ក្នុងនោះ គ្រួសារក្រីក្រកម្រិត១ចំនួន២៤០ ៧៨៣គ្រួសារ និងគ្រួសារក្រីក្រកម្រិត២ចំនួន៤១១ ៧០១គ្រួសារ
- កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋនិងគ្រួសារប្រជាពលរដ្ឋដែលមានការលំបាកផ្នែកជីវភាព ប្រជាពលរដ្ឋនិងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ដោយចាប់អនុវត្តពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១។ គិតមកដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ គ្រួសារដែលបានទទួលប្រាក់ឧបត្ថម្ភសរុបចំនួន៦១ ៦៧៨គ្រួសារ ចំណាយថវិកាសរុបចំនួន១៥ ៨៣៣,៤លានរៀល
- បានរៀបចំពិធីមីទ្ទីងអបអរសាទរខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៩
- បានរៀបចំនិងពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិកុមារ និងការពារឧត្តមប្រយោជន៍កុមារ
- បានរៀបចំនិងកំពុងអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩

- បានរៀបចំរបាយការណ៍លើកដំបូងនៃការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិជនពិការ របាយការណ៍វាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០១៤-២០១៨ និងរៀបចំឯកសារមួយចំនួនទៀត រួមមានផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព ២០១៩-២០២៣ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធ
- បានបង្កើតក្រុមការងារសកម្មភាពជនពិការតាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាសកម្មភាពជនពិការតាមរាជធានី ខេត្ត និងបានបណ្ដុះបណ្ដាល រៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងអំពីអនុសញ្ញាស្ដីពីសិទ្ធិជនពិការ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព
- បានបណ្ដុះបណ្ដាលវិជ្ជាជីវៈជូនជនពិការចំនួន២០៧នាក់ លើជំនាញកាត់ដេរសម្លៀកបំពាក់ និងកាបូប អេឡិចត្រូនិក ជួសជុលម៉ាស៊ីន អ៊ុតសក់ធ្វើមុខនិងសម្អាងការ ចម្លាក់ កសិកម្ម ជួសជុលទូរសព្ទ និងជំនាញគ្រប់គ្រងអាជីវកម្មនិងអនាម័យ
- បានផ្ដល់របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ចំនួន១៦ ៨០២ នាក់ ទៅតាម៣កម្រិត កម្រិត១ ឧបត្ថម្ភចំនួន១២ខែ កម្រិត២ ឧបត្ថម្ភចំនួន៦ខែ និងកម្រិត ៣ ឧបត្ថម្ភចំនួន៣ខែ ដោយមួយខែៗឧបត្ថម្ភចំនួន២០ ០០០រៀល ដោយក្នុងនោះ កម្រិត ១ មានចំនួន១១ ១៦៦នាក់ និងកម្រិត២ មានចំនួន៥ ៦៣៦នាក់
- បានរៀបចំនិងប្រកាសដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ ២០១៧-២០៣០
- បានចេញប្រកាសស្ដីពីលក្ខខណ្ឌនិងទម្រង់បែបបទនៃការស្នើសុំអនុញ្ញាតបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់ និងប្រកាសស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ការបង្កើតមជ្ឈមណ្ឌល និងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់
- បានរៀបចំទិវាមនុស្សចាស់កម្ពុជានិងមនុស្សចាស់អន្តរជាតិ ១តុលា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់មនុស្សវ័យចាស់
- បានបង្កើតសមាគមមនុស្សចាស់ចំនួន១ ៦៤៦ មានសមាជិកសរុបចំនួន២៩៤ ៤៤០នាក់ នៅតាម រាជធានី ខេត្តទាំង២៥
- បានបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់ ចំនួន១ ០២៣ មានសមាជិកសរុបចំនួន២៤ ៨០៨នាក់ ដែលបានជួយកែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់
- រាជរដ្ឋាភិបាលកម្ពុជាបានឧបត្ថម្ភថវិកាចំនួន៤ពាន់លានរៀលក្នុងមួយឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាពចាប់តាំងពីឆ្នាំ២០១៦
- បានរៀបចំបែបបទផ្ដល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការដែលត្រូវចូលនិវត្តន៍ចំនួន៥ ៨៨៥ នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន៤ ៧៤៩នាក់ និងបានផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត

- បានដំឡើងបន្ថែមប្រាក់សោធនប្រចាំខែតាមកម្រិតជូននិវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈជារៀងរាល់ឆ្នាំមកដល់ឆ្នាំ២០២១នេះ ប្រាក់របបសន្តិសុខសង្គមប្រចាំខែទាបបំផុតចំនួន៦៤ម៉ឺនរៀលក្នុងមួយខែ
- បានកែសម្រួលប្រាក់សោធនជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ រហូតមកដល់ឆ្នាំ២០២១ ប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់ចំនួន៦៤០ ០០០រៀលក្នុងមួយខែ
- បានផ្តល់បណ្ណថែទាំសុខភាពចំនួន១៣ ០០០បណ្ណ និងបណ្ណមូលនិធិសមធម៌ចំនួន៣៣ ០៧៩បណ្ណ ជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជន
- មូលនិធិជនពិការបានសហការជាមួយអង្គការដៃគូ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃជូនជនពិការចំនួន១៦៤ ០៦៩នាក់ ក្នុងនោះសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រចំនួន១១៣ ៧៩៧នាក់ និងស្តារលទ្ធភាពពលកម្មកាយសម្បទាបានចំនួន៥០ ២៧២នាក់ និងបានផ្តល់សេវាសហគមន៍ជូនជនពិការ ដូចជាការជួសជុលឧបករណ៍សិប្បនិម្មិតនិងរណប ការសម្របសម្រួលជូនជនពិការទៅទទួលសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការពិនិត្យនិងថែទាំសុខភាពសរុបចំនួន១៦ ៤៥៩នាក់
- បានផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យនិងថែទាំសុខភាព ជូនដល់ជនពិការក្រីក្រនៅតាមសហគមន៍បានចំនួន១៧ ៨៧៩នាក់ ដោយម្នាក់ៗទទួលបានថវិកា៣០ ០០០៛ និងបានសាងសង់ផ្ទះជូនគ្រួសារជនពិការក្រីក្រចំនួន២១ខ្នង។
- បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនឱ្យស្នាក់នៅមជ្ឈមណ្ឌលព្យាបាលស្តារនីតិសម្បទាចំនួន២០ ១៦៨នាក់ និងធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន១៩ ៨១៥នាក់
- បានអនុវត្តតាមអនុក្រឹត្យស្តីពីការជ្រើសរើសជនពិការចូលបម្រើការងារ និងបច្ចុប្បន្នជនពិការចំនួន៣ ០៩៥នាក់កំពុងបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ និងជនពិការចំនួន៣ ៨៩១នាក់កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាសវិស័យឯកជនចំនួន១០២
- បានដាក់ឱ្យប្រើប្រាស់ប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌនៃការចេញបណ្ណបើកបរយានយន្តសម្រាប់ជនពិការ រួមទាំងសៀវភៅគោលការណ៍ណែនាំស្តីពីជំនួយផ្នែកច្បាប់សម្រាប់ជនពិការ
- បានបើកវគ្គបណ្តុះបណ្តាលស្តីពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ
- បានសម្ពោធដាក់ឱ្យប្រើប្រាស់ជម្រាលគំរូក្នុងឃុំចំនួន២២ក្នុងខេត្តចំនួន៥ និងវីដេអូអប់រំស្តីពីបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ
- បាននិងកំពុងផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការ និងអ្នកនៅក្នុងបន្ទុកចំនួន១០២ ៥៥៥នាក់ និងអតីតយុទ្ធជនចំនួន១០២ ៦៦៨នាក់
- បានបង្កើតមជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៩

- បានសង្គ្រោះ អប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ថែទាំសុខភាពជូនជនអនាថាចំនួន៥ ៧៧១នាក់ ក្រៅពីសេវាខាងលើ ជនអនាថាចំនួន២ ២១៦នាក់ បានទទួលសេវាស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅក្នុងសហគមន៍។

៣.៦២- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទាបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម ដូចជាអត្ថប្រយោជន៍និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបបឬកម្មវិធីនីមួយៗនៅមានកម្រិត។ ការពង្រឹងសមត្ថភាពមន្ត្រីក៏ជាតម្រូវការចាំបាច់ដែលត្រូវបង្កើនឱ្យស្របតាមស្ថានភាពនិងតម្រូវការជាក់ស្តែង
- ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់សុខភាពសាធារណៈ សង្គម សេដ្ឋកិច្ច និងជីវភាពប្រជាជន។ ប្រជាជនជាច្រើនអត់ការងារធ្វើ បាត់បង់ចំណូលធ្លាក់ទៅក្នុងភាពក្រីក្រ ដែលជាបន្ទុកយ៉ាងធ្ងន់សម្រាប់រាជរដ្ឋាភិបាលក្នុងការស្តារនិងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និង
- កម្ពុជាមិនទាន់មានទិន្នន័យជាក់លាក់ស្តីពីកុមារកំព្រា កុមាររងាយរងគ្រោះ និងកុមារពិការ។

៣.៦៣- ក្រសួងផែនការ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានបង្កើតគណៈកម្មាធិការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ ដោយអនុក្រឹត្យចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានរដ្ឋមន្ត្រីក្រសួងផែនការជាប្រធាន ហើយក្រសួងផែនការកំពុងរៀបចំបង្កើតយន្តការស្ថាប័នដើម្បីតាមដាននិងជួយពន្លឿនការអនុវត្តការប្តេជ្ញាចិត្តក្រោយសន្និសីទកំពូលណៃរ៉ូប៊ី អំពីសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ ដែលបានប្រារព្ធធ្វើឡើងនៅឆ្នាំ២០១៩ នៅទីក្រុងណៃរ៉ូប៊ីនៃប្រទេសកេនយ៉ា
- បានរៀបចំរបាយការណ៍ស្តីពីស្ថានភាពភាគលាភប្រជាសាស្ត្រនិងភាគលាភយេនឌ័រនៅកម្ពុជា ឆ្នាំ២០២១ ដែលអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយនិងកម្មវិធីដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងអភិវឌ្ឍន៍
- បានបញ្ចប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការសកម្មភាព ២០១៩-២០២១ ដែលជាផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិប្រជាជន ២០១៦២០៣០- និងបានបន្តរៀបចំផែនការសកម្មភាព ២០២២-២០២៤ ដែលជាផែនការដំណាក់កាលទី៣ នៃគោលនយោបាយជាតិប្រជាជន ២០១៦២០៣០-។

៣.៦៤- ក្រសួងផែនការបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- សមត្ថភាពស្ថាប័ននៅមានកម្រិតក្នុងការដាក់បញ្ចូលបញ្ហាប្រជាជននិងឌីណាមិកប្រជា-សាស្ត្រទៅក្នុងផែនការអភិវឌ្ឍតាមវិស័យ
- ការយល់ដឹងអំពីបញ្ហាប្រជាជននិងការអភិវឌ្ឍនៅមានកម្រិតទាំងនៅថ្នាក់ជាតិនិងទាំងនៅថ្នាក់ក្រោមជាតិ

- ការសិក្សាស្រាវជ្រាវអំពីទំនាក់ទំនងបញ្ហាប្រជាជនជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជានៅមានកម្រិត
- ធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ដើម្បីបន្តអនុវត្តផែនការសកម្មភាពនៃគោលនយោបាយជាតិប្រជាជននៅមានកម្រិត។

## ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច

### ៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្លែកដឹកជញ្ជូន ថាមពល និងឌីជីថល

៣.៦៥- ក្រសួងសាធារណការនិងដឹកជញ្ជូនសម្រេចបានសមិទ្ធផលសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់មួយចំនួន ដូចជាច្បាប់ស្តីពីកំពង់ផែ ច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវទឹកនិងសមុទ្រ ច្បាប់ស្តីពីអាជីវកម្មដឹកជញ្ជូនផ្លូវគោក ច្បាប់ស្តីពីទឹកកខ្វក់ និងបានរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដូចជាអនុក្រឹត្យស្តីពីការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះនិងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ អនុក្រឹត្យស្តីពីការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះនិងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ ប្រកាសស្តីពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះគ្រប់ប្រភេទ ជាដើម
- បាននិងកំពុងប្រែក្លាយនិងងដំឡើងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការនិងដឹកជញ្ជូន
- បានតភ្ជាប់ទិន្នន័យជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពង្រឹងកំណែទម្រង់ការផ្តល់សេវាសាធារណៈ
- បានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្តល់សេវាសាធារណៈ នៅបណ្តាផ្សារទំនើបក្នុងរាជធានីភ្នំពេញ មានដូចជាAEON Mall, AEON Sen Sok, CHIPMONG NORO MALL និងនៅទីស្តីការក្រសួងថ្មី ព្រមទាំងនៅផ្សារទំនើបThe Heritage Walk ក្នុងខេត្តសៀមរាប
- បានអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពមុខងារសំខាន់ៗបន្ថែមក្នុងកម្មវិធីថែទាំផ្លូវ
- បានសហការបច្ចេកទេសរៀបចំកម្មវិធីMobile App យល់ដឹងពីទ្រឹស្តីនៃការបើកបរនិងច្បាប់ចរាចរណ៍ផ្លូវគោក ត្រួតពិនិត្យព័ត៌មានយានយន្តនិងបណ្ណបើកបរសម្រាប់មន្ត្រីសមត្ថកិច្ចប្រើប្រាស់
- បានរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការនិងដឹកជញ្ជូន
- បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្លូវថ្នល់
- បានសាងសង់ផ្លូវក្រវាត់ក្រុងទី៣ ប្រវែង៥២,៩៨៣គ.ម. ចាប់ពីសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល
- បានសាងសង់ផ្លូវល្បឿនលឿនតភ្ជាប់ពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ ប្រវែង ១៨៧,០៥គ.ម.

- បានតភ្ជាប់មុខតំណាស្ពានមិត្តភាពកម្ពុជា-ថៃ(ស្ទឹងបត់-បានណាងអៀង) និងសាងសង់អគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥
- គម្រោងធ្វើឱ្យប្រសើរឡើងវិញកំណាត់ផ្លូវជាតិលេខ២និងលេខ២២ ប្រវែង៧២,១៧គ.ម.
- គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងខេត្តព្រះសីហនុចំនួន១១ខ្សែប្រវែង ៥៩,១៦គ.ម. និងស្តារអូរប្រឡាយចំនួន៦ខ្សែ ប្រវែង២៧,១២គ.ម.
- គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវក្នុងខេត្តសៀមរាបចំនួន៣៨ខ្សែ ប្រវែងសរុប ១០៨,៧៤គ.ម.
- បានរៀបចំពិធីសម្ពោធបើកឱ្យប្រើប្រាស់គម្រោងស្ពានមិត្តភាពកម្ពុជា ជប៉ុន(ជ្រោយចង្វារទី១) គម្រោងផ្លូវជាតិលេខ៥៨ ប្រវែង១៧៤,១៦គ.ម. គម្រោងផ្លូវជាតិលេខ៥៥ ប្រវែង ១៨២,១៦គ.ម. និងគម្រោងស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រង់ ក្រូចឆ្មារ ប្រវែង១ ១៣១ម.
- បាននិងកំពុងអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការជាមួយប្រទេសចិន ជប៉ុន សាធារណរដ្ឋកូរ៉េ ថៃ ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក
- បានសិក្សាកែលម្អប្រព័ន្ធទឹកកខ្វក់និងទឹកភ្លៀង ស្ថិតក្នុងក្រុងស្ទឹងសែន ក្រុងបានលុង ក្រុងពោធិ៍សាត់ ក្រុងក្រចេះ ក្រុងស្ទឹងត្រែង ក្រុងសែនមនោរម្យ ក្រុងសំរោង ក្រុងសិរីសោភ័ណ ក្រុងប៉ៃលិន និងក្រុងច្បារមន
- បានលើកកម្ពស់សមត្ថភាពស្ថានីយប្រោះសម្អាតទឹកកាកសំណល់(៣០ ០០០ម$^{៣}$/ថ្ងៃ)
- បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយបញ្ហាទឹកជំនន់ ជីកស្តារប្រឡាយអូរឈើទាល ក្នុងខេត្តព្រះសីហនុ ប្រវែង១៦ ០០០ម.
- បានស្ថាបនាលូអ៊ុយបេតុងសរសៃដែកទំហំ ៦៥០ម.ម. x ៨០០ម.ម. សងខាងផ្លូវ ប្រវែងសរុប២ ០០០ម. ស្ថិតនៅផ្លូវជាតិលេខ៧៣ ក្នុងខេត្តក្រចេះ
- បានស្ថាបនាលូបេតុងសរសៃដែកមុខកាត់៨០០ម.ម. ប្រវែងសរុប៣ ៣០០ម. និងរ៉ឺហ្គាបេតុងចំនួន១១០កន្លែង ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦០ ខេត្តកំពង់ចាម
- បានធ្វើយុទ្ធនាការចំនួន២២លើក ដោយមានចែកមួកសុវត្ថិភាពកុមារ ស្ទីកឃ័រចំណាំងផ្លាត សៀវភៅច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ល។
- បានត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ចំនួន៣ ២៨៥ ១១៨គ្រឿង ក្នុងនោះ យានយន្តដែលត្រូវពិន័យមានចំនួន៥ ៦៦៧គ្រឿង
- បានត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស ចំនួន២៧៣ ២៤១គ្រឿង(មិនត្រូវតាមបច្ចេកទេសចំនួន៣៥ ៨៦០គ្រឿង)
- បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដោយប្រើប្រាស់បច្ចេកវិទ្យាកាម៉េរ៉ាឆ្លាតវៃនិងជញ្ជីងស្វ័យប្រវត្ត ដំណើរការសាកល្បងចំនួន៣ស្ថានីយជញ្ជីង (ថ្នល់កែង ព្រែកឯង និងព្រែកស្តី)
- បានជំរុញការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជានិងវៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០០៩ តាមរយៈការបង្កើតច្រកផ្លូវទឹកអន្តរជាតិថ្មី កោះរកា ខេត្តព្រៃវែង ព្រមទាំងតាមដានលើការសម្របសម្រួលនីតិវិធីចេញចូលនៅតាមច្រកព្រំដែន

- បានពង្រឹងគុណភាពផ្តល់សេវាសាធារណៈលើការងារចុះបញ្ជីជលយាន និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ផ្តល់បណ្ណបើកបរ និងសេវាផ្សេងៗទៀតដែលពាក់ព័ន្ធ និងជំរុញការអភិវឌ្ឍនិងគ្រប់គ្រងយានដ្ឋាននាវា
- បានសាងសង់ទីលានស្តុកកុងតឺន័រតំបន់D ទំហំ២៨ ០០០ម² និងទីលានក្រាលថ្មចម្រុះស្តុកសំបកកុងតឺន័រតំបន់សេដ្ឋកិច្ចពិសេស
- បានអនុវត្តគម្រោងអភិវឌ្ឍន៍ចំណតផែកុងតឺន័រថ្មីប្រវែង៣៥០ម. ជម្រៅទឹក១៤,៥០ម. (ឆ្នាំ២០១៩-២០២៤) អាចឱ្យនាវាផ្ទុកកុងតឺន័រ៥ ០០០TEU និងនាវាមានចំណុះផ្ទុក ៦០ ០០០ DWT ចូលចតផ្ទេរ ផ្ទុកបាន
- បានពង្រីកហេដ្ឋារចនាសម្ព័ន្ធនៅចំណតផែកុងតឺន័រLM១៧ ដំណាក់កាលទី៣
- បានអភិវឌ្ឍចំណតផែរណបពហុបំណងបន្ថែមតាមដងទន្លេ
- បានបញ្ចុះតម្លៃសេវាកម្មនិងបង្កើតសេវាកម្មជាកញ្ចប់ជូនអតិថិជន

៣.៦៦- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងសាធារណការនិងដឹកជញ្ជូនបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យរាំងស្ទះដល់ការអនុវត្តគម្រោងមួយចំនួន
- ខ្វះធនធានមនុស្សដែលមានសមត្ថភាពតាមវិស័យដើម្បីចូលរួមអនុវត្តការងារ
- ទឹកជំនន់កម្រិតខ្ពស់កើតឡើងជាញឹកញាប់ ព្រមទាំងមានភ្លៀងធ្លាក់ច្រើនបណ្តាលឱ្យប៉ះពាល់ដល់គុណភាពគ្រឹះផ្លូវថ្នល់
- ការដឹកលើសទម្ងន់កំណត់ដែលបណ្តាលឱ្យផ្លូវឆាប់ខូច
- ការទន្ទ្រានកាន់កាប់ដីចំណីផ្លូវខុសច្បាប់ នៅតាមបណ្តោយផ្លូវជាតិនិងផ្លូវខេត្តមួយចំនួន
- មិនមានផ្ទៃដីបម្រុងទុកសម្រាប់ការសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់
- ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់នៅតាមបណ្តារាជធានី ខេត្តនានានៅមានកម្រិត
- មិនមានការត្រួតពិនិត្យគុណភាពត្រឹមត្រូវលើមន្ទីរពិសោធន៍សំណង់។

៣.៦៧- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានធ្វើទំនើបកម្មការនាំផ្លូវហោះហើរដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណប នៅអាកាសយានដ្ឋានអន្តរជាតិទាំងបី ដោយកាត់បន្ថយបាននូវពេលវេលា រយៈចម្ងាយហោះហើរនិងថ្លៃដើមនៃការហោះហើរ
- បានផ្តល់អាជ្ញាបណ្ណផ្នែកអាកាសយានិក ចំនួន១០ក្រុមហ៊ុនក្នុងឆ្នាំ២០១៩ ចំនួន១០ក្រុមហ៊ុនក្នុងឆ្នាំ២០២០ និងចំនួន៩ក្រុមហ៊ុននៅឆ្នាំ២០២១
- បានផ្តល់អាជ្ញាបណ្ណវិស្វករថែទាំបច្ចេកទេសអាកាសយាន ចំនួន១១ក្រុមហ៊ុនក្នុងឆ្នាំ២០១៩ ចំនួន១២ក្រុមហ៊ុនក្នុងឆ្នាំ២០២០ និងចំនួន២ក្រុមហ៊ុននៅឆ្នាំ២០២១
- បានបង្កើតផ្នែកអ្នកបញ្ជាចរាចរណ៍ដែនអាកាស ចំនួន៦ក្រុមហ៊ុនក្នុងឆ្នាំ២០១៩ ចំនួន៦ក្រុមហ៊ុនក្នុងឆ្នាំ២០២០ និងចំនួន៦ក្រុមហ៊ុននៅឆ្នាំ២០២១

- បានធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា ផ្នែកសន្តិសុខ(CCAR Part-17) តាមការណែនាំរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ
- បានរៀបចំសេចក្តីព្រាងកម្មវិធីជាតិកិច្ចសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស
- បានពិនិត្យនិងកែសម្រួលកម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខ
- បានចុះហត្ថលេខាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ចុះហត្ថលេខាអនុស្សរណៈនៃការយោគយល់ និងឯកភាពជាគោលការណ៍ខ្លឹមសារនៃកិច្ចព្រមព្រៀង បានចំនួន៤៧ប្រទេស សម្រាប់កិច្ចព្រមព្រៀងទ្វេភាគី
- បានចុះហត្ថលេខាកិច្ចព្រមព្រៀងពហុភាគីអាស៊ានស្តីពីការងារដឹកជញ្ជូនតាមផ្លូវអាកាស និងសម្របសម្រួលការងារបច្ចេកទេសពាក់ព័ន្ធវិស័យអាកាសចរស៊ីវិល និងកំពុងរង់ចាំការផ្តល់សច្ចាប័នពីរដ្ឋសភាជាតិ
- បានដំឡើងឧបករណ៍ផ្តល់ទិសដៅរន្ទះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ អាកាសយានដ្ឋានស្ទឹងត្រែង និងអាកាសយានដ្ឋានកោះកុង បានចំនួន៦ស្ថានីយ។
- បានបង្កើតនិងបែងចែកមជ្ឈមណ្ឌលគ្រប់គ្រងចរាចរណ៍ដែនអាកាស ជាពីរដើម្បីសម្រួលការគ្រប់គ្រងលំហូរចរាចរណ៍ដែនអាកាសឱ្យបានកាន់តែល្អ និងកាត់បន្ថយបន្ទុកការងាររបស់តម្រួតចរាចរណ៍ដែនអាកាស
- បានបំពាក់កាំមេរ៉ាសុវត្ថិភាពនិងម៉ាស៊ីនកត់ត្រាគ្រប់គ្រងម៉ោងធ្វើការនិងវត្តមានមន្ត្រីព្យាករអាកាសធាតុនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ
- បានអភិវឌ្ឍរចនាសម្ព័ន្ធអាកាសយានដ្ឋាន ដូចជាការចុះធ្វើអធិការកិច្ច ការជួសជុលផ្លូវបរ និងចំណតយន្តហោះ ជាដើម។

**តារាង៣.១៥ : ចំណូលបានពីការផ្តល់សេវាកម្មនាំផ្លូវហោះហើរ(ហោះរំលងនិងនាំផ្លូវចុះចត)**

(ឯកតាដុល្លារអាម៉េរិក)

| ប្រភព | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|
| CATS | ២៣ ២៧០ ០៥៣ | ១២ ០២៥ ២១២ | ២ ៣៣៥ ៩២៤ |
| SCA | ៦៧២ ៤៧៤ | ៦៧៣ ៥៧៧ | (*) |

(*) ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនSCA បានបង្វិលថវិកាជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រភព : រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**តារាង៣.១៦ : អាកាសយានដ្ឋានអន្តរជាតិសាងសង់ថ្មី**

| អាកាសយានដ្ឋាន | ចាប់ផ្តើម | ពេលបញ្ចប់ | ចំណាយសាងសង់ (ដុល្លារអាម៉េរិក) |
|---|---|---|---|
| ភ្នំពេញថ្មី | ឧសភា ២០១៩ | ឧសភា ២០២៣ | ១ ៥០០ ០០០ ០០០ |
| សៀមរាបថ្មី | មីនា ២០២០ | តុលា ២០២៣ | ៨៨០ ០០០ ០០០ |
| តារាសាគរ | ២០១៧ | មិថុនា ២០២២ | ២០០ ០០០ ០០០ |

៣.៦៨- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ការប្រែប្រួលអាកាសធាតុនៅលើពិភពលោក បញ្ហារន្ទះ គឺជាបញ្ហាប្រឈមរបស់ឧបករណ៍វិទ្យុទាក់ទង វិទ្យុនាំផ្លូវ និងឃ្លាំមើល បើទោះបីជាយើងមានឧបករណ៍ការពាររន្ទះល្អយ៉ាងណាក៏ដោយ
- ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកជំនាញបច្ចេកទេសសំខាន់ៗ(ទាំងក្នុងនិងក្រៅប្រទេស) មិនបានរៀបចំនិងឆ្លើយតបទៅតាមផែនការបណ្តុះបណ្តាលដោយសារវិបត្តិកូវីដ-១៩
- ពុំមានការដោះស្រាយឱ្យបានច្បាស់លាស់និងទាន់ពេលវេលាចំពោះការឆ្លងរំខានពីសំណាក់ស្ថានីយវិទ្យុផ្សាយសំឡេងFM broadcasting station ចូលប្រេកង់បញ្ជាហោះហើរពីក្រសួងពាក់ព័ន្ធ(ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍)
- មិនទាន់បានបញ្ចូលប្រព័ន្ធឧបករណ៍វិទ្យុឃ្លាំមើលជំនាន់ក្រោយដែលមានឈ្មោះថា Multilateration and ADSB Ground station (MAGS) ទៅក្នុង Cambodia AIP នៅឡើយ
- ខ្វះខាតបទប្បញ្ញត្តិបច្ចេកទេសនិងបទដ្ឋានគតិយុត្តមួយចំនួនរបស់វិស័យអាកាសចរស៊ីវិលដែលចាំបាច់ត្រូវបន្តរៀបចំពិនិត្យនិងធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំទៅតាមតម្រូវការរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ ដែលបទប្បញ្ញត្តិទាំងអស់នោះ រួមមានLEG, ORG, AIR, PEL, OPS, DGs, ANS, AIG, AGA
- ការបណ្តុះបណ្តាលនៅក្រៅប្រទេស ដែលមានរយៈពេលលើសពីរបបកំណត់(រយៈពេល ២សប្តាហ៍ ៤សប្តាហ៍ ៣ខែ ៦ខែ ឬរហូតដល់១ឆ្នាំ) មិនអាចអនុវត្តបាន ដូចមានចែងក្នុងអនុក្រឹត្យស្តីពីការផ្តល់របបបេសកកម្ម បានកំណត់ឱ្យរយៈពេលត្រឹម៩យប់ ១០ថ្ងៃ
- ខ្វះសម្ភារៈឧបករណ៍ និងសម្ភារៈបច្ចេកទេស សម្រាប់ប្រតិបត្តិការនៃការផ្តល់សេវាកម្មលើការរុករកនិងសង្គ្រោះ។

៣.៦៩- ក្រសួងរ៉ែនិងថាមពលសម្រេចបានសមិទ្ធផលសំខាន់ៗមួយចំនួនទាក់ទងនឹងវិស័យថាមពលដូចខាងក្រោម៖

- បានធ្វើការសិក្សាសក្តានុពលនៃប្រភពថាមពលវារីអគ្គិសនីចំនួន១២កន្លែងបន្ថែមទៀត និងប្រភពថាមពលខ្យល់នៅក្នុងខេត្តចំនួន៦(មណ្ឌលគិរី កំពត កំពង់ស្ពឺ ព្រះសីហនុ កែប និងកំពង់ឆ្នាំង) ព្រមទាំងការសិក្សានិងស្វែងយល់អំពីការនាំចូលLNG ដើម្បីផលិតថាមពលអគ្គិសនីនាពេលអនាគត។ បានសិក្សាផែនការមេចំនួន២ គឺ ទី១)ផែនការមេបន្ទាន់សិក្សាដោយក្រុមហ៊ុនChugoku មកពីប្រទេសជប៉ុន និងទី២)ផែនការមេរយៈពេលវែងសិក្សាដោយក្រុមហ៊ុនIES មកពីអូស្ត្រាលី ដើម្បីកំណត់ចក្ខុវិស័យនៃការអភិវឌ្ឍថាមពលអគ្គិសនីនៅកម្ពុជា(ឆ្នាំ២០២១-២០៤០)
- បានពិនិត្យនិងរៀបចំគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល និងរៀបចំការអនុវត្តគម្រោងប្រសិទ្ធភាពថាមពលនិងសន្សំសំចៃថាមពល

- បានរៀបចំបទដ្ឋានបច្ចេកទេសអគ្គិសនី រួមមាន ១) ស្តង់ដារៀបចំខ្សែបណ្តាញនិងសុវត្ថិភាពអគ្គិសនីក្នុងអគារនិងលំនៅឋាន និងបទដ្ឋាននៃការបិទស្លាកសញ្ញាប្រសិទ្ធភាពថាមពលលើឧបករណ៍អគ្គិសនី ២)សេចក្តីណែនាំបច្ចេកទេសផលិតបង្គោលអគ្គិសនីតង់ស្យុងមធ្យម និងតង់ស្យុងទាប ៣)សេចក្តីណែនាំបច្ចេកទេសនៃការប្រើប្រាស់ប្រភេទបង្គោលតាមទីតាំង និង ៤)សេចក្តីណែនាំបច្ចេកទេសប្រើប្រាស់កាបកប់ក្រោមទឹក
- បានរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃថាមពលបរមាណូស៊ីវិល។

៣.៧០- គិតត្រឹមខែមិថុនា ឆ្នាំ២០២១នេះ សមិទ្ធផលសម្រេចបាននៅក្នុងការអភិវឌ្ឍសមត្ថភាពផលិត បញ្ជូនចែកចាយនិងការភ្ជាប់បណ្តាញអគ្គិសនី ទទួលបាននូវលទ្ធផលតាមគោលដៅនៃការអភិវឌ្ឍនីមួយៗដូចខាងក្រោម៖

- ការអភិវឌ្ឍប្រភពអគ្គិសនីបានកើនឡើងពី២ ៩៩៨,៩៧មេហ្គាវ៉ាត់ ដល់៣.៨៩៦,៧៧មេហ្គាវ៉ាត់ ក្នុងនោះ ប្រភពផលិតអគ្គិសនីក្នុងស្រុកកើនឡើងពី២ ៣៧២,២២មេហ្គាវ៉ាត់ ដល់២ ៩១៦,០២ មេហ្គាវ៉ាត់ ធ្វើឱ្យការនាំចូលអគ្គិសនីកើនឡើងពី៦២៦,៧៥មេហ្គាវ៉ាត់ ដល់៩៨០,៧៥ មេហ្គាវ៉ាត់
- ការអភិវឌ្ឍខ្សែបញ្ជូននិងអនុស្ថានីយបន្ថែម រហូតដល់ពាក់កណ្តាលឆ្នាំ២០២១ កម្ពុជាមានខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ប្រវែង៣ ៣៧៥,៣២គីឡូម៉ែត្រ និងអនុស្ថានីយចំនួន ៤៦កន្លែង ដែលគ្របដណ្តប់ផ្ទាល់ចំនួន២៤រាជធានី ខេត្ត នៅសល់ខេត្តចំនួន១ប៉ុណ្ណោះ ដែលពុំទាន់មានអនុស្ថានីយផ្តល់ពីប្រភពនៅក្នុងខេត្តផ្ទាល់នៅឡើយ គឺខេត្តប៉ៃលិន
- ការអភិវឌ្ឍខ្សែបណ្តាញតង់ស្យុងមធ្យមប្រវែង៣៧ ១៦១គីឡូម៉ែត្រ ត្រង់ស្វូម៉ាទ័រចែកចាយចំនួន២១ ៧០៨គ្រឿង និងខ្សែតង់ស្យុងទាប ប្រវែង៤០ ៥៩២គីឡូម៉ែត្រ ដែលបានគ្របដណ្តប់លើភូមិចំនួន១៣ ៧៩៨ភូមិ នៃចំនួនភូមិសរុប១៤ ១៦៨ ទូទាំងប្រទេសត្រូវជា៩៧,៥៣%
- ការភ្ជាប់ចរន្តឱ្យអ្នកប្រើប្រាស់ចំនួន២,៩១លានខ្នងផ្ទះនៃចំនួនខ្នងផ្ទះសរុប៣,៥៩លានខ្នងផ្ទះ ស្មើនឹង៨៤,៤%ទូទាំងប្រទេសបានភ្ជាប់អគ្គិសនីប្រើប្រាស់រួច
- អនុគ្រោះថ្លៃលក់អគ្គិសនីឱ្យលំនៅឋានដែលប្រើប្រាស់ថាមពលមិនលើសពី១០គីឡូវ៉ាត់ម៉ោង ក្នុងមួយខែ ឱ្យបង់ថ្លៃ៣៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង លំនៅឋានដែលប្រើប្រាស់ពី១១ ដល់៥០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ឱ្យបង់ថ្លៃ៤៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង និងលំនៅឋាន ដែលប្រើប្រាស់ពី៥១ដល់២០០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ឱ្យបង់ថ្លៃ៦១០រៀលក្នុងមួយ គីឡូវ៉ាត់ម៉ោង ព្រមទាំងការប្រើប្រាស់អគ្គិសនីសម្រាប់ធ្វើកសិកម្មដែលប្រើចាប់ពីម៉ោង៩ យប់រហូតដល់ម៉ោង៧ព្រឹក ដែលឱ្យបង់ថ្លៃ៤៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង និងសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅជនបទឱ្យបង់ថ្លៃត្រឹមតែ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ការពង្រីកខ្សែបណ្តាញអគ្គិសនីដោយតម្លៃទាបជូនកម្មករ និយោជិត សិស្ស និស្សិត នៅតាមផ្ទះបន្ទប់ជួល បានចំនួន៣៤៩៨៥៨បន្ទប់ជួល។

## តារាង៣.១៧ : សូចនាករវិស័យថាមពល

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | | ពាក់កណ្ដាលឆ្នាំ ២០២១ |
|---|---|---|---|---|---|---|
| | | ជាក់ស្ដែង | ជាក់ស្ដែង | ផែនការ | ជាក់ស្ដែង | |
| បរិមាណផ្គត់ផ្គង់ថាមពលអគ្គិសនី | លាន គម៉.វ. | ៩ ៧៣៨,៨ | ១១ ៧៣៧,៩០ | ១៣ ៥០៨,៣ | ១២ ៤០០,៧៥ | ៦ ៣៧០,៧៥ |
| សន្ទស្សន៍នៃភូមិដែលបានសាងសង់ផ្គត់ផ្គង់អគ្គិសនី | % | ៨៦,៨៥ | ៩៤,០៨ | ៩៧,២៨ | ៩៧,៣៩ | ៩៧,៥៣ |
| បរិមាណប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ប្រជាជនម្នាក់ | គ.វ.ម./ ១នាក់ | ៥៩៩ | ៧២៨,៩២ | ៨០៨ | ៨១១,៧៣ | ៤០២,២៤ |
| សន្ទស្សន៍នៃខ្នងផ្ទះដែលបានភ្ជាប់ចរន្តអគ្គិសនី | % | ៧២,១៦ | ៧៧,៨៧ | ៧៦,០០ | ៨១,០៦ | ៨៤,៤០ |
| សន្ទស្សន៍នៃការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ | % | ៤៩,៤៦ | ៤៨,៥២ | ≥៣៣ | ៤៥,២៤ | ៣៩,៨៧ |
| ប្រវែងខ្សែបណ្ដាញបញ្ជូនជាតិ១១៥/ ២៣០/៥០០គីឡូវ៉ុល | គ.ម. | ២ ១៤១ | ២ ២៦៧,៥៥ | ២ ៧៨២,១៣ | ៣ ១២៩,៨៣ | ៣ ៣៧៥,៣២ |
| រៀបចំបទដ្ឋានបច្ចេកទេសនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខសុវត្ថិភាព និងការពារសុវត្ថិភាពនៃសារធាតុវិទ្យុសកម្ម និងបរមាណូ | ឯកសារ | _ | _ | ១ | ១ | ១ |
| រៀបចំបទដ្ឋានបច្ចេកទេសនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុវត្ថិភាពអគ្គិសនីគោលនយោបាយប្រសិទ្ធភាពថាមពលស្លាកសញ្ញានិងការគ្រប់គ្រងថាមពល | ឯកសារ | _ | _ | ១ | ១ | ១ |

ប្រភព : ក្រសួងរ៉ែនិងថាមពល

៣.៧១- ទន្ទឹមនឹងវឌ្ឍនភាពដូចបានរំលេចខាងលើ ក្រសួងរ៉ែនិងថាមពលបាននិងកំពុងជួបប្រទះនូវបញ្ហាប្រឈមធំៗមួយចំនួន ដូចខាងក្រោម៖

- ភូមិដែលនៅសល់ចំនួន៣៥០ភូមិ ដែលពុំទាន់មានបណ្ដាញអគ្គិសនី បញ្ហារអាក់រអួលគុណភាពនៃការផ្គត់ផ្គង់អគ្គិសនី យកថ្លៃផ្សេងៗលើសពីគោលការណ៍កំណត់ ប្រជាពលរដ្ឋមានមន្ទិលសង្ស័យលើចំនួនប្រើប្រាស់និងលើនាឡិកាស្ទង់ និងភ្ជាប់ចរន្តអគ្គិសនីសម្រាប់ធុរកិច្ច
- ការយល់ដឹងលើសន្តិសុខនិងសុវត្ថិភាពបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មនៅមានកម្រិតនៅឡើយដែលតម្រូវឱ្យមានការផ្សព្វផ្សាយ បណ្ដុះបណ្ដាលឱ្យកាន់តែទូលំទូលាយក្នុងចំណោមស្ថាប័នពាក់ព័ន្ធនឹងធុរកិច្ច។

៣.៧២- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សម្រេចបានសមិទ្ធផលសំខាន់មួយចំនួនដូចខាងក្រោម៖

- បានជំរុញនិងបង្កើនលទ្ធភាពនៃការផ្ដល់សេវាប្រៃសណីយ៍ឱ្យកាន់តែទូលំទូលាយប្រកបដោយគុណភាពនិងមានទំនុកចិត្ត។ ជាក់ស្ដែង ការពង្រីកបណ្ដាញប្រៃសណីយ៍បានកើនឡើងដល់២១៦ទីតាំង(ធៀបនឹង៩៤ទីតាំងក្នុងឆ្នាំ២០១៨) ក្នុងនោះ ប្រៃសណីយ៍កម្ពុជាមានសាខាចំនួន៥៧ និងក្រុមហ៊ុនឯកជនផ្ដល់សេវាបញ្ញើឆាប់រហ័សចំនួន៥១(ឆ្នាំ២០១៨មានតែ៣៤ក្រុមហ៊ុន) ដែលមានសាខាចុះបញ្ជីសរុប១០៨ កំពុងធ្វើអាជីវកម្មនៅទូទាំងប្រទេស។ ជាលទ្ធផល សូចនាករសំខាន់ពីរដូចបង្ហាញក្នុងតារាងខាងក្រោម ត្រូវបានលើកកម្ពស់ក្នុងចន្លោះពីឆ្នាំ២០១៩ ពាក់កណ្ដាលឆ្នាំ២០២១

## តារាង៣.១៨ : សូចនាករវិស័យប្រៃសណីយ៍និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|---|---|
| អត្រាអ្នកប្រើប្រាស់សេវាប្រៃសណីយ៍ | ក្នុង១០០ នាក់ឆ្នាំ/ | ១០,០ | ៩,៣ | ១០,២ |
| រង្វង់បម្រើសេវា | គ.ម$^{២}$/ការិ. | ១ ០៤០ | ៩២៣ | ៨៣៨ |
| ចំនួនប្រជាជនដែលមួយការិអាចទទួលបម្រើសេវា . | នាក់ការិ/. | ២០១ ១៦៤ | ១៧៤ ១៨៦ | ១៤៥ ៥៥២ |

- ទោះបីមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ការប្រើប្រាស់សេវាទូរសព្ទចល័ត អ៊ិនធឺណិតនិងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ត្រូវបានពង្រឹងនិងពង្រីកយ៉ាងឆាប់រហ័ស ដែលចំនួននេះកើនលើសគោលដៅព្យាករណ៍តាមបណ្ដាឆ្នាំ។ នៅក្នុងតំបន់ជនបទ ប្រជាជនអាចប្រើសេវា 2G3Gឬ4Gនៅលើទូរសព្ទដៃរបស់ពួកគាត់ ក្នុងនោះ បណ្ដាញទូរសព្ទចល័តជំនាន់ទី៤ (4G) បានផ្ដល់សេវាគ្របដណ្ដប់ដល់ប្រជាជនប្រមាណ៩២% ហើយបណ្ដាញទូរសព្ទចល័តជំនាន់ទី៥(5G) ត្រូវបានដាក់ឱ្យធ្វើការសាកល្បងផងដែរ។ ជាលទ្ធផល សូចនាករសេវាទូរគមនាគមន៍មូលដ្ឋានសំខាន់ពីរ ដូចបង្ហាញក្នុងតារាងខាងក្រោម បានឆ្លុះបញ្ចាំងពីវឌ្ឍនភាពក្នុងរយៈពេលពីឆ្នាំ២០១៩ ដល់ពាក់កណ្ដាលឆ្នាំ២០២១

## តារាង៣.១៩ : អត្រាអ្នកប្រើប្រាស់សេវាទូរសព្ទនិងសេវាអ៊ិនធឺណិតសរុប ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|---|---|
| **អត្រាអ្នកប្រើប្រាស់សេវាទូរសព្ទសរុប** | | | | |
| ទូរសព្ទចល័ត | ក្នុងប្រជាជន១០០នាក់ | ១៣៣,០៧ | ១២៦,១៩ | ១២២,៨៤ |
| ទូរសព្ទអចល័ត | ក្នុងប្រជាជន១០០នាក់ | ០,៣៥ | ០,៣០ | ០,២៦ |
| **អត្រាអ្នកប្រើប្រាស់សេវាអ៊ិនធឺណិតសរុប** | | | | |
| អ៊ិនធឺណិតចល័ត | ក្នុងប្រជាជន១០០នាក់ | ៩៩,០០ | ៩៨,៩៥ | ១០៣,៧៨ |
| អ៊ិនធឺណិតអចល័ត | ក្នុងប្រជាជន១០០នាក់ | ១,៣៨ | ១,៧២ | ១,៨២ |

- បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវបានលើកកម្ពស់តាមរយៈការរៀបចំសេវ្របករណ៍វិបសាយ សេវ្របករណ៍អ៊ីមែល និងសេវ្របករណ៍គ្រប់គ្រងអាសយដ្ឋានអាយភី ដោយផ្ដល់

សេវាបង្ហោះគេហទំព័រចំនួន២៣ ប្រព័ន្ធអ៊ីមែលចំនួន១១ ចុះឈ្មោះអាសយដ្ឋានអាយភីចំនួន ១៩ ជូនក្រសួង ស្ថាប័ន។ ផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបានឆ្លើយតបរបាយការណ៍អំពីឧប្បត្តិហេតុចំនួន១៦៩ករណី ភាគច្រើនទទួលបានពីក្រសួង ស្ថាប័ន ក្រុមហ៊ុន ធនាគារនៅក្នុងប្រទេសកម្ពុជា និងក្រុមឆ្លើយតបបន្ទាន់នៃបញ្ហាកុំព្យូទ័ររបស់ប្រទេសក្នុងតំបន់និងពិភពលោក ដូចជាប្រទេសថៃ អេស្ប៉ាញ ហ្វាំងឡង់ គុយបា កាហ្សាក់ស្ថាន ព័រទុយហ្គាល់ ជប៉ុន រុស្ស៊ី អេស្តូនី ហ្វីលីពីន លីទុយអានី អំពីករណីដូចជាការវាយប្រហារ Distribute Denial of Service (DDoS) អ៊ីមែលនិងហ្វេសប៊ុកបោកបញ្ឆោតលក់ទំនិញតាមអនឡាញ វិបសាយផ្ទុកតំណភ្ជាប់ក្លែងបន្លំ មេរោគ“Emotet” និងមេរោគ“Avalanche” រាលដាលក្នុងប្រទេសកម្ពុជាជាដើម។

**តារាង៣.២០ : សូចនាករវិស័យប.គ.ព.និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១**

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|
| ផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រ ដល់ក្រុមហ៊ុនប្រកបអាជីវកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ចំនួន | ៧២ | ១៣០ | ៥៥ |
| តភ្ជាប់និងជួសជុលខ្សែកាបអុបទិកជូនក្រសួង ស្ថាប័ន | គីឡូម៉ែត្រ | ៩,៨០ | ១៦,៤០ | ២០,៩៣ |

ប្រភព : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថលនិងអក្ខរកម្មឌីជីថល ដល់មន្ត្រីរាជការតាមក្រសួង ស្ថាប័ន ព្រមទាំងបញ្ជ្រាបការយល់ដឹងអំពីសារប្រយោជន៍នៃការប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍ឆ្លាតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតំបន់ជនបទសរុបប្រមាណ៨ ៤២១នាក់
- បានស្រាវជ្រាវលើបច្ចេកវិទ្យាឌីជីថល ដូចជាបច្ចេកវិទ្យាភាសានិងបញ្ញាសិប្បនិម្មិត និងចូលរួមកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីឌីជីថល និងជំរុញនវានុវត្តន៍ឌីជីថល តាមរយៈកម្មវិធីឌីជីថលកម្ពុជាឆ្នាំ២០១៩ ដែលមានអ្នកចូលរួម៣០ ០០០នាក់ កម្មវិធីពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលមានការចូលរួមពីក្រុមហ៊ុនប្រមាណ២០០ និងកម្មវិធីពានរង្វាន់ស្ត្រីកម្ពុជាក្នុងវិស័យបច្ចេកវិទ្យា ដែលមានស្ត្រីចូលរួមប្រមាណ១៥០នាក់
- បានផ្លាស់ប្តូរពីវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ទៅជាបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជាដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីដឹកនាំគ្រប់គ្រង ការអភិវឌ្ឍការអប់រំ ការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ បច្ចេកវិទ្យាឌីជីថល ព្រមទាំងចូលរួមលើកកម្ពស់ប្រព័ន្ធនវានុវត្តន៍ជាតិ សហគ្រិន និងធុរកិច្ចថ្មីឌីជីថល។

## តារាង៣.២១ : សូចនាករការកសាងសមត្ថភាពនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាល ឆ្នាំ២០២១ |
|---|---|---|---|---|
| ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ ជំនាញបច្ចេកវិទ្យាឌីជីថល | នាក់ | ៤០០ | ៤៧០ | ៥១០ |
| ការបណ្តុះបណ្តាលជំនាញឌីជីថល | នាក់ | ៣ ៩៦៤ | ២ ៦១៣ | ១ ៨៤៤ |
| ការស្រាវជ្រាវ | គម្រោង | ៥ | ៦ | ៥ |
| កម្មវិធីលើកកម្ពស់សហគ្រិនភាពនិងនវានុវត្តន៍ឌីជីថល | កម្មវិធី | ១២ | ៨ | ៦ |

ប្រភព : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

៣.៧៣- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ភាពមិនទាន់ពេញលេញនិងគ្រប់ជ្រុងជ្រោយនៃក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍នៅមិនទាន់មានវិសាលភាពគ្របដណ្តប់ទូលំទូលាយ និងការបិទខ្ទប់ក្នុងគោលដៅទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យប៉ះពាល់ដល់ដំណើរការដឹកជញ្ជូននិងចែកបញ្ញើប្រៃសណីយ៍
- ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅមិនទាន់មានវិសាលភាពគ្របដណ្តប់ពេញផ្ទៃប្រទេស រីឯគុណភាពសេវាអនឡាញក៏នៅមានកម្រិត
- ការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់ និងការឆ្លងរំខាននៅមិនទាន់អាចគ្រប់គ្រងបានទាំងស្រុង
- ប្រព័ន្ធរដ្ឋាភិបាលឌីជីថលមានសភាពដាច់ដោយឡែកៗពីគ្នានិងច្រំដែល មិនមានសង្គតិភាពរវាងគ្នា និងគ្មានថ្នាលជាតិរួមមួយដែលមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នសម្រាប់ផ្លាស់ប្តូរនិងចែករំលែកទិន្នន័យក្នុងក្របខ័ណ្ឌអន្តរស្ថាប័ននៅឡើយ
- ការបណ្តុះបណ្តាលមន្ត្រីរាជការ សិស្ស និស្សិត ត្រូវធ្វើតាមប្រព័ន្ធអប់រំពីចម្ងាយ ដែលពេលខ្លះមានការលំបាកក្នុងការអនុវត្តកម្មវិធីពិសោធន៍ជាក់ស្តែង។

## ៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

៣.៧៤- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រេចបានសមិទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា(គ.អ.ឧ.) ឆ្នាំ២០១៥-២០២៥ និងការជំរុញកិច្ចដំណើរការនិងទាក់ទាញការវិនិយោគនៅតាមតំបន់សេដ្ឋកិច្ចពិសេសដូចខាងក្រោម៖

- បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគ.អ.ឧ. សម្រាប់ឆ្នាំ២០១៧-២០១៨ ដែលទទួលបានការអនុម័តពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

- បានរៀបចំ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលប្រព័ន្ធតាមដាននិងវាយតម្លៃការអនុវត្តគ.អ.ឧ.
- បាននិងកំពុងរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិលើការអនុវត្តគ.អ.ឧ.
- បានបន្តជំរុញការងារផ្សព្វផ្សាយនិងទាក់ទាញវិនិយោគ ព្រមទាំងបាននិងកំពុងបន្តរៀបចំសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីវិនិយោគនិងសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស ស្របតាមវិធានការគោលនយោបាយនិងផែនការសកម្មភាពដែលបានកំណត់ក្នុងគ.អ.ឧ.
- បានរៀបចំដំណើរទស្សនកិច្ចការងារទៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងក្រុងបាវិត ខេត្តស្វាយរៀង ព្រមទាំងកិច្ចប្រជុំបូកសរុបលទ្ធផលនៃដំណើរទស្សនកិច្ចការងារទាំងពីរលើក ដើម្បីជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសតាមតំបន់ជាយដែន ដោះស្រាយបញ្ហាប្រឈមរបស់អ្នកវិនិយោគនិងទាក់ទាញអ្នកវិនិយោគឱ្យមកបណ្ដាក់ទុនកាន់តែច្រើនក្នុងតំបន់សេដ្ឋកិច្ចពិសេសតាមតំបន់ជាយដែន
- បានចុះបញ្ជីគម្រោងវិនិយោគថ្មីក្នុងតំបន់សេដ្ឋកិច្ចពិសេសចំនួន៤១គម្រោង នៅឆ្នាំ២០២០ មានការថយចុះចំនួន៥៨គម្រោង ធៀបនឹងឆ្នាំ២០១៩ ចំណែកឯទុនវិនិយោគក៏បានថយចុះប្រមាណ៧៧៦លានដុល្លារអាម៉េរិក ពោលគឺថយចុះពីប្រមាណ១ ០១២លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៩ មកត្រឹម២៣៦លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២០។

៣.៧៥- ក្នុងកិច្ចខិតខំប្រឹងប្រែងជំរុញនិងទាក់ទាញការវិនិយោគ និងការអភិវឌ្ឍវិស័យឧស្សាហកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសង្កេតឃើញបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការរាតត្បាតនៃជំងឺកូវីដ-១៩ បានធ្វើឱ្យគម្រោងវិនិយោគក្នុងវិស័យឧស្សាហកម្មនិងវិស័យទេសចរណ៍ទទួលរងនូវផលប៉ះពាល់ខ្លាំង តាមរយៈការផ្អាកការបញ្ជាទិញពីបណ្ដាប្រទេសដែលជាទីផ្សាររបស់កម្ពុជា និងការរឹតបន្តឹងការធ្វើដំណើររបស់ភ្ញៀវទេសចរ។ កត្តាទាំងនេះ បានធ្វើឱ្យសកម្មភាពវិនិយោគថ្មីក្នុងវិស័យទាំងពីរនេះមានការថយចុះទាំងចំនួនគម្រោងនិងទុនវិនិយោគក្នុងឆ្នាំ២០២០កន្លងទៅ។ ការអូសបន្លាយនៃការរីករាលនៃជំងឺនេះ បានធ្វើឱ្យសាជីវកម្មពហុជាតិជាច្រើនជួបប្រទះបញ្ហារាំងស្ទះនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ជាហេតុជំរុញឱ្យសាជីវកម្មទាំងនោះចាប់ផ្ដើមគិតគូរនិងរៀបចំឡើងវិញនូវយុទ្ធសាស្ត្រខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួន ដោយប្ដូរពីការពង្រាយខ្សែច្រវាក់ផលិតកម្មសកលឈានទៅរកការបង្រួម ឬបង្វិតមូលដ្ឋានផលិតកម្មឱ្យកៀកនឹងទីផ្សារសំខាន់ៗវិញ។ ចំពោះមុខស្ថានភាពនៃការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកលនេះ សេដ្ឋកិច្ចកម្ពុជាដែលបាននិងកំពុងធ្វើសមាហរណកម្មទៅក្នុងខ្សែច្រវាក់ផលិតកម្មសកល ជាពិសេសវិស័យកាត់ដេរនិងផលិតសម្លៀកបំពាក់ អាចនឹងទទួលរងការធ្លាក់ចុះនៃការវិនិយោគប្រភេទស្វែងរកប្រសិទ្ធភាពផលិតកម្ម ដែលកម្ពុជាធ្លាប់ទទួលបាននាពេលកន្លងមក
- ថ្លៃដឹកជញ្ជូននិងភស្តុភារកម្ម និងថ្លៃអគ្គិសនីនៅកម្ពុជា នៅតែស្ថិតក្នុងកម្រិតមួយខ្ពស់ជាងបណ្ដាប្រទេសជិតខាង ទន្ទឹមគ្នានឹងការកើនឡើងថ្លៃដឹកជញ្ជូនតាមនាវាក្នុងឆ្នាំ២០២១ អាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិយាកាសធុរកិច្ចនិងវិនិយោគរបស់កម្ពុជា

- កង្វះសហគ្រាសផ្គត់ផ្គង់វត្ថុធាតុដើមក្នុងស្រុក នៅតែបន្តជាបញ្ហាប្រឈមក្នុងការទាក់ទាញការវិនិយោគពីសហគ្រាសកម្មន្តសាលបរទេសធំៗ ដែលជាទូទៅត្រូវការដៃគូផលិតនិងផ្គត់ផ្គង់ធាតុចូលផលិតកម្មក្នុងស្រុកដើម្បីកាត់បន្ថយចំណាយលើការនាំចូលវត្ថុធាតុដើម
- ការដាក់ចេញគោលនយោបាយអនុគ្រោះពាក់ព័ន្ធនឹងការជំរុញនិងលើកទឹកចិត្តការវិនិយោគរបស់ប្រទេសជិតខាងក្នុងតំបន់ អាចប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា។

៣.៧៦- ឆ្នាំ២០១៩ ជាឆ្នាំកំពូលនៃវិស័យទេសចរណ៍កម្ពុជា ដែលសម្រេចបានកំណើនក្នុងអត្រា ៦,៦% ជាមួយការមកដល់នៃទេសចរអន្តរជាតិ៦,៦លាននាក់ និងទេសចរជាតិ១១,៣លាននាក់ ព្រមទាំងបានបង្កើតមុខរបរនិងការងារទេសចរណ៍ជូនប្រជាពលរដ្ឋប្រមាណ៦៣ម៉ឺននាក់ និងចំណូលទេសចរណ៍អន្តរជាតិប្រមាណ៤ ៩១៩លានដុល្លាអាម៉េរិក។ កិច្ចសហប្រតិបត្តិការទេសចរណ៍ភាគខាងត្បូង(កម្ពុជា ថៃ វៀតណាម) និងកិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់ត្រីកោណ(កម្ពុជា ឡាវ វៀតណាម) បាននិងកំពុងដំណើរការក្នុងការពង្រីកវិស័យទេសចរណ៍។ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥ ផែនការមេអភិវឌ្ឍវិស័យទេសចរខេត្តកែប ២០២១-២០៣៥ ផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥ និងគោលនយោបាយអេកូទេសចរណ៍ជាតិ(២០១៩-២០៣០) ត្រូវបានរៀបចំនិងអនុម័ត។ ដូចនេះ ដើម្បីពង្រឹងគុណភាពនិងស្តង់ដាសេវានិងសុវត្ថិភាពភ្ញៀវទេសចរ ក្រសួងបានពង្រឹងការបណ្តុះបណ្តាលអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ស្របតាមស្តង់ដាអាស៊ាន និងផែនការសកម្មភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥ និងកិច្ចសហប្រតិបត្តិការជាមួយសមាគមការធ្វើដំណើរអាស៊ីប៉ាស៊ីហ្វិក។ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្តល់នូវប្រភេទទិដ្ឋាការថ្មី សម្រាប់ទេសចរអាចចេញចូលច្រើនដងក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាការចូលរួមដល់ការជំរុញនូវគោលនយោបាយទេសចរមកច្រើនដង។ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមពិព័រណ៍ទេសចរណ៍អន្តរជាតិជាច្រើនលើកនៅអាស៊ាន អឺរ៉ុប កូរ៉េ រុស្ស៊ី អាម៉េរិក ឥណ្ឌា និងមជ្ឈិមបូព៌ា ដើម្បីធ្វើទីផ្សារទេចរណ៍កម្ពុជា។

**តារាង៣.២២ : សូចនាករវិស័យទេសចរណ៍និងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១**

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|
| ទេសចរណ៍អន្តរជាតិ | លាននាក់ | ៦,៦ | ១,៣១ | ០,១៤ |
| ទេសចរណ៍ជាតិ | លាននាក់ | ១១,៣ | ៧,២៣ | ១,៧០ |
| សេវាកម្មស្នាក់នៅ | បន្ទប់ | ៨៤ ៥២៨ | ៨០ ២១៩ | ៨០ ២១៩ |
| កម្លាំងពលកម្មបម្រើឱ្យវិស័យទេសចរណ៍ | ពាន់នាក់ | ៦៣០ | ៣០០ | ២៥ |
| ចំណូលទេសចរណ៍អន្តរជាតិ | លានដុល្លារអាម៉េរិក | ៤ ៩១៩ | ១ ០២៣ | ១៨០ |

ប្រភព : ក្រសួងទេសចរណ៍

៣.៧៧- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងទេសចរណ៍បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការវិនិយោគផលិតផលទេសចរណ៍ថ្មីៗដែលមានភាពទាក់ទាញទេសចរណ៍នៅមានកម្រិត។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់នៅតាមគោលដៅទេសចរណ៍(ផ្លូវថ្នល់ កំពង់ផែ អាកាសយានដ្ឋានទេសចរណ៍)
- ខ្វះការបំពាក់អាងស្តុកSeptic Tank អាងបង្គន់អនាម័យ និងប្រព័ន្ធលូនៅតាមបណ្តាមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍នៅតាមខេត្ត តំបន់ឆ្នេរមួយចំនួន និងបណ្តាខេត្តនៅតាមដងទន្លេ
- ខ្វះធនធានមនុស្សក្នុងជំនាញទេសចរណ៍
- ការផ្សព្វផ្សាយប្រព័ន្ធChina Ready សម្រាប់ប្រតិបត្តិករទេសចរណ៍ ក៏ដូចជាទេសចរចិននៅមានកម្រិត
- ខ្វះយន្តការសម្រាប់ការជំរុញឱ្យអនុវត្តការពង្រឹងគុណភាពសេវាកម្មតាមរយៈប្រព័ន្ធចំណាត់ថ្នាក់បមាណីយភាព និងការអនុវត្តក្រមប្រតិបត្តិនិងក្រមសីលធម៌វិជ្ជាជីវៈ
- ផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ បានធ្វើឱ្យរចនាសម្ព័ន្ធវិស័យទេសចរណ៍ រួមមានធនធានមនុស្ស(ផ្នែកសេវាកម្មហូបចុក ធ្វើដំណើរ ស្នាក់នៅ និងមគ្គុទ្ទេសក៍ទេសចរណ៍) ទីផ្សារ និងការផ្សព្វផ្សាយទេសចរណ៍ ដែលក្នុងនោះការីទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ ត្រូវបានបាត់បង់ការងារដែលទាមទារឱ្យមានការបណ្តុះបណ្តាលឡើងវិញ
- ខ្វះកងកម្លាំងនគរបាលទេសចរណ៍សម្រាប់ប្រចាំការនៅតាមតំបន់គោលដៅទេសចរណ៍សំខាន់ៗ រួមទាំងចំណេះដឹងផ្នែកភាសាបរទេសនៅមានកម្រិត។

៣.៧៨- ក្នុងវិស័យប្រេងកាត ក្រសួងរ៉ែនិងថាមពល បានអនុវត្តនូវបណ្តាសកម្មភាពជាអាទិភាពដែលបានដាក់ចេញនិងទទួលបានលទ្ធផលដូចខាងក្រោម៖

- ច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- ប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ និងសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ និងប្តូរដល់យានយន្ត
- ប្រកាសស្តីពីបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិអិលភីជីក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ និងបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់និងប្តូរយានយន្ត
- ផលិតកម្មប្រេងពីប្លុកA បានចំនួន១ ៨៨៩ពាន់បារ៉ែល នៅឆ្នាំ២០២០ និង២៨៨ ៣៦៥ ពាន់បារ៉ែល គិតត្រឹម៦ខែ ឆ្នាំ២០២១
- ជំរុញការទទួលខុសត្រូវសង្គមនិងបរិស្ថានរបស់ក្រុមហ៊ុនចុះកិច្ចព្រមព្រៀងប្រេងកាត ដោយអនុវត្តបន្តជារៀងរាល់ឆ្នាំចំនួន៣គម្រោង។ ទន្ទឹមនឹងនេះដែរ បានចុះត្រួតពិនិត្យនិងអធិការកិច្ចសកម្មភាពក្នុងវិស័យប្រេងកាត នៅស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈតាមបណ្តារាជធានីខេត្ត។

## តារាង៣.២៣ : ចំណូលមិនមែនសារពើពន្ធដែលប្រមូលបានពីវិស័យប្រេងកាត

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | ចំណូលមិនមែនសារពើពន្ធដែលប្រមូលបានពីវិស័យប្រេងកាត | លានរៀល | ៧ ៩៣៤ | ១២ ៨៦១ | ១ ០៧០ |

៣.៧៩- ការរីករាលដាលនៃជំងឺកូវីដ-១៩ ពីចុងឆ្នាំ២០១៩ បានធ្វើឱ្យការរៀបចំគោលនយោបាយជាតិប្រេងកាតឆ្នាំ២០២០-២០៣០ ក៏ដូចជាការចាប់ផ្តើមផលិតប្រេងនៅប្លុកA មានការយឺតយ៉ាវ។ ទន្ទឹមនេះ ការប្រកាសក្ស័យធនរបស់ប្រតិបត្តិករនៃគម្រោងប្រេងកាតប្លុកA ធ្វើឱ្យផលិតកម្មប្រេងត្រូវផ្អាកដំណើរការ និងរង់ចាំអ្នកវិនិយោគថ្មីមកបន្តដំណើរការឡើងវិញ។

៣.៨០- ក្រសួងពាណិជ្ជកម្មសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- អភិវឌ្ឍការធ្វើពិពិធកម្មផលិតផល (១)បានរៀបចំនិងផ្សព្វផ្សាយគោលនយោបាយជាតិស្តីពី "ដំឡូងមី ២០២០-២០២៥" និងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតក្រុមការងារអន្តរស្ថាប័ន សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីដំឡូងមី (២)បានរៀបចំសេចក្តីព្រាងគោលនយោបាយម្រេចកម្ពុជានិងស្វាយចន្ទី (៣)បានអភិវឌ្ឍផលិតផលហាឡាលកម្ពុជា តាមរយៈការចេញវិញ្ញាបនបត្រឱ្យប្រើប្រាស់ស្លាកសញ្ញាហាឡាលកម្ពុជាជូនដល់វិស័យឯកជន (៤)បានរៀបចំវេទិកាស្តីពីការអភិវឌ្ឍកសិពាណិជ្ជកម្មកម្ពុជា វេទិកាធុរកិច្ច វិនិយោគ និងទេសចរណ៍ ចូលរួមរៀបចំយុទ្ធសាស្ត្រអាជីវកម្មបរិយាបន្នសម្រាប់កម្ពុជា (៥)បានសម្របសម្រួល រៀបចំបង្កើតមជ្ឈមណ្ឌលជំរុញអភិវឌ្ឍវិស័យស្មូនដីកម្ពុជា នៅខេត្តកំពង់ឆ្នាំង ត្រៀមរៀបចំបង្កើតមជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យចម្លាក់ប្រាក់ស្ពាន់កម្ពុជានៅខេត្តកណ្តាលនិងមជ្ឈមណ្ឌលជំរុញអភិវឌ្ឍន៍វិស័យ ចម្លាក់ថ្មកម្ពុជានៅខេត្តពោធិ៍សាត់ និង(៦)បានស្រាវជ្រាវ ប្រមូលទិន្នន័យផលិតផលសក្តានុពល ដូចជាស្វាយកែវរមៀតនិងចេកនៅខេត្តបាត់ដំបង ផលិតផលម្សៅអង្ករខ្សាយតែកែច្នៃពីស្លឹកគ្រៃរបស់ខេត្តបន្ទាយមានជ័យ និងដំណាំស្វាយកែវរមៀត អំបិល ទឹកត្រីខេត្តកំពត ម្នាស់នៅខេត្តស្ទឹងត្រែង ខេត្តកោះកុង និងខេត្តព្រះសីហនុ
- អភិវឌ្ឍការធ្វើពិពិធកម្មទីផ្សារនាំចេញ (១)បានរៀបចំវេទិកាជំរុញពាណិជ្ជកម្មនិងវិនិយោគក្រៅប្រទេស សហប្រតិបត្តិការជាមួយដៃគូពាណិជ្ជកម្មតាមរយៈការសហការនិងរៀបចំជំនួបពិភាក្សារវាងភាគីពាក់ព័ន្ធ (២)បានរៀបចំនិងសម្របសម្រួលបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស(ហាយនឹង ក្វាងចូវ ស៊ីអាន ហុងកុង យានថាយ គុនមីញ ហៃណាន សៀវមិន និងឈិនទូ) (៣)បានចូលរួមក្នុងព្រឹត្តិការណ៍ពាណិជ្ជកម្ម សម្រាប់រៀបចំមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស និង(៤)បានបង្កើតស្ថានតំណាងពាណិជ្ជកម្មនៅក្រៅប្រទេសថ្មីៗបន្ថែមទៀត។

៣.៨១- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងលើកកម្ពស់សោភណភាពរមណីយដ្ឋានបេតិកភណ្ឌពិភពលោក និងទីតាំងវប្បធម៌សំខាន់ៗ ដើម្បីបង្កើនភាពទាក់ទាញសម្រាប់វិស័យទេសចរណ៍ និង

ជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ រមណីយដ្ឋានប្រាសាទព្រះវិហារ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក សារមន្ទីរជាតិ សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី សារមន្ទីរព្រះនរោត្តមសីហនុ អង្គរ សារមន្ទីរកុលាលភាជន៍នៅភូមិតានី។ល។

- បានដំឡើងសិល្បៈទស្សនីយភាពថ្មីចំនួន១៧ស្នាដៃ ហើយក៏បានផលិតនិងជំរុញការផលិតភាពយន្តក្នុងប្រទេសកម្ពុជាបានចំនួនប្រមាណ៨៨៩ភាពយន្ត ព្រមទាំងបានរៀបចំព្រឹត្តិការណ៍និងកម្មវិធីសំខាន់ៗដើម្បីគាំទ្រនិងជំរុញដល់តួអង្គនៅក្នុងវិស័យឯកជននិងអង្គការសង្គមស៊ីវិលឱ្យដើរតួនាទីកាន់តែផុសផុលឡើងនៅក្នុងឧស្សាហកម្មវប្បធម៌និងសេដ្ឋកិច្ចច្នៃប្រតិដ្ឋ តាមរយៈការបង្កើតទំនិញនិងសេវាវប្បធម៌ថ្មីៗ
- បានអភិវឌ្ឍមូលធនមនុស្សនៅក្នុងផ្នែកសិល្បៈនិងវប្បធម៌ចំនួន១២ ២៤៩នាក់ ដើម្បីអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ និងការបង្កើតមុខរបរនៅក្នុងវិស័យវប្បធម៌ ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ
- បានស្វាគមន៍ភ្ញៀវទេសចរចូលទស្សនារមណីយដ្ឋានបេតិកភណ្ឌពិភពលោកនិងទីតាំងវប្បធម៌សំខាន់ៗបានចំនួនសរុបប្រមាណ៥ ៣៨០ ០៥៦នាក់ រួមមានភ្ញៀវអន្តរជាតិសរុបប្រមាណ៣ ៧២៣ ៨៣៧នាក់និងភ្ញៀវបង់ថ្លៃចូលទស្សនាសរុបប្រមាណ៣ ៩៦១ ៧០០នាក់។

## ៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

៣.៨២- បានបង្កើតគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានតួនាទីស្នូលក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដូចជាកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម គ្រប់គ្រងថ្នាលបច្ចេកវិទ្យារួម កំណត់ស្តង់ដាបច្ចេកទេស សុសវែរ ហាដវែរ និងសន្តិសុខឌីជីថល និងរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល និងបានពន្លឿនការធ្វើបរិវត្តកម្មសេដ្ឋកិច្ច និងសង្គមឌីជីថល ដើម្បីផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើងសំដៅលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ ដោយសង្កត់ធ្ងន់ទៅលើការតភ្ជាប់និងទំនើបកម្មបណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល និងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់សេវាសាធារណៈ សម្រួលដល់ការបំពេញការងារទាំងស្ថាប័នសាធារណៈ ធុរកិច្ច ការសិក្សា និងការប្រាស្រ័យទាក់ទង នៅក្នុងជីវភាពប្រចាំថ្ងៃ។

៣.៨៣- ប្រព័ន្ធឌីជីថលនិងមាតិកាជាខេមរភាសានៅមានកម្រិត ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃបច្ចេកវិទ្យានិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅតាមទីជនបទ។ សន្តិសុខឌីជីថលនៅមានកង្វះខាតជាពិសេសលើកម្រិតអ្នកប្រើប្រាស់។ ចំណែកហេដ្ឋារចនាសម្ព័ន្ធឌីជីថល ក៏ពុំទាន់ធានាបានទៅនឹងឧប្បត្តិហេតុដែលអាចកើតមាននៅតាមក្រសួង ស្ថាប័ន វិស័យឯកជន និងប្រជាពលរដ្ឋ។

៣.៨៤- ក្រសួងពាណិជ្ជកម្មសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- អភិវឌ្ឍគោលនយោបាយនិងកិច្ចការនីតិកម្មក្នុងវិស័យពាណិជ្ជកម្ម (១)បានចូលរួមតាក់តែងនិងផ្សព្វផ្សាយច្បាប់ស្តីពី"ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក" ច្បាប់ស្តីពីការអនុម័ត

យល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង(២) បានអនុវត្តប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា (www.setfo.gov.kh) និងតភ្ជាប់ជាមួយប្រព័ន្ធទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

- អភិវឌ្ឍសហគ្រិនភាពនិងរបៀបរបបនៃការធ្វើធុរកិច្ច (១)បានរៀបចំប្រកាសស្ដីពីការបង្កើតក្រុមការងារបច្ចេកទេសសិក្សាលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃកសិពាណិជ្ជកម្ម រវាងក្រសួងពាណិជ្ជកម្មនិងក្រុមហ៊ុនយ៉ាម៉ាតុហ្គ្រីន (២)បានផ្សព្វផ្សាយពីសារប្រយោជន៍នៃការរៀបចំសមាគមអាជីវកម្ម លិខិតបទដ្ឋានទាំងឡាយទាក់ទងដល់ការបង្កើតសមាគម និងចុះជួយរៀបចំបង្កើតសមាគមអាជីវកម្ម និង(៣)បានជំរុញឱ្យអាជីវករ ពាណិជ្ជករក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនលើគ្រប់ប្រតិបត្តិការពាក់ព័ន្ធ ជាពិសេសពង្រឹងនិងពង្រីកការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីទាញយកផលវិជ្ជមានឱ្យបានច្រើនពីការធ្វើពាណិជ្ជកម្មក្នុងបរិបទសេដ្ឋកិច្ចឌីជីថល។

៣.៨៥- បញ្ហាប្រឈមសំខាន់ក្នុងការអនុវត្តកិច្ចការខាងលើនេះ គឺសមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិតក្នុងការអនុវត្តជំនាញបច្ចេកទេសនៃការងាររបស់ខ្លួន ដើម្បីឆ្លើយតបនឹងប្រតិបត្តិការនៃសេដ្ឋកិច្ចសកល រួមមានបរិបទនៃសេដ្ឋកិច្ចឌីជីថល បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ និងស្ថានភាពនៃសកលភាវូបនីយកម្មដទៃទៀត។

៣.៨៦- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានបង្កើត“**ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**” ដែលក្នុងនោះមានគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងក្លាយជាយន្តការដឹកនាំ និងតម្រង់ទិសដ៏មានប្រសិទ្ធភាព ហើយក៏ក្លាយជាធនធានបញ្ញវន្តដ៏សំខាន់សម្រាប់ជួយជំរុញល្បឿនអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅកម្ពុជា
- បានរៀបចំសេចក្ដីព្រាងផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(វ.ប.ន.) របស់កម្ពុជាឆ្នាំ២០៣០
- បានរៀបចំសេចក្ដីព្រាងសៀវភៅណែនាំស្ដីពី“យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍”
- បានរៀបចំសេចក្ដីព្រាងបញ្ជីធនធានមនុស្សដែលមានជំនាញវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលកំពុងបម្រើការងារនៅតាមក្រសួងស្ថាប័ន សភាពាណិជ្ជកម្ម វិស័យឯកជន ស្ថាប័នសាធារណៈ សមាគម និងអង្គការសង្គមស៊ីវិលនានា
- បានអភិវឌ្ឍគម្រោងការផ្លាស់ប្ដូរឌីជីថលនៅលើវេបផតថលរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងអភិវឌ្ឍប្រព័ន្ធអនុម័តតាមអ៊ិនធឺណិត
- បានពង្រឹងការងារមាត្រាសាស្ត្រលើការអនុវត្តច្បាប់និងបទប្បញ្ញត្តិបច្ចេកទេសនានាឱ្យបានរឹងមាំនិងត្រឹមត្រូវ ដើម្បីធានាប្រយោជន៍រវាងអ្នកផ្គត់ផ្គង់និងអ្នកប្រើប្រាស់ផលិតផលទំនិញ និងធ្វើឱ្យមានជំនឿទុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជ

កម្មនិងវិស័យផ្សេងៗទៀត និងគាំទ្រដល់កិច្ចដំណើរការខ្សែច្រវាក់ផលិតកម្ម ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មឱ្យដំណើរការដោយមានភាពជឿជាក់លើផលិតផល និងបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនិងអង្គការជាតិ អន្តរជាតិនានា ដើម្បីជំរុញឱ្យវិស័យមាត្រាសាស្ត្រកាន់តែដើរតួនាទីឈានមុខក្នុងការធ្វើព្យាសកម្ម តេស្តវិភាគ អនុម័តគំរូ និងត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ។

៣.៨៧- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការងារមួយចំនួនដែលបានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ក្រោមជាតិ នៅមិនទាន់បានបំពេញឱ្យរលូន ដោយសារកង្វះធនធានមនុស្សមានសមត្ថភាព ថវិកាមានកម្រិត និងមធ្យោបាយក្នុងការអនុវត្ត
- ការយល់ដឹងរបស់ពាណិជ្ជករ អាជីវករ សិប្បករ សេវាករនៅមានកម្រិត ពាក់ព័ន្ធនឹងវិស័យជំនាញរបស់ក្រសួង ដូចជាវិស័យមាត្រាសាស្ត្រ ស្តង់ដាជាដើម
- លទ្ធភាពទទួលបានហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់សមត្ថភាពវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៅចោទជាបញ្ហានៅឡើយ
- ការសហការពីអន្តរក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដី ក្នុងការចែករំលែកព័ត៌មាននិងទិន្នន័យលើការងារមួយចំនួន នៅមានកម្រិត។

៣.៨៨- ព្រឹត្តិការណ៍សំខាន់ៗរបស់ជាតិនិងអន្តរជាតិត្រូវបានប្រព័ន្ធឃោសនារបស់រដ្ឋផ្សព្វផ្សាយយ៉ាងទូលំទូលាយ រួមមានព្រះរាជសកម្មភាពរបស់ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សកម្មភាពថ្នាក់ដឹកនាំស្ថាប័នព្រឹទ្ធសភា ស្ថាប័នរដ្ឋសភា និងប្រមុខរាជរដ្ឋាភិបាល ព្រមទាំងសកម្មភាពរបស់ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ ដែលធ្វើសកម្មភាពលើគ្រប់វិស័យជូនប្រជាពលរដ្ឋយើងទូទាំងប្រទេស ដើម្បីលើកស្ទួយកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា។ ប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសប្រមាណ៨៥% បានទទួលសេវាផ្តល់ព័ត៌មាន ផ្តល់ការអប់រំ និងការកម្សាន្ត ប្រកបដោយគុណភាពនិងសមធម៌ តាមរយៈមធ្យោបាយផ្សេងៗគ្នា ដូចជាទូរទស្សន៍ វិទ្យុ សារព័ត៌មានបោះពុម្ព និងមធ្យោបាយផ្សេងៗទៀតស្របតាមលទ្ធភាពដែលប្រជាពលរដ្ឋមាន។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន(២០១៤) ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០២០។

### តារាង៣.២៤ : សូចនាករវិស័យព័ត៌មាន ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| ក- ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ | | | | |
| ១- ស្ថានីយទូរទស្សន៍រដ្ឋ(ទ.ទ.ក.) | | | | |
| - ស្ថានីយកណ្ដាល | ចំនួន | ១ | ១ | ១ |
| - ស្ថានីយខេត្ត | ចំនួន | ៩ | ៩ | ៩ |
| ២- ស្ថានីយវិទ្យុរដ្ឋ(វិទ្យុជាតិកម្ពុជា) | | | | |

| | | | | |
|---|---|---|---|---|
| - ស្ថានីយកណ្តាល( AM ) | ចំនួន | ៣ | ៣ | ៣ |
| - ស្ថានីយខេត្ត(FM ) | ចំនួន | ២៣ | ២៣ | ២៣ |
| ៣- ទីភ្នាក់ងារសារព័ត៌មានរដ្ឋ | អង្គភាព | ១ | ១ | ១ |
| ខ- ប្រព័ន្ធផ្សព្វផ្សាយឯកជន | | | | |
| ១- ស្ថានីយទូរទស្សន៍ឯកជន | ចំនួន | ២០ | ២០ | ២០ |
| ២- ស្ថានីយទូរទស្សន៍ខ្សែកាប(ភ.ព.) | អង្គភាព | ២ | ២ | ២ |
| ៣- ស្ថានីយទូរទស្សន៍ខ្សែកាប(ខេត្ត) | អង្គភាព | ២១០ | ២១២ | ២១២ |
| ៤- ស្ថានីយវិទ្យុឯកជន(ភ.ព.) | ចំនួន | ៧៩ | ៧៩ | ៧៩ |
| ៥- ស្ថានីយវិទ្យុឯកជន(ខេត្ត) | ចំនួន | ១៣៧ | ១៣៩ | ១៤១ |
| ៦- ទូរទស្សន៍Digital | ចំនួន | ១១ | ១២ | ១២ |
| ៧- ទូរទស្សន៍OTT | ចំនួន | ៧ | ៧ | ៧ |
| ៨- ទូរទស្សន៍ប្រព័ន្ធSatellite | ចំនួន | ២ | ២ | ២ |
| ៩- សារព័ត៌មានបោះពុម្ព(កាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី ភាសាខ្មែរ និងបរទេស) | អង្គភាព | ៦៥៣ | ៦៦៨ | ៦៧០ |
| ១០- គេហទំព័រនិងTV Online | អង្គភាព | ៣១៥ | ៦៦៩ | ៧១៦ |
| ១១- រោងពុម្ពនិងគ្រឹះស្ថានបោះពុម្ព | អង្គភាព | ១៣៨ | ១៣៦ | ១៣៦ |
| ១២- សមាគមសារព័ត៌មាន | អង្គភាព | ៤០ | ៥១ | ៥០ |
| ១៣- ទីភ្នាក់ងារសារព័ត៌មានបរទេសប្រចាំនៅកម្ពុជា | អង្គភាព | ២១ | ២៤ | ២៦ |
| ១៤- ទីភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម | ចំនួន | ០ | ១ | ១ |

ប្រភព : ក្រសួងព័ត៌មាន

៣.៨៩- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងព័ត៌មានបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ប្រជាពលរដ្ឋប្រមាណ១៥% នៅពុំទាន់ទទួលបានព័ត៌មានឬទទួលបានតិចតួច ជាពិសេសប្រជាជនក្រីក្ររស់នៅក្នុងតំបន់ដាច់ស្រយាល
- ផែនការកសាងលិខិតបទដ្ឋានគតិយុត្ត(អនុក្រឹត្យ ច្បាប់) សម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍កំពុងស្ថិតក្នុងដំណើរការសិក្សាស្រាវជ្រាវនៅឡើយ
- ការកសាងស្ថានីយវិទ្យុនិងទូរទស្សន៍ថ្មីនៅថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ ដោយមូលហេតុការរួមចំណែករបស់ខេត្តគោលដៅខ្លះមិនមានលទ្ធភាពម្ចាស់ការក្នុងការកំណត់ទីតាំង និងខ្វះថវិកាក្នុងការកសាងមូលដ្ឋានគ្រឹះចាំបាច់ជាបឋម សម្រាប់ការកសាងស្ថានីយវិទ្យុ និងទូរទស្សន៍
- ការពង្រឹកសមត្ថភាពស្ថាប័ន ទាំងការដឹកនាំ ការគ្រប់គ្រង និងទាំងការងារជំនាញអាចនឹងជួបការលំបាកខ្លះក្នុងរយៈពេល២ឆ្នាំខាងមុខ នៅពេលដែលមន្ត្រីគ្រប់គ្រងនិងមន្ត្រីជំនាញចំនួនច្រើនត្រូវចូលនិវត្តន៍ដោយគំហុកខណៈដែលមន្ត្រីបន្តវេននៅមានបទពិសោធទាប ជាពិសេសនៅតាមបណ្តាញផ្សព្វផ្សាយថ្នាក់ក្រោមជាតិ
- មូលដ្ឋានសម្ភារៈបច្ចេកទេសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ(វិទ្យុជាតិ ទូរទស្សន៍ជាតិ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា) ឈានដល់ដំណាក់កាលត្រូវផ្លាស់ប្តូរនិងធ្វើទំនើបកម្ម

ជាពិសេសការត្រៀមលក្ខណៈផ្លាស់ប្តូរពីប្រព័ន្ធអាណាឡូកទៅប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីឆ្លើយតបនឹងគម្រោងផ្លាស់ប្តូររបស់អាស៊ាននិងពិភពលោក។

## ៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

៣.៩០- ធនាគារជាតិនៃកម្ពុជាទទួលបានជោគជ័យក្នុងការរក្សាអតិផរណាបន្តមានកម្រិតទាបក្នុងរង្វង់៣% និងអត្រាប្តូរប្រាក់៤ ០៧៨រៀលក្នុង១ដុល្លារអាម៉េរិក រវាងឆ្នាំ២០១៩ និងឆមាសទី១ ឆ្នាំ ២០២១។ ធនាគារជាតិនៃកម្ពុជា បានអនុវត្តឧបករណ៍គោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់មួយចំនួន រួមមានអត្រាប្រាក់បម្រុងកាតព្វកិច្ច មូលបត្រអាចជួញដូរបាន និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានានិងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ចាប់តាំងពីខែមេសា ឆ្នាំ ២០២០ អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលនិងរូបិយបណ្ណត្រូវបានកាត់បន្ថយពី៨% និង១២,៥% រៀងគ្នាមក៧% ដូចគ្នាដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ មូលបត្រអាចជួញដូរបាន គឺជាឧបករណ៍មួយសម្រាប់ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ព្រមទាំងជាឧបករណ៍សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុគ្រប់គ្រងសន្ទនីយភាពលើស។

៣.៩១- គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ មូលបត្រអាចជួញដូរបានមិនទាន់ដល់តណាប្រតិទានជារៀលមាន៤៧១ ប៊ីលានរៀល និងជាដុល្លារអាម៉េរិកមាន៣,៧ ប៊ីលានដុល្លារអាម៉េរិក។ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ដែលបានបង្កើតឡើងនៅឆ្នាំ២០១៦ មានគោលបំណងបន្តពង្រឹងការអភិវឌ្ឍទីផ្សារអន្តរធនាគារ លើកកម្ពស់ការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងពង្រឹងការប្រើប្រាស់ប្រាក់រៀល។ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ធ្វើឡើងតាមរយៈការដេញថ្លៃដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដេញថ្លៃប្រាក់រៀលជាមួយនឹងការកំណត់ទំហំទឹកប្រាក់ដេញថ្លៃពីធនាគារជាតិនៃកម្ពុជា ជាមួយនឹងតណាប្រតិទាន៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ។ រហូតមកដល់បច្ចុប្បន្ន សន្ទនីយភាពជារៀលត្រូវបានផ្តល់ដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុចំនួន២៨ ហើយប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាមិនទាន់ដល់តណាប្រតិទានមាន៣,៦ទ្រីលានរៀល។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីជួយរក្សាស្ថិរភាពប្រាក់រៀលធៀបនឹងដុល្លារអាម៉េរិក ដោយបានលក់ប្រាក់ដុល្លារអាម៉េរិកសុទ្ធ៤៨លានដុល្លារអាម៉េរិក នៅឆមាសទី១ ឆ្នាំ២០២១ និង២១០ លានដុល្លារអាម៉េរិកនៅឆ្នាំ២០២០ ក៏ដូចជាទិញប្រាក់ដុល្លារអាម៉េរិកសុទ្ធ១,៣ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០១៩។

៣.៩២- ធនាគារជាតិនៃកម្ពុជា បានកែលម្អការអនុវត្តតាមស្តង់ដាបាសែលស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ជាពិសេសផ្តោតលើការគ្រប់គ្រងហានិភ័យ។ បទប្បញ្ញត្តិមួយចំនួន ដូចជាដើមទុនតាមបទប្បញ្ញត្តិ ហានិភ័យតណាទាន ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិ

ការ ត្រូវបានពិនិត្យឡើងវិញ ហើយការកែសម្រួលបទប្បញ្ញត្តិទាំងនោះបានប្រព្រឹត្តទៅតាមពេលវេលាកំណត់។ ធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមរៀបចំយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និងត្រូវបានអនុម័តពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ និងចុះហត្ថលេខាដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ មានផែនការសកម្មភាពចំនួន១១៥ ដោយបានបែងចែកជាបីដំណាក់កាលអនុវត្ត(រយៈពេលខ្លី មធ្យម និងវែង) និងបានបែងចែកមុខងារទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធយ៉ាងច្បាស់លាស់ ដែលនឹងជួយជំរុញឱ្យការអនុវត្តប្រកបដោយប្រសិទ្ធភាពនិងជោគជ័យខ្ពស់។

៣.៩៣- ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោងនិងប្រព័ន្ធរីថែលផេ ដើម្បីសម្រួលការផ្ទេរប្រាក់និងការទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថានតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ប្រព័ន្ធខេមបូឌានស៊ែស្វិច កំពុងត្រូវបានដាក់ឱ្យដំណើរការបឋមដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានតាមរយៈបណ្ណទូទាត់ឥណពន្ធលើម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្ត(ATMs) និងម៉ាស៊ីនឆូតកាត(POS)។ ទន្ទឹមនោះ ខេអេចឃ្យូអរកូដ(KHQR Code) ដែលជាស្តង់ដាឃ្យូអរកូដ(QR Code) សម្រាប់ការទូទាត់នៅក្នុងប្រទេសកម្ពុជា ក៏ត្រូវបានបង្កើតឡើងនិងដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ដើម្បីសម្រួលដល់ការធ្វើអន្តរប្រតិបត្តិការទូទាត់តាមរយៈឃ្យូអរកូដស្របតាមតម្រូវការទីផ្សារនិងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ព្រមទាំងគាំទ្រដល់ការអនុវត្តគម្រោងភ្ជាប់ការទូទាត់ជាមួយប្រទេសក្នុងតំបន់។ ក្នុងក្របខ័ណ្ឌតំបន់ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការជាផ្លូវការ លើការភ្ជាប់ការទូទាត់តាមឃ្យូអរកូដរវាងប្រទេសកម្ពុជានិងប្រទេសថៃ។ ថ្មីៗនេះសេវាផ្ទេរប្រាក់ឆ្លងដែនតាមរយៈប្រព័ន្ធបាគងរវាងប្រទេសកម្ពុជានិងប្រទេសម៉ាឡេស៊ីត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការក្រោមកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជានិងធនាគារមេយប៊ែង។ ការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ដូចបានរៀបរាប់ ខាងលើបានផ្តល់នូវមធ្យោបាយទូទាត់ឌីជីថលដែលមានប្រសិទ្ធភាព សុវត្ថិភាព ភាពងាយស្រួល និងកម្រៃសមរម្យសម្រាប់សម្រួលដល់ជីវភាពរស់នៅនិងការអនុវត្តការងារធុរៈកិច្ច ដូចជាការទូទាត់លើការទិញទំនិញនិងសេវា ការទូទាត់លើប្រតិបត្តិការពាណិជ្ជកម្មអេឡិចត្រូនិក ការផ្ទេរប្រាក់ជូនសាច់ញាតិ(Remittance) និងការបើកប្រាក់បៀវត្សបុគ្គលិកជាដើម។ ការណ៍នេះបានរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនិងសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា ជាពិសេសកាត់បន្ថយការទូទាត់ដោយប្រើប្រាស់សាច់ប្រាក់ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

៣.៩៤- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំពង្រឹងនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពោលមានដូចជា ១) ការដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០២០

២) ការដាក់ចេញនូវសេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន នៅឆ្នាំ២០២១ ៣) ការដាក់ចេញឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់ធនាគារពាណិជ្ជនៅឆ្នាំ២០១៩ និងឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ(MDI) និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់(PSI)នៅឆ្នាំ២០២០។ លើសពីនេះទៅទៀត អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ ដើម្បីបង្កើនការយល់ដឹងដល់គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្តល់សេវាទូទាត់សងប្រាក់។ ក្រៅពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏បានធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងស្រុកនិងអន្តរជាតិ។ ក្នុងឆ្នាំ២០១៩ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរក្នុងស្រុករួមមាន ១) ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ២)ក្រសួងទេសចរណ៍ ៣)អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង ៤)ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ លើសពីនេះទៅទៀត នៅឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរក្នុងស្រុក ដូចជាអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ និងអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការនិងដឹកជញ្ជូន ព្រមទាំងបានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស រួមមាន ១)អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុម៉ាដាហ្គាស្កា ២)នីហ្សេរីយ៉ា ៣)នូវែលសេឡង់ ៤)ឥណ្ឌា និង ៥)សេណេហ្កាល់។ ជាចុងក្រោយក្នុងឆ្នាំ២០២១ ការចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានរវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាជាមួយអាជ្ញាធរក្នុងស្រុកដូចជា ១)រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និង ២)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងការចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសដូចជា ១)អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុប្រេស៊ីល និង ២)អេស្តូនី។

**តារាង៣.២៥ : សូចនាករគោលនយោបាយរូបិយវត្ថុនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១**

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្តាលឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀល | ភាគរយ | ៨ | ៧ (ចាប់ពីខែមេសា) | ៧ |
| ២ | អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយបណ្ណ | ភាគរយ | ១២,៥ | ៧ (ចាប់ពីខែមេសា) | ៧ |
| ៣ | មូលបត្រអាចជួញដូរបានNCD ជារៀល | ប៊ីលានរៀល | ២៥៤ | ៣៥៧ | ៤៧១ |
| ៤ | មូលបត្រអាចជួញដូរបានNCD ជារូបិយបណ្ណ | ប៊ីលានដុល្លារអាម៉េរិក | ២,៧ | ៤,៣ | ៣,៧ |
| ៥ | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាLPCO | ទ្រីលានរៀល | ៣,៩ | ៣,៩ | ៣,៨ |
| ៦ | អន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ទិញដុល្លារអាម៉េរិក(លក់ដុល្លារអាម៉េរិក) | លានដុល្លារអាម៉េរិក | ១ ៣២៤ | (២១០) | (៤៨) |
| ៧ | អតិផរណា(ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ) | ភាគរយ | ១,៩ | ២,៩ | ៣ |
| ៨ | អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាម៉េរិក(មធ្យមប្រចាំឆ្នាំ) | | ៤ ០៦១ | ៤ ០៩០ | ៤ ០៨៤ |

ប្រភព : ធនាគារជាតិនៃកម្ពុជា

## តារាង៣.២៦ : សូចនាករវិស័យធនាគារនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាល ឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | ទ្រព្យសកម្ម | ទ្រីលានរៀល | ១៧២,១០ | ២០៣,៤៨ | ២២១,៧៩ |
| ២ | ឥណទានទៅអតិថិជន * | ទ្រីលានរៀល | ១០២,០៧ | ១២៥,០១ | ១៣៧,២៤ |
| ៣ | ប្រាក់បញ្ញើពីអតិថិជន * * | ទ្រីលានរៀល | ១០៣,៥៦ | ១២១,២៥ | ១៣០,៨៤ |
| ៤ | ដើមទុនបានបង់ជម្រះ | ទ្រីលានរៀល | ១៩,៦៣ | ២១,៧២ | ២៤,០៨ |
| ៥ | ប្រាក់បញ្ញើជារៀល * * * | ទ្រីលានរៀល | ៧,៥១ | ៩,៥៥ | ១៦,០០ |
| ៦ | ប្រាក់បញ្ញើជារូបិយបណ្ណ * * * | ទ្រីលានរៀល | ៩៦,០៥ | ១១១,៧០ | ១២៦,២៥ |
| ៧ | អនុបាតសន្ទនីយភាព | % | ១៥៥,៨% | ១៦១,៣% | ១៦០,៥% |
| ៨ | អនុបាតសាធនភាព | % | ២៤,០% | ២៣,២% | ២៤,៣% |
| ៩ | អនុបាតឥណទានមិនដំណើរការ | % | ២,០% | ២,១% | ២,៥% |

*ឥណទានទៅអតិថិជន (មិនរាប់បញ្ចូលឥណទានទៅអតិថិជនអនិវាសជននិងមិនរាប់បញ្ចូលឥណទានទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

* *ប្រាក់បញ្ញើពីអតិថិជន (មិនរាប់បញ្ចូលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

* * *ប្រាក់បញ្ញើ (រាប់បញ្ចូលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

ប្រភព : ធនាគារជាតិនៃកម្ពុជា

## តារាង៣.២៧ : សូចនាករវិស័យមីក្រូហិរញ្ញវត្ថុនិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១

| ល.រ. | សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាល ឆ្នាំ២០២១ |
|---|---|---|---|---|---|
| ១ | ទ្រព្យសកម្ម | ទ្រីលានរៀល | ៣៥,៨៩ | ៣៤,២៩ | ៣៧,០១ |
| ២ | ឥណទានទៅអតិថិជន | ទ្រីលានរៀល | ២៩,៣៦ | ២៧,៥៣ | ៣០,៧៩ |
| ៣ | ប្រាក់បញ្ញើពីអតិថិជន | ទ្រីលានរៀល | ១៥,៣៩ | ១៤,៤៧ | ១៥,៨៩ |
| ៤ | ដើមទុនបានបង់ជម្រះ | ទ្រីលានរៀល | ៣,៤៧ | ៣,៦៦ | ៤,១២ |
| ៥ | ប្រាក់បញ្ញើជារៀល | ទ្រីលានរៀល | ២,០២ | ១,៦៧ | ១,៧៦ |
| ៦ | ប្រាក់បញ្ញើជារូបិយបណ្ណ | ទ្រីលានរៀល | ១៣,៣៦ | ១២,៨១ | ១៤,១៣ |
| ៧ | អនុបាតសន្ទនីយភាព | % | ១៧៨,១% | ២៤០,៤% | ១៧២,១% |
| ៨ | អនុបាតសាធនភាព | % | ១៩,០% | ២២,៤% | ២៣,៥% |
| ៩ | អនុបាតឥណទានមិនដំណើរការ | % | ០,៨% | ១,៨% | ២,៣% |

ប្រភព : ធនាគារជាតិនៃកម្ពុជា

៣.៩៥- កម្រិតដុល្លារូបនីយកម្មខ្ពស់ នៅតែជាបញ្ហាប្រឈមសម្រាប់ការរក្សាស្ថិរភាពថ្លៃនិងអត្រាប្ដូរប្រាក់នៅកម្ពុជា។ ការប្រើប្រាស់ប្រាក់រៀល ទោះបីជាកើនឡើង ប៉ុន្តែកម្រិតដុល្លារូបនីយកម្ម

ហាក់មានស្ថិរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារកំណើននៃការប្រើប្រាស់រូបិយបណ្ណ ជាពិសេសប្រាក់ដុល្លារអាម៉េរិក។ ដោយកង្វះបទពិសោធលើផ្នែកដំណោះស្រាយពិសេស ធនាគារជាតិនៃកម្ពុជាត្រូវពឹងផ្អែកលើជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកដើម្បីបណ្តុះបណ្តាលនិងជួយធ្វើសេចក្តីព្រាងច្បាប់ស្តីពីដំណោះស្រាយពិសេស។ ទោះជាយ៉ាងណា ការរីករាលដាលនៃជំងឺកូវីដ-១៩ បានពន្យារពេលដល់ការបណ្តុះបណ្តាលនិងការពិគ្រោះយោបល់នានាដែលធ្វើឱ្យការងារធ្វើសេចក្តីព្រាងច្បាប់មានការយឺតយ៉ាវ។

## ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

### ៥.១- ការអភិវឌ្ឍទីផ្សារការងារ

៣.៩៦- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានការដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩ ២០២៣-និងបន្តជំរុញការអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយនានា ដូចជាគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥២០-២៥ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦២០៣០- គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ២០១៥២០២-៥ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦២០២៥- កម្មវិធីការងារសមរម្យរបស់អង្គការអន្តរជាតិខាងការងារ ២០១៩-២០២៣ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ២០១៩២០២៣ និងផែនការជាតិប្រឆាំង-ការកាត់បន្ថយពលកម្មកុមារនិងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥
- បានអនុវត្តដោយភាពជោគជ័យនូវអនុសាសន៍ទាំង១០ របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានដាក់ចេញក្នុងកម្មវិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតរោងចក្រនៅទូទាំងប្រទេស ដោយបានធ្វើឱ្យអត្រាមានការងារធ្វើនៅកម្ពុជាមានរហូតដល់ ៩៩,៣%។ បន្ថែមពីលើការងារក្នុងស្រុក ក្រសួងបានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាដើម្បីបង្កើតទីផ្សារការងារនៅក្រៅប្រទេស ដែលមកដល់បច្ចុប្បន្ន ពលករកម្ពុជាប្រមាណ១,៣លាននាក់ កំពុងស្នាក់នៅនិងធ្វើការនៅបរទេស ដោយបានបញ្ញូនប្រាក់បញ្ញើមកក្នុងប្រទេសវិញក្នុងមួយឆ្នាំប្រមាណ៣ប៊ីលានដុល្លារអាម៉េរិក។ ទន្ទឹមគ្នានេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងក៏បានកើនឡើងក្នុងឆ្នាំ២០១៩ ចំនួន១៨២ដុល្លារអាម៉េរិកក្នុងមួយខែ ហើយទោះប្រឈមនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏បានឈ្នួលអប្បបរមាត្រូវបានដំឡើងចំនួន១៩០ដុល្លារ អាម៉េរិកក្នុងមួយខែ នៅឆ្នាំ២០២០ និងចំនួន១៩២ដុល្លារអាម៉េរិកក្នុងមួយខែ នៅឆ្នាំ២០២១ ផងដែរ បើបូកនឹងប្រាក់អត្ថប្រយោជន៍បន្ថែម កម្មករនិយោជិតម្នាក់អាចទទួលប្រាក់ឈ្នួលពី២០៩ ដល់២២០ដុល្លារអាម៉េរិកក្នុងមួយខែ

- បានពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការចុះធ្វើអធិការកិច្ចក្នុងពេលតែមួយសំដៅកាត់បន្ថយបន្ទុករបស់ម្ចាស់រោងចក្រ សហគ្រាស និងធានាប្រសិទ្ធភាពនិងអនុលោមភាពតាមច្បាប់ ហើយក្រុមការងារអធិការកិច្ចអន្តរក្រសួងបានចុះធ្វើអធិការកិច្ចរួមគ្នាតែមួយដងក្នុង១ឆ្នាំ ព្រមទាំងបានបន្តការលើកកម្ពស់លក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ ជាពិសេសផ្តោតលើកម្រិតហានិភ័យពាក់ព័ន្ធនឹងបទដ្ឋានស្នូលនៃលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ ដូចជាសេវាសង្គ្រោះអប្បបរមា បន្ទប់បំបៅកូន កន្លែងហូបបាយនៅតាមតំបន់ឧស្សាហកម្ម
- បានពង្រឹងយន្តការដោះស្រាយវិវាទការងារ ការដោះស្រាយកូដកម្ម បាតុកម្ម តាមរយៈគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា និងសហការជាមួយអង្គការដៃគូពាក់ព័ន្ធ និយោជក សហជីព សង្គមស៊ីវិល ដើម្បីអភិវឌ្ឍសុខដុមនីយកម្មសង្គមនិងទំនាក់ទំនងវិជ្ជាជីវៈ និងការលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ហើយអត្រានៃវិវាទការងារដែលបានដោះស្រាយក៏មានអត្រាខ្ពស់ប្រមាណ៨០% ក្នុងមួយឆ្នាំផងដែរ
- បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ដោយបានបើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងវិស័យទេសចរណ៍ដែលព្យួរកិច្ចសន្យាការងារដោយសារជំងឺកូវីដ ១៩-ព្រមទាំងបានសម្របសម្រួលនិងចូលរួមយុទ្ធនាការជាតិចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ដល់ប្រជាពលរដ្ឋ ជាពិសេសកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស បានសរុបប្រមាណ៩៩ម៉ឺននាក់។ ក្រសួងបានខិតខំពង្រឹងវិធានសុខាភិបាល លក្ខខណ្ឌការងារ និងកែសម្រួលវិធានអនាម័យ សុវត្ថិភាព និងសុខភាពការងារ នៅតាមរោងចក្រ សហគ្រាស និងពង្រឹងការអប់រំផ្សព្វផ្សាយការយល់ដឹងអំពីផលវិបាកដោយសារការរីករាលដាលនៃជំងឺកូវីដ១៩- ដើម្បីចូលរួមកាត់បន្ថយការឆ្លងពីកម្មករនិយោជិតម្នាក់ទៅម្នាក់ទៀត និងធ្វើឱ្យរោងចក្រ សហគ្រាសអាចដំណើរការជាប្រក្រតី ធានាបាននូវនិរន្តរភាពអាជីវកម្មផលិតកម្ម ជួយកាត់បន្ថយនូវការបាត់បង់ការងារធ្វើនិងចំណូលរបស់កម្មករនិយោជិត
- បានបង្កើតក្រុមការងារដោះស្រាយការរីករាលដាលនៃជំងឺកូវីដ-១៩ តាមបណ្តារោងចក្រសហគ្រាសនានា ក្នុងរាជធានី ខេត្ត ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយកំណត់លក្ខណវិនិច្ឆ័យក្នុងការផ្អាកនិងបើកឡើងវិញនូវសកម្មភាពអាជីវកម្ម ផលិតកម្ម ដោយវិធានការរដ្ឋបាល។ ជាមួយគ្នានេះ ក្រសួងក៏បានដាក់ចេញនូវវិធានការចាំបាច់នានា ពេលបើកដំណើរការរោងចក្រ សហគ្រាសឡើងវិញ ដោយអនុវត្តវិធានការការពារការរីករាលដាលជំងឺកូវីដ-១៩ ក្រសួងបានចុះវាយតម្លៃអំពីកម្រិតហានិភ័យនៃការផ្អាកសកម្មភាពអាជីវកម្មផលិតកម្មរបស់រោងចក្រសហគ្រាសទាំងស្រុងឬផ្នែកខ្លះនៃរោងចក្រ សហគ្រាស
- បានពង្រឹងនិងពង្រីកយន្តការ **"វេទិកាការងារ"** ដោយបានរៀបចំពិព័រណ៍ការងារ ទិវាជ្រើសរើសកម្លាំងពលកម្មថ្នាក់ជាតិនិងនៅតាមមូលដ្ឋានសរុបចំនួន១០៩លើក និងបានពង្រីកការ

ផ្តល់សេវាការងារទូទាំងប្រទេសដោយសារការពង្រីកសេវាមជ្ឈមណ្ឌលការងាររហូតដល់ចំនួន១៤និងមជ្ឈមណ្ឌលការងារចល័តចំនួន៣ និងការកើនឡើងនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការផ្តល់សេវា ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវា

- បានរៀបចំច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី នៅឆ្នាំ២០១៩ ដែលមានវិសាលភាពកាន់តែទូលំទូលាយ ធានាសង្គតិភាពនិងសមធម៌រវាងមន្ត្រីរាជការសាធារណៈនិងកម្មករនិយោជិត និងបានពង្រឹងការអនុវត្តរបបសន្តិសុខសង្គម ដោយបានចុះបញ្ជិកាសមាជិកផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត និងសម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន ដោយបានចុះបញ្ជិកាសមាជិកសរុបចំនួន២,៤លាននាក់ (ស្រី១,៥លាននាក់) និងបានផ្តល់តារកាលិកផ្នែកហានិភ័យការងារចំនួន១៦៤.៦៦២នាក់ ចំណាយថវិកាអស់១៥១,៣៣ប៊ីលានរៀល។ ក្រសួងបានបន្តការពិនិត្យព្យាបាលជំងឺដោយមិនបង់ប្រាក់ជូនកម្មករ និយោជិត តាមរយៈការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដោយបានពង្រីកសមាជិកដល់ចំនួនប្រមាណ២,៦លាននាក់(ស្រី១,៦លាននាក់) និងមានអ្នកទៅប្រើប្រាស់សេវាកើនដល់ចំនួន៨ ០៩៨ ០៤០ដង/នាក់ និងចំណាយថវិកាអស់ប្រមាណ១ ០០០,៤១ ប៊ីលានរៀល ហើយបានកំពុងរៀបចំដាក់ឱ្យដំណើរការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននាពេលខាងមុខនេះផងដែរ។

៣.៩៧- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការអនុវត្តសិទ្ធិសេរីភាពសហជីពផ្ទុយពីលក្ខន្តិកៈសហជីព ការមិនគោរពភាពជាតំណាងបំផុត និងបទប្បញ្ញត្តិជាធរមានដែលមិនស្របតាមច្បាប់ស្តីពីសហជីព បណ្តាលឱ្យកើតមានវិវាទ ហើយដឹកនាំធ្វើកូដកម្មដោយខុសនីតិវិធីច្បាប់ និងមិនបានបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការបញ្ឈប់កម្មករនិយោជិត ដែលជាជនត្រូវបានការពារ
- ការរៀបចំវគ្គបណ្តុះបណ្តាលដល់កម្មករនិយោជិតនិងនិយោជកនៅមានកម្រិត ដែលធ្វើឱ្យការយល់ដឹងពីរបៀបរបបធ្វើការងារ សិទ្ធិការងារ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅមានកម្រិត
- ការរីករាលដាលនៃជំងឺកូវីដ១៩ ធ្វើឱ្យប៉ះពាល់ដល់ខ្សែច្រ-វាក់ផលិតកម្ម ការផលិត និងការកើតចេញជាកូដកម្ម បាតុកម្ម ទាមទារប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ មកពីការលុបការបញ្ជាទិញ ការព្យួរកិច្ចសន្យាការងារ ការកាត់បន្ថយចំនួនកម្មករនិយោជិត ការព្យួរការងារ និងការបិទទ្វារលែងដំណើរការ ហើយចំនួនកម្មករនិយោជិតបានចុះបញ្ជិកាការបង់ភាគទានទាំងផ្នែកហានិភ័យនិងផ្នែកថែទាំសុខភាពក៏មានការថយចុះ
- ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នមានវិសាលភាពត្រឹមតែវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ដែលត្រូវសិក្សាពីលទ្ធភាពបន្ថែមក្នុងការពង្រីកវិសាលភាព និងទាមទារឱ្យមានការវិភាគបែបសេដ្ឋកិច្ចស្មុគស្មាញនិងប្រើប្រាស់ធនធានច្រើន និងមិនទាន់មានឧបករណ៍និងយន្តការក្នុងការតាមដាន វាយតម្លៃបម្រែបម្រួលប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា

- កង្វះខាតការគ្រប់គ្រងនិងការផ្ដល់ឯកសារស្របច្បាប់ជូនពលករ នីតិវិធី និងការរៀបចំបែបបទបញ្ជូនពលករទៅបរទេសមានរយៈពេលវែង ព្រមទាំងតួនាទីរបស់ទីភ្នាក់ងារជ្រើសរើសឯកជនមួយចំនួននៅមានកម្រិត ដែលតម្រូវឱ្យបន្តយកចិត្តទុកដាក់ក្នុងការអនុវត្តគោលនយោបាយស្ដីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា
- ការយល់ដឹងអំពីប្រកាសនិងបទបញ្ញានានារបស់កម្មករនិយោជិតខ្មែរ ជនបរទេស និយោជក អ្នកគ្រប់គ្រង និងរដ្ឋបាល នៅតាមរោងចក្រ សហគ្រាស នៅមានកម្រិតក្នុងការបំពេញបែបបទក្នុងការចុះបញ្ជីតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម និងការប្រើប្រាស់ហត្ថពលកម្មបរទេស។

## ៥.២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព

៣.៩៨- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រេចបានសមិទ្ធផលសំខាន់ៗទាក់ទងនឹងសហគ្រាសធុនតូចនិងមធ្យមដូចខាងក្រោម៖

- សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសរុបមានចំនួន៤៣ ០៨២មូលដ្ឋាន សរុបកម្លាំងពលកម្មចំនួន៤២៨ពាន់នាក់
- បានអនុវត្តគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូចនិងមធ្យម និងការលើកទឹកចិត្តផ្នែកឥណទាន តាមរយៈធនាគារសហគ្រាសធុនតូចនិងមធ្យម និងការកែទម្រង់អត្រាការប្រាក់កម្ចីសម្រាប់វិស័យនេះ និងបានកំពុងអនុវត្តបន្តដោយយកចិត្តទុកដាក់
- បន្តធ្វើប្រតិភូកម្មអំណាចជូនដល់រដ្ឋបាលក្រុង ស្រុក ខេត្ត និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពជាងមុនក្នុងការគ្រប់គ្រងមូលដ្ឋានសហគ្រាស រោងចក្រ ឧស្សាហកម្ម សិប្បកម្មគ្រប់ប្រភេទ តាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- បានបន្តការយកចិត្តទុកដាក់បន្ថែម និងខិតខំបម្រើសេវាសាធារណៈជូនធុរជនឱ្យបានល្អ ឱ្យបានលឿន និងមានតម្លាភាព ដោយបង្វែរទៅរកការអនុវត្តតាមប្រព័ន្ធអនឡាញឱ្យបានជាអតិបរមា
- បានបញ្ចប់សេចក្ដីព្រាងគោលនយោបាយលើកទឹកចិត្ត សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ចែកចេញជាបីផ្នែក គឺផ្នែកបច្ចេកទេស ផ្នែកហិរញ្ញវត្ថុ និងផ្នែកទីផ្សារ
- បានសាកល្បងបង្កើតសួនអេកូ សហគ្រាសធុនតូចនិងមធ្យម នៅខេត្តកណ្ដាល និងពីរកន្លែងទៀតនៅខេត្តកំពង់ចាមនិងកំពង់ឆ្នាំង ក្រោមប្រធានបទ“ខេត្តមួយសួនសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មមួយ” តាមរយៈកិច្ចសហប្រតិបត្តិការមេគង្គ ឡានឆាង

៣.៩៩- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ បានធ្វើឱ្យការជំរុញដំណើរការរោងចក្រ ការបង្កើតរោងចក្រថ្មី និងមូលដ្ឋានរោងចក្រសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បានជួបឧបសគ្គនិងមានតួលេខថយចុះដែលមិនធ្លាប់មានពីមុន

- ខ្វះធនធានមនុស្សមានសមត្ថភាព ជាពិសេសផ្នែកអភិវឌ្ឍវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់រៀបចំប្រព័ន្ធអនឡាញKey Single Portal ក្នុងការចុះបញ្ជីអនឡាញនិងសេវាកម្មផ្សេងទៀតរបស់ក្រសួង
- យន្តការច្រកចេញចូលតែមួយឬដំបូលតែមួយសម្រាប់ប្រមូលទិន្នន័យ និងចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម មិនទាន់ដំណើរការពេញលេញនៅឡើយ ដោយត្រូវការពេលវេលានិងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ
- សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មនៅរាយប៉ាយមិនទាន់ប្រមូលផ្ដុំនៅឡើយ ហើយយន្តការសម្រាប់ផ្ដល់និងទទួលព័ត៌មានអំពីសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្មនៅមានកម្រិត
- លទ្ធភាពទទួលបានហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់សមត្ថភាពវិស័យសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម នៅចោទជាបញ្ហានៅឡើយ។

៣.១០០- ដើម្បីចូលរួមអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទាក់ទាញការវិនិយោគ ដើម្បីបង្កើតចង្កោមសហគ្រាសធុនតូចនិងមធ្យម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- បាននិងកំពុងគិតគូរផ្ដល់ការលើកទឹកចិត្តដល់ការវិនិយោគបង្កើតបណ្ដុំសហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព នៅក្នុងសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីវិនិយោគ
- បានរៀបចំសិក្ខាសាលាស្ដីពីការតភ្ជាប់រវាងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេសនិងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា ដោយសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
- បានចូលរួមសិក្ខាសាលាស្ដីពីការផ្សព្វផ្សាយអនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព
- បានចូលរួមក្នុងកិច្ចប្រជុំផ្លាស់ប្ដូរបទពិសោធស្ដីពីការរៀបចំចង្កោមសិប្បកម្មខ្នាតតូចនិងមធ្យម។

៣.១០១- ក្រសួងពាណិជ្ជកម្ម សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- អភិវឌ្ឍកិច្ចការស្រាវជ្រាវនិងបណ្ដុះបណ្ដាលពាណិជ្ជកម្ម (១)បានរៀបចំវគ្គបណ្ដុះបណ្ដាលនៅថ្នាក់ជាតិស្ដីពីការគ្រប់គ្រងហានិភ័យអាជីវកម្មនិងលក្ខខណ្ឌស្ដង់ដាពាណិជ្ជកម្ម (២) បានរៀបចំវគ្គបណ្ដុះបណ្ដាលនៅថ្នាក់ក្រោមជាតិស្ដីពីការស្វែងរកទីផ្សារ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នីតិវិធីនាំចេញនាំចូលកសិផល ការប្រើប្រាស់ច្បាប់កម្មសិទ្ធិបញ្ញា អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញ នាំចូលផលិតកម្មកសិកម្មតាមកិច្ចសន្យាកិច្ចសម្រួលពាណិជ្ជកម្មនៅកម្ពុជា (៣)បានសិក្សាស្រាវជ្រាវជាបឋមលើដំណាំចេក ស្វាយចន្ទី បោះពុម្ពអត្ថបទស្រាវជ្រាវទាក់ទងនឹងរបាំងពន្ធគយនិងរបាំងមិនមែនពន្ធគយ លើមុខទំនិញសក្ដានុពលសម្រាប់ការនាំចេញ ការសិក្សាស្រាវជ្រាវស្ដីពីPublic Private Partnership for Social Goods ចូលរួមធ្វើការសិក្សាស្រាវជ្រាវអំពីយុទ្ធសាស្ត្រពាណិជ្ជកម្មដើម្បីទាញយកប្រយោជន៍ជាអតិបរិមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់កម្ពុជា

- អភិវឌ្ឍកិច្ចការពាណិជ្ជកម្មនៅតាមរាជធានី ខេត្ត (១)បានផ្សព្វផ្សាយនិងជំរុញទស្សនៈថ្មីៗ ដើម្បីពង្រីកសកម្មភាពពាណិជ្ជកម្ម ដូចជាជំរុញចលនាភូមិមួយផលិតផលមួយ ការផលិតទំនិញសរីរាង្គតាមតម្រូវការទីផ្សារ ជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម សិក្សាទំនិញសក្តានុពល (២)បានផ្តល់ការប្រឹក្សានិងពិគ្រោះយោបល់ពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មនិងការធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម (៣)បានរៀបចំផ្សារចុងសប្តាហ៍ ដើម្បីដាក់តាំងលក់បន្លែសុវត្ថិភាព មាន់ស្រែ ពងមាន់ស្រែ អង្ករប្រណីត និងដំណាំកសិផលដទៃទៀត (៤)បានចូលរួមវេទិកាសាធារណៈដើម្បីប្រមូលយកនូវសំណូមពររបស់ប្រជាពលរដ្ឋនិងអាជីវករទាក់ទងនឹងវិស័យពាណិជ្ជកម្ម សំដៅផ្តល់នូវដំណោះស្រាយចំពោះមុខទាន់ពេលវេលា (៥)បានផ្សព្វផ្សាយណែនាំអំពីតម្រូវការទីផ្សារ ពិសេសចំពោះមុខទំនិញកសិផលដែលជាតម្រូវការទីផ្សារក្នុងស្រុកនិងទីផ្សារអន្តរជាតិ ដើម្បីតម្រង់ទិសឱ្យកសិករអាចសម្រេចចិត្តដាំដុះបានត្រឹមត្រូវជៀសវាងការធ្លាក់ថ្លៃនិងទំនិញកកស្ទះ (៦)បានចុះបង្ហាត់បង្រៀនកសិករពីចំណេះដឹងអាជីវកម្មនិងរបៀបកត់ត្រាសៀវភៅដល់សមា ជិកក្រុមផលិត (៧)បានរៀបចំចង្កោម(អ្នកប្រមូលទិញ អ្នកផលិត អ្នកផ្តល់សេវា) លើផលិតផលមាន់ស្រែ ដំឡូងមី បន្លែ និងផលិតផលដទៃទៀតដែលមានការតភ្ជាប់រវាងអ្នកទិញទំនិញនិងអ្នកលក់ទំនិញរវាងទំនិញនិងសេវា (៨)បានពន្យល់ណែនាំពីរបៀបជ្រើសរើស និងការដាក់តាំងលក់នូវទំនិញជាគ្រឿងឧបភោគនិងបរិភោគ ព្រមទាំងធ្វើការអប់រំក៏ដូចជាណែនាំដល់អាជីវករឱ្យលក់ទំនិញដែលមានគុណភាពល្អ មានស្លាកសញ្ញាត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិនៃច្បាប់ និង(៩)បានសម្របសម្រួលខ្សែបន្ទាត់ឥណទានជាកម្ចីដើម្បីពង្រីកអាជីវកម្ម ផលិតកម្ម ដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម
- អភិវឌ្ឍយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម (១)បានបើកវគ្គបណ្តុះបណ្តាលនិងវគ្គផ្សព្វផ្សាយផ្តល់គំនិតនិងផ្លាស់ប្តូរឥរិយាបថអវិជ្ជមានទាំងឡាយដែលមានភាពរើសអើងដល់ស្ត្រី និងក្មេងស្រី និងរារាំងដល់សកម្មភាពអសកម្មដែលនាំឱ្យគ្មានការរីកចម្រើននៅក្នុងសង្គមជាតិ និងការគោរពសិទ្ធិមនុស្ស (២)បានបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម តាមរយៈសិក្ខាសាលានានាក្នុងវិស័យពាណិជ្ជកម្ម និង(៣)បានរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០២១-២០២៥ ក្នុងវិស័យពាណិជ្ជកម្ម។

៣.១០២- ទន្ទឹមនឹងសមិទ្ធផលខាងលើ បញ្ហាប្រឈមសំខាន់មួយដែលក្រសួងពាណិជកម្មកំពុងបន្តប្រឈម គឺកម្រិតយល់ដឹងពីគោលគំនិតយេនឌ័រនិងអនុសញ្ញាស៊ី-ដ ក្នុងវិស័យពាណិជ្ជកម្មរបស់មន្ត្រីរាជការ អាជីវករ ពាណិជ្ជករ នៅមានកម្រិត សមត្ថភាពផលិតទំនិញនិងសេវារបស់សហគ្រាសធុនតូចនិងមធ្យមនៅមានកម្រិតទាំងបរិមាណនិងគុណភាពនៅឡើយ។

## ៥.៣- ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន

៣.១០៣- ក្រសួងពាណិជកម្ម សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ពង្រឹងការអភិវឌ្ឍវិស័យឯកជន (១)បានរៀបចំអនុក្រឹត្យស្តីពីការទទួលស្គាល់សមាជិកសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ បន្ទាយមានជ័យ ព្រះសីហនុ កោះកុង មណ្ឌលគិរី ក្រចេះ

ស្ទឹងត្រែង រតនគិរី សៀមរាប **និងខេត្តឧត្តរមានជ័យ** (២)បានរៀបចំប្រកាសស្តីពីការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ ព្រះសីហនុ និងមណ្ឌលខេត្តកណ្តាល កំពង់ឆ្នាំង និងប្រកាសស្តីពីការទទួលស្គាល់ប្រធានសហព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជាអាណត្តិទី៣ និង(៣)បានរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតក្រុមការងាររៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិនិងក្រុមប្រឹក្សាភិបាលនៃសមាគមលើកកម្ពស់ម្រេចកំពត

- ពង្រឹងនិងពង្រីកកិច្ចសម្រួលពាណិជ្ជកម្ម (១)បានរៀបចំប្រកាសស្តីពីកម្រងសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីកាត់បន្ថយតម្លៃសេវាសាធារណៈសំដៅជំរុញកិច្ចសម្រួលពាណិជ្ជកម្ម (២)បានធ្វើប្រតិភូកម្មក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី(D) សម្រាប់ទំនិញកសិផលដល់គ្រប់មន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន(៣) បានតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្រដើមកំណើតទំនិញជាមួយធនាគារសម្រាប់ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (៤)បានបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំឯកសារនាំចេញ នាំចូល និង(៥)បានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើប្រសិទ្ធភាពនៃការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មជាមួយវិស័យឯកជន។

## ៥.៤- ការពង្រឹងការប្រកួតប្រជែង

៣.១០៤- ក្រសួងពាណិជកម្ម សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- កិច្ចការប្រកួតប្រជែងនិងកិច្ចការការពារអ្នកប្រើប្រាស់ (១) បានរៀបចំនិងចូលរួមកសាងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនិងគោលនយោបាយប្រកួតប្រជែងអាស៊ាន និង (២)បានតាមដាន ត្រួតពិនិត្យ និងសម្របសម្រួលជាប្រចាំលើបញ្ហាពាក់ព័ន្ធនឹងការប្រកួតប្រជែងដោយមិនស្មោះត្រង់
- ពង្រឹងយន្តការដោះស្រាយវិវាទពាណិជ្ជកម្ម (១)បានសម្របសម្រួលនិងដោះស្រាយជាមូលដ្ឋានលើវិវាទពាណិជ្ជកម្ម និង(២)បានសហការជាមួយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងជំរុញដំណើរការតុលាការពាណិជ្ជកម្ម ដើម្បីធានាឱ្យការដោះស្រាយវិវាទពាណិជ្ជកម្មប្រកបដោយភាពត្រឹមត្រូវនិងការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្មមានភាពស្មោះត្រង់។

៣.១០៥- បញ្ហាប្រឈមសំខាន់មួយដែលក្រសួងពាណិជ្ជកម្មជួបប្រទះ គឺកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធនៅមានកម្រិតដែលនាំមកនូវការយល់ច្រឡំចំពោះសមត្ថកិច្ចទទួលខុសត្រូវជាក់លាក់តាមអាណត្តិការងារ។

# ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

## ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ

៣.១០៦- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក.) បានអនុវត្តសកម្មភាពសំខាន់ៗ ក្នុងការលើកកម្ពស់ឧស្សាហកម្មកែច្នៃ តាមរយៈការជំរុញការវិនិយោគលើការកែច្នៃកសិផលដែលមានសក្តានុពលមានដូចខាងក្រោម៖

- បានចុះកិច្ចព្រមព្រៀងជាមួយក្រុមការងារកាំវ៉ាក់ក្នុងកិច្ចសហប្រតិបត្តិការកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា អូស្ត្រាលី ស្តីពីការលើកកម្ពស់ការវិនិយោគក្នុងវិស័យកសិចំណីអាហារនៅកម្ពុជា ដែលក្នុងនោះបានបង្កើតផ្នែកទទួលបន្ទុកវិស័យកសិចំណីអាហារប្រចាំនៅ ក.អ.ក. ដែលមានមន្ត្រីបង្គោលច្បាស់លាស់ទទួលការងារនេះ និងរៀបចំឱ្យមានការចូលរួមពីសំណាក់មន្ត្រីបង្គោលពីក្រសួងពាក់ព័ន្ធផងដែរ ដើម្បីងាយស្រួលក្នុងការបណ្តុះបណ្តាល និងចែករំលែកបទពិសោធ ដែលសមិទ្ធផលនេះគឺជាផ្លែផ្កាមួយនៃកិច្ចសហប្រតិបត្តិការកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា អូស្ត្រាលី ស្តីពីការលើកកម្ពស់ការវិនិយោគក្នុងវិស័យកសិចំណីអាហារនៅកម្ពុជា។

៣.១០៧- ក្រសួងពាណិជ្ជកម្មសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- ការបង្កើនផលិតភាពផលិតកម្មផ្នែកកសិកម្ម (១) ពង្រឹងនិងពង្រីកផលិតភាពការអនុវត្ត “គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច” ដែលផ្តោតលើការបង្កើនបរិមាណគុណភាពនិងការកែច្នៃនៃផលិតផល៥ប្រភេទគឺស្រូវក្រអូប បន្លែ មាន់ស្រែ ដំឡូងមី និងសរសៃសូត្រ គ្របដណ្តប់១៧ខេត្ត (២) សហការជាមួយកម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា អូស្ត្រាលី ដើម្បីរៀបចំពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពី “ទីផ្សារសម្រាប់ផលិតផលកសិកម្មដែលមានតម្លៃខ្ពស់របស់កម្ពុជា” (៣) ជំរុញផលិតផលកសិកម្មកម្ពុជាឱ្យមានការប្រើប្រាស់កាន់តែច្រើនជំនួសឱ្យការនាំចូលនិងឈានទៅរកការនាំចេញទៅលក់នៅលើទីផ្សារអន្តរជាតិ (៤) ពង្រឹងនិងពង្រីកនូវយុទ្ធនាការទិញផលិតផលខ្មែរ ជាពិសេសផលិតផលកសិកម្ម និង(៥) ចូលរួមអភិវឌ្ឍស្ថាប័នក្នុងវិស័យឯកជនលើផ្នែកកសិកម្ម
- ពង្រឹងនិងពង្រីកនូវសន្តិសុខស្បៀង (១) តាមដានស្តុកផលិតផលក្នុងស្រុកចាំបាច់សម្រាប់ ជីវភាពប្រចាំថ្ងៃ (២) ពង្រឹងនិងថែរក្សាស្តុកយុទ្ធសាស្ត្រស្បៀងត្រៀមបម្រុងសម្រាប់ចូលរួម អន្តរាគមន៍សង្គ្រោះដល់ជនរងគ្រោះដោយទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះមហន្តរាយផ្សេងៗ (៣) ពង្រឹងនិងធានានូវស្ថិរភាពតម្លៃអង្ករទីផ្សារក្នុងស្រុក ដើម្បីរក្សានូវផលប្រយោជន៍ជីវភាពរស់នៅរបស់ប្រជាជន និងទប់ស្កាត់កុំឱ្យជនឆ្លៀតឱកាសធ្វើឱ្យចលាចលនៅលើទីផ្សារ (៤) ពង្រឹងនិងពង្រីកការចរចាទ្វេភាគីស្តីពីការធ្វើពាណិជ្ជកម្មអង្ករ (៥) ចូលរួមពិនិត្យ រៀបចំគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករក្នុងក្របខ័ណ្ឌឥណទានសម្បទានសហប្រតិបត្តិការពីសាធារណរដ្ឋប្រជាមានិតចិនជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីចិន និង(៦) អភិវឌ្ឍសមត្ថភាពផលិតនិងស្តុកទុកស្រូវ/អង្ករដើម្បីបង្កើនសមត្ថភាពផ្គត់ផ្គង់ក្នុងពេលចាំបាច់។

៣.១០៨- ចាប់ពីឆ្នាំ២០១៩មកដល់ពាក់កណ្ដាលឆ្នាំ២០២១នេះ ក្រសួងបានបណ្ដុះបណ្ដាលមន្ត្រីសរុបចំនួន២ ៣០៨នាក់។ ដោយឡែកក្រសួង បានបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមូលដ្ឋាន រួមមានជំនាញកាត់ដេរ ជួសជុលកុំព្យូទ័រ ជួសជុលម៉ាស៊ីនដេរ គ្រឿងយន្តកសិកម្ម ធ្វើសង្ហារិម អ៊ុតសក់ កាត់សក់។ល។ សរុបបានចំនួន៤ ៤១៦នាក់។ ការស្ដារនិងសាងសង់ផ្លូវជនបទបានចំនួនប្រវែង១ ១៦០គ.ម. បើបូកទាំងទិន្នន័យដើមគ្រាពីឆ្នាំ២០១៨មក មានប្រវែងសរុបចំនួន៣០ ៤០២,៤២គ.ម.។ កែលម្អផ្លូវជនបទទៅជាកៅស៊ូពីរជាន់ឬបេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុចំនួន៥៩៦គ.ម.។ សាងសង់ស្ពានបេតុងបានចំនួន១៩កន្លែង ថែទាំនិងជួសជុលស្ពានបេតុងនិងសំណង់បង្ហៀរទឹកសរុបចំនួន៣១កន្លែង សាងសង់អណ្ដូងទឹកគ្រប់ប្រភេទបានចំនួន៦ ៤៩៧អណ្ដូង បានដាំកូនឈើអមសងខាងផ្លូវជនបទតាមបណ្ដារាជធានី ខេត្ត បានចំនួន៨៨ ០០៤ដើម ចែកពាងត្រងទឹកភ្លៀងដល់ប្រជាពលរដ្ឋតាមគ្រួសារបានចំនួន១០៦ ២៨៦ពាង សាងសង់បង្គន់អនាម័យជនបទបានចំនួន៥ ៤៣៧បង្គន់។

### តារាង៣.២៨ : សូចនាករវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៨ ចាប់ផ្ដើម | ២០១៩ | ២០២០ | ពាក់កណ្ដាល ឆ្នាំ២០២១ |
|---|---|---|---|---|---|
| ការស្ដារនិងសាងសង់ផ្លូវជនបទ (លើប្រវែងផ្លូវសរុប៤៥ ២០០គ.ម.) | ផែនការ (គ.ម.) | ២៩ ២៤២,៤២ | ៣០ ៨៦០ | ៣៣ ០៧៩ | ៣៦ ១៨០ |
| | អនុវត្ត (គ.ម.) | ២៩ ២៤២,៤២ | ២៩ ៦៣៤,៤២ | ៣០ ៣១២,៤២ | ៣០ ៤០២,៤២ |
| កែលម្អផ្លូវជនបទទៅជាកៅស៊ូពីរជាន់ ឬបេតុង ដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុ | ផែនការ (គ.ម.) | ១០០ | ១២០ | ១៤៤ | ១៧២ |
| | អនុវត្ត (គ.ម.) | ១០០ | ២៦១ | ១៨៨ | ១៤៧ |
| ថែទាំផ្លូវជាលក្ខណៈខួបនិងប្រចាំ | ផែនការ (គ.ម.) | ៧ ៤៥៧,៣៣ | ៨ ៩៤៨ | ១០ ៧៣៨ | ១២ ៨៨៦ |
| | អនុវត្ត (គ.ម.) | ៧ ៤៥៧,៣៣ | ១០ ៦៦៤,៣៣ | ១៤ ០៨១,៣៣ | ១៧ ៥៧៨,៣៣ |
| សមាមាត្រនិងប្រជាពលរដ្ឋកម្ពុជានៅតំបន់ជនបទដែលទទួលបានសេវាទឹកស្អាតនិងមានសុវត្ថិភាព | ផែនការ (%) | ៥៨ | ៦៧ | ៧២ | ៧៨ |
| | អនុវត្ត (%) | ៦០ | ៧៥ | ៧៧ | ៨៤ |
| សមាមាត្រនិងប្រជាពលរដ្ឋកម្ពុជានៅតំបន់ជនបទដែលទទួលបានសេវាអនាម័យ | ផែនការ (%) | ៧១ | ៧៨ | ៨១ | ៨៤ |
| | អនុវត្ត (%) | ៦០ | ៧៤.៦ | ៧៦.៩ | ៧៧ |
| | ផែនការ (ខេត្ត) | ០ | ១ | ២ | ៣ |

| | | | | | |
|---|---|---|---|---|---|
| ខេត្តដែលបានបញ្ឈប់បន្ទោបង់ពាសវាលពាសកាល | អនុវត្ត (ខេត្ត) | 0 | 0 | 0 | 0 |
| មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈចល័ត | ផែនការ (មណ្ឌល) | 0 | ៥ | ១០ | ១៥ |
| | អនុវត្ត (មណ្ឌល) | 0 | 0 | ១ | 0 |
| ចំនួនប្រជាពលរដ្ឋដែលបានទទួលការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈមូលដ្ឋាន | ផែនការ (នាក់) | ៤ ៣១៣ | ៧ 000 | ១០ 000 | ១៥ 000 |
| | អនុវត្ត (នាក់) | ៤ ៣១៣ | ៦ ៨០២ | ៨ ៦៣៤ | ៨ ៧២៩ |
| ចំនួនគ្រួសារដែលបានបង្កើតសហគ្រាសខ្នាតតូចថ្មី ក្រោយបានទទួលការបណ្ដុះបណ្ដាលជំនាញមូលដ្ឋាន | ផែនការ (គ្រួសារ) | ពុំមានទិន្នន័យ | ១៥0 | ២៥0 | ៣៥0 |
| | អនុវត្ត (គ្រួសារ) | 0 | 0 | 0 | 0 |
| មន្ត្រីរាជការក្រសួងដែលទទួលបានការពង្រឹងសមត្ថភាពដល់៨០ម៉ោងក្នុងមួយឆ្នាំៗក្នុងម្នាក់ៗ | ផែនការ (ម៉ោង/នាក់) | ៤២ម៉ោង/ម្នាក់ | ៤៥ម៉ោង/ម្នាក់ | ៥០ម៉ោង/ម្នាក់ | ៦០ម៉ោង/ម្នាក់ |
| | អនុវត្ត (ម៉ោង/នាក់) | ៤២ម៉ោង/ម្នាក់ | - | - | 0 |
| ចំនួនសហគមន៍ជនជាតិដើមភាគតិចបានទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទ | ផែនការ (សហគមន៍) | ១៤៣ | ១៥៣ | ១៦៣ | ១៧៣ |
| | អនុវត្ត (សហគមន៍) | ១៤៣ | ១៥៤ | ១៥៥ | ១៥៦ |

ប្រភព : ក្រសួងអភិវឌ្ឍន៍ជនបទ

៣.១០៩- រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ២០១៤-២០២៥ ដោយតំបន់ជនបទនឹងទទួលបានទឹកស្អាតប្រើប្រាស់១០០%នៅត្រឹមឆ្នាំ២០២៥។ បច្ចុប្បន្ន អត្រាគ្របដណ្ដប់ទឹកស្អាតជនបទ៨៤% និងអនាម័យជនបទ៧៧%។ ក្រសួងបានបណ្ដុះបណ្ដាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានចំនួន ១៣៩វគ្គ បណ្ដុះបណ្ដាលសួនដំណាំគ្រួសារនិងរបៀបធ្វើរោងជីកំប៉ុស្តិ៍បានចំនួន៥៤៥គ្រួសារ បានផ្ដល់ប្រឹក្សាដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការងារទីផ្សារបានចំនួន៩០នាក់ វគ្គបណ្ដុះបណ្ដាលជំនាញ បង្កើតការងារថ្មីជូនប្រជាពលរដ្ឋ ដូចជាតម្បាញហូល ក្រមា មេជាងចង្ក្រានជីវឧស្ម័ន សិប្បកម្មផលិតសាប៊ូ ដែលមានអ្នកចូលរួម៩៣៨នាក់។ សម្រាប់ការអភិរក្សនិងអភិវឌ្ឍន៍ជនជាតិដើមភាគតិច ក្រសួងបានវាយតម្លៃនិងកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចបានចំនួន២៩៩សហគមន៍ និងពង្រឹងសមត្ថភាពជនជាតិដើមភាគតិចបានចំនួន៤៦៥ភូមិ។

៣.១១០- ទន្ទឹមនឹងការទទួលបានជោគជ័យក្នុងការអនុវត្តការងារសម្រាប់ឆ្នាំ២០១៩-២០២១ កន្លងមកនេះ ក្រសួងក៏នៅមានជួបប្រទះនូវបញ្ហានិងការប្រឈមមួយចំនួនដូចខាងក្រោម៖

- វិធានការទប់ស្កាត់ជំងឺកូវីដ-១៩ បានធ្វើឱ្យរាំងស្ទះដល់ការអនុវត្តសកម្មភាពមួយចំនួន
- ថវិកាជាតិនៅមានកម្រិត មិនអាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនិងការកែលម្អផ្លូវពីផ្លូវល្បាយក្រួសទៅជាផ្លូវក្រាលកៅស៊ូនិងបេតុង
- កង្វះអគារសិក្សាសមរម្យ កន្លែងសម្រាប់សិក្ខាកាមនិងបុគ្គលិកស្នាក់នៅ និងរោងជាងសម្រាប់ហាត់ការ
- ខ្វះគ្រូបង្គោលដែលមានជំនាញច្បាស់លាស់នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន
- ប្រជាពលរដ្ឋនៅជនបទមួយចំនួន នៅមានទម្លាប់ពឹងផ្អែកលើការគាំទ្រពីខាងក្រៅជាងការចូលរួម និងចំណេះដឹងក្នុងភាពជាម្ចាស់នៅមានកម្រិត។

៣.១១១- លទ្ធផលសំខាន់ៗដែលសម្រេចបាន ក្នុងការអនុវត្តគោលនយោបាយជាអាទិភាពលើវិស័យសកម្មភាពមីនមានដូចខាងក្រោម៖

- បានបញ្ចប់ការស្រាវជ្រាវចម្ការមីនដែលនៅសេសសល់ក្នុងស្រុកចំនួន៧៣
- ពហុកោណចំនួន៣ ៩៥៨ សមមូលផ្ទៃដីទំហំ៩២ ៣៩៤ ៧០៤ម² ត្រូវបានកាត់ចេញពីផ្ទៃដីដែលមានការសង្ស័យ តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស
- ផ្ទៃដីដែលសង្ស័យមានគ្រាប់បែកចង្កោមចំនួន៦០គ.ម² និងផ្ទៃដីមីនចំនួន២៨០គ.ម² ត្រូវបានបោសសម្អាត ក្នុងនោះបានរកឃើញនិងបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន៣៣ ៣៦០គ្រាប់ និងគ្រាប់មីនប្រឆាំងរថក្រោះចំនួន៦៤៤គ្រាប់
- ប្រជាពលរដ្ឋចំនួន២ ៨៤០ ៦១២នាក់ បានទទួលការអប់រំស្តីពីការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម
- បានបង្កើតយន្តការសម្រាប់គាំទ្រដល់ជនពិការដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនិងក្រុមគ្រួសារ ដោយបានសហការជាមួយភាគីពាក់ព័ន្ធដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការការពារនិងលើកកម្ពស់សិទ្ធិជនពិការ រួមទាំងគោលនយោបាយជាតិស្តីពីការជំរុញឱ្យមានជនពិការចូលបម្រើការងារក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលនិងវិស័យឯកជន
- បានពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិស្តីពីពិការភាព ដើម្បីធានាថាតម្រូវការនិងសិទ្ធិរបស់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមព្រមទាំងជនរងគ្រោះដោយប្រយោលត្រូវបានដោះស្រាយទាន់ពេលវេលានិងសមស្របតាមរយៈការសិក្សាគុណភាពជីវិត
- បានផ្តល់ការគាំទ្រដល់អ្នករស់រានជីវិតពីគ្រោះថ្នាក់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងជនរងគ្រោះដោយប្រយោល ក្នុងផលិតកម្មកសិកម្មខ្នាតតូច ដោយបានធ្វើសកម្មភាព

សិក្សាលើប្រាក់ចំណូលមធ្យមដែលទទួលបានពីផលិតកម្មចំណីអាហារខ្នាតតូចដែលរកបានក្នុងអតីតតំបន់ដែលមានមីន ដោយបែងចែកតាមភេទនិងស្ថានភាពជនជាតិដើម

- បានចូលរួមជំរុញការអនុវត្តកាតព្វកិច្ចនៃការអនុវត្តអនុសញ្ញាអន្តរជាតិ ស្ដីពីការហាមប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្សនិងការបំផ្លាញគ្រាប់មីន
- បន្តគាំទ្រប្រតិបត្តិការបោសសម្អាតមីនក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ដោយបានបញ្ជូនកងទ័ពមួកខៀវកម្ពុជាចំនួន១៥ក្រុម ឱ្យទៅចូលរួមបំពេញបេសកកម្មនៅសាធារណរដ្ឋស៊ូដង់ ស៊ូដង់ខាងត្បូង សាធារណរដ្ឋអាហ្វ្រិកកណ្ដាល ប្រទេសម៉ាលី និងប្រទេសលីបង់ សរុបកម្លាំង៧៨៧នាក់ ក្នុងនោះមានស្ត្រី៦៥នាក់។

**តារាង៣.២៩ : សូចនាករវិស័យសកម្មភាពមីននិងលទ្ធផលនៃការអនុវត្ត ឆ្នាំ២០១៩-២០២១**

| សូចនាករ | ឯកតា | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ ២០២១ |
|---|---|---|---|---|
| ចំនួនជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស្លាប់/របួស) | នាក់ | ៧៧ | ៦៥ | ២៦ |
| ចំនួនជនរងគ្រោះដោយសារការលេងនិងច្នៃគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស្លាប់/របួស) | នាក់ | ៤៨ | ៣០ | ១២ |
| ចំនួនជនពិការដោយសារមីនសំណល់ជាតិផ្ទុះពីសង្គ្រាមទទួលបានការ/ផ្សព្វផ្សាយពីសិទ្ធិ | នាក់ | ៣១២ | ២៣៤ | ១១៤ |
| ចំនួនជនពិការដោយសារមីនសំណល់ជាតិផ្ទុះពីសង្គ្រាមទទួលបានសេវា/ស្ដារលទ្ធភាពពលកម្មកាយសម្បទា | នាក់ | ៣ ៤០៩ | ៣ ៦៧៣ | ១ ៤៦៨ |
| ចំនួនជនពិការដោយសារមីនសំណល់ជាតិផ្ទុះពីសង្គ្រាមដែលទទួលបានការ/ចូលរួមចំណែកឧបត្ថម្ភពីអាជ្ញាធរមីន | នាក់ | ១១២ | ៩៤ | ៣៨ |
| សរុបផ្ទៃដីបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. | ១២ ៦៧៧ | ១៥ ៣២៨ | ១០ ២៤៦ |
| ផ្ទៃដីបោសសម្អាតមីន | ហ.ត. | ៩ ១៣៧ | ៩ ៤៧៨ | ៧ ៨៣៥ |
| ផ្ទៃដីបោសសម្អាតសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. | ៣ ៥៤០ | ៥ ៨៥០ | ២ ៤១១ |

ប្រភព : អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

៣.១១២- ទន្ទឹមនឹងសមិទ្ធផលខាងលើ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ប្រទេសម្ចាស់ជំនួយធំៗមួយចំនួនបានផ្លាស់ប្ដូរគោលនយោបាយរបស់ខ្លួន ដោយងាកទៅផ្ដល់ជំនួយលើវិស័យផ្សេងវិញ ធ្វើឱ្យគម្រោងផែនការបោសសម្អាតមួយចំនួនត្រូវបានផ្អាក
- ការកាត់តម្រឹមថវិការបស់រាជរដ្ឋាភិបាលកម្ពុជា បណ្ដាលឱ្យប៉ះពាល់ដល់ដំណើការរៀបចំកសាងផែនការបោសសម្អាត ក៏ដូចជាការចុះទៅពិនិត្យកិច្ចប្រតិបត្តិការនៅទីវាល
- ប្រតិបត្តិករមិនអាចដាក់ពង្រាយកម្លាំងបោសសម្អាតក្នុងតំបន់បិទខ្ទប់បានដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ លើសពីនេះ កម្លាំងបោសសម្អាតមួយចំនួនបានឆ្លងជំងឺកូវីដ-១៩ ដែលធ្វើឱ្យប៉ះពាល់ដល់ការបំពេញការងារយ៉ាងខ្លាំង។

៣.១១៣- គិតត្រឹមពាក់កណ្ដាលឆ្នាំ២០២១ ផ្ទៃដីដាំដុះដំណាំកសិកម្មសរុបសម្រេចបាន៣,៤៧៥លានហិកតា ក្នុងនោះផ្ទៃដីដាំដុះដំណាំស្រូវមានចំនួន២,៦៣៣លានហិកតា ដំណាំសាកវប្បកម្មមានចំនួន០,០៨៨លានហិកតា និងដំណាំឧស្សាហកម្មមានចំនួន០,៧៥៤លានហិកតា។ រីឯការនាំចេញផលិតផលកសិកម្មសម្រេចបាន៤៤៥លានតោន។, នៅក្នុងឆ្នាំ២០២០ ផ្ទៃដីដាំដុះដំណាំកសិកម្មសរុបសម្រេចបាន៥,០២៤លានហិកតានិងទទួលបានបរិមាណផលសរុបចំនួន២៩៧៥៨លានតោន។, ការនាំចេញផលិតផលកសិកម្មសរុប៤៨៧លានតោន។, ដោយឡែកនៅឆ្នាំ២០១៩ ផ្ទៃដីដាំដុះដំណាំកសិកម្មសម្រេចបានចំនួន៤,៨៨២លានហិកតា ដោយទទួលបានបរិមាណផលដំណាំចំនួន៣០,២២៩លានតោន និងបាននាំចេញផលិតផលកសិកម្មសរុប៤៨៨លានតោន។,

៣.១១៤- ចាប់ពីឆ្នាំ២០១៩ដល់ត្រឹមពាក់កណ្ដាលឆ្នាំ២០២១នេះ ផលិតកម្មសត្វមានការរីកចម្រើនគួរឱ្យកត់សម្គាល់ គឺចាប់ពី៤៥,៨៥លានក្បាលនៅឆ្នាំ២០១៩ កើនដល់៥៣,៩០លានក្បាល នៅឆ្នាំ២០២០ គឺកើនលើសឆ្នាំ២០១៩ចំនួន១៧,៦% ដែលធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានសមត្ថភាពផលិតសាច់សម្រាប់បម្រើតម្រូវការក្នុងស្រុកបានប្រមាណជា២៥៦ពាន់តោន ឬ៨៥%នៃតម្រូវការសាច់សរុបប្រមាណ៣០១ពាន់តោនក្នុង១ឆ្នាំ។ ក្នុងឆមាសទី១ ឆ្នាំ២០២១នេះ ផលិតកម្មសត្វសរុបកើនដល់៥១,២៦លានក្បាល ធៀបឆមាសទី១ឆ្នាំ២០២០ដែលមានចំនួន៤៧,២៣លានក្បាល គឺកើនបានចំនួន៨,៥% ដែលអាចផ្គត់ផ្គង់សាច់សត្វគ្រប់ប្រភេទបានចំនួន១៣៤,៤៥ពាន់តោន គឺស្មើ៥២,៩៣%នៃផែនការប្រចាំឆ្នាំចំនួន២៥៤ពាន់តោន។

៣.១១៥- ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ផលិតភាពក្នុងការដាំដុះ ក៏ដូចជាការចិញ្ចឹមសត្វនៅមានកម្រិតទាបនៅឡើយ ដែលបញ្ហាប្រឈមខ្លាំងក្នុងការប្រកួតប្រជែងទីផ្សារ ពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។ ម៉្យាងវិញទៀត គុណភាពនៃធាតុចូលកសិកម្មនិងសេវាផ្នែកកសិកម្មនៅថ្នាក់មូលដ្ឋាននៅមានភាពទន់ខ្សោយ។ ការបន្សាំរបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុ ការផ្សព្វផ្សាយបច្ចេកទេសតាមផ្នែកនីមួយៗ រួមទាំងការផ្ដល់ព័ត៌មានទីផ្សារកសិផលឱ្យបានទៅដល់កសិករនៅមានកម្រិត។ ម៉្យាងទៀត កសិករតែងជួបប្រទះនូវការធ្លាក់ចុះនៃតម្លៃកសិផលនៅលើទីផ្សារក្រោយការប្រមូលផល។ ការគ្រប់គ្រង ការប្រើប្រាស់ដីកសិកម្មឱ្យចំគោលដៅ និងសក្ដានុពលនៅតាមភូមិសាស្ត្រនីមួយៗនៅតែជាបញ្ហាដែលក្រសួងកំពុងគិតគូរអំពីការកំណត់តំបន់ដាំដុះឱ្យសមស្រប
- ប្រព័ន្ធស្រោចស្រពកសិកម្មនៅពុំទាន់បានគ្របដណ្ដប់លើផ្ទៃដីដាំដុះឱ្យបានទូលំទូលាយ ជាពិសេសការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកចូលស្រែដោយស្វ័យប្រវត្តិពុំទាន់បានពង្រីកដល់ដីស្រែរបស់កសិករនៅឡើយ

- ការងារស្រាវជ្រាវនិងការផ្តល់សេវាបច្ចេកទេសកសិកម្មនៅមានកម្រិត ហើយសមត្ថភាពទទួលយកចំណេះដឹងអំពីបច្ចេកទេសដាំដុះ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងការប្រើប្រាស់ធាតុចូលកសិកម្មសមស្របតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលរបស់ប្រជាកសិករក៏នៅមានកម្រិត ដែលបានជះឥទ្ធិពលដល់ថ្លៃដើមផលិតខ្ពស់ពិបាកប្រកួតប្រជែងនៅលើទីផ្សារ។ ការវិនិយោគក្នុងផ្នែកអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មនៅមានទំហំតូច ដែលត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់
- បទល្មើសនៃការលួចនាំចូលសត្វនិងសម្ភារៈកសិកម្មដោយខុសច្បាប់នៅតែកើតមាន ជាពិសេសខេត្តនៅជាប់ព្រំដែន។

៣.១១៦- ក្រសួងធនធានទឹកនិងឧតុនិយមសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានធ្វើការជួសជុល ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រទាំងតូចទាំងធំនៅទូទាំងប្រទេសក្នុងឆ្នាំ២០១៩-២០២១ ហើយសម្រេចបាន១៣៨គម្រោង ដែលបានបង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុបចំនួន៨៦ ៧៥៣ហ.ត. ក្នុងនោះ(ស្រូវរដូវវស្សា៥៧ ២១៧ហ.ត. និងស្រូវរដូវប្រាំង២៩ ៥៣៦ហ.ត.) និងស្រោចស្រពដំណាំរួមផ្សំបាន២ ២០៨ ហ.ត.
- បានជួលជុលសំណង់ទ្វារទឹក សរុបចំនួន៧៨កន្លែង សំណង់លូទឹក សរុបចំនួន៥៨កន្លែង សំណង់ស្ពាក់ទឹក សរុបចំនួន៤០កន្លែង និងសំណង់បង្ហៀរទឹក សរុបចំនួន៦កន្លែង
- បានធ្វើការជួសជុលថែទាំទំនប់ក្នុងរយៈពេល៣ឆ្នាំ(២០១៩-២០២១)នៅតាមបណ្តាខេត្តសរុបចំនួន៦៧កន្លែង ប្រវែង៧៧ ៣៣១ម.
- បានធ្វើការងារជីក ស្តារប្រឡាយក្នុងឆ្នាំ២០១៩-២០២១ នៅតាមបណ្តាខេត្តសរុបចំនួន១៦០ខ្សែ ប្រវែង៣៤២ ១០០ម.
- បានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹកនៅតាមប្រព័ន្ធធារាសាស្ត្រ ក្នុងឆ្នាំ២០១៩-២០២១ នៅតាមបណ្តាខេត្ត ហើយសម្រេចបានសរុបចំនួន៤៧សហគមន៍ ដែលមានផ្ទៃដីស្រូវសរុប១៥៣ ៥២៤ហ.ត. ក្នុងនោះផ្ទៃដីស្រូវវស្សា១០៧ ៥៣៣ហ.ត. ស្រូវប្រាំង ៤៥ ៩៩១ហ.ត. និងមាន២៧ ៥៨៥គ្រួសារ
- បានអនុវត្តការងាររៀបចំការពារច្រាំងទន្លេនៅក្នុងខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ក្នុងឆ្នាំ២០១៩-២០២១ សម្រេចបានសរុបចំនួន២២គម្រោង ដែលសរុបមានប្រវែង២៦ ៧០០ម.
- បានសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃបានចំនួន៤គម្រោង នៅខេត្តកោះកុង ហើយការពារទប់ស្កាត់ទឹកប្រៃកុំឱ្យប៉ះពាល់ផ្ទៃដី សរុបចំនួន២ ២៣៥ហត.
- បានជួសជុលនិងថែទាំជាប្រចាំទំនប់ការពារទប់ស្កាត់ទឹកប្រៃបានចំនួន៤០គម្រោង នៅខេត្តកោះកុងនិងខេត្តព្រះសីហនុ
- បានសាងសង់ស្ថានីយបូមទឹកបានចំនួន២កន្លែង ជួសជុលស្ថានីយបូមទឹកបានចំនួន១២កន្លែង និងធ្វើការជួសជុលម៉ាស៊ីនបូមទឹកចល័តបានចំនួន៩៥គ្រឿង

- បានសាងសង់ស្ថានីយជលសាស្ត្រ២កន្លែង ជួសជុលស្ថានីយជលសាស្ត្រ៣៨កន្លែង ដំឡើងក្តារម៉ែត្រវាស់កម្ពស់ទឹកចំនួន៤កន្លែង និងជួសជុលក្តារម៉ែត្រវាស់កម្ពស់ទឹកចំនួន១កន្លែង
- បានសាងសង់ដំឡើងស្ថានីយឧតុនិយមបានចំនួន៣៣កន្លែង ជួសជុលកែលម្អស្ថានីយឧតុនិយមបានចំនួន៤១កន្លែង ដំឡើងប៉ុស្តិ៍តម្រងទឹកភ្លៀងចំនួន៦៣កន្លែង ជួសជុលប៉ុស្តិ៍តម្រងទឹកភ្លៀង បានចំនួន១២កន្លែង និងបំពាក់ឧបករណ៍ស្វ័យប្រវត្តបានចំនួន៧កន្លែង។

៣.១១៧- បញ្ហាប្រឈមមួយចំនួន ដែលបានរាំងដល់ក្រសួងធនធានទឹកនិងឧតុនិយម មិនអាចសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រមានដូចខាងក្រោម៖

- ការផ្តល់ថវិកាលើការងារជួសជុល ស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រមានការយឺតយ៉ាវ និងពុំចំរដូវកាលសាងសង់ ព្រមទាំងនៅមានកម្រិតដែលពុំអាចឆ្លើយតមតាមតម្រូវការជាក់ស្តែង
- ថវិកាលើការងារជួសជុលនិងថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតទាប
- ការចូលរួមរបស់កសិករលើការងារប្រើប្រាស់និងថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតទាប

## ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ

៣.១១៨- ក្នុងកំឡុងឆ្នាំ២០១៩-២០២១ កម្ពុជាបានចូលរួមជាមួយបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គផ្សេងទៀត ដើម្បីពិនិត្យនិងពិភាក្សាអំពីតម្រូវការ បញ្ហាប្រឈម និងផែនការដែលត្រូវរួមគ្នាគិតគូរនិងអនុវត្តឱ្យមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍទន្លេមេគង្គនិងធនធានក្នុងអាងប្រកបដោយចីរភាព ដោយ៖

- បានបន្តសហការចូលរួមជាមួយគណៈកម្មការទន្លេមេគង្គនិងប្រទេសជាសមាជិក ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ សេចក្តីថ្លែងការណ៍ក្រុងសៀមរាបឆ្នាំ២០១៨នៃកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គ លើកទី៣ នីតិវិធីនិងគោលការណ៍ណែនាំ និងឧបករណ៍បច្ចេកទេស សម្រាប់ការគ្រប់គ្រងការប្រើប្រាស់ទឹកបានកាន់តែល្អប្រសើរនិងប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ
- បានសហការរៀបចំនិងអនុម័តឯកសារ ដើម្បីបម្រើដល់ការគ្រប់គ្រង ការអភិវឌ្ឍ ការប្រើប្រាស់ និងការអភិរក្សធនធានទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ រួមមានយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ឆ្នាំ២០២១-២០៣០ យុទ្ធសាស្ត្រនិងផែនការមេលើផ្នែកជលផលបរិស្ថាន ការប្រែប្រួលអាកាសធាតុ ទឹកជំនន់ ភាពរាំងស្ងួត នាវាចរណ៍ ជាដើម
- បានអនុម័តនិងសហការអនុវត្តផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២១-២០២៥ ផែនការការងារប្រចាំឆ្នាំ ផែនការការងារផ្អែកលើគម្រោង ផែនការចង្អុលថ្នាក់ជាតិ ២០២១-២០២៥ ដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងនិងយុទ្ធសាស្ត្រផែនការមេតាមវិស័យ
- បានបន្តសហការដើម្បីពង្រឹងការលើកកម្ពស់ប្រព័ន្ធព្យាករណ៍ទឹកជំនន់ ភាពរាំងស្ងួត បណ្តាញពិនិត្យតាមដានទន្លេ ការផ្សព្វផ្សាយជាសាធារណៈ ការលើកកម្ពស់ចំណេះដឹង ការចូលរួមរបស់ភាគីពាក់ព័ន្ធ ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការតំបន់ ដើម្បីការគ្រប់គ្រងនិងនិរន្តរភាពអាងទន្លេមេគង្គនិងធនធានក្នុងអាង។

៣.១១៩- បញ្ហាប្រឈមនៅក្នុងការអនុវត្តគោលនយោបាយអាទិភាពនិងសកម្មភាពទាំងឡាយដែលកំណត់នៅក្នុងផ.យ.អ.ជ.២០១៩-២០២៣ រួមទាំងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ពីឆ្នាំ ២០១៩ ដល់ត្រឹមពាក់កណ្តាល ឆ្នាំ២០២១ មានដូចខាងក្រោម៖

- ស្ថានភាពប្រែប្រួលផ្នែកជលសាស្ត្រ ដូចជាលំហូរទឹកទាប ភាពរាំងស្ងួត គ្រោះទឹកជំនន់កំពុងតែកើតមានក្នុងអាងទន្លេមេគង្គ ដែលចាំបាច់ត្រូវតាមដានជាប្រចាំ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលនិងសាធារណជន ដើម្បីជ្រាប ត្រៀមបង្ការ និងមានវិធានការសមស្រប
- សន្ទុះនៃការអភិវឌ្ឍក្នុងអាងទន្លេមេគង្គក្នុងប្រទេសតាមដងទន្លេ មានការកើនឡើងជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ ដែលកត្តាទាំងនេះអាចបង្កឱ្យមានផលប៉ះពាល់ឆ្លងដែនដែលចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់និងរួមគ្នាគិតគូរដោះស្រាយ
- ដំណើរការគ្រប់គ្រងអភិវឌ្ឍន៍និងកសាងផែនការអាងទន្លេផ្អែកតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះមានលក្ខណៈស្មុគស្មាញ
- ទំហំការងារមានការកើនឡើងជាលំដាប់ តែចំនួនមន្ត្រីបុគ្គលិកនិងសមត្ថភាព ព្រមទាំងធនធាននិងមធ្យោបាយគាំទ្រដល់កិច្ចដំណើរការការងារនៅមានកម្រិត។

## ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

៣.១២០- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រេចបានសមិទ្ធផលសំខាន់ៗទាក់ទងនឹងការផ្គត់ផ្គង់ទឹកស្អាតដូចខាងក្រោម៖

- បានយកចិត្តទុកដាក់អនុវត្តគោលនយោបាយឧបត្ថម្ភធនសម្រាប់ប្រជាពលរដ្ឋក្រីក្រ ដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានការប្រើប្រាស់ទឹកដែលមានតម្លៃថោកក្នុងកម្រិតអប្បបរមា ក្នុងនោះប្រជាពលរដ្ឋក្រីក្រចំនួន៣៥ ០០៦គ្រួសារ បានទទួលនូវការឧបត្ថម្ភធនសម្រាប់ការតភ្ជាប់បណ្តាញទឹកស្អាត។ លើសពីនេះទៀត ក្រសួងបានកំណត់ថ្លៃលក់ទឹកស្អាតនិងចុះកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួល៧០០រៀល/ម$^{៣}$ ហើយម្ចាស់ផ្ទះជួលលក់ឱ្យកម្មករ កម្មការិនី សិស្ស និស្សិត ក្នុងតម្លៃ៨០០រៀល/ម$^{៣}$។ បច្ចុប្បន្នសម្រេចតភ្ជាប់បណ្តាញទឹកស្អាតបានចំនួន៥ ៦៣០ផ្ទះ ដែលមានបន្ទប់ជួលចំនួន១២២ ២៩១បន្ទប់ សម្រេចបាន ១០០%
- បានបន្តពង្រឹងគុណភាពសេវាស្របតាមបុរេលក្ខខណ្ឌគោលចំនួន៤ គឺ ត្រូវមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ
- បានបន្តការពិភាក្សាក្នុងក្របខ័ណ្ឌអន្តរក្រសួង ស្ថាប័ន ដើម្បីជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី "ការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា" ដែលបច្ចុប្បន្នកំពុងដាក់ឆ្លងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងការកសាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់និងតម្រូវការនៃកំណែទម្រង់លិខិតបទដ្ឋានគតិយុត្ត

- បានបង្កើនប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចនិងតម្រង់ទិសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដោយបានដាក់ចេញនូវគោលការណ៍ធ្វើប្រតិភូកម្មការងារអធិការកិច្ចទូទៅជូនមន្ទីររាជធានី ខេត្ត
- បានពង្រឹងការអនុវត្តលក្ខខណ្ឌនៃប្រកាសអនុញ្ញាតឬអាជ្ញាបណ្ណ ដែលផ្តោតការយកចិត្តទុកដាក់លើប្រតិបត្តិករដែលមានអាជ្ញាបណ្ណ ព្រមទាំងបានចេញប្រកាសកំណត់ថ្លៃសិទ្ធិជាវទឹកសម្រាប់ទំហំនាឡិកា១៥ម.ម. និងបានកែសម្រួលនីតិវិធីសម្រាប់ការចេញ កែម្រួល បន្ត ព្យួរ និងដកហូតប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- បានលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សលើវិស័យទឹកស្អាត ដោយមានវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីប្រតិបត្តិករ និងអាជីវករទឹកស្អាតឯកជន អំពីការគ្រប់គ្រងបច្ចេកទេស និងជំនាញសំខាន់ផ្សេងៗទៀត ដូចជាជំនាញមេកានិកនិងអគ្គិសនី និងជំនាញគ្រប់គ្រងគម្រោង
- បានលើកទឹកចិត្តចំពោះការវិនិយោគលើការផលិតនិងលក់ទឹកស្អាតដុំ ដើម្បីជួយគាំទ្រដល់ប្រតិបត្តិករទឹកស្អាតឯកជនមួយចំនួនដែលជួបការលំបាកបញ្ហាប្រភពទឹកឬខ្វះទុនវិនិយោគពង្រីកផលិតកម្មនិងបណ្តាញចែកចាយ។

៣.១២១- ទន្ទឹមនឹងនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ប្រភពទឹកនៅតំបន់មួយចំនួន ទទួលរងនូវការបំពុលដោយសារទឹកសំណល់ពីលំនៅឋាន វិស័យសេវាកម្ម កសិកម្ម ឧស្សាហកម្ម។ល។
- កង្វះខាតមជ្ឈមណ្ឌលបណ្តុះបណ្តាលនិងសិក្សាស្រាវជ្រាវលើវិស័យទឹកស្អាត
- ការងារមួយចំនួនដែលបានធ្វើប្រតិភូកម្មអំណាចទៅថ្នាក់ក្រោមជាតិ នៅមិនទាន់បានបំពេញឱ្យរលូន ដោយសារកង្វះធនធានមនុស្សមានសមត្ថភាព ថវិកាមានកម្រិត និងមធ្យោបាយក្នុងការអនុវត្ត។

## ភូមិមួយផលិតផលមួយ

៣.១២២- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានដឹកនាំនិងសម្របសម្រួលរៀបចំរចនាសម្ព័ន្ធការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រួមមាន (១)ការបង្កើតក្រុមការងារបច្ចេកទេសជំរុញចលនាភូមិមួយផលិតផលមួយចំនួន ១០ក្រសួង (២)ការបង្កើតគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយ រាជធានី ខេត្ត ចំនួន២៥រាជធានី ខេត្ត (៣)ការបង្កើតក្រុមការងារដឹកនាំសម្របសម្រួលការងារចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ ចំនួន៤ក្រសួង
- បានរៀបចំឯកសារគតិយុត្តសំខាន់ៗចំនួន៣ រួមមាន (១)គោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ (២)គោលការណ៍ណែនាំស្តីពីការចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ និង(៣)ផែនការយុទ្ធសាស្ត្រជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ៥ឆ្នាំលើកទី១ ២០១៩-២០២៣

- បានសហការជាមួយនឹងក្រសួងពាណិជ្ជកម្ម រៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ ថ្ងៃទី៩ មេសា ជារៀងរាល់ឆ្នាំ និងរៀបចំឱ្យមានគោលការណ៍ណែនាំរួមស្តីពីការរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរនៅទូទាំងប្រទេស
- បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី ខេត្ត ចំនួន១០ខេត្ត ក្នុងការប្រមូលចងក្រងសមាជិកចលនាភូមិមួយផលិតផលមួយ ដែលការងារនេះនឹងពង្រីកទៅ១៥រាជធានី ខេត្តបន្ថែមទៀតនៅឆ្នាំ២០២២
- បានសហការនិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងវិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសិក្សាស្រាវជ្រាវ រួមមាន (១)សមាគមពាណិជ្ជករដឹកជញ្ជូន ទំនិញ និងក្រុមហ៊ុនSuper App (២)សកលវិទ្យាល័យភូមិន្ទកសិកម្ម (៣) រាជបណ្ឌិត្យសភាកម្ពុជា ក្នុងគោលបំណងរួមគ្នាលើកកម្ពស់ផលិតផលខ្មែរ ក្នុងចលនាភូមិមួយផលិតផលមួយនៅកម្ពុជា។

៣.១២៣- ទន្ទឹមនឹងវឌ្ឍនភាពខាងលើ គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ការធ្វើសមាហរណកម្មផែនការសកម្មភាពនិងគម្រោងថវិកានៅមិនទាន់មានភាពឆ្លើយតបឱ្យគ្នាទៅវិញទៅមក
- សកម្មភាពការងារមួយចំនួនដែលមានលក្ខណៈជាការចូលរួមប្រជុំពិភាក្សា ការរៀបចំទិវាជាតិលើកកម្ពស់ផលិតផលខ្មែរ ការតាំងពិព័រណ៍ផលិតផល ការបណ្តុះបណ្តាល និងការងារមួយចំនួនទៀតត្រូវបានលុបចោល ក្រោមហេតុផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩
- ការសម្របខ្លួនរបស់មន្ត្រីរាជការដែលតម្រូវឱ្យអនុវត្តការងារតាមប្រព័ន្ធអនឡាញ
- កង្វះខាតបុគ្គលិកសកម្មនិងមានការយល់ដឹងខ្ពស់លើដំណើរការអនុវត្តការងារជំរុញចលនាភូមិមួយផលិតផលមួយ។

## ៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព

៣.១២៤- ក្រសួងរ៉ែនិងថាមពល បានបន្តអនុវត្តគោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដោយពង្រឹងអភិបាលកិច្ចលើការធ្វើប្រតិបត្តិការធនធានរ៉ែ តាមរយៈការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម បង្កើនការប្រមូលចំណូលថវិកាជាតិ ពង្រឹងយន្តការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែ លុបបំបាត់សកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ និងលើកកម្ពស់ការអភិវឌ្ឍសហគមន៍មូលដ្ឋានដែលមានប្រតិបត្តិការធនធានរ៉ែ។ អនុលោមតាមផែនការសកម្មភាពការងារខាងលើ នៅក្នុងរយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១នេះ ក្រសួងរ៉ែនិងថាមពល សម្រេចលទ្ធផលដូចជារៀបចំក្រុមការងារត្រួតពិនិត្យនិងធ្វើអធិការកិច្ចធនធានរ៉ែចំនួន៤ក្រុម ទៅតាមប្រភេទអាជីវកម្មធនធានរ៉ែ ដូចជាអាជីវកម្មរ៉ែឧស្សាហកម្ម អាជីវកម្មរ៉ែខ្សាច់ អាជីវកម្មរ៉ែថ្មសំណង់ និងអាជីវកម្មរ៉ែខ្សាច់បកនិងរណ្តៅដី ដែលរយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១នេះ ក្រុមការងារទាំង៤

ក្រុមខាងលើបានចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចប្រតិបត្តិការធនធានរ៉ែបានចំនួន២៧៦ការដ្ឋាន ដោយបានពិន័យជាប្រាក់លើបទល្មើសធនធានរ៉ែបានចំនួន៧៤០ ៣០៧ដុល្លារអាម៉េរិក និង ៣៨០លានរៀល ព្រមទាំងបានកៀរគរចំណូលបន្ថែមចំនួន១៦៦ ៧៩៦ដុល្លារអាម៉េរិក។ បន្ថែមពីលើនេះ ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញបានចុះពិនិត្យភាពអនុលោមនិងផ្ទៀងផ្ទាត់បរិមាណផលិតកម្មបានចំនួន៦២២ការដ្ឋាន ដោយបានកៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែបន្ថែមបានចំនួន ៣ ១៧៤ ៨៩៥ដុល្លារអាម៉េរិក និងពិន័យជាប្រាក់បានចំនួន៩០លានរៀល។ លើសពីនេះ ក្រសួងរ៉ែនិងថាមពលបានរៀបចំសេចក្តីណែនាំលេខ៥០ រថ.សណន ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែនិងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីជំរុញការអភិវឌ្ឍសិប្បកម្មរ៉ែស្របតាមគោលដៅគោលនយោបាយជាតិស្តីពីធនធានរ៉ែ ក៏ដូចជាសម្រួលការស្នើសុំធ្វើអាជីវកម្មរ៉ែខ្នាតតូច។ ទន្ទឹមនេះ តាមរយៈអនុក្រឹត្យលេខ១៩៥ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការនាំចេញផលិតផលរ៉ែ និងប្រកាសអន្តរក្រសួងលេខ៦១៤ សហវ.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីនីតិវិធីបែបបទស្នើសុំនាំចេញផលិតផលរ៉ែ ក្រសួងបានអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែដែលមានផលិតផលរ៉ែចំនួន៣ប្រភេទកំពុងមានសកម្មភាពនាំចេញ ដូចជាម៉្សៅរ៉ែមាស ខ្សាច់ទន្លេ និងថ្មអារ។ បន្ថែមពីលើនេះ ក្នុងគោលដៅជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែឱ្យមានការទទួលខុសត្រូវបរិស្ថាននិងសង្គម ក្រសួងបានតម្រូវឱ្យសម្បទានិកត្រូវសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលត្រូវមានការទទួលស្គាល់ដោយក្រសួងបរិស្ថានមុននឹងក្រសួងរ៉ែនិងថាមពល ផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ហើយសម្បទានិកត្រូវធ្វើប្រតិបត្តិការធនធានរ៉ែអនុលោមតាមគម្រោងផែនការអាជីវកម្ម បទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ លើសពីនេះ ក្រសួងរ៉ែនិងថាមពល បានបង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍមូលដ្ឋានដែលបានមកពីការរួមចំណែកបង់វិភាគទានដោយស្ម័គ្រចិត្តឬបង់ថវិកាតាមបរិមាណផលិតកម្មរ៉ែដែលបានធ្វើអាជីវកម្ម ដើម្បីប្រើប្រាស់ជាប្រយោជន៍ដល់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ដែលបានទទួលរងផលប៉ះពាល់ដោយផ្ទាល់និងប្រយោលពីការធ្វើប្រតិបត្តិការធនធានរ៉ែ ក្នុងគោលបំណងបង្កើនសុខដុមនីយកម្មរវាងសហគមន៍មូលដ្ឋាននិងការដ្ឋានរ៉ែ ដែលកន្លងមក ក្រសួងរ៉ែនិងថាមពលបានអភិវឌ្ឍសហគមន៍មូលដ្ឋានដោយប្រើប្រាស់មូលនិធិរ៉ែចំនួន៤៦គម្រោង នៅក្នុងរាជធានី ខេត្តចំនួន១១។

### តារាង៣.៣០ : ចំណូលមិនមែនសារពើពន្ធក្នុងវិស័យរ៉ែ ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | | ២០២០ | | ២០២១ | |
|---|---|---|---|---|---|---|---|
| | | ផែនការ | ជាក់ស្តែង | ផែនការ | ជាក់ស្តែង | ផែនការ | ពាក់កណ្តាល ឆ្នាំ២០២១ |
| ចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែដែលប្រមូលបានធៀបផែនការ | លានដុល្លារអាម៉េរិក | ១៨,០ | ២១,៤៨ | ២២,០ | ២៧,៥១ | ២៣,០ | ១៥,២៤ |

ប្រភព : ក្រសួងរ៉ែនិងថាមពល

៣.១២៥- ការរីករាលដាលជំងឺកូវីដ-១៩ គឺជាបញ្ហាដ៏សំខាន់ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងអភិវឌ្ឍធនធានរ៉ែ រួមទាំងការកៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ

ផងដែរ។ ទន្ទឹមនេះ កង្វះខាតធនធានមនុស្សនិងថវិកា ក៏ជាបញ្ហាចម្បងក្នុងការអនុវត្តការងារ ដើម្បីសម្រេចគោលនយោបាយអាទិភាពនិងសកម្មភាពនានា ដែលបានកំណត់ក្នុងផ.យ.អ.ជ. ២០១៩-២០២៣ ផងដែរ។

៣.១២៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចយ៉ាងសកម្មទៅលើការងារគ្រប់ផ្នែកលើអនុវិស័យជលផល ក្នុងនោះរួមមានការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើសជលផល ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយ។ ទន្ទឹមនឹងនេះ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍនានា ក្នុងការផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ការនេសាទទឹកសាបសម្រេចបាន១៨០ ០១០តោន ស្មើនឹង៣៩,៩១% ក្នុងនោះ ការនេសាទដោយជាយត្រីសម្រេចបាន១ ៣១០តោន ស្មើនឹង១២% ការនេសាទគ្រួសារក្នុងដែននេសាទសម្រេចបាន១៥៣ ៤០០តោន ស្មើនឹង៥១,១៣% និងការនេសាទគ្រួសារក្នុងវាលស្រែសម្រេចបាន២៥ ៣០០តោន ស្មើនឹង១៨,០៧%
- ការនេសាទសមុទ្រសម្រេចបាន៦៧ ៩០០តោន ស្មើនឹង៥២,២៣%
- ការចិញ្ចឹមត្រី បង្គា សម្រេចបាន១៤៧ ៤១២តោន ស្មើនឹង៣០,៦៥% ការចិញ្ចឹមក្រពើ សម្រេចបាន១៤២ ៤០០ក្បាល ស្មើនឹង៤៣,១៥% និងការភ្ញាស់កូនត្រី សម្រេចបាន១២២,៥លានកូន ស្មើនឹង៤៥,៣៥%
- ការកែច្នៃផល ផលិតផលជលផល សម្រេចបាន៣៨ ៨៧០តោន ស្មើនឹង៤២,២៥% ក្នុងនោះ ផលទឹកសាបសម្រេចបាន៣១ ៩១០តោន ស្មើនឹង៣៩,៨៩% ផលទឹកសមុទ្រ សម្រេចបាន៦ ៩៦០តោន ស្មើនឹង៥៨% និងការផលិតទឹកត្រីសម្រេចបាន៣៧លានលីត្រ ស្មើនឹង៦៦,៨៣%
- ការនាំចេញផលផលិតផលជលផលសម្រេចបាន២ ៤០៩តោន ស្មើនឹង២៤,០៩% ក្នុងនោះ ផលស្រស់សម្រេចបាន២ ២៥៩តោន ស្មើនឹង២៨,២៤% និងផលកែច្នៃសម្រេចបាន១៥០តោន ស្មើនឹង៧,៥០%
- ការការពារ បង្ក្រាបបទល្មើសជលផល សម្រេចបាន១ ៤៩២ករណី ក្នុងនោះ ការការពារបង្ក្រាបបទល្មើសទឹកសាបសម្រេចបាន១ ៣៩៨ករណី និងការការពារបង្ក្រាបបទល្មើសសមុទ្រសម្រេចបាន៩៤ករណី។

៣.១២៧- ក្រសួងបានចេញប្រកាសបង្កើតសហគមន៍ព្រៃឈើថ្មីចំនួន៥០សហគមន៍ គ្របដណ្តប់លើផ្ទៃដី១២ ១៦៦ហិកតា។ បច្ចុប្បន្ន សហគមន៍ព្រៃឈើសរុបមានចំនួន៦៤១សហគមន៍ គ្របដណ្តប់លើផ្ទៃដី៥២២ ២១៩ហ.ត. ក្នុងនោះក្រសួងបានចេញប្រកាសចំនួន៥៣៤សហគមន៍ លើផ្ទៃដី៤៤៩ ២៣៣ហ.ត. និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ ចំនួន៤៤៧សហគមន៍លើផ្ទៃដី

៣៦៩ ២៣៣ហ.ត. លើសពីនេះបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១០៦សហគមន៍ គ្របដណ្ដប់លើផ្ទៃដីទំហំ៧២ ៦២០ហ.ត.។ ជាមួយគ្នានេះ ក្រសួងបាននិងកំពុងយកចិត្តទុកដាក់លើការបង្កើតមុខរបរបន្ថែមដល់ប្រជាសហគមន៍ក្នុងការបង្កើនចំណូលនិងលើកកម្ពស់ជីវភាពរស់នៅ។ ក្រសួងបានថែទាំចម្ការឈើចាស់ចំនួន៦៥៤ហ.ត. ចម្ការពូជឈើ៩៤ហ.ត. ឡូត៍បង្ហាញកសិរុក្ខកម្មចំនួន៤៤ហ.ត. និងបានដាំឈើជាចម្ការថ្មីចំនួន៤ ២៧២ហ.ត.។ ជាមួយគ្នានេះ បានរៀបចំបង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ ដោយគិតមកទល់ពេលបច្ចុប្បន្នមានចំនួន៨០ទីតាំងលើផ្ទៃដីសរុបចំនួន៥០០ ១៧៨ហ.ត. ក្នុងនោះ១៦ទីតាំងមានបណ្ណកម្មសិទ្ធិលើផ្ទៃដីទំហំ១០៦ ៥២២ហ.ត.។ ការដាំឈើជាលក្ខណៈក្រុមហ៊ុនដៃគូសហការនិងលក្ខណៈគ្រួសារលើផ្ទៃដីសរុបមានចំនួន១០២ ១០៨ហ.ត. និងគម្រោងដាំឈើក្នុងសម្បទាន ដីសេដ្ឋកិច្ចមានចំនួន១៧ ក្រុមហ៊ុន លើផ្ទៃដីចុះកិច្ចសន្យាទំហំ២៨០ ៨៧០ហ.ត.។ ក្រសួងបានធ្វើការចុះបញ្ជិកាការចិញ្ចឹមសត្វត្រចៀកកាំបានចំនួន២២៦ទីតាំង និងការចិញ្ចឹមសត្វព្រៃផ្សេងៗបានចំនួន៦០ទីតាំង។ សំណុំរឿងបទល្មើសព្រៃឈើនិងសត្វព្រៃ និងការកាប់រានដីព្រៃមានចំនួន៣ ០៤៤ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន១ ៣២៦ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន១ ៧១៨ករណី។

៣.១២៨- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- បទល្មើសព្រៃឈើ ជលផល ការលួចនាំចូលសត្វនិងសម្ភារៈកសិកម្មដោយខុសច្បាប់នៅតែកើតមាន ពិសេសខេត្តនៅជាប់ព្រំដែន
- សកម្មភាពកាប់រានហ៊ុមព័ទ្ធដីព្រៃឈើ ការរានដីព្រៃលិចទឹកដោយខុសច្បាប់ គឺនៅតែកើតមានពុំចេះចប់រហូតមកទល់បច្ចុប្បន្ននេះ។

៣.១២៩- ក្រសួងបរិស្ថានសម្រេចបានសមិទ្ធផលសំខាន់ៗទាក់ទងនឹងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

- បានរៀបចំបង្កើតតំបន់ការពារធម្មជាតិ ដែលបច្ចុប្បន្នមានផ្ទៃដីសរុបជាង៧លានហ.ត. ឬស្មើប្រមាណ៤១% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជាក្នុងនោះ រួមមានឧទ្យានជាតិចំនួន១២តំបន់ ដែនជម្រកសត្វព្រៃចំនួន១៩តំបន់ តំបន់ការពារទេសភាពចំនួន១៣តំបន់ តំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន៩តំបន់ តំបន់រាមសារចំនួន៥តំបន់ តំបន់ស្នូលនៃបបរិយជីវមណ្ឌល៣តំបន់ បេតិកភណ្ឌធម្មជាតិចំនួន១៣តំបន់ តំបន់ឧទ្យានជាតិសមុទ្រ១តំបន់ និងរបៀងអភិរក្សជីវៈចម្រុះចំនួន៣តំបន់
- បានរៀបចំកំណត់និងបែងចែកតំបន់គ្រប់គ្រង បោះបង្គោលព្រំ បណ្តុះបណ្តាលមន្ត្រីជំនាញនិងឧទ្យានុរក្ស បំពាក់ឧបករណ៍ មធ្យោបាយនិងសម្ភារចាំបាច់ ពង្រឹងការងារល្បាត និងអនុវត្តវិធានការច្បាប់លើបទល្មើសធនធានធម្មជាតិ

- បានបង្កើតនិងចងក្រងបណ្ដាតំបន់ការពារធម្មជាតិនានា ឱ្យទៅជាប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមានលក្ខណៈស៊ីចង្វាក់គ្នាផ្នែកអេកូឡូស៊ីនិងយុទ្ធសាស្ត្រសម្រាប់ប្រជាជាតិកម្ពុជា ក្នុងគោលដៅទ្រទ្រង់និរន្តរភាពសម្រាប់បរិស្ថានសេដ្ឋកិច្ច សង្គមកិច្ច និងមរតកធម្មជាតិ-វប្បធម៌ ព្រមទាំងបានធានាការពារនិងអភិរក្សប្រព័ន្ធតំបន់ការពារធម្មជាតិប្រទេសកម្ពុជា ដើម្បីអាចបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការទ្រទ្រង់ជីវិតសត្វលោក និងលើកកម្ពស់សន្តិសុខស្បៀង និងសេដ្ឋកិច្ច សង្គម នៅកម្ពុជាតាមរយៈសេវាកម្មប្រព័ន្ធអេកូឡូស៊ី
- បានសហការទប់ស្កាត់បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយធំនៅតំបន់ការពារធម្មជាតិ និងរបៀង អភិរក្សជីវៈចម្រុះ
- អនុវត្តគម្រោងឥណទានកាបូនក្នុងតំបន់ការពារធម្មជាតិជាមួយដៃគូអន្តរជាតិ
- បានសម្របសម្រួលរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិចំនួន១៨២សហគមន៍
- បានបន្តបង្កើតនិងចងក្រងជាបណ្ដាញសហគមន៍ថ្នាក់មូលដ្ឋានចំនួន៣៥ ថ្នាក់តំបន់ចំនួន ៣ និងថ្នាក់ជាតិចំនួន១
- សហគមន៍ចំនួន៣២ ក្នុងចំណោម១៨២សហគមន៍តំបន់ការពារធម្មជាតិ បានទទួលការគាំទ្រផ្នែកបច្ចេកទេស ទុនផលិត រួមទាំងថវិកា ពូជសត្វ ពូជដំណាំ និងសម្ភារៈសម្រាប់ផ្ដល់សេវាទេសចរណ៍ធម្មជាតិ
- បានបង្កើតតំបន់បេតិកភណ្ឌធម្មជាតិចំនួន១១តំបន់
- បោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិបានចំនួន៣សហគមន៍ និងតំបន់បេតិកភណ្ឌធម្មជាតិចំនួន២តំបន់ សរុប៧៦បង្គោល និងបោះបង្គោលព្រំប្រទល់ដីគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិចំនួន១៦៤គម្រោង
- បានពិនិត្យនិងអនុម័តប្លង់មេលើគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ ទំហំមិនលើសពី១០ហិកតា ចំនួន១០គម្រោង
- បានចុះសិក្សាផូស៊ីលឆ្អឹងដាយណូស័រស្ថិតនៅដែនជម្រកសត្វព្រៃតាតៃ ខេត្តកោះកុង និងប្រមូលទិន្នន័យផូស៊ីលបឋមនៅ (ដើមឈើ ឆ្អឹង ធ្យូងកាល់ និងដានជើងសត្វ)ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម ខេត្តសៀមរាប (ភ្នំគូលែន)តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព និងដែនជម្រកសត្វព្រៃ "ព្រៃឡង់" ភូមិសាស្ត្រខេត្តព្រះវិហារ
- បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន លើផ្ទៃដីសរុបចំនួន២ ០២០ហិកតា ក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន នរោត្តម "ភ្នំគូលែន" និងបានប្រមូលនិងរក្សាពូជកេសរកូលព្រៃចំនួនជាង៥ ០០០សំណាក តំណាងឱ្យ២០៩ប្រភេទ ក្នុងនោះ១១៤ប្រភេទត្រូវបានកត់ត្រាចូលប្រព័ន្ធទិន្នន័យ
- បានបញ្ចូលការងាររបស់មជ្ឈមណ្ឌលទៅក្នុងកម្មវិធីរបស់ICC Angkor និងបានបង្ហាញពីវឌ្ឍនភាពរបស់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ក្នុងកិច្ចប្រជុំICC Angkor ចំនួន៣លើក។
- បានចុះពិនិត្យតាមដានគុណភាពទឹកសាធារណៈ ទឹកក្រោមដី ទឹកកខ្វក់ និងតំបន់ងាយរងការបំពុល នៅតាមរាជធានី ខេត្តគោលដៅចំនួន១១៨ទីតាំង និងបានយកសំណាកទឹក ៦៤៥ មកវិភាគ

- បានចុះពិនិត្យទីតាំងនិងវាយតម្លៃសមត្ថភាពអាងប្រព្រឹត្តិកម្មសំណល់រាវរោងចក្រចំនួន ៦៨០ទីតាំង
- បានតាមដានគុណភាពខ្យល់សាធារណៈជាប្រចាំនៅតាមរាជធានីខេត្តចំនួន៤១ទីតាំង និងប្រើប្រាស់រថយន្ត " វិស្ពុត្រួតពិនិត្យគុណភាពខ្យល់ " ចំនួន២០លើក
- បានចុះត្រួតពិនិត្យវាយតម្លៃគុណភាពខ្យល់និងសំឡេងដល់ក្រុមហ៊ុនចំនួន២៣៥
- បានចុះត្រួតពិនិត្យទីតាំងស្នើសុំបញ្ចេញសំណល់គ្រោះថ្នាក់១៣៣ទីតាំង
- បានចុះពង្រឹងប្រសិទ្ធភាពសេវាប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនរាជធានី ក្រុង ស្រុក ចំនួន៧៣ក្រុង ស្រុក
- បានចុះត្រួតពិនិត្យនិងពង្រឹងការអនុវត្តច្បាប់ តាមបណ្ដារោងចក្រសហគ្រាស អាជីវកម្ម សេវាកម្មដែលងាយរងការបំពុលបរិស្ថានចំនួន៥៣៦ទីតាំង និងបានបំពាក់ឧបករណ៍ស្វ័យប្រវត្តចំនួន១ទីតាំង
- បានចុះអធិការកិច្ចប្រភពបំពុល ក្នុងករណីកើតមានបណ្ដឹងអំពីបញ្ហាបំពុលបរិស្ថានចំនួន ៣៥ករណី និងបានអនុវត្តបញ្ជាកែប្រែលើប្រភពបំពុលចំនួន៥៦ករណី
- បានពិនិត្យផ្ដល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមចំនួន ២២៩គម្រោង
- បានជំរុញម្ចាស់គម្រោងចំនួន៦៣៧ ឱ្យមករៀបចំកិច្ចសន្យាការពារបរិស្ថាន
- បានចុះអង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននិងកិច្ចសន្យាការពារបរិស្ថាន បានចំនួន៤៣៩គម្រោង
- បានវិភាគសំណាកទឹក ដី ភក់ ខ្យល់ អាស៊ីតបរិយាកាសចំនួន១៤៦៤ សំណាក និងវិភាគរកវត្ថុមានសារពាង្គកាយកែច្នៃរស់(GMOs & LMOs) ចំនួន១៦សំណាក
- បានពង្រឹងនិងពង្រីកសកម្មភាពអប់រំបរិស្ថាន ដល់គ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិត និងវត្តអារាម ពិសេសការផ្សព្វផ្សាយការអនុវត្តគោលការណ៍សាលាមេត្រីបរិស្ថាន និងអារាមមេត្រី បរិស្ថានពាក់កណ្ដាលអាណត្តិដល់សាលាបានចំនួន២៨៨សាលា និងវត្តអារាមបានចំនួន៥០អារាម
- បានជំរុញការចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថានដល់រូបវន្តបុគ្គល នីតិបុគ្គលដែលបានប្រតិបត្តិបរិស្ថានល្អ បង្ហាញស្នាដៃ និងគំនិតច្នៃប្រតិដ្ឋនានាទាក់ទងនឹងវិស័យបរិស្ថាន ដោយបានផ្ដល់ជាបណ្ណសរសើរសរុបចំនួន១ ២៨៧នាក់
- បានបង្កើនការផ្សព្វផ្សាយព័ត៌មានបរិស្ថានទូលំទូលាយទៅដល់សាធារណជនគ្រប់ស្រទាប់វណ្ណៈស្ដីពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

## តារាង៣.៣១ : សមិទ្ធផលសម្រេចបានក្នុងវិស័យបរិស្ថាន ឆ្នាំ២០១៩-២០២៣

| ល.រ. | សូចនាករសំខាន់ៗ | ឯកតា | លទ្ធផលសម្រេចបាន | | |
|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ពាក់កណ្ដាលឆ្នាំ២០២១ |
| ១ | បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានកាត់បន្ថយធៀបទិន្នន័យឆ្នាំគោល | Gg $CO_2$ សមមូល | ២,៨០ | ២,៨៣៩ | N/A |
| ២ | តាមដានគុណភាពទឹកសាធារណៈ ទឹកក្រោមដី ទឹកកខ្វក់ និងតំបន់ងាយរងការបំពុលតាមរាជធានីខេត្ត | សំណាក | ៣២០ | ២២២ | ១០៣ |
| ៣ | ពិនិត្យតាមដានគុណភាពខ្យល់សាធារណៈនៅតាមរាជធានី ខេត្ត | ទីតាំង | ៣០ | ៤១ | ៤១ |
| ៤ | តំបន់ការពារធម្មជាតិចំនួន៣៧ ត្រូវបានកំណត់ព្រំប្រទល់កំណត់ | តំបន់ការពារធម្មជាតិ | ៥តំបន់(៤៨០ បង្គោល) និងបែងចែកតំបន់គ្រប់គ្រងចំនួន១ | ៥តំបន់(600 បង្គោល) និងបែងចែកតំបន់គ្រប់គ្រងចំនួន១ | ៥តំបន់(600បង្គោល) និងបែងចែកតំបន់គ្រប់គ្រងចំនួន១ |
| ៥ | តំបន់ការពារធម្មជាតិថ្មីៗចំនួន១៥តំបន់ត្រូវបានរៀបចំ បង្កើត | តំបន់ការពារធម្មជាតិ | ២ PA | ១០ PA | ១ PA |
| ៦ | សិក្សានិងរៀបចំបង្កើតសហគមន៍ តំបន់ការពារធម្មជាតិ(សរុប) | សហគមន៍ | ១៦៨ | ១៧៤ | ១៨២ |
| ៧ | ចំនួនគម្រោងបានបំពេញនីតិវិធីច្បាប់ ក្នុងការអនុវត្តគម្រោងវិនិយោគ អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ | គម្រោង | ២៣ | ៣០ | ៤៦ |
| ៨ | កម្មវិធីសាលាមេត្រីបរិស្ថាន | សាលា | ១១០ | ៧០ | ១០៨ |

៣.១៣០- ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលខាងលើ ក្រសួងបរិស្ថានបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- មានភាពយឺតយ៉ាវក្នុងការចុះសិក្សានិងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ផែនការគ្រប់គ្រង និងការបែងចែកនិងកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ ដើម្បីប្រសិទ្ធភាពការពារតំបន់ស្នូលនិងតំបន់អភិរក្សក្នុងតំបន់ការពារធម្មជាតិ
- មានភាពស្មុគស្មាញក្នុងការដោះស្រាយទំនាស់ក្នុងការប្រើប្រាស់ដីនៅក្នុងនិងជុំវិញតំបន់ការពារធម្មជាតិ
- កិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត
- ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស នៅមិនទាន់បានគ្រប់គ្រាន់ដល់មន្ត្រី និងឧទ្យានុរក្សសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនិងអភិវឌ្ឍន៍សហគមន៍នៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ

- ថវិកានិងធនធានពីរាជរដ្ឋាភិបាលនៅមានកម្រិត ដើម្បីរក្សាស្ថិរភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព
- ខ្វះសម្ភារៈនិងមធ្យោបាយសម្រាប់ប្រតិបត្តិការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ
- កង្វះខាតព័ត៌មាននិងទិន្នន័យអំពីជីវៈចម្រុះនិងធនធានធម្មជាតិ
- ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យសកម្មភាពមួយចំនួនធំត្រូវបានពន្យារពេលអនុវត្ត និងថវិកាសម្រាប់អនុវត្តសកម្មភាពត្រូវបានកាត់បន្ថយ
- ហេដ្ឋារចនាសម្ព័ន្ធមិនទាន់ត្រូវបានតភ្ជាប់ទៅតំបន់ទេសចរណ៍មួយចំនួន
- កង្វះនូវការតភ្ជាប់គម្រោងវិនិយោគទេសចរណ៍ធម្មជាតិនិងសហគមន៍ទេសចរណ៍
- ការបរបាញ់សត្វព្រៃនិងកាប់រានដីព្រៃនៅតាមតំបន់មួយចំនួន
- សកម្មភាពការងារភាគច្រើនជាការងារអប់រំផ្សព្វផ្សាយ ដែលតម្រូវមានអ្នកចូលរួមច្រើន ក៏ប៉ុន្តែដោយសារបរិបទនៃជំងឺកូវីដ-១៩ សកម្មភាពមួយចំនួនគឺមិនអាចសម្រេចបានតាមគោលដៅ។

៣.១៣១- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានកសាងចំណេះដឹងនិងសមត្ថភាពដល់មន្ត្រីរាជការ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងបុគ្គលិកអង្គការ សហគមន៍លើការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- បានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារគ្រប់គ្រងនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- បានរៀបចំការិយាល័យលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុក
- បានអនុវត្តគម្រោងរស់នៅជាមួយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ
- បានចុះអនុស្សរណៈនៃការយោគយល់រវាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាមួយដៃគូអភិវឌ្ឍ ដូចជាកម្មវិធីស្បៀងអាហារពិភពលោក អង្គការការីតាស់កម្ពុជា អង្គការអាក់សិនអេដអន្តរជាតិ កម្ពុជា
- បានធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ ដោយភ្ជាប់ទៅនឹងប្រព័ន្ធរក្សាទុកទិន្នន័យខូចខាតនិងបាត់បង់។

៣.១៣២- ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលខាងលើ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- សមត្ថភាពលើការប៉ាន់ប្រមាណនិងវាយតម្លៃហានិភ័យ ការតាមដានត្រួតពិនិត្យ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅមានកម្រិត

- ក្នុងពេលមានហេតុការណ៍គ្រោះមហន្តរាយកើតឡើងនៅតាមតំបន់មួយចំនួនដែលនៅឆ្ងាយ ការចល័តកងកម្លាំងដែលមានជំនាញសម្រាប់ការអន្តរាគមន៍សង្គ្រោះត្រូវប្រើរយៈពេលយូរ ហើយក្នុងនេះ កងកម្លាំងដែលឈរជើងនៅមូលដ្ឋានមិនមានជំនាញនិងឧបករណ៍សម្រាប់សង្គ្រោះដែលធ្វើឱ្យមានការយឺតយូរនិងមិនធានាសុវត្ថិភាពគ្រប់គ្រាន់សម្រាប់ការ សង្គ្រោះ
- ការផ្តល់ព័ត៌មានគ្រោះមហន្តរាយទាន់ហេតុការណ៍PRISM នៅមិនទាន់បានអនុវត្តតាមបច្ចេកទេសគ្រប់ជ្រុងជ្រោយនៅតាមមូលដ្ឋានជាច្រើន ហើយបានធ្វើឱ្យការផ្តល់ព័ត៌មានពីហេតុការណ៍គ្រោះមហន្តរាយ ពីថ្នាក់ខេត្តមកថ្នាក់ជាតិមានការយឺតយូរ
- មិនទាន់មានការវិភាជន៍ថវិកាជាក់លាក់ សម្រាប់សកម្មភាពកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

៣.១៣៣- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានជួសជុលនិងអភិរក្សសំណង់បុរាណសរុបប្រមាណ១០៩សំណង់ រួមមានប្រាសាទបុរាណចំនួន៨៦ ព្រះវិហារបុរាណចំនួន៧ ស្ពានបុរាណចំនួន៥ និងសំណង់ផ្សេងៗចំនួន១១
- បានជួសជុលនិងអភិរក្សវត្ថុបុរាណ/វត្ថុសិល្បៈសរុបប្រមាណ៨.២៩៦វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង/គ្រាប់ និងវត្ថុជាតិពន្ធុសាស្ត្រសរុបប្រមាណ៥០៩មុខ រកឃើញនិងទទួលបានវត្ថុបុរាណ/វត្ថុសិល្បៈពីគ្រប់ប្រភពសរុបប្រមាណ៣១.៤៣៤វត្ថុ/រូប/ដុំ/បំណែក/ផ្ទាំង/គ្រាប់ ចុះបញ្ជីវត្ថុបុរាណ/វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រសរុបប្រមាណ២៣.៥៨៧វត្ថុ/រូប/ដុំ/ផ្ទាំង/បំណែក/គ្រាប់ បញ្ចូលទិន្នន័យវត្ថុបុរាណ/វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋាន សរុបប្រមាណ១២ ៣៧៥ វត្ថុ/រូប/ដុំ/ផ្ទាំង/បំណែក។
- បាននិងកំពុងរៀបចំឯកសារដើម្បីស្នើសុំចុះ “ប្រាសាទកោះកេរ“ ”នំបញ្ចុក“ ”ល្បាច់គុនល្បុក្កតោ” និងទីក្រុងបាត់ដំបង ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ និងបណ្តាញទីក្រុងដែលមានភាពច្នៃប្រឌិតរបស់អង្គការយូណេស្កូ ហើយក៏បានរៀបចំបញ្ជីត្រៀមដើម្បីគ្រោងស្នើសុំចុះសម្បត្តិវប្បធម៌ដែលមានសក្តានុពលផ្សេងទៀតទៅក្នុងបញ្ជីបេតិកភណ្ឌរបស់អង្គការយូណេស្កូ រួមមានក្រុមប្រាសាទបន្ទាយឆ្មារ រមណីយដ្ឋានអង្គរបុរីនិងភ្នំដា រមណីយដ្ឋានគូលែន ក្រុមប្រាសាទបេងមាលា ក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ រមណីយដ្ឋានឧដុង្គ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក អតីតមន្ទីរឃុំឃាំង “ម-១៣” និងព្រះរាជពិធីបុណ្យអុំទូក។
- បានយកចិត្តទុកដាក់និងសហការជាមួយសហគមន៍ក្នុងការបណ្តុះបណ្តាលនិងរៀបចំការសម្តែងសិល្បៈ ដោយក្នុងនោះក្រសួងបានស្តារឱ្យល្ខោនវត្តកៀនស្វាយក្រៅរស់រានឡើងវិញ ព្រមទាំងបានពង្រឹងការថែរក្សាវប្បធម៌របស់សហគមន៍សំខាន់ៗ រួមទាំងសហគមន៍របស់ជនជាតិដើមភាគតិច។

៣.១៣៤- ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលខាងលើ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ខ្វះធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តការងារ
- ខ្វះមធ្យោបាយដឹកជញ្ជូន ដើម្បីប្រមូលវត្ថុបុរាណនៅតាមបុរាណដ្ឋាននិងទីទួលឆ្ងាយៗមករក្សាទុក
- ខ្វះកិច្ចសហការពីអាជ្ញាធរមានសមត្ថកិច្ចនិងប្រជាជនក្នុងមូលដ្ឋាន ដើម្បីចូលរួមបង្ការនិងបង្ក្រាបបទល្មើសទន្ទ្រានបុរាណដ្ឋាននានា។

## ៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

៣.១៣៥- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានចុះបញ្ជីចេញបណ្ណកម្មសិទ្ធិដីចំនួន៦ ១៩៦ ៣៤០បណ្ណ ស្មើនឹង៨៨,៥%នៃក្បាលដីប៉ាន់ស្មាន៧លានក្បាលដី ក្នុងនោះការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន៥ ៥៧៤ ១០២បណ្ណ
- បានចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបាន៣៣សហគមន៍ ស្មើនឹង៨៥៦បណ្ណ ទំហំ៣៣ ៨៩៩ហ.ត. មាន៣ ២៣៥គ្រួសារ
- បានបំប្លែងទិន្នន័យពីMicrosoft Access ទៅPostgreSQL ជារៀងរាល់ថ្ងៃសម្រាប់ដាក់ឱ្យដំណើរការផ្តល់សេវាសាធារណៈតាមQR Code
- បានបង្កើតកម្មវិធីស្កេនQR Code លើសន្លឹកបណ្ណ មុនពេលចែកជូនដល់ម្ចាស់កម្មសិទ្ធិនិងរៀបចំកម្មវិធីសម្រាប់តាមដានពិនិត្យអ្នកចូលមើលព័ត៌មានសុរិយោដី និងបានBackup ទិន្នន័យ តាមរយៈSynology WorkStation ជាប្រចាំ
- បានបញ្ចប់ការកសាងផែនទីព្រំប្រទល់រដ្ឋបាល ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងផែនទីប្រើប្រាស់ដីបច្ចុប្បន្ននៃក្រុង ស្រុក ខណ្ឌចំនួន១៧៦ ស្មើ ៨៦% នៃចំនួនក្រុង ស្រុក ខណ្ឌ សរុប ២០៣ ទូទាំងប្រទេស
- បានរៀបចំនិងសម្រេចផែនការរូបវន្តតំបន់ឆ្នេរសមុទ្រកម្ពុជា ១)ប្លង់គោលប្រើប្រាស់ដីកោះរ៉ុង ២)សេចក្តីព្រាងប្លង់គោលប្រើប្រាស់ដីកោះចំនួន៧កោះ(កោះរ៉ុងសន្លឹម កោះឬស្សី កោះក្របី កោះសេះនិងកោះតី កោះទន្សាយ កោះពុតសារកណ្តាល កោះអំពិល) និង ៣)ប្លង់គោលនិងផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ ដែសមុទ្រ ស្ទឹង ព្រែក បឹង ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- បានបញ្ចប់គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ មានប្រវែង៨៤ ៥០៥ម.
- បានសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើប ចំនួន២ស្ថានីយ
- បានរៀបចំគោលនយោបាយនិងលិខិតគតិយុត្តទាក់ទងនឹងការអភិវឌ្ឍទីក្រុង ដូចជាច្បាប់ភូមិបាល(ថ្មី) ច្បាប់ស្តីពីលំនៅឋាន ច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម ជាដើម។

## តារាង៣.៣២ : សមិទ្ធផលសម្រេចបានក្នុងវិស័យដីធ្លី ឆ្នាំ២០១៩-២០២១

| សូចនាករ | ឯកតា | ២០១៩ | | ២០២០ | | ពាក់កណ្ដាលឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | គោលដៅ | លទ្ធផល | គោលដៅ | លទ្ធផល | គោលដៅ | លទ្ធផល |
| អត្រាចុះបញ្ជីអចលនវត្ថុ (ចេញបណ្ណកម្មសិទ្ធិ) | % | ៧៨ | ៨៤ | ៨៤ | ៨៦,៨ | ៩០ | ៨៨,៥ |
| ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច | សហគមន៍ | ៣៤ | ២៥ | ៤៤ | ៣៣ | ៥៤ | ៣៣ |
| សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារប្រជាពលរដ្ឋ | គ្រួសារ | ៧៩ ០៤៥ | ៨០ ៨៦២ | ៧៩ ៥៤៥ | ៨៥ ០៧១ | ៨០ ០៤៥ | ៨៥ ៦៩៩ |
| ផ្ទះដែលបានសាងសង់ជូនគ្រួសារកងទ័ព នគរបាលជាតិ និងអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ | ខ្នងផ្ទះ | ៧ ១៩៩ | ៧ ២៣៦ | ៧ ៦៩៩ | ៧ ៧៦៩ | ៨ ១៩៩ | ៧ ៧៦៩ |
| ផែនការប្រើប្រាស់ដីថ្នាក់ឃុំសង្កាត់ | ផែនការ | ១៧៩ | ៨២ | ១៩៩ | ៨៧ | ២១៩ | ១១៧ |
| ប្លង់គោលប្រើប្រាស់ ដីថ្នាក់ស្រុក ខណ្ឌ | ប្លង់គោល | ១៩ | ០ | ២៥ | ៣ | ២៩ | ៣ |
| ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុងនិងទីប្រជុំជន | ប្លង់គោល | ២៣ | ១៤ | ២៥ | ១៤ | ២៧ | ១៤ |
| ផែនការរៀបចំដែនដីថ្នាក់ខេត្ត | ផែនការ | ៧ | ៣ | ៩ | ៣ | ១១ | ៣ |
| ផែនការរៀបចំដែនដីតាមតំបន់ | ផែនការ | ១ | ០ | ១ | ០ | ២ | ០ |

ប្រភព : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣.១៣៦- ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជាការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងសំណល់ ប្រព័ន្ធលូ ជាដើម ដើម្បីបំពេញតម្រូវការនៃកំណើនសំណង់និងការវិនិយោគលើលំនៅឋានដែលមានតម្លៃសមរម្យសម្រាប់ប្រជាជនកម្ពុជា។

### ៦.៤- ការធានានិរន្តរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

៣.១៣៧- ក្រសួងបរិស្ថាន សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

- បានសិក្សាស្រាវជ្រាវនិងបោះពុម្ពឯកសារ រួមមាន (១)របាយការណ៍ការកាត់បន្ថយហានិភ័យលើការវិនិយោគថាមពលកកើតឡើងវិញ (២)របាយការណ៍វាយតម្លៃសក្ដានុពល

ថាមពលពន្លឺព្រះអាទិត្យ ប្រើសម្រាប់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល (៣) ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃការជំរុញវិស័យឧស្សាហកម្មបៃតងនៅកម្ពុជា (៤)ការវាយតម្លៃសក្តានុពលនៃការអភិវឌ្ឍបៃតង ជាភាសាខ្មែរនិងភាសាអង់គ្លេស (៥)បានបោះពុម្ពផែនការយុទ្ធសាស្រ្តទីក្រុងនិរន្តរភាពសម្រាប់ក្រុងគោលដៅទាំង៧(ក្រុងកែប ព្រះសីហនុ បាត់ដំបង សៀមរាប កំពង់ចាម សួង និងក្រុងបាវិត) )៦ (របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តងលើកទី១របស់កម្ពុជា)First Biennial Update Report: fBUR) (៧) របាយការណ៍បច្ចុប្បន្នភាពនៃការចូលរួមចំណែករបស់ជាតិក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(Updated Nationally Determined Contribution: Updated NDC)ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍រយៈពេលវែងប្រកប(៨) ដោយអព្យាក្រឹតកាបូន)Long-Term Strategy for Carbon Neutrality: LTS4CN) (៩) យុទ្ធសាស្រ្តនិងសកម្មភាពសេដ្ឋកិច្ចចក្រា និង(១០)ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ និងកម្មវិធីស្រាវជ្រាវ

- បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣០ ដោយមានភ្ជាប់នូវគម្រោងវិនិយោគទីក្រុងបៃតង/និរន្តរភាពចំនួន៤៨គម្រោង
- បានដំឡើងបន្ទះថាមពលពន្លឺព្រះអាទិត្យនៅ (១)មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ខេត្តសៀមរាប និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និង (២)សហគមន៍ស្រែអំពិល ស្ថិតក្នុងឃុំក្តុលមានជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និងកំពុងសិក្សាពីលទ្ធភាពតបណ្តាញជូនសហគមន៍ប្រើប្រាស់ជាមួយថាមពល៣២គីឡូវ៉ាត់
- បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានកាត់បន្ថយធៀបទិន្នន័យឆ្នាំគោល២០១៨ និងគោលដៅ ឆ្នាំ២០១៩ មានចំនួន២,៨០ GgCO2 សមមូល និង២០២០ មានចំនួន២,៨៤ GgCO2 សមមូល ដែលបានគណនាតាមយន្តការអភិវឌ្ឍន៍ស្អាតនិងយន្តការឥណទានកាបូនរួមគ្នា
- ភាគរយនៃឃុំ/សង្កាត់ងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ធៀបទិន្នន័យឆ្នាំគោល២០១៨(៤០%) និងគោលដៅឆ្នាំ២០១៩(៣៩%) ក្នុងនោះការងារសម្រេចបានចំនួន៣,៧% ធៀបនឹងឆ្នាំ២០១៨(សូចនាករធ្លាក់ចុះពី៤០%នៃឆ្នាំ២០១៨ មកត្រឹម៣៦,៣%នៃឆ្នាំ២០១៩)។ ចំណែកគោលដៅឆ្នាំ២០២០ មាន៣៨% ក្នុងនោះសម្រេចបាន១,៥%ដែលចំនួនឃុំងាយរងគ្រោះធ្លាក់ចុះមកត្រឹម៣៦,៥% ធៀបនឹងសូចនាករឆ្នាំដដែល។ ការងារទាំងអស់នេះបានអនុវត្តដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុនិងគម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិនិងអនុវត្តសកម្មភាពអាទិភាព
- កម្រិតត្រៀមរបស់ស្ថាប័ន ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ធៀបទិន្នន័យឆ្នាំគោល២០១៨(៤៩%) និងគោលដៅឆ្នាំ២០១៩(៥៣%) ក្នុងនោះសម្រេចបានតែ៤,៨% ដែលសូចនាករកើនពីប្រមាណ៤៨,២% មកសម្រេចគោលដៅ៥៣%ក្នុងឆ្នាំ២០១៩ និង

គោលដៅឆ្នាំ២០២០(៥៧%) ក្នុងនោះសម្រេចបានប្រហែល៥% ដែលសូចនាករកើនឡើង៥២%មកសម្រេចគោលដៅ៥៧%ក្នុងឆ្នាំ២០២០

- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្ដីពីជីវៈចម្រុះបានចំនួន២ដង ដើម្បីកំណត់ផែនការតាមវិស័យដើម្បីបញ្ជ្រាបខ្លឹមសារអភិរក្សជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិកនៃក្រុមការងារបច្ចេកទេសជីវៈចម្រុះ
- បានសិក្សាស្រាវជ្រាវទិន្នន័យនិងសមិទ្ធលទ្ធភាពសម្រាប់រៀបចំគោលនយោបាយស្ដីពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដូចជាផែនទីគោលនិងផែនការគ្រប់គ្រងការប្រើប្រាស់ដីធ្លីសម្រាប់បង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី យន្តការហិរញ្ញវត្ថុសម្រាប់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ការរៀបចំគោលគំនិតទស្សនាទានអំពីការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី។

៣.១៣៨- ទន្ទឹមនឹងសមិទ្ធផលខាងលើ ក្រសួងបរិស្ថានបានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ចំនួនមន្ត្រីជំនាញបច្ចេកទេសនិងធនធានហិរញ្ញវត្ថុមិនទាន់ឆ្លើយតបតាមទំហំការងារផ្នែកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ការអនុវត្តបច្ចេកវិទ្យា សេដ្ឋកិច្ចបៃតង និងនវានុវត្តន៍
- ពុំទាន់បានរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រស្ដីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ឧបករណ៍តាមដានការវាយតម្លៃសក្ដានុពលការកាត់បន្ថយបរិមាណឧស្ម័នផ្ទះកញ្ចក់ធៀបនឹងទិន្នន័យឆ្នាំគោលនៅមានកម្រិត
- សមត្ថភាពស្ថាប័ននៅមានកម្រិតក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដូចដែលបានកំណត់នៅក្នុងឆ្នាំគោលនិងឆ្នាំគោលដៅ
- ថវិកាសម្រាប់អនុវត្តសកម្មភាពអាទិភាពនៅមានកម្រិតតិចតួចនិងសកម្មភាពមួយចំនួនត្រូវពន្យារពេលដោយស្ថានភាពជំងឺកូវីដ-១៩ ដែលបាននិងកំពុងការរីករាលដាល
- ខ្វះការស្រាវជ្រាវនិងទិន្នន័យសម្រាប់ការងារកំណត់ទីតាំងអភិរក្សក្រៅដែនធម្មជាតិដោយសារកង្វះថវិកានិងជំនាញការសម្រាប់អនុវត្តសកម្មភាពនេះ។

# ជំពូកទី៤

# ជំហានបន្ទាប់

## ១- ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

### ១.១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន

៤.១- ក្រសួងមហាផ្ទៃ នឹងបន្តលើកកម្ពស់គុណភាពសេវាសាធារណៈ និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងសន្តិសុខជាតិ ស្ថេរភាពនយោបាយ សណ្ដាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម។

វិធានការគោលនយោបាយដែលត្រូវកែសម្រួលឬបន្តអនុវត្ត និងវិធានការគោលនយោបាយថ្មីៗដែលត្រូវលើកឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមនានាពីឆ្នាំ២០២១ដល់ឆ្នាំ២០២៣ មានដូចខាងក្រោម៖

- រៀបចំវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីលើការរៀបចំផែនការចុះសវនកម្ម ដោយជ្រើស រើសសវនដ្ឋានដែលមានហានិភ័យខ្ពស់ជាគោលដៅចម្បង ពិសេសរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់
- បន្តអនុវត្តយន្តការសិក្សានិងពិភាក្សាដើម្បីជំរុញកិច្ចដំណើរការបើកច្រកទ្វារព្រំដែនដែលបានព្រមព្រៀងរវាងកម្ពុជានិងបណ្ដាប្រទេសជាប់ព្រំដែន
- បន្តរៀបចំកិច្ចប្រជុំលើកទី២ ក្រុមការងារចម្រុះស្ដីពីច្រកទ្វារព្រំដែនគោកវៀតណាម កម្ពុជា និងកម្ពុជា វៀតណាម នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យពិភាក្សាក្នុងការរៀបចំផែនការមេស្ដីពីការបង្កើតឬដំឡើងកម្រិតច្រកទ្វារព្រំដែនគោកវៀតណាម កម្ពុជា ពីពេលនេះដល់ឆ្នាំ ២០៣០
- បន្តចុះសិក្សាលើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្ដានុពលសេដ្ឋកិច្ច ជាពិសេសគឺការថែរក្សាដែនអធិបតេយ្យនិងបូរណភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងពិនិត្យវាយតម្លៃរួមគ្នាជាមួយភាគីប្រទេសជិតខាងនៅទីតាំងច្រកទ្វារជាក់ស្ដែងដែលភាគីទាំងពីរមានបំណងស្នើបង្កើតនិងដំឡើងកម្រិត
- បន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិនិងច្បាប់អន្តោប្រវេសន៍ តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍ នៅតាមព្រំដែនគោក អាកាសយានដ្ឋាន និងព្រំដែនទឹកជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់ ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីបញ្ជូនចេញទៅប្រទេសដើមវិញ
- ថែរក្សាសន្តិភាព ការពារអធិបតេយ្យជាតិ បូរណភាពទឹកដី ខឿនសន្តិសុខ និងខឿនសេដ្ឋ-កិច្ចជាតិ។ ចាត់វិធានការគន្លឹះទប់ស្កាត់នូវអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ឧបាយកលញុះញង់និងសកម្មភាពបដិវត្តន៍ពណ៌។ ទន្ទឹមនេះចាត់តាំងអនុវត្តផែនការធានាសុវត្ថិភាពសម្រាប់ព្រឹត្តិការណ៍នយោបាយជាតិ ព្រឹត្តិការណ៍តំបន់និងអន្តរជាតិដែលប្រព្រឹត្តធ្វើឡើងនៅកម្ពុជា

- លើកកម្ពស់សមត្ថភាពនិងពង្រឹងវិធានការជំនាញធានាស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដោយខិតខំជំរុញចលនាអនុវត្តគោលនយោបាយ "ភូមិឃុំសង្កាត់មានសុវត្ថិភាព" ដើម្បីកាត់បន្ថយជាអតិបរមានូវបទល្មើសគ្រប់ប្រភេទ ជាពិសេសបទល្មើសដែលជះឥទ្ធិពលអវិជ្ជមានដល់ចិត្តសាស្ត្រសង្គមនិងធ្វើឱ្យប្រជាពលរដ្ឋមានការព្រួយបារម្ភ
- បន្តរឹតបន្តឹងការអនុវត្តច្បាប់និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធដល់ការថែរក្សា និងកែលម្អសណ្តាប់ធ្នាប់សាធារណៈនិងរបៀបរៀបរយសង្គម សំដៅកាត់បន្ថយហានិភ័យ ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ អគ្គិភ័យ ក៏ដូចគ្រោះមហន្តរាយនានា និងលើកកម្ពស់ភាពថ្លៃថ្នូររបស់ជាតិ
- បន្តលើកកម្ពស់ដល់សមត្ថភាពកងកម្លាំងនគរបាលជាតិនិងមន្ត្រីពន្ធនាគារទូទាំងប្រទេស ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងផលប៉ះពាល់នានាដែលជាកត្តាប្រឈម។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានគាំទ្រឧបត្ថម្ភជាច្រើន ដូចជាការសាងសង់អគារសិក្សា អគារស្នាក់នៅ ទីលានបាញ់គ្រាប់ពិត អាងហែល ទឹកប្រព័ន្ធលូ ផ្លូវក្នុងបរិវេណ ទាំងនៅបណ្ឌិត្យសភានិងសាលានគរបាលជាតិភូមិភាគទាំង៦ ជាបន្តបន្ទាប់តាមលំដាប់លំដោយអាទិភាព។ ទន្ទឹមនេះ បន្តស្វែងរកដៃគូសហការនិងសប្បុរសជនក្នុងក្របខ័ណ្ឌជាតិ អន្តរជាតិ ដើម្បីកៀរគរជំនួយឧបត្ថម្ភក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងឧបត្ថម្ភសម្ភារៈហ្វឹកហាត់ទាក់ទងនឹងជំនាញចាំបាច់មួយចំនួនបន្ថែមទៀតស្របតាមតម្រូវការជំនាញនិងផែនការដែលបានកំណត់។ ក្រោយពេលស្ថានភាពជំងឺកូវីដ-១៩បានធូរស្រាលវិញ បណ្ឌិត្យសភាបានរៀបចំនូវផែនការនិងវិធានការ ដើម្បីស្តារឡើងវិញនូវផលប៉ះពាល់ផ្សេងៗដោយសារជំងឺកូវីដ-១៩ដូចខាងក្រោម៖
    - រៀបចំផែនការដើម្បីបន្តវគ្គបណ្តុះបណ្តាលខ្លីៗឡើងវិញ ដែលមានជាមធ្យម៤០វគ្គក្នុងមួយឆ្នាំ
    - បន្តធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិឡើងវិញឱ្យបានពេញលេញ ស្របតាមផែនការសកម្មភាពប្រចាំឆ្នាំដែលបានកំណត់ និងអនុស្សរណៈយោគយល់គ្នាជាមួយដៃគូ
    - បន្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល ស្របតាមផែនការដែលបានកំណត់
    - ធ្វើប្រក្រតីកម្មឡើងវិញនូវរាល់សកម្មភាពផ្សេងទៀត ដែលអាក់ខានដោយសារវិបត្តិជំងឺកូវីដ-១៩។

៤.២- ក្រសួងការពារជាតិ នឹងបន្តអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់កងយោធពលខេមរភូមិន្ទនិងកងកម្លាំងនគបាលយុត្តិធម៌ តាមរយៈការអនុវត្ត ***យុទ្ធសាស្ត្រ៣ សកម្មភាពប្រតិបត្តិការ និងការអភិវឌ្ឍ១០*** ព្រមទាំងធ្វើបច្ចុប្បន្នកម្ម និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ

- អភិវឌ្ឍធនធានមនុស្សនិងការបង្កើនសមត្ថភាពកម្លាំងប្រដាប់អាវុធតាមរយៈការធ្វើទំនើបកម្ម ការបំពាក់បច្ចេកវិទ្យាសមស្រប និងបង្កើនគុណភាពហ្វឹកហ្វឺន ជាពិសេសការបណ្ដុះបណ្ដាលយោធិនអាជីព ការកសាងជួរកងកម្លាំងប្រដាប់អាវុធវ័យក្មេងដើម្បីបន្តវេន
- បន្តផ្ដល់ការយកចិត្តទុកដាក់អតីតយុទ្ធជន យោធិនពិការ គ្រួសារយោធិនពលីមរណៈ និងគ្រួសារកងទ័ព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសតាមរយៈការបន្តផ្ដល់និងការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសម្បទានដីសង្គមកិច្ច និងគម្រោងអភិវឌ្ឍន៍សម្រាប់សហគមន៍ និងគ្រួសារកងទ័ពនៅតាមបន្ទាត់ព្រំដែន
- លើកកម្ពស់កិច្ចសហប្រតិបត្តិការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រវាងកងកម្លាំងប្រដាប់អាវុធជាមួយក្រសួងស្ថាប័ន ព្រមទាំងបន្តពង្រឹងប្រពៃណីនៃទំនាក់ទំនងរវាងកងកម្លាំងប្រដាប់អាវុធនិងប្រជាជន តាមរយៈការធ្វើអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ ការបំពេញប្រតិបត្តិការមនុស្សធម៌ និងការជួយបង្កបង្កើនផល ព្រមទាំងការរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ
- ពង្រឹងនិងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍកងកម្លាំងប្រដាប់អាវុធលើជំនាញអាជីព វិស័យកសិកម្ម សិប្បកម្ម ព័ត៌មានវិទ្យានិងជំនាញផ្សេងៗទៀត
- អនុវត្តគម្រោងវិនិយោគបៃតងពិសេសវិស័យថាមពលតាមសហគមន៍កងទ័ព ដើម្បីជួយសម្រួលដល់ការងារអភិវឌ្ឍន៍នានារបស់សហគមន៍។

## ១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

៤.៣- ទិសដៅបន្តក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ សម្រាប់ឆ្នាំ២០២១ដល់ឆ្នាំ២០២៣

ដើម្បីបន្តការងារប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជានឹងពង្រឹង និងបង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំង៣ដូចខាងក្រោម៖

**ពង្រឹងការអប់រំមិនឱ្យប្រព្រឹត្តអំពើពុករលួយ**

- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ.ប.ព. នឹងបន្តពង្រឹងនិងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយច្បាប់ ការអប់រំស្ដីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅតាមស្ថាប័នអង្គភាពរបស់ខ្លួននីមួយៗឱ្យបានញឹកញាប់និងគ្រប់ៗគ្នា
- ត្រូវខិតខំរិះរកវិធីអប់រំថ្មីៗទៀតឱ្យសមស្របទៅនឹងបរិបទដែលមានការលំបាកក្នុងការប្រមូលផ្ដុំដូចជាក្នុងករណីនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ក្រៅពីនោះសម្រាប់ទំពាំងស្នងឫស្សី អង្គភាពប្រឆាំងអំពើពុករលួយនិងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងស្ថាប័នពាក់ព័ន្ធបន្តសហការគ្នាឱ្យបានជិតស្និទ្ធ ពង្រឹងគុណភាពនៃការបង្រៀនមេរៀនស្ដីអំពីការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅតាមគ្រឹះស្ថានសិក្សាពីបឋមរហូតដល់ឧត្តមសិក្សា សាលាវិជ្ជាជីវៈ ហើយរិះរកវិធាន រូបភាពថ្មីៗបន្ថែមទៀត ដើម្បីបញ្ជ្រាបការប្រយុទ្ធប្រឆាំងអំពើពុករលួយទៅសិស្ស និស្សិតឱ្យបានទាន់ពេល ដើម្បីពេលអ្នកទាំងនោះចេញមកបំពេញការងារ ក៏ដូចជាប្រកបរបរចិញ្ចឹមជីវិតមានជាមូលដ្ឋាននូវស្មារតីសុចរិតភាព និងភាពស្អាតស្អំ។ អង្គភាពប្រឆាំង

អំពើពុករលួយ ត្រូវតែធ្វើជាស្នូលដល់គ្រប់ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ និងមូលដ្ឋាននូវខ្លឹមសារ ការបូកសរុប ដកពិសោធន៍ ការអប់រំផ្សព្វផ្សាយ ការលើកសរសើរស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋានណាដែលបំពេញកិច្ចការនេះបានល្អជារៀងរាល់ឆ្នាំ។

- អង្គភាពប្រឆាំងអំពើពុករលួយបង្កើនការផ្សព្វផ្សាយការងារប្រឆាំងអំពើពុករលួយរបស់ខ្លួនបន្ថែមទៀត ដូចជាការបង្កើតនូវមធ្យោបាយសោតទស្សន៍ជាដើម ដើម្បីទំនាក់ទំនងជាមួយសាធារណជនកាន់តែស្អិតរមួតជាមួយគ្នា។

## ការងារបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ

- ការងារបង្ការទប់ស្កាត់អំពើពុករលួយកាន់តែមានភាពងាយស្រួលជាងមុន នៅពេលដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានដាក់ចេញនូវអភិក្រមទាំង៥ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ដែលអភិក្រមទាំង៥នេះបានផ្តោតយ៉ាងសំខាន់ទៅលើការពង្រឹងអភិបាលកិច្ច តម្លាភាព ការផ្តល់សេវាសាធារណៈ លទ្ធកម្ម ការសន្សំសំចៃ ការបង្កើនសុចរិត-ភាព។ល។
- ក្រសួងស្ថាប័ននីមួយៗ ត្រូវយកចិត្តទុកដាក់ បូកសរុបជាទៀងទាត់អំពីការអនុវត្តនូវអភិក្រមទាំង៥របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**(ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់)
- ការពង្រឹងសុចរិតភាព អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈនិងឯកជន នឹងនៅតែបន្តដើរតួជាយុទ្ធសាស្ត្រគន្លឹះក្នុងការបង្ការ ទប់ស្កាត់អំពើពុករលួយ។ រាជរដ្ឋាភិបាលកម្ពុជា នឹងនៅតែបន្តជំរុញ រៀបចំ និងអនុវត្តផែនការប្រឆាំងអំពើពុករលួយក្នុងស្ថាប័នសាធារណៈ និងកម្មវិធីប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន និងរិះរកគន្លឹះថ្មីៗបន្ថែមទៀតក្នុងការធ្វើយ៉ាងណាឱ្យការងារបង្ការនិងទប់ស្កាត់អំពើពុករលួយមានដំណើរការទៅមុខឥតឈប់ឈរនៅគ្រប់ជាន់ថ្នាក់
- ទាំងអង្គភាពប្រឆាំងអំពើពុករលួយ ទាំងគ្រប់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋានតែងតែបានរួមគ្នាបង្កើតឡើងនូវស្នាដៃជាប្រវត្តិសាស្ត្រក្នុងរយៈពេលជាង១០ឆ្នាំចុងក្រោយនេះ លើការងារប្រកាសទ្រព្យសម្បត្តិ ដូច្នេះទាំងអង្គភាព ទាំងគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងមូលដ្ឋានត្រូវតែបន្តអនុវត្តកិច្ចការនេះកុំបីមានការយឺតយ៉ាវ ព្រោះថានេះក៏ជាវិធានការមួយយ៉ាងល្អនៃការឆ្លុះកញ្ចក់ផងដែរ។

## ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ

- ការងារអនុវត្តច្បាប់បង្ក្រាបក៏បានដើរទន្ទឹមគ្នាជាមួយនឹងការអប់រំ បង្ការ និងទប់ស្កាត់។ យន្តការទទួលនិងដោះស្រាយពាក្យប្តឹង ត្រូវបានទទួលការវាយតម្លៃជាវិជ្ជមានជាទូទៅពីសំណាក់អ្នកប្តឹងដែលអ.ប.ព. ធ្វើបានរហ័សនិងគ្រប់ជ្រុងជ្រោយ និងបានចុះស្រាវជ្រាវដល់ស្ថាប័ន និងទីកន្លែងមូលដ្ឋាន ហើយមានមូលដ្ឋានគតិយុត្តច្បាស់លាស់។ រាល់ការមកប្តឹងផ្ទាល់ ប្តឹងតាមប្រអប់សំបុត្រស តាមប្រៃសណីយ៍ ទូរសព្ទ អ៊ីមែល និងតាមបណ្តាញទំនាក់ទំនងសង្គម (Facebook, Telgram, Line, WeChat, WhatsApp, ព័ត៌មានជាចំហលើសារព័ត៌មាន តាមការប្រមូលព័ត៌មានជាសម្ងាត់របស់អ.ប.ព.) ត្រូវបានយកមកពិនិត្យនិងដោះស្រាយក្នុងកិច្ច

ប្រជុំព្រឹកព្រលឹម(ចាប់ផ្ដើមម៉ោង០៧:៣០នាទី) នៅរៀងរាល់ព្រឹកនៃថ្ងៃធ្វើការដើម្បីពិនិត្យពាក្យប្ដឹងដែលបានដាក់មកអង្គភាពប្រឆាំងអំពើពុករលួយ ពាក្យប្ដឹងពិសេសផ្សេងទៀតត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាវិន័យនិងត្រួតពិនិត្យផ្ទៃក្នុង ដើម្បីប្រជុំវិភាគនិងដោះស្រាយ ដោយមានការបើកទ្វារជូនដល់ម្ចាស់បណ្ដឹងចូលស្ដាប់ការជជែកវែកញែក ក៏ដូចជាការផ្ដល់នូវធាតុចូលបន្ថែមលើករណីបណ្ដឹងរបស់ខ្លួន

- ឱកាសក្នុងការចូលរួមនិងការមើលឃើញផ្ទាល់នូវសក្ដីភាពនៃកិច្ចប្រឹងប្រែងប្រកបដោយសមត្ថភាព ដោយស្មារតីទទួលខុសត្រូវ វិជ្ជាជីវៈច្បាស់លាស់របស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងការដោះស្រាយបណ្ដឹងតែងតែទទួលបាននូវការសាទរពីសំណាក់អ្នកប្ដឹង។ យន្តការដោះស្រាយបណ្ដឹងនិងស៊ើបអង្កេត ក៏ត្រូវបានប្រើប្រាស់សម្រាប់ព័ត៌មានដែលទទួលបានទាំងប្រភពចំហនិងចារកម្ម ក្រោមគោលការណ៍តឹងរ៉ឹងនិងមិនអាចដោះដូរបាននៃការរក្សាការសម្ងាត់នៃប្រភព ក៏ដូចជាសាក្សីទាំងនៅក្នុងនិងនៅក្រៅអង្គភាពប្រឆាំងអំពើពុករលួយ។

៤.៤- សម្រាប់អាណត្តិដែលនៅសល់របស់ជ.យ.អ.ជ. ក្រសួងមុខងារសាធារណៈនឹង៖

- បន្តបង្កើនប្រសិទ្ធភាពក្នុងការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់សលាកបត្រព័ត៌មាន លិខិតបទដ្ឋានឯកត្តជន និងពិនិត្យការផ្លាស់ប្ដូរស្ថានភាពរដ្ឋបាលរបស់គ្រួសារមន្ត្រីរាជការស៊ីវិល
- បន្តបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងក្របខ័ណ្ឌរបស់មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិថ្នាក់ក្រោមជាតិគ្រប់ក្រសួង ស្ថាប័ន
- បន្តជំរុញការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤.៥- នៅឆ្នាំ២០២១-២០២៣ ក្រសួងបានដាក់ចេញសកម្មភាពអាទិភាព ក្នុងនោះរួមមានការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា ការរៀបចំសេចក្ដីព្រាងច្បាប់អធិការកិច្ចនិងនីតិវិធីច្បាប់អធិការកិច្ច ការងារផ្សព្វផ្សាយច្បាប់ ការងារស្ទង់មតិការយល់ដឹងច្បាប់ ការងាររៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពររបស់ប្រជាពលរដ្ឋ ការងារអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាលគ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការងារត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ បទដ្ឋាននានា ការងារទទួលនិងសម្របសម្រួលដោះស្រាយបណ្ដឹង ការងារអភិវឌ្ឍន៍ស្ថាប័ន ការងារពង្រឹងសមត្ថភាពមន្ត្រីរាជការជំនាញក្នុងប្រទេស(វិទ្យាស្ថានជាតិអធិការកិច្ច)និងក្រៅប្រទេស និងការងារបញ្ញាបយេនឌ័រ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់អភិបាលកិច្ចល្អនិងពង្រឹងនីតិរដ្ឋ។

## តារាង ៤.១ : សូចនាករនិងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣

| ល.រ. | សូចនាករ | ឯកតា | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| | **ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា** | | | | |
| | ១- ការងារស្ទង់មតិ យល់ដឹងអំពីច្បាប់ | នាក់ | | ៣ ០០០ | ៣ ៥០០ |
| | ២- ការងារអប់រំផ្សព្វផ្សាយច្បាប់ | នាក់ | ៣០០ | ៣៥ ០០០ | ៤០ ០០០ |
| | ៣- រៀបចំវេទិកាសាធារណៈមូលដ្ឋាន | នាក់ | ៥០០ | ៣ ៥០០ | ៤ ០០០ |
| | **ការងារអធិការកិច្ច** | | | | |
| | ១- ការងារអធិការកិច្ចគ្រប់គ្រងរដ្ឋបាល គ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យរដ្ឋ | ស្ថាប័ន អង្គភាព | ១៦០ | ៣៦៦ | ៤២០ |
| | ២- ការងារតាមដានការអនុវត្តច្បាប់ | ស្ថាប័ន អង្គភាព | ៧០ | ១ ២២៤ | ១ ២៥៤ |
| | ៣- ការងារទទួលពាក្យបណ្តឹង | ករណី | ១៦១ | ១៨៦ | ១៨៦ |
| | **ការងាររដ្ឋបាលកិច្ចការទូទៅ** | | | | |
| | ១- បណ្តុះបណ្តាលជំនាញការងារអធិការកិច្ច | នាក់ | ១០០ | ៣៥០ | ៤០០ |

## ១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

៤.៦- ក្រសួងមុខងារសាធារណៈ នឹងបន្តជំរុញនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈនិងការផ្តល់សេវាសាធារណៈក្នុងទម្រង់ជាឌីជីថល រួមទាំងការផ្តល់វគ្គបណ្តុះបណ្តាលតាមអនឡាញ។

៤.៧- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) នឹងបន្តផ្តោតលើកិច្ចការជាអាទិភាពនិងចំណុចដៅមួយចំនួនដូចខាងក្រោម៖

- ពិនិត្យនិងកែសម្រួលផ.ស.ថ. ឆ្នាំ២០២១ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើសកម្មភាពដែលមានអាទិភាពខ្ពស់និងចាំបាច់បំផុតសម្រាប់ឆ្នាំ២០២១ រួមបញ្ចូលទាំងការផ្អាកឬការពន្យារពេលការចុះមូលដ្ឋាន និងការរៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាធំៗ ដើម្បីជៀសវាងការរីរាលដាលនៃជំងឺកូវីដ-១៩
- ពង្រឹងនិងផ្តោតការអនុវត្តសកម្មភាពក្នុងឆមាសទី២នៃផ.ស.ថ. ឆ្នាំ២០២១ និងគម្រោងកម្មវិធីនានារួមបញ្ចូលទាំងការតាមដាននិងការគាំទ្រក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផ.ស.ថ. ឆ្នាំ២០២១
- ពង្រឹងសមត្ថភាពនិងជំនាញមូលដ្ឋានអំពីបច្ចេកវិទ្យារបស់បុគ្គលិកទាំងអស់ ដើម្បីធានាប្រសិទ្ធភាព ការអនុវត្តសកម្មភាពរបស់ខ្លួន តាមរយៈប្រព័ន្ធអនឡាញផ្សេងៗដូចជា Zoom, BlueJeans, Skype។ល។

៤.៨- ក្រសួងយុត្តិធម៌បន្តអនុវត្តការងារអាទិភាពសំខាន់ៗដូចខាងក្រោម៖

**យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌៖**

- ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់
- ជំរុញលទ្ធភាពទទួលព័ត៌មានអំពីច្បាប់និងតុលាការឱ្យកាន់តែប្រសើរ បន្តពង្រឹងគុណភាពនៃដំណើរការរឿងក្តីនិងសេវាកម្មពាក់ព័ន្ធ រកវិធីសាស្ត្រថ្មីៗដែលកំណត់ដោយច្បាប់ ក្នុងការអនុវត្តអំណាចតុលាការនិងជាសមត្ថកិច្ចផ្នែកអយ្យការ ដើម្បីបង្កើនគុណភាពសេវាយុត្តិធម៌ បណ្តុះបណ្តាលខាងបច្ចេកទេសដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់និងតុលាការឱ្យអាចបំពេញអាណត្តិរបស់ខ្លួនបានជោគជ័យ រៀបចំដាក់ឱ្យដំណើរការតុលាការជំនាញ ដូចជាតុលាការពាណិជ្ជកម្មនិងតុលាការការងារ។

**អនុម័តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត**

- សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី លក្ខន្តិកៈក្រឡាបញ្ជី លក្ខន្តិកៈអាជ្ញាសាលា ព្រមទាំងសេចក្តីព្រាងច្បាប់មួយចំនួនទៀត។

**ដោះស្រាយរឿងក្តី**

- បណ្តុះបណ្តាលច្បាប់មូលដ្ឋាន បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងស្ត្រីនិងកុមារ និងជំនាញផ្សេងៗដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា និងអ្នកប្រកបវិជ្ជាជីវៈច្បាប់
- គ្រប់គ្រងសំណុំរឿងទាំងអស់និងចាត់ការទៅតាមនីតិវិធីបន្តការដោះស្រាយការកកស្ទះសំណុំរឿង យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សមត្ថភាព និងលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យយុត្តិធម៌ និងតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់។

**គ្រប់គ្រងស្ថាប័ន**

- ជ្រើសរើសមន្ត្រីវិជ្ជាជីវៈតុលាការដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែង បង្កើនសមត្ថភាពការងារនិងពង្រឹងការអនុវត្តការងារគ្រប់គ្រងរួម ពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារនៅក្រសួងនិងនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងពង្រឹងនិងពង្រីកការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

## ១.៤- ការពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន

# ២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

## ២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់

៤.៩- ក្រសួងមហាផ្ទៃនឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ការបន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិនិងច្បាប់អន្តោប្រវេសន៍ តាមរយៈការទប់ស្កាត់លំហូរជនអន្តោប្រវេសន៍នៅតាមព្រំដែនគោក អាកាសយានដ្ឋាន និងព្រំដែនទឹក ជាមួយនឹងការស្រាវជ្រាវរកជនអន្តោប្រវេសន៍ខុសច្បាប់ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ជូនចេញទៅប្រទេសដើមវិញ

- រៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីអន្តោប្រវេសន៍ឆ្នាំ១៩៩៤ និងបានដាក់ជូនក្រុមការងារក្រសួងមហាផ្ទៃពិនិត្យ កែសម្រួល និងបានរៀបចំកិច្ចប្រជុំផ្ទៃក្នុងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីពិនិត្យ កែសម្រួល អនុក្រឹត្យលេខ ៣០អនក្រ.បក ស្តីពីបែបបទសម្រាប់អនុវត្ត ចំពោះការអនុញ្ញាតឱ្យជនបរទេសអន្តោប្រវេសន៍ចេញ ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំសេចក្តីព្រាងកែសម្រួលរចនាសម្ព័ន្ធការិយាល័យចំណុះនាយកដ្ឋានជនបរទេសអន្តោប្រវេសន៍។

៤.១០- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នឹងបន្តដឹកនាំការអនុវត្តឱ្យមានប្រសិទ្ធភាពនូវយុទ្ធសាស្រ្តទាំង៥របស់ផែនការជាតិ៥ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរួមមាន (១)ការកាត់បន្ថយតម្រូវការគ្រឿងញៀន (២)ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន (៣)ការព្យាបាលស្តារនីតិសម្បទានិងធ្វើសមាហរណកម្ម (៤)ការពង្រឹងសមត្ថភាពអនុវត្តច្បាប់ និង(៥)កិច្ចសហប្រតិបត្តិការអន្តរជាតិ។

## ២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

៤.១១- ក្រសួងពាណិជ្ជកម្ម នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- អភិវឌ្ឍប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការផ្តល់លិខិតអនុញ្ញាត ការចុះបញ្ជីកែប្រែ និងអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- អភិវឌ្ឍការតភ្ជាប់ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួង តាមរយៈប្រព័ន្ធថ្នាលបច្ចេកវិទ្យា
- លើកកម្ពស់ការចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចំណេះដឹងសាធារណៈ សមត្ថភាពមន្ត្រី និងមន្ត្រីអនុវត្តច្បាប់ផ្នែកកម្មសិទ្ធិបញ្ញានិងសាធារណជនទូទៅ ព្រមទាំងបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានអប់រំតាមរាជធានី ខេត្ត ក្រុង
- រៀបចំកម្មវិធីនិងវគ្គបណ្តុះបណ្តាល ដល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារ នាំចេញ នាំចូលនៅក្រសួងពាណិជ្ជកម្ម
- អភិវឌ្ឍប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្រដើមកំណើតទំនិញ
- បង្កើនសមត្ថភាពមន្ទីរពិសោធន៍ដើម្បីទទួលបានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ បំពាក់សម្ភារៈ និងឧបករណ៍ដល់មន្ទីរពិសោធន៍ខ្នាតតូចនៅតាមព្រំដែន
- បង្កើនសកម្មភាពផ្សព្វផ្សាយការយល់ដឹងអំពីសុវត្ថិភាពម្ហូបអាហារនៅគ្រប់មជ្ឈដ្ឋាន។

៤.១២- គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដាក់ទិសដៅការងារសម្រាប់អនុវត្តនៅឆ្នាំខាងមុខដូចខាងក្រោម៖

- ខិតខំពន្លឿនបញ្ចប់ការរៀបចំឯកសារបទដ្ឋានគតិយុត្តមួយចំនួន ដូចជាសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស សេចក្តីព្រាងអនុក្រឹតស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃ

ព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្ដីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត ក្រោយពីច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១

- ធ្វើឱ្យប្រសើរឡើងនូវការផ្ដល់សេវាសាធារណៈតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាពិសេសសេវាស្នើសុំចុះបញ្ជីគម្រោងវិនិយោគនិងសេវាស្នើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ
- បន្តពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពនៃយន្តការច្រកចេញ ចូលតែមួយ និងយន្តការត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងវិនិយោគ និងខិតខំផ្ដល់សេវាថែទាំវិនិយោគដែលជាកត្តាសំខាន់ក្នុងការជំរុញនិងទាក់ទាញវិនិយោគ
- ជំរុញការបង្កើតនិងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស នៅតាមតំបន់មានសក្ដានុពលនិងនៅតាមបណ្ដោយព្រំដែន
- រៀបចំឡើងវិញនូវគេហទំព័រកក.អ.. សៀវភៅមគ្គុទ្ទេសក៍ និងខិត្តបណ្ណផ្សព្វផ្សាយវិនិយោគផ្អែកលើច្បាប់ស្ដីពីវិនិយោគដែលទើបអនុម័តថ្មី
- បន្តរៀបចំសិក្ខាសាលា សន្និសីទ ឬវេទិកាជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការផ្សព្វផ្សាយអំពីច្បាប់ស្ដីពីវិនិយោគ ព្រមទាំងសក្ដានុពលនិងកាលានុវត្តភាពនៃការវិនិយោគនៅកម្ពុជាដើម្បីជំរុញនិងទាក់ទាញការវិនិយោគក្នុងស្រុកនិងបរទេស។

## ២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

៤.១៣- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្ន ជាមួយបណ្ដាតួអង្គអភិវឌ្ឍសម្រាប់ការអភិវឌ្ឍប្រទេស
- ចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់និងពិភពលោក ដើម្បីបង្កើនកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍប្រទេស ពិសេសទាក់ទាញនូវទំនុកចិត្តមកលើសុខសន្តិភាព សុវត្ថិភាព និងបរិស្ថានវិនិយោគរបស់កម្ពុជា ក៏ដូចជាដើម្បីគោលដៅនៃការលើកកម្ពស់ កិត្យានុភាពរបស់កម្ពុជាផងដែរ
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនិងការបង្កើតបន្ថែមនូវយន្តការថ្មីៗ ដើម្បីទាក់ទាញការវិនិយោគថែមទៀត ទាំងវិស័យឯកជនទាំងស្ថាប័នអភិវឌ្ឍផ្លូវការ ក៏ដូចជាដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម ជំរុញការធ្វើពិពិធភាវូបនីយកម្មឧស្សាហកម្មនិងកសិកម្មដែល ផ្ដល់តម្លៃបន្ថែមខ្ពស់ អនុវត្តយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល លើកកម្ពស់ប្រសិទ្ធភាពសក្តិសិទ្ធភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៤.១៤- ក្រោមការដឹកនាំនិងភាពជាម្ចាស់ដ៏រឹងមាំរបស់រាជរដ្ឋាភិបាល និងដោយមានការគាំទ្រពីតួអង្គអភិវឌ្ឍទាំងអស់គ.ជ.នា/ក.អ.ក. កំពុងបន្តអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយសំដៅឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងជាមូលដ្ឋានទៅសម្រេចចក្ខុវិស័យជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងន័យនេះគ.ជ.នា/ក.អ.ក. នឹងបន្តដឹកនាំ កៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍតាមរយៈការសម្របសម្រួលភាពជាដៃគូនៅគ្រប់កម្រិត និងអនុវត្តវិធានការគោលនយោបាយនិងសកម្មភាពដែលកំណត់នៅក្នុងផ.យ.អ.ជ.២០១៩-២០២៣ ប្រកបដោយភាពបត់បែន។

## ២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក

៤.១៥- ក្រសួងពាណិជ្ជកម្ម នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំផ្ដល់សេវាពិគ្រោះយោបល់និងប្រឹក្សាកិច្ចការពាណិជ្ជកម្មនិងទីផ្សារជូនដល់ធុរជនជាលក្ខណៈអនឡាញ
- រៀបចំបង្កើតទីផ្សារឌីជីថល
- អភិវឌ្ឍការរៀបចំ ចងក្រង និងផ្សព្វផ្សាយស្ថិតិពាណិជ្ជកម្មសំខាន់ៗ និងទាន់ពេលវេលាជូនសាធារណជន ជាពិសេសពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្ម
- ពង្រឹងការតាមដានការងារនិងសម្របសម្រួលលើកិច្ចការ ក្នុងតារាងកម្មវិធីការងាររបស់រាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងពិនិត្យលើសង្គតិភាពនៃច្បាប់ឬសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីបំពេញកាតព្វកិច្ចក្នុងនាមជាសមាជិក
- សិក្សាលើបញ្ហាគាំទ្រក្នុងស្រុក រួមមានប្រព្រឹត្តិកម្មពិសេស តម្លាភាព គោលការណ៍សមាមាត្រ និងការជ្រោមជ្រែងដល់កសិករ។

# ៣- ការអភិវឌ្ឍធនធានមនុស្ស

## ៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៤.១៦- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ សម្រាប់រយៈពេល២ឆ្នាំកន្លះខាងមុខ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញគោលនយោបាយអប់រំរយៈពេលមធ្យមពីរនិងអាទិភាពកំណែទម្រង់នានា តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ឆ្ពោះទៅរួមចំណែកក្នុងការអនុវត្តអាទិភាពរបស់រាជរដ្ឋាភិបាលដូចខាងក្រោម៖

- **គោលនយោបាយទី១** ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

- **គោលនយោបាយទី២** ធានាភាពសក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

៤.១៧- ក្រសួងបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដោយផ្តោតលើសសរស្តម្ភ៥ (១)ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា (៣)ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃការសិក្សា ដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និង(៥)ការកែទម្រង់ឧត្តមសិក្សាដូចខាងក្រោម៖

- **យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ** (១)កំណែទម្រង់ការគ្រប់គ្រងការសិក្សា ផ្តោតលើវង្វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ការកែលម្អវិធីសាស្ត្របង្រៀននិងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល (២)កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ផ្តោតលើការធានាការចូលរួមរបស់មាតាបិតាសិស្សនិងសហគមន៍មូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងការអនុវត្តគោលនយោបាយអប់រំនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (៣)កំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុ ផ្តោតលើការបង្កើនស្វ័យភាពនិងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ និងការបង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ និង(៤)កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ផ្តោតលើការបណ្តុះបណ្តាលដោយផ្តោតលើវិធីសាស្ត្របង្រៀននិងកម្មវិធីបំប៉ននៅនឹងកន្លែង ការបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ
- **យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា** (១)ពិនិត្យលទ្ធភាពប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល (២)ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនិងធនធានមនុស្ស (៣)រៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាឱ្យឆ្លើយតបទៅនឹងការវិវត្តឧស្សាហកម្ម (៤)ជំរុញការស្រាវជ្រាវនិងលើកទឹកចិត្តការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង(៥)វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងនិងវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- **យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន** (១)ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាពនិងសមធម៌ (២)លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិន ភាព (៣)អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នា ដោយសន្តិភាពនិងសុខដុមនីយកម្ម (៤)បង្កឱកាសឱ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានានៅក្នុងការអភិវឌ្ឍសហគមន៍និងសង្គមជាតិ និង(៥)ពង្រឹងយន្តការគ្រប់គ្រងនិងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន

- **យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា** (១)អភិវឌ្ឍក្របខ័ណ្ឌច្បាប់និងគតិយុត្ត (២)អភិវឌ្ឍកីឡាកម្រិតខ្ពស់ (៣)ការអភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា (៤) អភិវឌ្ឍវិស័យអប់រំកាយនិងកីឡានៅគ្រប់គ្រឹះស្ថានសិក្សានិងសហគមន៍ និង (៥)អភិរក្សនិងអភិវឌ្ឍកីឡាគ្រប់ប្រភេទ។

៤.១៨- ក្រសួងអប់រំ យុវជន និងកីឡា ផ្តោតការអនុវត្តយុទ្ធសាស្ត្រអាទិភាពតាមអនុវិស័យដូចខាងក្រោម ៖

**ការអប់រំកុមារតូច**

- បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន
- លើកកម្ពស់គុណភាពសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដា
- ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច។

**ការអប់រំបឋមសិក្សា**

- វិធានការបង្កើនការចូលរៀនឱ្យបានទៀងទាត់និងរៀនចប់បឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានសិក្សាស្អាតនិងមានសុវត្ថិភាព ស្របតាមស្តង់ដាសាលាបឋមសិក្សា ជាពិសេសសាលារៀនមិនគ្រប់កម្រិតនិងសាលារៀនជួបការលំបាក
- លើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនដែលមានស្រាប់ និងកែលម្អការពង្រាយគ្រូ
- ពង្រឹងសមត្ថភាពគ្រូបង្រៀននិងអ្នកពាក់ព័ន្ធលើកម្មវិធីអំណាននិងគណិតវិទ្យាថ្នាក់ដំបូង
- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលសម្រាប់គ្រូបឋមសិក្សា
- កែលម្អការផ្គត់ផ្គង់និងការប្រើប្រាស់សៀវភៅសិក្សាគោលនិងសម្ភារៈរៀននិងបង្រៀន
- ពង្រឹងការងារអធិការកិច្ចនិងការពិនិត្យតាមដាននិងវាយតម្លៃពីគ្រប់កម្រិតថ្នាក់
- ពង្រឹងការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

**ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស**

- វិធានការកែលម្អការចូលរៀននិងរក្សាឱ្យបានគង់វង្សនៅមធ្យមសិក្សា ជាពិសេសក្រុមជួបការលំបាក
- ពង្រីកហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈរូបវន្តសម្រាប់សាលាមធ្យមសិក្សា
- ពង្រឹងនិងពង្រីកមុខវិជ្ជាវិទ្យាសាស្ត្រ ស្ទែម និងភាសាបរទេសដើម្បីឆ្លើយតបក្របខ័ណ្ឌជំនាញសតវត្សទី២១
- ជំរុញការអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងអភិក្រមការគ្រប់គ្រងតាមសាលារៀននៅកម្រិតសាលារៀន
- ពង្រីកការអនុវត្តស្តង់ដាគំរូសាលារៀនជំនាន់ថ្មី
- អភិវឌ្ឍក្របខ័ណ្ឌធានាគុណភាពអប់រំរបស់សាលារៀននៅមធ្យមសិក្សា

- ពង្រឹងប្រព័ន្ធពិនិត្យ តាមដាន និងវាយតម្លៃនៃអធិការកិច្ចនៅតាមសាលារៀន
- ពង្រីកភាពជាដៃគូជាមួយវិស័យឯកជននិងសហគ្រាស ដើម្បីពង្រឹងការអប់រំបច្ចេកទេស
- ពង្រឹងតម្រង់ទិសការសិក្សាឆ្ពោះទៅរកអាជីពនិងពង្រីកការអប់រំបច្ចេកទេស។

**ការអប់រំឧត្តមសិក្សា**

- បង្កើនការវិនិយោគលើកម្មវិធីអប់រំឧត្តមសិក្សាអាទិភាព ដោយផ្អែកលើលទ្ធផល
- កែលម្អសមត្ថភាពនៃការបង្រៀននិងរៀននិងការស្រាវជ្រាវ តាមរយៈការបង្កើតភាពជាដៃគូឧត្តមសិក្សា
- បង្កើនបុគ្គលិកសិក្សាពេញម៉ោងដែលមានគុណវុឌ្ឍិថ្នាក់បណ្ឌិត
- ពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនិងធនធានមនុស្សរបស់គ្រឹះស្ថានឧត្តមសិក្សាឆ្ពោះទៅទទួលបានស្វ័យភាពពេញលេញ
- កែលម្អប្រព័ន្ធធានាគុណភាពអប់រំនៅឧត្តមសិក្សា។

**ការអប់រំក្រៅប្រព័ន្ធ**

- អភិវឌ្ឍនិងកែលម្អកម្មវិធីអប់រំក្រៅប្រព័ន្ធ
- លើកកម្ពស់កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ
- ប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ជំរុញវិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងការចូលរួមគាំទ្រដល់កម្មវិធីអប់រំក្រៅប្រព័ន្ធរបស់អ្នកពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃការសិក្សាពេញមួយជីវិត
- កែលម្អប្រសិទ្ធភាពនិងគុណភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់។

**ការអភិវឌ្ឍយុវជន**

- ពង្រឹងជំនាញឌីជីថលនិងលើកកម្ពស់ចំណេះដឹងអនុវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាសម្រាប់យុវជន ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មដំណាក់កាលទី៤
- បង្កើនការបណ្តុះទម្លាប់នៃការគិតបែបច្នៃប្រឌិតនិងការបង្កើតថ្មីតាមរយៈស្មារតីសហគ្រិនភាព ការលើកកម្ពស់ការប្រកបមុខរបរដោយខ្លួនឯង និងលទ្ធភាពទទួលបានសេវាណែនាំអាជីវកម្មនិងការងារ និងព័ត៌មានទីផ្សារ
- អភិវឌ្ឍយុវជនឱ្យបានពេញលេញនិងអប់រំពួកគេឱ្យរស់នៅជាមួយគ្នាក្នុងសន្តិភាពនិងសុខដុមនីយកម្ម ប្រកបដោយស្មារតីស្នេហាជាតិ ស្រឡាញ់ប្រជាជន ជឿជាក់និងផ្តល់តម្លៃខ្ពស់ដល់ខ្លួនឯង មានភាពជាអ្នកដឹកនាំ និងការយល់ដឹងទូលំទូលាយអំពីសង្គម
- លើកទឹកចិត្តយុវជនឱ្យចែករំលែកការយល់ឃើញទស្សនវិស័យ និងចូលរួមក្នុងដំណើរការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍និងសង្គម
- ប្រែក្លាយមជ្ឈមណ្ឌលយុវជនឱ្យក្លាយទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមសហគមន៍។

**ការអភិវឌ្ឍការអប់រំកាយនិងកីឡា**

- អភិវឌ្ឍសមត្ថភាពកីឡាកម្រិតខ្ពស់
- ដំណើរឆ្ពោះទៅកីឡាស៊ីហ្គេមឆ្នាំ២០២៣
- អភិវឌ្ឍសមត្ថភាពស្ថាប័នរបស់អនុវិស័យអប់រំកាយនិងកីឡា
- អភិវឌ្ឍសមត្ថភាពគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម និងមន្ត្រីបច្ចេកទេសកីឡា
- លើកកម្ពស់ការប្រកួតកីឡាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់
- អភិវឌ្ឍបន្តនិងកែលម្អបរិក្ខារកីឡាដែលមានស្រាប់
- ពង្រឹងការអនុវត្តអប់រំកាយនិងកីឡានៅតាមគ្រឹះស្ថានសិក្សា
- លើកកម្ពស់ការអប់រំកាយនិងកីឡានៅតាមសហគមន៍
- លើកកម្ពស់ការផ្សព្វផ្សាយកីឡាគ្រប់ប្រភេទដល់សាធារណជន។

## ៣.២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

៤.១៩- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧ ២០២៥-ផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៩២០២៣- និងបង្កើនកិច្ចសហការជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍនានាដើម្បីចូលរួមគាំទ្រការអភិវឌ្ឍវិស័យអវ.ប..
- បន្តពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័នគាំទ្រការផ្តល់សេវាការងារទាំងផ្នែករូបវន្តនិងប្រព័ន្ធឌីជីថល សំដៅប្រមូលផ្សព្វផ្សាយព័ត៌មានស្ថិតិទីផ្សារការងារបានទាន់ពេលវេលាឆ្លើយតបតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា ព្រមទាំងជំរុញការរៀបចំវេទិកាការងារតាមថ្នាក់មូលដ្ឋានរាជធានីខេត្ត ដើម្បីបង្កើនឱកាសទទួលបានការងារកាន់តែងាយស្រួលដល់យុវជន
- បន្តពង្រឹងយន្តការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា នៅតាមគ្រឹះស្ថានអ.ប.វ .ដោយសុំគោលការណ៍នៃការផ្តល់រង្វាន់លើកទឹកចិត្តដល់គ្រឹះស្ថានអ.ប.វ. សម្រាប់ការអនុវត្តការធានាគុណភាពនិងរៀបចំរបាយការណ៍ផ្ទូផ្ទងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជានិងក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន
- បន្តអភិវឌ្ឍនិងអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត១ ២ និង៣ លើជំនាញអគ្គិសនី/អេឡិចត្រូនិក មេកានិករថយន្តសំណង់ កម្មន្តសាល និងធុរកិច្ច/ព័ត៌មានវិទ្យា
- បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងដៃគូអភិវឌ្ឍនានា ដើម្បីចូលរួមគាំទ្រដល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយគុណភាពនិងតាមតម្រូវការជាក់ស្តែងនៃសភាពការណ៍ ជាពិសេសក្នុងដំណាក់កាលចាំបាច់ត្រូវបង្កើនសមត្ថភាព

ជំនាញនិងបណ្តុះបណ្តាលជំនាញឡើងវិញនៃកម្លាំងពលកម្មដែលកំពុងស្ថិតនៅក្នុងទីផ្សារការងារស្រាប់និងឱកាសការងារថ្មីៗ។

## ៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ

៤.២០- អន្តរាគមន៍ជាអាទិភាព នឹងផ្តោតជាចម្បងលើការផ្តល់សេវាសុខាភិបាលគ្រប់ជ្រុងជ្រោយជូនប្រជាពលរដ្ឋកម្ពុជា ក្នុងនោះរួមមានសេវាអប់រំសុខភាព បង្ការ ពិនិត្យពិគ្រោះជំងឺ ការធ្វើរោគវិនិច្ឆ័យ ផ្តល់ការព្យាបាលថែទាំ និងស្តារនីតិសម្បទាដែលមានគុណភាពនិងប្រសិទ្ធភាពខ្ពស់ ព្រមទាំងពង្រឹងការឆ្លើយតបនឹងបញ្ហាសុខភាពសាធារណៈនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ តាមរយៈការពង្រឹងការអនុវត្តសកម្មភាពនៃកម្មវិធីសុខភាពជាអាទិភាពនិងការពង្រឹងប្រព័ន្ធសុខាភិបាល។ ក្រសួងសុខាភិបាល នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- លើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ ផ្តល់វ៉ាក់សាំងបង្ការជំងឺ និងអាហារូបត្ថម្ភ
- លើកកម្ពស់ការបង្ការនិងគ្រប់គ្រងជំងឺឆ្លងៈ ទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ មេរោគអេដស៍/ជំងឺអេដស៍ របេង គ្រុនចាញ់ ជំងឺរលាកថ្លើម ជំងឺឆ្លងតំបន់ត្រូពិក ជំងឺបណ្តាលមកពីដង្កូវព្រូន ជំងឺហង់សិនឬជំងឺឃ្លង់ ជំងឺឆ្លងដែលលេចឡើងឬលេចឡើងសាជាថ្មី
- លើកកម្ពស់ការបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង
- បន្ថយកត្តាហានិភ័យនិងកត្តាសង្គមប៉ះពាល់ដល់សុខភាព ដូចជាថ្នាំជក់/គ្រឿងញៀន គ្រឿងស្រវឹង ចំណីអាហារ អនាម័យ ទឹកស្អាត បង្គន់ប្រើប្រាស់។ល។
- ផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍និងរបួស ការត្រៀមបម្រុង និងការឆ្លើយតបគ្រោះមហន្តរាយ ហានិភ័យសុខភាពបរិស្ថាន ការបំពុលបរិយាកាស និងការប្រែប្រួលអាកាសធាតុ
- ពង្រីកសេវាសំណុំសកម្មភាពអប្បបរមានៅមណ្ឌលសុខភាពនិងសេវាសំណុំសកម្មភាពបង្គ្រប់នៅមន្ទីរពេទ្យបង្អែក ដោយបង្កើនសកម្មភាពផ្តល់សេវាបង្ការជំងឺនិងលើកកម្ពស់សុខភាព ចុះផ្តល់សេវាតាមមូលដ្ឋាន ពង្រឹងប្រព័ន្ធបញ្ជូនអ្នកជំងឺ ដោយត្រៀមសេវាបញ្ជូនលើ២៤ម៉ោង។ល។
- ពង្រឹងការអនុវត្តយន្តការត្រួតពិនិត្យតាមដាននិងលើកកម្ពស់គុណភាពសេវា ទាំងគុណភាពនៃការគ្រប់គ្រងនិងគុណភាពសេវាថែទាំព្យាបាល នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិអនុលោមតាមគោលការណ៍/ពិធីសារនៃការព្យាបាល មគ្គុទ្ទេសក៍ ប្រតិបត្តិគ្លីនិក ដោយរាប់បញ្ចូលទាំងវិធានការបង្ការឬទប់ទល់ភាពស៊ាំនៃអតិសុខុមប្រាណនិងឱសថព្យាបាល អនុវត្តវិធានបង្ការនិងគ្រប់គ្រងការឆ្លងរោគនៅមូលដ្ឋានសុខាភិបាល
- បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យប្រកាន់ឥរិយាបថត្រឹមត្រូវនិងប្រតិបត្តិរបៀបរបបរស់នៅប្រកបដោយសុខភាព

- លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីមូលនិធិសមធម៌ របបសន្តិសុខសង្គម និង ជំនួយសង្គម
- បង្កើនគុណភាពនៃការបណ្តុះបណ្តាល នៅគ្រប់គ្រឹះស្ថានបណ្ដុះបណ្តាលសាធារណៈ និង ឯកជនដោយយកចិត្តទុកដាក់លើកម្មវិធីសិក្សាដែលផ្តោតលើសមត្ថភាព
- អភិវឌ្ឍយន្តការសម្រាប់ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានបណ្តុះបណ្តាលទាំង សាធារណៈនិងឯកជន ដើម្បីវាយតម្លៃនិងរក្សាគុណភាពនៃកម្មវិធីសិក្សានិងការបណ្តុះ បណ្តាល
- លើកកម្ពស់ការអនុវត្ត ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យសុខាភិបាល
- ផ្គត់ផ្គង់ឱសថ បរិក្ខារ វ៉ាក់សាំង ប្រតិកម្មករ និងសម្ភារៈពេទ្យ ដែលមានបរិមាណនិងគុណ ភាពគ្រប់គ្រាន់ ទាន់ពេលវេលា ជាពិសេសមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព និងមន្ទីរពេទ្យ បង្អែក លើកកម្ពស់ការប្រើប្រាស់ឱសថ បរិក្ខារដែលបានចែងនៅក្នុងបញ្ជី "ឱសថសារវន្ត" ដោយមានវេជ្ជបញ្ជា ការវេចខ្ចប់ និងការផ្តល់ឱ្យអ្នកជំងឺបានត្រឹមត្រូវ
- ផ្តល់ព័ត៌មានទាន់ពេលវេលាដល់បុគ្គលិកសុខាភិបាលនិងសាធារណជនអំពីឱសថ ផលិត ឱសថ(ឱសថសម័យនិងឱសថបូរាណ) និងផលិតផលគ្រឿងសម្អាងណាដែលបង្ក ហានិភ័យដល់សុខភាព
- ពង្រឹងបណ្តាញមន្ទីរពិសោធន៍វេជ្ជសាស្ត្រទូទាំងប្រទេស ការប្រើប្រាស់ឈាម និងផលិត ផលឈាមមានគុណភាពនិងសុវត្ថិភាព និងបំពាក់ឧបករណ៍វេជ្ជសាស្ត្រកម្រិតមូលដ្ឋាន ដល់ប៉ុស្តិ៍សុខភាព/មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកគ្រប់កម្រិត ដើម្បីបង្កើនសមត្ថភាព នៃការផ្តល់សេវាសុខាភិបាល
- ពង្រីកហេដ្ឋារចនាសម្ព័ន្ធធនធានព័ត៌មានវិទ្យា ការប្រាស្រ័យទាក់ទងនិងបច្ចេកវិទ្យាដោយ រាប់បញ្ចូលទាំងផ្នែករឹងនិងផ្នែកទន់ និងផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ស្តីពីការប្រើប្រាស់ បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងពង្រឹងប្រព័ន្ធរាយការណ៍បន្ទាន់ដែលកំពុងដំណើរ ការបច្ចុប្បន្ន
- ពង្រឹងការអនុវត្តច្បាប់និងនីតិក្រមសុខាភិបាល ដូចជាការចុះបញ្ជិកា ការផ្តល់អាជ្ញាបណ្ណ ការ លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលអត់ច្បាប់ ការអនុវត្តគោលនយោបាយ/ នីតិក្រមទាក់ទងនឹងសុវត្ថិភាពចំណីអាហារ អនាម័យ/សុខភាពបរិស្ថាន។ល។

៤.២១- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅតែបន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍លើកទី៥ គោលនយោបាយនិងសេចក្តី សម្រេចចិត្តរបស់រាជរដ្ឋាភិបាល(លិខិតលេខ២១៣ សជណ.សស) ក្នុងការប្រយុទ្ធទប់ស្កាត់ការ រីករាលដាលមេរោគអេដស៍និងជំងឺអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ និង ការបញ្ចប់អេដស៍នៅឆ្នាំ២០២៥ ក្នុងនោះ យើងនឹងបន្តជំរុញផែនការពង្រឹងស្ថាប័ន បង្កើនវិមជ្ឈការ ការងារអេដស៍ទៅថ្នាក់ក្រោមជាតិ និងធ្វើសមាហរណកម្មកម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺ អេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងបន្តការផ្តល់បណ្ណសមធម៌ដល់គ្រប់អ្នកផ្ទុកមេរោគ អេដស៍។

## សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

៤.២២- ក្រុមប្រឹក្សា នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ២០១៩-២០២៣
- បន្តអនុវត្តសេចក្ដីជូនដំណឹងរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី លេខៈ៩៣៤ ស.ជ.ណ. ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២០
- បន្តពង្រឹងយន្តការស្ថាប័នដើម្បីលើកកម្ពស់អភិបាលកិច្ចលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ទាំងថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចូលរួមអនុវត្តផែនការសកម្មភាពនៃចលនាបង្កើនអាហារូបត្ថម្ភពិភពលោក ដំណើរការក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ វេទិកាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងវេទិកានានា និងការបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភថ្នាក់ខេត្ត
- បន្តកិច្ចសហការជាមួយអង្គការFAO, WFP, UNICEF, WHO, GIZ, HKI និងស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងដៃគូអភិវឌ្ឍដទៃទៀត ដើម្បីលើកកម្ពស់វិស័យសន្តិ-សុខស្បៀងនិងអាហារូបត្ថម្ភ
- បន្តពង្រឹងនិងពង្រីកបណ្ដាញធុរកិច្ចនៃចលនាបង្កើនអាហារូបត្ថម្ភនិងបណ្ដាញយុវជនជើងឯកអាហារូបត្ថម្ភ
- ធ្វើការវាយតម្លៃពាក់កណ្ដាលអាណត្តិយុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី២ ឆ្នាំ២០១៩-២០២៣ និងដាក់ឱ្យប្រើប្រាស់ និងត្រួតពិនិត្យតាមដានសូចនាកររួមគ្នារបស់ក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- បន្តអនុវត្តផែនទីបង្ហាញផ្លូវស្ដីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០
- បន្តអនុវត្តផែនទីបង្ហាញផ្លូវស្ដីពីសកម្មភាពសកលដើម្បីឆ្លើយតបភាពស្គមស្គាំងរបស់កុមារ ឆ្នាំ២០៣០
- បន្តអនុវត្តសេចក្ដីថ្លែងការណ៍រួមរបស់កិច្ចប្រជុំកំពូលស្ដីពីប្រព័ន្ធស្បៀងដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅទីក្រុងញូយ៉ក កាលពីឆ្នាំ២០២១
- បន្តអនុវត្តសេចក្ដីថ្លែងការណ៍រួមរបស់កិច្ចប្រជុំកំពូលស្ដីពីអាហារូបត្ថម្ភដើម្បីកំណើន ដែលរៀបចំឡើងដោយរដ្ឋាភិបាលជប៉ុននៅទីក្រុងតូក្យូ កាលពីឆ្នាំ២០២១
- បន្តពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្ដីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងធ្វើបច្ចុប្បន្នភាពជាប្រចាំលើគេហទំព័រ www.foodsecurity.gov.kh ធ្វើបច្ចុប្បន្នភាពជា

ប្រចាំFacebook page: https://web.facebook.com/fsncu2016 និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

- បន្តកសាងសមត្ថភាពដល់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើវិស័យសន្តិ-សុខស្បៀងនិងអាហារូបត្ថម្ភ
- បន្តរៀបចំទិវាជាតិអាហារូបត្ថម្ភនិងទិវាអាហារូបត្ថម្ភថ្នាក់ក្រោមជាតិ នៅថ្ងៃទី៦ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ
- បន្តការត្រួតពិនិត្យតាមដាន វាយតម្លៃ លើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

៤.២៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មីនិងការពង្រីកវិសាលភាពលើកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រនិងងាយរងគ្រោះតាមរយៈការបន្តដំណើរការកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ សិក្សារៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាលក្ខណៈកញ្ចប់គ្រួសារសម្រាប់ក្រុមជនរងគ្រោះនិងងាយរងគ្រោះ។

៤.២៤- ក្រសួងផែនការ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តរៀបចំយុទ្ធសាស្ត្រនិងគោលការណ៍ណែនាំបច្ចេកទេសស្តីពីអាហារបញ្ចូលមីក្រូសារជាតិគ្រប់ទម្រង់
- បន្តពង្រីកនិងពង្រឹងកម្មវិធីបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារមូលដ្ឋានផ្សេងៗទៀតដែលសមស្រប និងធានាបាននូវគុណភាព សុវត្ថិភាព និងបរិមាណគ្រប់គ្រាន់តាមតម្រូវការ និងបន្តពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់
- បន្តជំរុញដាក់បញ្ចូលមីក្រូសារជាតិគ្រប់កម្រិតទៅក្នុងចំណីអាហារសមស្រប និងធានាបាននូវគុណភាព សុវត្ថិភាព និងបរិមាណគ្រប់គ្រាន់តាមតម្រូវការទៅក្នុងបញ្ជីស្តង់ដាជាតិ
- បន្តបង្កើនការផ្សព្វផ្សាយចំណេះដឹង ស្តីពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិអំបិល អ៊ីយ៉ូដ ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក អង្ករបញ្ចូលមីក្រូសារជាតិ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យបានទូលំទូលាយ
- បន្តបង្កើនការត្រួតពិនិត្យគុណភាព សុវត្ថិភាព ការផលិត ការវេចខ្ចប់ ការចែកចាយ ការប្រើប្រាស់ អាហារបញ្ចូលមីក្រូសារជាតិអំបិលអ៊ីយ៉ូដ) ទឹកត្រី ទឹកស៊ីអ៊ីវមានជាតិដែក( ឱ្យមានប្រសិទ្ធភាព
- បន្តសម្របសម្រួលជាមួយផលិតករអំបិលខេត្តកំពត កែប ដើម្បីបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិលឡើងវិញក្រោយពីសហគមន៍អ្នកផលិតអំបិលប្រចាំខេត្តកំពត កែប ត្រូវបានបញ្ចប់តាំងពីឆ្នាំ២០១៩
- បន្តសហការជាមួយអង្គការកម្មវិធីស្បៀងអាហារពិភពលោក ពង្រីកកម្មវិធីបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ និងបន្តសហការជាមួយអង្គការHKI ធ្វើការស្រាវជ្រាវលើការបញ្ចូលវីតាមីនបេ១(B1) ក្នុងអំបិលអ៊ីយ៉ូដ។

### វិស័យទឹកស្អាត

៤.២៥- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ជំរុញការអនុម័តសេចក្ដីព្រាងច្បាប់ "ការគ្រប់គ្រងផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា" និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយស្ដីពីការផ្គត់ផ្គង់ទឹកស្អាត
- បន្តពង្រឹងវឌ្ឍនភាពអង្គភាពរដ្ឋាករទឹកសាធារណៈ
- ពង្រឹងការគ្រប់គ្រងទិន្នន័យនិងស្ថិតិវិស័យទឹកស្អាត
- លើកកម្ពស់សមត្ថភាពបច្ចេកទេសនិងការគ្រប់គ្រងគុណភាពទឹក។

## ៣.៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

៤.២៦- ក្រសួងកិច្ចការនារី នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- អនុវត្តនិងផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តនានា
- បញ្ចប់សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីសមភាពយេនឌ័រនិងស្នើសុំការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា
- បញ្ចប់សេចក្ដីព្រាងគោលការណ៍ណែនាំជាតិស្ដីពីការបញ្ជ្រាបយេនឌ័រតាមវិស័យ
- បញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍបៃតង
- ពង្រីកកាលានុវត្តភាព បរិយាកាសមេត្រីភាព ដើម្បីអភិវឌ្ឍជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ជាពិសេសនៅតាមសហគមន៍ជនបទនិងការអភិវឌ្ឍសហគ្រិនភាព អាជីវកម្មខ្នាតមីក្រូ តូច និងមធ្យមរបស់ស្ត្រី ការអភិវឌ្ឍមុខងារមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី ឱ្យស្របតាមបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤និងសេដ្ឋកិច្ចឌីជីថល ក្នុងក្របខ័ណ្ឌស្តារសេដ្ឋកិច្ចក្រោយពីវិបត្តិកូវីដ-១៩
- លើកកម្ពស់ការចូលរួមរបស់ស្ត្រីនិងក្មេងស្រីក្នុងវិស័យអប់រំនិងជំនាញដែលស្របតាមបរិបទនៃទីផ្សារការងារនិងការអប់រំកម្រិតខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងការអប់រំផ្នែកវិទ្យា-សាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ការងារលើកកម្ពស់សីលធម៌សង្គមនិងតម្លៃស្ត្រី តាមរយៈការពង្រឹងការអនុវត្តកម្មវិធីភាពជាមាតាបិតា វប្បធម៌អហិង្សា ជំរុញការអនុវត្តច្បាប់និងផែនការយុទ្ធសាស្ត្រ ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារគ្រប់រូបភាព រួមទាំងការលើកកម្ពស់សុខុមាលភាពស្ត្រីនិងក្មេងស្រី ជាពិសេសនៅក្នុងក្របខ័ណ្ឌកិច្ចគាំពារសង្គម

- ការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ នយោបាយ និងវិស័យឯកជន និងជាពិសេសនៅក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២
- ផ្សព្វផ្សាយនិងតាមដានការអនុវត្តច្បាប់ជាតិពាក់ព័ន្ធនឹងស្ត្រី គោលនយោបាយជាតិ អនុសាសន៍គន្លឹះរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ
- ពង្រីកវិសាលភាពក្នុងការផ្ដល់សេវាជួយដល់ស្ត្រីនិងក្មេងស្រី ដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកន្លែងផ្ដល់សេវាចម្រុះជួយជនរងគ្រោះនៅតាមមន្ទីរពេទ្យខេត្ត តាមរយៈក្រុមការងារឆ្លើយតបពហុវិស័យនៅគ្រប់កម្រិត
- ពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់ សហគមន៍អាស៊ាន និងជាសកល ក្នុងការលើកកម្ពស់សិទ្ធិស្ត្រីនិងកុមារ ជាពិសេសកម្ពុជាជាប្រធានគណៈកម្មការស្ដីពីស្ត្រីអាស៊ានឆ្នាំ២០២១នេះ
- អភិវឌ្ឍសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័នឱ្យស្របតាមការវិវឌ្ឍនិងតម្រូវការជាក់ស្ដែងរបស់សង្គមដែលកើតមានថ្មីៗ ជាពិសេសក្នុងបរិបទកំឡុងនិងក្រោយវិបត្តិកូវីដ-១៩។

៤.២៧- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មីនិងការពង្រីកវិសាលភាពលើកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រនិងងាយរងគ្រោះ តាមរយៈការបន្តដំណើរការកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ សិក្សារៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាលក្ខណៈកញ្ចប់គ្រួសារសម្រាប់ក្រុមជនរងគ្រោះនិងងាយរងគ្រោះ
- ដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្ដល់សេវាអប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ការថែទាំសុខភាព ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ បង្កឱកាសស្ដារជីវភាពនិងធ្វើសមាហរណកម្មទៅក្នុងសង្គមដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស
- អនុវត្តកម្មវិធីអភិវឌ្ឍគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដោយប្រមូលផ្ដុំលើការសិក្សានិងរៀបចំគោលនយោបាយជាតិស្ដីពីការគាំពារគ្រួសារ ការរៀបចំទិវាអន្តរជាតិស្ដីពីគ្រួសារ ១៥ឧសភា ការបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ផ្ដល់សេវាស្ដារនីតិសម្បទាជូនជនរងគ្រោះដោយសារការជួញដូរមនុស្ស អនីតិជនទំនាស់នឹងច្បាប់ និងជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន
- បន្តពង្រឹងប្រព័ន្ធនិងគុណភាពសេវាកិច្ចការពារកុមារ ដោយប្រមូលផ្ដុំលើការបង្កើតនិងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យថ្នាក់ជាតិដើម្បីគ្រប់គ្រងទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះ
- បង្កើនប្រសិទ្ធភាពផ្ដល់សេវាសុខុមាលភាពជនពិការនិងលើកកម្ពស់សិទ្ធិជនពិការ ដោយប្រមូលផ្ដុំលើការរៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងជនពិការឱ្យបានច្បាស់លាស់ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបង្កើតមុខរបរដល់ជនពិការ សម្របសម្រួលនិងជំរុញឱ្យក្រសួង ស្ថាប័នរដ្ឋ និង

សហគ្រាសឯកជនអនុវត្តកាតព្វកិច្ចទទួលជនពិការចូលបម្រើការងារ និងរៀបចំលក្ខណៈងាយស្រួលសម្រាប់ជនពិការបម្លាស់ទី និងលើកទឹកចិត្តចលនាកីឡាសិល្បៈរបស់ជនពិការ

- ពង្រឹងសកម្មភាពសមាគមមនុស្សចាស់ តាមឃុំ សង្កាត់ ដោយប្រមូលផ្តុំលើការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមមនុស្សចាស់ ការពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់និងអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ថ្នាក់រាជធានី ខេត្ត និងការកែសម្រួលលក្ខន្តិកៈសមាគមមនុស្សចាស់
- ជំរុញអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០
- សហការជាមួយបេឡាជាតិរបបសន្តិសុខសង្គមប.ស.ស. ដើម្បីផ្តល់សេវាធានារ៉ាប់រងសុខភាពសម្រាប់អតីតមន្ត្រីរាជការស៊ីវិល
- បន្តកែសម្រួលរបបសន្តិសុខសង្គម តាមរយៈការកាត់បន្ថយគម្លាតនៃរបបសោធនរបស់នគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ និងការបង្កើនប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងអ្នកនៅក្នុងបន្ទុក
- បន្តផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទនិងរបបគោលនយោបាយថែទាំសុខភាពជូនជនពិការ។

៤.២៨- ក្រសួងផែនការ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធនានា ដើម្បីតាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ តាមរយៈការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយជាតិប្រជាជនដំណាក់កាលទី៣ ២០២២-២០២៤ ដើម្បីឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមនិងវិធានការឆ្លើយតបទាំងឡាយដែលជះឥទ្ធិពលដល់ផ្នែកប្រជាសាស្ត្រដែលកើតមានឡើងថ្មីៗ ដែលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ទន្ទឹមនឹងនោះ ការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ នឹងត្រូវពង្រឹងឱ្យកាន់តែខ្លាំងថែមទៀត
- បន្តពង្រឹងយន្តការស្ថាប័ននិងសម្របសម្រួលការអនុវត្តការប្តេជ្ញាចិត្តនៃការអភិវឌ្ឍដោយផ្តោតមកលើប្រជាជនរបស់រាជរដ្ឋាភិបាល តាមរយៈការរៀបចំកម្មវិធីពិគ្រោះយោបល់គោលនយោបាយ ដើម្បីពង្រឹងការយល់ដឹងអំពីផលប៉ះពាល់គោលនយោបាយនៃការធ្វើហិរញ្ញប្បទានអភិវឌ្ឍន៍ និងការវិភាជថវិកាជាតិសម្រាប់ការវិនិយោគនិងការអភិវឌ្ឍលើវិស័យអាទិភាព នាពេលអនាគត
- រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃគោលនយោបាយជាតិប្រជាជននៅឆ្នាំ ២០២៣ ដែលឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងផលប៉ះពាល់នៃបម្រែបម្រួលប្រជាសាស្ត្រទៅលើការអភិវឌ្ឍសង្គម សេដ្ឋកិច្ច នៅក្នុងបរិការណ៍តាមបែបគន្លងថ្មី ដោយគិតគូរពីហានិភ័យនៃជំងឺកូវីដ-១៩ និងហានិភ័យនៃជំងឺនិងព្រឹត្តិការណ៍ជាសកលផ្សេងទៀតដែលអាចកើតមានឡើងនាពេលអនាគត។

## ៥- ការធ្វើពិពិធកម្មសេដ្ឋកិច្ច

## ៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

៤.២៩- ក្រសួងសាធារណការនិងដឹកជញ្ជូន នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តនីតិវិធីក្នុងការរៀបចំច្បាប់ដែលពាក់ព័ន្ធ ដូចជាច្បាប់ស្ដីពីទឹកកខ្វក់និងប្រព័ន្ធលូ ច្បាប់ស្ដីពីកំពង់ផែ ច្បាប់ស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹក វិសោធនកម្មច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក និងលិខិតគតិយុត្តមួយចំនួនទៀត
- រៀបចំសេចក្ដីព្រាងផែនការមេស្ដីពីការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយនិងភស្តុភារកម្ម
- រៀបចំកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង សម្រាប់ពង្រឹងសមត្ថភាព បុគ្គលិក មន្ត្រីរាជការ និងអ្នកបច្ចេកទេសអនុវត្តគម្រោងសាងសង់នានា
- អភិវឌ្ឍមុខងារវិភាគព័ត៌មានលេខអត្តសញ្ញាណយានជំនិះឆ្លាតវៃនៃប្រព័ន្ធចុះបញ្ជីយានជំនិះ ដើម្បីទាញយកព័ត៌មានយានជំនិះ តាមស្តង់ដាអន្តរជាតិ
- បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងដីចំណីផ្លូវ ដើម្បីទប់ស្កាត់ការរំលោភទន្ទ្រានកាន់កាប់ ប្រើប្រាស់ដីចំណីផ្លូវដោយខុសច្បាប់
- ជំរុញការសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់និងអភិវឌ្ឍថ្មីទំនើប ប្រកបដោយគុណភាពឆ្លើយតបនឹងនិរន្តរភាពបរិស្ថាននិងឧត្តមានុវត្តន៍អន្តរជាតិ ដើម្បីធានាធ្វើចរាចរណ៍បានគ្រប់រដូវទូទាំងប្រទេស និងតភ្ជាប់ទៅក្នុងតំបន់និងសកលលោក
- ស្ដារនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដើម្បីគាំទ្រគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
- ស្ដារឡើងវិញនូវវិស័យដឹកជញ្ជូនតាមផ្លូវដែក
- កែសម្រួលប្រកាសស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់បណ្ណបើកបរយានយន្ត
- បន្តអនុវត្តផែនការបណ្តុះបណ្តាលស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ពង្រឹងការងារគ្រប់គ្រងនិងការចុះបញ្ជីនាវាតាមផ្លូវទឹក ទាំងការងារពាក់ព័ន្ធផ្សេងទៀតនៅតាមបណ្ដាមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តដែលមានផ្លូវទឹក តាមរយៈការចុះផ្សព្វផ្សាយនិងណែនាំដល់មន្ត្រីអនុវត្តនិងប្រតិបត្តិករ
- បន្តជំរុញនិងសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជានិងវៀតណាមស្ដីពីការដឹកជញ្ជូនតាមផ្លូវទឹកឆ្នាំ២០០៩ក្នុងបរិបទកូវីដ-១៩
- ពង្រឹងគុណភាពមន្ទីរពិសោធន៍ឱ្យបានសមស្របតាមស្តង់ដាISO/IEC១៧០២៥
- បន្តរៀបចំសិក្សានូវទស្សនទានកំពង់ផែសេរី សម្រាប់កំពង់ផែស្វយ័តក្រុងព្រះសីហនុ
- គម្រោងអភិវឌ្ឍន៍នៅទីតាំងចំណតផែកុងតឺន័រLM១៧ គម្រោងអភិវឌ្ឍន៍នៅទីតាំងចំណតផែវណបគ.ម.លេខ៦(KM៦) ទីតាំងចំណតផែទន្លេបិទ(UM២) ចំណតផែកោះរកា និងនៅទីតាំងផ្សេងៗទៀត រួមមានការពង្រីកហេដ្ឋារចនាសម្ព័ន្ធផែនិងការបំពាក់គ្រឿងចក្រ/

ឧបករណ៍ផ្សេងៗបន្ថែមទៀត ក្នុងគោលបំណងផ្ដល់លទ្ធភាពនិងពង្រីកវិសាលភាពនៃការលើកដាក់ទំនិញនិងគម្រោងអភិវឌ្ឍន៍ចំណតផែទេសចរណ៍អន្តរជាតិនៅចំណតផែពហុបំណងTS៣ សម្រាប់កំពង់ផែស្វយ័តភ្នំពេញ

៤.៣០- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បង្កើនចំនួនអ្នកធ្វើដំណើរតាមផ្លូវអាកាសជាតិនិងអន្តរជាតិឱ្យបានចំនួនកាន់តែច្រើនឡើង
- លើកកម្ពស់គុណភាពសេវាកម្មនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ស៊ីវិលដើម្បីធានាសុវត្ថិភាពនិងសន្តិសុខសម្រាប់ប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស
- រៀបចំសេចក្ដីព្រាងកិច្ចព្រមព្រៀងរវាងSSCA-CATS កម្ពុជានិងចិន កម្ពុជានិងឡាវ និងកម្ពុជានិងថៃ លើកិច្ចសហប្រតិបត្តិការសម្រាប់ការផ្ដល់សេវាកម្មក្នុងការរុករកនិងសង្គ្រោះ
- បន្តស្នើសុំធ្វើការកែសម្រួលអនុស្សរណៈយោគយល់គ្នារវាងកម្ពុជានិងសិង្ហបុរីស្ដីអំពីការស៊ើបអង្កេតគ្រោះថ្នាក់និងឧបទ្ទវហេតុយន្តហោះ បន្តរៀបចំ ចងក្រង និងកែសម្រួលសេចក្ដីព្រាងច្បាប់ស្ដីពីការស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍
- បន្តបណ្ដុះបណ្ដាលធនធានមនុស្សជំនាញអាកាសចរណ៍ស៊ីវិលទៅតាមកម្រិតស្ដង់ដារបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

៤.៣១- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងវិស័យប្រៃសណីយ៍ ដើម្បីធានាការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍និងការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ តាមរយៈការកសាងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រួមជាមួយនឹងការជំរុញនវានុវត្តន៍ ការធ្វើពិពិធកម្មសេវាកម្មនិងផលិតផលប្រៃសណីយ៍ ការធ្វើទំនើបកម្មប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៃសេវាប្រៃសណីយ៍ និងពង្រីកបណ្ដាញប្រៃសណីយ៍ឱ្យមានវិសាលភាពទូលំទូលាយខិតកាន់តែជិតប្រជាជនដើម្បីគាំទ្រធុរកិច្ចតាមប្រព័ន្ធអេឡិចត្រូនិកនិងសេវាសាធារណៈរបស់រដ្ឋាភិបាលឌីជីថល
- ជំរុញការអភិវឌ្ឍ និងការដាក់ពង្រាយហេដ្ឋារចនាសម្ព័ន្ធបណ្ដាញខ្សែកាបអុបទិកឆ្អឹងខ្នងនិងអ៊ិនធឺណិតល្បឿនលឿន ព្រមទាំងពង្រីកវិសាលភាពគ្របដណ្ដប់សេវាទូរសព្ទចល័តឱ្យកាន់តែទូលំទូលាយ ដោយលើកទឹកចិត្តការវិនិយោគដល់វិស័យឯកជន និងការប្រើប្រាស់យន្តការកាតព្វកិច្ចសេវាសកល ពិសេសតំបន់ជនបទដាច់ស្រយាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានកម្រទូរគមនាគមន៍ ពង្រឹងកិច្ចការពារសិទ្ធិអ្នកប្រើប្រាស់ទប់ស្កាត់ការឆ្លងរំខាន ធានាសុវត្ថិភាពសុខភាពសាធារណៈ និងលើកកម្ពស់គុណភាពសេវាដើម្បីកាត់បន្ថយគម្លាតឌីជីថល។

## ៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

៤.៣២- ក្រសួងទេសចរណ៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ការកែទម្រង់ក្នុងវិស័យទេសចរណ៍កម្ពុជាឱ្យទៅជាគោលដៅទេសចរណ៍គុណភាព សុវត្ថិភាព និងនិរន្តរភាពដោយទាញយកមកវិញនូវចំនួនភ្ញៀវទេសចរអន្តរជាតិ និងជំរុញសកម្មភាពទេសចរណ៍ក្នុងស្រុក។ ផែនទីចង្អុលផ្លូវស្ដីពីផែនការស្ដារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ត្រូវបានអនុវត្តជា៣ដំណាក់កាលដូចខាងក្រោម៖
  - ដំណាក់កាលទី១ ការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាល ទម្លាប់ថ្មីនិងរៀបចំផែនការសម្រាប់ការស្ដារឡើងវិញ(២០២១)
  - ដំណាក់កាលទី២ ការស្ដារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩(២០២២-២០២៣)
  - ដំណាក់កាលទី៣ ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍កម្ពុជា (២០២៤-២០២៥)។
- ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១ ស្ដីពីការអនុវត្តផែនទីចង្អុលផ្លូវស្ដីពីការស្ដារនិងលើកស្ទួយវិស័យទេសចរណ៍ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ផ្ដោតសំខាន់លើគោលដៅយុទ្ធសាស្ត្រចំនួន៣ គឺ (១)ជំនួយផ្នែកសេដ្ឋកិច្ចចំពោះវិស័យឯកជននិងការងារ (២)ជំរុញទេសចរណ៍ក្នុងស្រុកនិងត្រៀមទទួលភ្ញៀវទេសចរណ៍អន្តរជាតិ "ទេសចរណ៍ពិសេសស្ថិតក្រោមការគ្រប់គ្រង" (៣)រៀបចំយន្តការអភិបាលកិច្ចទេសចរណ៍ឡើងវិញដោយដាក់ចេញសកម្មភាពយុទ្ធសាស្ត្រចំនួន២៣និងសកម្មភាពយុទ្ធសាស្ត្រលម្អិតចំនួន១០៥សកម្មភាព។ កិច្ចការដែលបានអនុវត្តក្នុងផែនការសកម្មភាពសម្រាប់ឆ្នាំ២០២១ គឺជាមូលដ្ឋានគ្រឹះសម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍ទេសចរណ៍ឆ្នាំ២០២២-២០២៣
- ការអនុម័តនៃផែនទីចង្អុលផ្លូវស្ដីពីផែនការស្ដារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ២០២១-២០២៥ នាពេលនេះគឺស្របពេលដែលរាជរដ្ឋាភិបាលបានកំពុងប្រកាសជំរុញយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋនិងពង្រឹងយន្តការគ្រប់គ្រងការឆ្លងរីករាលដាលជំងឺកូវីដ-១៩ក្នុងសហគមន៍ផងដែរ។ ជាងនេះទៅទៀត ការបន្តអនុវត្តទស្សនាទានស្ដីពីកញ្ចប់ទស្សនកិច្ចទេសចរណ៍វ៉ាក់សាំងកូវីដ-១៩ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ សម្រាប់ស្ដារវិស័យទេសចរណ៍និងសេដ្ឋកិច្ចនៅតាមគោលដៅទេសចរណ៍អាទិភាពដែលមានសុវត្ថិភាពនិងមានហានិភ័យទាបឬការគ្រប់គ្រងហានិភ័យ
- ទន្ទឹមនឹងនេះផងដែរ "ផែនការយុទ្ធសាស្ត្រស្ដីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង" ត្រូវបានរៀបចំឡើងដើម្បីត្រៀមលក្ខណៈក្នុងការបើកទទួលទេសចរណ៍វ៉ាក់សាំងតាមដំណាក់

កាលវិវត្តនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការគ្រប់គ្រងនៃវិបត្តិ។ ផែនការនេះ គ្របដណ្ដប់លើការគិតគូរក្នុងការតាមដានហានិភ័យរបស់ប្រភពទីផ្សារទេសចរណ៍សំខាន់ៗសម្រាប់កម្ពុជា ក្នុងការបើកទទួលទេសចរណ៍វ៉ាក់សាំង ជម្រើសតំបន់គោលដៅសម្រាប់ការបើកជាជំហានៗ និងការគ្រប់គ្រងរំហូរភ្ញៀវទេសចរណ៍ទាំងមុនពេលមកដល់ នៅពេលមកដល់ ពេលកំពុងស្នាក់នៅ និងពេលចាកចេញពីប្រទេសកម្ពុជាវិញ។ ទន្ទឹមនេះ ក៏មានការគិតគូរពីការធានាសុវត្ថិភាព និងផ្ដល់ទំនុកចិត្តជូនភ្ញៀវទេសចរណ៍ក្នុងពេលធ្វើដំណើរកម្សាន្តនិងស្នាក់នៅក្នុងប្រទេសកម្ពុជា ដោយសកម្មភាពនិងអាជីវកម្មទេសចរណ៍ទាំងអស់ត្រូវគោរពតាមវិធានការនិងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល

- ស្របពេលដែលរាជរដ្ឋាភិបាលបានប្រកាសបើកប្រទេសដើម្បីទទួលទេសចរអន្តរជាតិឡើងវិញដោយសម្រួលលក្ខខណ្ឌនៃការធ្វើដំណើរទាំងស្រុងដោយមិនតម្រូវឱ្យធ្វើចត្តាឡីស័ក ការដាក់ចេញនូវយុទ្ធនាការ "ទស្សនាស្រុកយើងក្រោមស្មារតីស្រឡាញ់ជាតិ ត្រូវស្គាល់ទឹកដី" សំដៅជំរុញចលនាទេសចរណ៍ផ្ទៃក្នុងតាមរយៈការបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋអាចធ្វើដំណើរបានទូទាំងប្រទេសប្រកបដោយសុវត្ថិភាពនិងក្ដីសប្បាយរីករាយ។ ក្នុងន័យនេះ ឯកសារ *"វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣"* ត្រូវបានអនុម័តជាផ្លូវការកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ ដែលក្នុងនោះ រួមមានទាំងវិធានការរដ្ឋបាល វិធានការសុខាភិបាល វិធានការសារពើពន្ធ និងវិធានការមិនមែនសារពើពន្ធ សរុបចំនួន៣៥វិធានការ សំដៅសម្រេចគោលដៅចំនួន៥ (១)ការលើកកម្ពស់ទំនុកចិត្តនិងភាពជឿជាក់របស់ភ្ញៀវទេសចរផ្ទៃក្នុង (២)ការជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម ប្រតិបត្តិករទេសចរតាមគន្លងប្រក្រតីភាពថ្មី (៣) ការបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរផ្ទៃក្នុង (៤)ការអភិវឌ្ឍផលិតផលទេសចរបម្រើឱ្យចលនាទេសចរផ្ទៃក្នុង (៥)ការផ្សព្វផ្សាយ ការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈ
- ការខិតខំផ្សព្វផ្សាយតាមរយៈព្រឹត្តិការណ៍សំខាន់ៗមានដូចជា (១)ព្រឹត្តិការណ៍កីឡាទូកក្ដោងអន្តរជាតិនៅខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ (២) កិច្ចប្រជុំទេសចរណ៍អាស៊ាននាឆ្នាំ២០២២។

៤.៣៣- ក្រសួងរ៉ែនិងថាមពល នឹងរៀបចំគោលនយោបាយជាតិប្រេងកាត ឆ្នាំ២០២៣-២០៣៣ និងដាក់ចេញផែនការសកម្មភាពសម្រាប់អនុវត្តឱ្យបាននៅឆ្នាំ២០២៣។

៤.៣៤- ក្រសួងពាណិជ្ជកម្ម នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ចូលរួមកសាង កែលម្អគោលនយោបាយនិងយុទ្ធសាស្ត្រជំរុញពាណិជ្ជកម្មសម្រាប់គាំទ្រដល់ផលិតផលនិងសេវាកម្មកម្ពុជា ដើម្បីជំរុញទៅកាន់ទីផ្សារក្នុងនិងក្រៅប្រទេស
- ផ្សព្វផ្សាយអំពីគោលនយោបាយជំរុញពាណិជ្ជកម្ម តាមរយៈការរៀបចំព្រឹត្តិការណ៍ពាណិជ្ជកម្មសិក្ខាសាលានិងសកម្មភាពពិព័រណ៍នានា

- សិក្សាស្រាវជ្រាវនិងប្រមូលធាតុចូលចងក្រងជាឯកសារស្ដីពី "បរិយាកាសធុរកិច្ចនៅតាមបណ្ដាខេត្តនានា"
- អភិវឌ្ឍការរៀបចំវេទិកាជំរុញពាណិជ្ជកម្មនៅក្រៅប្រទេសនិងការពិនិត្យតាមដាននូវវឌ្ឍនភាពនៃមជ្ឈមណ្ឌលពាណិជ្ជកម្មដែលនឹងបង្កើតនិងបង្កើតរួចហើយ។

៤.៣៥- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការជំរុញអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (គ.អ.ឧ.) ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ ផ្អែកតាមអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍វាយតម្លៃពាក់កណ្ដាលអាណត្តិនៃការអនុវត្តគ.អ.ឧ. ជំហានបន្ទាប់នៃការអនុវត្តគោលនយោបាយនេះ នឹងផ្ដោតសំខាន់លើ (១)ការបន្តពង្រឹងការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការជំរុញការធ្វើពិពិធកម្មទីផ្សារដោយផ្ដោតការយកចិត្តទុកដាក់បន្ថែមលើការនាំចេញទៅទីផ្សារក្នុងតំបន់និងការបង្កើនសកម្មភាពផលិតផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក (២)ការដាក់ចេញវិធានការគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព និង(៣)ការបង្កើនការយកចិត្តទុកដាក់និងពង្រឹងយន្តការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។

៤.៣៦- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងលើកកម្ពស់សោភណភាពរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនិងទីតាំងវប្បធម៌សំខាន់ៗ ដើម្បីបង្កើនភាពទាក់ទាញសម្រាប់វិស័យទេសចរណ៍ និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាព
- បន្តស្រាវជ្រាវនិងដំឡើងស្នាដៃសិល្បៈទស្សនីយភាពថ្មីៗ ក៏ដូចជាផលិតនិងជំរុញការផលិតភាពយន្តក្នុងប្រទេសកម្ពុជា ព្រមទាំងរៀបចំព្រឹត្តិការណ៍និងកម្មវិធីសំខាន់ៗដើម្បីគាំទ្រនិងជំរុញដល់តួអង្គក្នុងវិស័យឯកជននិងអង្គការសង្គមស៊ីវិលឱ្យដើរតួកាន់តែផុសផុលឡើងនៅក្នុងឧស្សាហកម្មវប្បធម៌និងសេដ្ឋកិច្ចច្នៃប្រឌិត តាមរយៈការបង្កើតទំនិញនិងសេវាវប្បធម៌ថ្មីៗ
- បន្តពង្រឹងគុណភាពនិងបរិមាណនៃមូលធនមនុស្សនៅក្នុងផ្នែកសិល្បៈនិងវប្បធម៌ ដើម្បីអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ និងការបង្កើតមុខរបរនៅក្នុងវិស័យវប្បធម៌ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងកាត់បន្ថយភាពក្រីក្រ។

## ៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

៤.៣៧- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ក្នុងគោលបំណងធានាបាននូវគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃការតភ្ជាប់បណ្ដាញ ការរក្សាទុក ដំណើរការ និងការចែករំលែកទិន្នន័យ ដែលជាមូលដ្ឋានសម្រាប់គាំទ្រដល់ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល
- រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ដើម្បីធានាបាននូវសុវត្ថិភាពនិងសន្តិសុខខ្ពស់សម្រាប់ការគ្រប់គ្រង ប្រតិបត្តិការ និងការប្រើប្រាស់ប្រព័ន្ធឬបច្ចេកវិទ្យាឌីជីថល ដែលជាមូលដ្ឋានគ្រឹះនៃការកសាងទំនុកចិត្ត និងភាពជឿជាក់លើការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល
- រៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ដើម្បីរៀបចំនិងកែលម្អក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការរៀបចំស្ដង់ដានិងនិម្មាបនកម្មរដ្ឋាភិបាលឌីជីថលស្របតាមគោលការណ៍ និយាម ម៉ូដែល ការវិវត្តនៃបច្ចេកវិទ្យា និងឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ ដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព ក្នុងគោលដៅរួមចំណែកគាំទ្រដល់ការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលឱ្យបានរឹងមាំនិងរស់រវើក
- ធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសេវារដ្ឋបាលផ្ទៃក្នុង(G2G) ឱ្យមានភាពសាមញ្ញ ងាយស្រួល និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាលរបស់រាជរដ្ឋាភិបាល តាមរយៈការលើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរបស់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្លាស់ប្ដូររបៀបរបបការងារលើឯកសារក្រដាសទៅជាការងារលើឯកសារអេឡិចត្រូនិក និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសការងាររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល
- ការកសាងមូលធនមនុស្សឌីជីថល នឹងផ្ដោតលើការកសាងសមត្ថភាព ដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលសម្រាប់បម្រើឱ្យការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព គុណភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

៤.៣៨- ក្រសួងពាណិជ្ជកម្ម នឹងបន្តពង្រឹងសមត្ថភាពមន្ត្រី ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងការបំពេញការងារពីចម្ងាយទាំងបច្ចេកទេសនិងសម្ភារៈ បង្កើតនិងបង្កើនកម្មវិធីបច្ចេកទេសព័ត៌មានវិទ្យាបម្រើឱ្យការធ្វើពាណិជ្ជកម្មស្របទៅតាមសេដ្ឋកិច្ចឌីជីថលនិងបដិវត្តន៍ឧស្សាហកម្មទី៤។

៤.៣៩- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- ជំរុញនិងលើកកម្ពស់បរិស្ថានធុរកិច្ចនិងវិនិយោគ ដែលរួមមានការលើកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធបញ្ញត្តកម្ម ការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន

- ជំរុញស្តង់ដាជាតិបន្ថែមទៀត សម្រាប់ផលិតផលឧស្សាហកម្ម សេវាកម្ម និងកសិកម្ម ដើម្បីបន្តនិរន្តរភាពក្នុងការលើកកម្ពស់គុណភាពផលិតផលក្នុងស្រុក និងរក្សានូវសុវត្ថិភាព និងចូលរួមការពារបរិស្ថាន សន្តិសុខសង្គម ការពារសុខុមាលភាពសាធារណៈ និងការប្រកួតប្រជែង
- រៀបចំ កំណត់ ជំរុញ និងសហការចងក្រងលើការផ្ទេរបច្ចេកវិទ្យាជាតិ ក្នុងចំណោមស្ថាប័នសិក្សានិងស្រាវជ្រាវ។

៤.៤០- ក្រសួងព័ត៌មាន នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិនិងលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនឱ្យខិតខំពង្រីកសក្តានុពលប្រសិទ្ធភាពនិងវិសាលភាពនៃការផ្សាយគ្របដណ្តប់ឱ្យបានទូលំទូលាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទ្វីបនានា ដើម្បីផ្តល់ព័ត៌មាន ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាពនិងសមធម៌ជូនប្រជាពលរដ្ឋខ្មែរនៅគ្រប់ច្រកល្ហកនៃមាតុប្រទេសនិងឆ្ពោះទៅកាន់ពិភពលោកខាងក្រៅ រួមចំណែកលើកតម្កើងអត្តសញ្ញាណនិងមោទនភាពជាតិខ្មែរនិងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ
- កសាងផែនការទំនើបនីយកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស សម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ជាតិ(វិទ្យុជាតិ ទូរទស្សន៍ជាតិ និងទីភ្នាក់ងារសារព័ត៌មានកម្ពុជា) ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់នៃការផ្សព្វផ្សាយជាសំឡេងផ្លូវការរបស់ជាតិ
- បន្តជំរុញការសាងសង់ស្ថានីយវិទ្យុនិងទូរទស្សន៍ថ្នាក់ក្រោមជាតិនៅតាមបណ្តាខេត្តបន្តទៀតដោយផ្តល់អាទិភាពចំពោះបណ្តាខេត្តនៅប៉ែកពាយព្យនិងឦសាននៃមាតុប្រទេស
- ជំរុញការបើកវគ្គបណ្តុះបណ្តាលបច្ចេកទេស និងលើកកម្ពស់សមត្ថភាពសម្រាប់មន្ត្រីផលិតកម្មវិធីនិងព័ត៌មានថ្នាក់ក្រោមជាតិ។

## ៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

៤.៤១- ធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗនិងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចជាតិ។ ការងារធ្វើសេចក្តីព្រាងច្បាប់ស្តីពីដំណោះស្រាយពិសេស អាចសម្រេចបាន ប៉ុន្តែត្រូវការពេលវេលាច្រើនទៀត។ សេចក្តីព្រាងច្បាប់នេះ រំពឹងថានឹងបញ្ចប់ក្នុងត្រីមាសទី២ ឆ្នាំ២០២២ ច្បាប់នេះនឹងត្រូវការពេលវេលាដើម្បីអនុម័តដោយសារវាត្រូវការដំណើរការតាមនីតិវិធីសមស្របមួយ។ លើសពីនេះ ដើម្បីឱ្យរបបដំណោះស្រាយពិសេសមួយដំណើរការល្អ វាទាមទារឱ្យមានការរៀបចំបទប្បញ្ញត្តិមួយចំនួនដើម្បីអនុវត្តច្បាប់។ ដូច្នេះពេលវេលាសមស្របសម្រាប់របបដំណោះស្រាយពិសេសអាចនឹងបញ្ចប់ក្នុងឆ្នាំ២០២៦។ ជាមួយគ្នានេះដែរ កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានសម្រេចបង្កើតក្រុម

ការងាររៀបចំយុទ្ធសាស្ត្រចាកចេញពីវិបត្តិកូវីដ-១៩ ដើម្បីត្រៀមរៀបចំរួចជាស្រេចនូវនីតិវិធីចាំបាច់ផ្សេងៗសម្រាប់ដំណើរការចាកចេញពីវិបត្តិកូវីដ-១៩។

## តារាង៤.២ : សូចនាករសំខាន់និងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣

| ល.រ. | សូចនាករ | ឯកតា | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ១ | អតិផរណា | ភាគរយ | ២,៦ | ២,៤ | ២,៥ |
| ២ | អត្រាប្តូរប្រាក់ | រៀល/១ដុល្លារអាមេរិក | ៤ ១០០ | ៤ ១០០ | ៤ ១០០ |

## តារាង៤.៣ : សូចនាករវិស័យធនាគារនិងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣

| ល.រ. | សូចនាករ | ឯកតា | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ១ | ទ្រព្យសកម្ម | ទ្រីលានរៀល | ២៣៧,៥៩ | ២៦៨,៤១ | ២៩៩,៥៦ |
| ២ | ឥណទានទៅអតិថិជន * | ទ្រីលានរៀល | ១៥០,០២ | ១៧៥,៣៥ | ២០០,៨១ |
| ៣ | ប្រាក់បញ្ញើពីអតិថិជន * * | ទ្រីលានរៀល | ១៤១,៤៨ | ១៦០,៧១ | ១៨០,៣៣ |
| ៤ | ដើមទុនបានបង់ជម្រះ | ទ្រីលានរៀល | ២៥,៧៨ | ២៩,២៧ | ៣២,៧៥ |
| ៥ | ប្រាក់បញ្ញើជារៀល * * * | ទ្រីលានរៀល | ១៣,៧១ | ១៧,៥៣ | ២១,៣៧ |
| ៦ | ប្រាក់បញ្ញើជារូបិយបណ្ណ * * * | ទ្រីលានរៀល | ១២៨,៩២ | ១៤៦,៨៨ | ១៦៤,៧០ |
| ៧ | អនុបាតសន្ទនីយភាព | % | ១៦០,០% | ១៦៥,០% | ១៥០,០% |
| ៨ | អនុបាតសាធនភាព | % | ២៣,០% | ២២,០% | ២០,០% |
| ៩ | អនុបាតឥណទានមិនដំណើរការ | % | ២,៥% | ៤,០% | ២,៨% |

ប្រភព : ធនាគារជាតិនៃកម្ពុជា

*ឥណទានទៅអតិថិជន(មិនរាប់បញ្ចូលឥណទានទៅអតិថិជនអនិវាសជន និងមិនរាប់បញ្ចូលឥណទានទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

* *ប្រាក់បញ្ញើពីអតិថិជន(មិនរាប់បញ្ចូលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

* * *ប្រាក់បញ្ញើ(រាប់បញ្ចូលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)

## តារាង៤.៤ : សូចនាករវិស័យមីក្រូហិរញ្ញវត្ថុ និងគោលដៅអនុវត្ត ឆ្នាំ២០២១-២០២៣

| ល.រ. | សូចនាករ | ឯកតា | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ១ | ទ្រព្យសកម្ម | ទ្រីលានរៀល | ៣៩,០៤ | ៤៣,៩០ | ៤៨,៧៧ |
| ២ | ឥណទានទៅអតិថិជន | ទ្រីលានរៀល | ៣៣,៧៩ | ៣៩,៦៩ | ៤៥,៦៣ |
| ៣ | ប្រាក់បញ្ញើពីអតិថិជន | ទ្រីលានរៀល | ១៦,៨៩ | ១៨,៦៨ | ២០,៥៥ |
| ៤ | ដើមទុនបានបង់ជម្រះ | ទ្រីលានរៀល | ៤,៤៥ | ៥,៤៤ | ៦,៣៩ |
| ៥ | ប្រាក់បញ្ញើជារៀល | ទ្រីលានរៀល | ១,៦៨ | ១,៦២ | ១,៥៩ |
| ៦ | ប្រាក់បញ្ញើជារូបិយបណ្ណ | ទ្រីលានរៀល | ១៣,៣៥ | ១២,៩០ | ១២,៦៧ |
| ៧ | អនុបាតសន្ទនីយភាព | % | ១៧០,០% | ១៦០,០% | ១៥០,០% |
| ៨ | អនុបាតសាធនភាព | % | ២៣,០% | ២០,០% | ២១,០% |
| ៩ | អនុបាតឥណទានមិនដំណើរការ | % | ៣,២% | ៣,៥% | ៣,១% |

ប្រភព : ធនាគារជាតិនៃកម្ពុជា

# ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

## ៥.១- ការអភិវឌ្ឍទីផ្សារការងារ

៤.៤២- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- បន្តអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង១០ចំណុចរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី**
- បន្តខិតខំអនុវត្តឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពខ្ពស់នូវយុទ្ធសាស្ត្រអាទិភាពទាំង៥ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៩-២០២៣ ព្រមទាំងគោលនយោបាយជាតិពាក់ព័ន្ធ
- ត្រៀមលក្ខណៈដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បអនុវត្តនូវផែនការដើម្បីស្តារសេដ្ឋកិច្ចឡើងវិញក្នុងពេលនិងក្រោយវិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសក្នុងវិស័យដែលរងផលប៉ះពាល់ពីការរីករាលដាលជំងឺនេះ
- បន្តពង្រឹងការងារចុះអធិការកិច្ចអន្តរក្រសួង និងធ្វើទំនើបកម្មការធ្វើអធិការកិច្ចការងារដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យានិងកម្រិតហានិភ័យរបស់រោងចក្រសហគ្រាស ជាមូលដ្ឋានក្នុងការធ្វើអធិការកិច្ច និងការធ្វើអធិការកិច្ចការងារលើ រោងចក្រសហគ្រាសចំនួន១លើកក្នុងមួយឆ្នាំ ហើយធានាប្រសិទ្ធភាព គុណភាពនិងតម្លាភាពក្នុងការផ្តល់សេវាដោយដាក់រាល់សេវាទាំងអស់របស់ក្រសួងទៅក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន
- បន្តយន្តការក្រុមប្រឹក្សាប្រាក់ឈ្នួលអប្បបរមា ដើម្បីធានាបាននូវការចរចាប្រាក់ឈ្នួលអប្បបរមានិងអត្ថប្រយោជន៍ផ្សេងៗប្រកបដោយភាពសុខដុមរមនានិងអាចទទួលយកបានពីគ្រប់ភាគី និងបន្តសហការជាមួយដៃគូ ជាពិសេសអង្គការអន្តរជាតិខាងការងារក្នុងការសិក្សាលទ្ធភាពពង្រីកវិសាលភាពនៃប្រាក់ឈ្នួលអប្បបរមា
- បន្តជំរុញការផ្សព្វផ្សាយនិងការរៀបចំវគ្គបណ្តុះបណ្តាលដល់កម្មករនិយោជិតនិងនិយោជកឱ្យមានការយល់ដឹងពីសិទ្ធិការងារ ច្បាប់ស្តីពីសហជីព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- បន្តសិក្សាស្រាវជ្រាវ សហការ និងពិភាក្សាជាមួយភាគីពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ គោលនយោបាយជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ ច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងពិនិត្យមើលលើការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីឱ្យស្របតាមការវិវត្តនៃសេដ្ឋកិច្ច សង្គមនាពេលបច្ចុប្បន្ន
- បន្តពង្រឹងយន្តការដោះស្រាយវិវាទការងារឱ្យទទួលបានអត្រាសះជាឱ្យកាន់តែខ្ពស់សំដៅឆ្លើយតបនឹងតម្រូវការភាគីវិវាទ និងដាក់ឱ្យដំណើរការសាកល្បងការដោះស្រាយវិវាទបុគ្គលដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងពង្រឹងការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈឱ្យបានត្រឹមត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តជាតិជាធរមាន និងអនុសញ្ញាអន្តរជាតិខាងការងារដែលកម្ពុជាបានផ្តល់សច្ចាប័ន

- បន្តពង្រឹងអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា សំដៅអនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់តាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា បទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការស្តីពីការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញាសម្រាប់ឆ្នាំ២០២០-២០២៤ ដើម្បីធានាសន្តិភាព ស្ថិរភាពនយោបាយ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ
- បន្តប្រែក្លាយរោងចក្រ សហគ្រាសជាមួយសហគមន៍សុខសាន្តមួយរបស់កម្មករនិយោជិតដែលពោរពេញដោយសមត្ថភាព លក្ខខណ្ឌការងារល្អប្រសើរ ផលិតភាព ឥរិយាបថការងារ ការទទួលខុសត្រូវសង្គម និងមានសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ដោយក្រសួងនឹងផ្តល់ជាវិញ្ញាបនបត្របញ្ជាក់ជូនរោងចក្រ សហគ្រាសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខណៈវិនិច្ឆ័យ
- ពង្រឹងនិងពង្រីកវិសាលភាពក្នុងការផ្តល់សេវាការងារនិងព័ត៌មានទីផ្សារការងារ ព្រមទាំងការផ្តល់ប្រឹក្សាយោបល់ការងារ អាជីព ដើម្បីធ្វើការផ្គូផ្គង និងឆ្លើយតបបាននូវតម្រូវការកម្លាំងពលកម្មតាមទីផ្សារការងារ ដោយបង្កើនភាពជាដៃគូជាមួយវិស័យឯកជន
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធសម្រាប់អនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ ដោយបន្តពង្រីកការអនុវត្តរបបសន្តិសុខសង្គម គុណភាព និងប្រសិទ្ធភាពនៃសេវា និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននៅឆ្នាំ២០២១។

## ៥.២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព

៤.៤៣- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តគាំទ្រនិងជំរុញលើកទឹកចិត្តដល់បណ្តារោងចក្រ សហគ្រាសធុនធំ ធុនតូច ធុនមធ្យម និងសិប្បកម្ម ដើម្បីរួមគ្នាជម្នះនឹងវិបត្តិកូវីដ-១៩ ជាពិសេសផ្តោតលើសហគ្រាសកម្មន្តសាល ផ្នែកស្បៀង ម្ហូបអាហារ និងភេសជ្ជៈ និងផ្នែកផលិតកម្មដែលផលិតសម្ភារៈប្រើប្រាស់ការពារនិងទប់ស្កាត់ជំងឺកូវីដ-១៩
- បន្តអនុវត្តយុទ្ធសាស្ត្រគៀរគរវិនិយោគដែលប្រើប្រាស់បច្ចេកវិទ្យាទំនើប ជាពិសេសផ្នែកផលិតនិងកែច្នៃកសិឧស្សាហកម្មដែលជាប្រភពធនធានដែលមានសក្តានុពលក្នុងស្រុកសម្រាប់បម្រើការនាំចេញនិងផលិតផលិតផលជំនួសឱ្យការនាំចូល ដើម្បីបង្កើនការធ្វើពិពិធកម្មសេដ្ឋកិច្ច
- ជំរុញការធ្វើពិពិធកម្មឧស្សាហកម្ម តាមរយៈការផ្ទេរបច្ចេកវិទ្យានិងការទាក់ទាញវិនិយោគដើម្បីធ្វើសមាហរណកម្មទៅនឹងខ្សែច្រវាក់ផលិតកម្មនិងខ្សែច្រវាក់តម្លៃតំបន់និងពិភពលោកដើម្បីគោលដៅនៃចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និង២០៥០
- ជំរុញនិងលើកកម្ពស់សុវត្ថិភាពនិងគុណភាពផលិតផលក្នុងស្រុក

- បន្តអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥
- ជំរុញនិងលើកកម្ពស់បរិស្ថានធុរកិច្ចនិងវិនិយោគ ដែលរួមមានការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធបញ្ញត្តកម្ម ការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន
- លើកកម្ពស់សមត្ថភាពសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។

៤.៤៤- ក្រសួងពាណិជ្ជកម្ម នឹងបន្តផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងវិស័យពាណិជ្ជកម្ម និងអភិវឌ្ឍសមត្ថភាពជូនវិស័យឯកជននិងភាគីពាក់ព័ន្ធទាំងក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនការយល់ដឹង និងរួមចំណែកគាំទ្រដល់កិច្ចអភិវឌ្ឍពាណិជ្ជកម្មស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ អាណត្តិទី៦របស់រាជរដ្ឋាភិបាលកម្ពុជា បន្តសម្របសម្រួលជាមួយវិស័យឯកជនដើម្បីពង្រីកទីផ្សារក្នុងស្រុកតាមរយៈការពង្រឹងនិងពង្រីកកិច្ចសន្យាទិញ លក់ និងការនាំចេញទៅក្រៅប្រទេស និងសម្របសម្រួលជាមួយសហគ្រាសធុនតូចនិងមធ្យម ក្នុងការរៀបចំផែនការវិនិយោគដើម្បីអភិវឌ្ឍនូវប្រតិបត្តិការអាជីវកម្មរបស់សហគ្រាសធុនតូចនិងមធ្យម។

៤.៤៥- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ពន្លឿនការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដោយបញ្ចូលប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់លក្ខខណ្ឌវិនិច្ឆ័យ និងមុខសញ្ញាផលិតកម្មសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព ដែលត្រូវទទួលបានការលើកទឹកចិត្តសំដៅជំរុញឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់វត្ថុធាតុដើម(ឧស្សាហកម្មប្រតិគមន៍ Backward Linkages) ដែលនឹងចូលរួមបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក អនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

## ៥.៣- ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន

៤.៤៦- ក្រសួងពាណិជ្ជកម្ម នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំបង្កើតសភាពាណិជ្ជកម្មនិងសម្របសម្រួលក្នុងការរៀបចំសមាគមអាជីវកម្មនៅតាមខេត្តជាបន្តបន្ទាប់ ព្រមទាំងផ្សព្វផ្សាយពីតួនាទី ភារកិច្ច និងអត្ថប្រយោជន៍នៃសភាពាណិជ្ជកម្មនិងសមាគមអាជីវកម្ម សម្រាប់ការអភិវឌ្ឍនូវប្រតិបត្តិការពាណិជ្ជកម្ម
- ចុះស្រាវជ្រាវកំណត់ទីតាំងភូមិសាស្ត្រផលិតផលដែលមានសក្តានុពលទៅលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃ
- ជំរុញការផ្សារភ្ជាប់រវាងអ្នកប្រមូលទិញ អ្នកកែច្នៃ អ្នកនាំចេញ និងភាគីពាក់ព័ន្ធទៅនឹងអ្នកដាំដុះ និងសហការជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោះស្រាយវិវាទកម្មករនិងម្ចាស់រោងចក្រ។

### ៥.៤- ការពង្រឹងការប្រកួតប្រជែង

៤.៤៧- ក្រសួងពាណិជ្ជកម្ម នឹងបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវាច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ប្រកួតប្រជែង និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ផ្តល់ប្រឹក្សាយោបល់និងការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈការសម្រុះសម្រួលជូនដល់អាជីវករ ពាណិជ្ជករ និងសម្របសម្រួលជាមួយមជ្ឈមណ្ឌលជាតិផ្នែកមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

## ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

### ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ

៤.៤៨- ក្រសួងពាណិជ្ជកម្ម នឹងបន្ត៖

- សម្របសម្រួលជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ទាំងអស់ក្នុងការជំរុញនិងពន្លឿនការអនុវត្តសកម្មភាពគម្រោងឱ្យសម្រេចបានតាមសូចនាករនិងផែនការរួមរបស់គម្រោងលើការបង្កើនបរិមាណគុណភាពនិងការកែច្នៃនៃផលិតផលកសិកម្មសំខាន់ៗ
- រៀបចំយន្តការនិងយុទ្ធសាស្ត្រដកថយ/បញ្ចប់គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច ដើម្បីធានាបាននូវនិរន្តរភាពនិងភាពជាម្ចាស់ នៅពេលបញ្ចប់គម្រោងតាមរយៈការផ្ទេរមុខងារនិងការទទួលខុសត្រូវទៅថ្នាក់ក្រោមជាតិ
- សិក្សា រៀបចំ និងអនុវត្តគម្រោងជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករក្នុងក្របខ័ណ្ឌឥណទានសម្បទានសហប្រតិបត្តិការពីសាធារណរដ្ឋប្រជាមានិតចិន។

៤.៤៩-ក្រសួងអភិវឌ្ឍន៍ជនបទ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ស្តារនិងសាងសង់ផ្លូវជនបទ
- កែលម្អផ្លូវជនបទទៅជាកៅស៊ូពីរជាន់ឬបេតុងដើម្បីធន់នឹងការប្រែប្រួលអាកាសធាតុ
- ថែទាំផ្លូវជាលក្ខណៈខួបនិងប្រចាំ
- រៀបចំបញ្ជីសារពើភណ្ឌផ្លូវ ផែនទីផ្លូវជនបទ និងការដាក់ស្លាកចរាចរណ៍
- បន្តសាងសង់និងជួសជុលអណ្តូងគ្រប់ប្រភេទ ស្តារស្រះសហគមន៍ អាងត្រងទឹកភ្លៀងគ្រប់ប្រភេទ ប្រព័ន្ធចែកចាយទឹកសហគមន៍ ស្តារប្រព័ន្ធធារាសាស្ត្រខ្នាតតូច
- បង្កើតកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ
- សាងសង់បង្គន់អនាម័យនិងកន្លែងលាងដៃតាមសាលារៀននៅជនបទ

៤.៥០- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីននឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំជំនួបជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងបរិស្ថាន និងភាគីពាក់ព័ន្ធនានា ក្នុងគោល

បំណងដាក់បញ្ចូលគម្រោងបោសសម្អាតមីន ទៅក្នុងគម្រោងដែលក្រសួងទាំងនោះត្រូវអនុវត្ត

- រៀបចំចេញផ្សាយគោលការណ៍ណែនាំស្ដីពីយន្តការភូមិអស់មីន ដើម្បីកៀរគរប្រភពថវិកាពីវិស័យឯកជននិងសប្បុរសជននានា
- រៀបចំជំនួបពិភាក្សាជាមួយបណ្ដាទូតនានា ដើម្បីផ្សព្វផ្សាយពីវិស័យសកម្មភាពមីននិងស្វែងរកលទ្ធភាពកៀរគរធនធានបន្ថែមទៀត
- បន្តអនុវត្តយន្តការដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥។

៤.៥១- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- រៀបចំធ្វើយុទ្ធនាការជាទ្រង់ទ្រាយធំប្រកបដោយប្រសិទ្ធភាព ក្នុងការបំផុសប្រជាកសិករនៅតាមមូលដ្ឋាន ដែលមានសក្ដានុពលផលិតកម្មកសិកម្ម ឱ្យធ្វើការដាំដុះដំណាំស្បៀង ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ស្របតាមវិធានបច្ចេកទេសកសិកម្មទំនើប
- បង្កើនសន្ទុះនៃការអនុវត្តផែនការសកម្មភាពចាំបាច់ក្នុងស្ថានភាពបន្ទាន់ជាការឆ្លើយតប ដើម្បីបង្កើនផលិតកម្មស្បៀងប្រកបដោយគុណភាពនិងសុវត្ថិភាពសំដៅរួមចំណែកបង្កើននូវឱកាសការងារនិងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ក៏ដូចជាពលករដែលទើបតែត្រឡប់ពីបរទេសវិញ
- បង្កើនសកម្មភាពឆ្លើយតបបន្ទាន់ក្នុងគម្រោងដែលកំពុងអនុវត្ត ដើម្បីដោះស្រាយបញ្ហាទឹកដោយការប្រើប្រព័ន្ធសន្សំសំចៃទឹក ការជួយជីកនិងស្ដារស្រះ ត្រពាំង និងអណ្ដូងជាដើម
- អប់រំបណ្ដុះបណ្ដាលកសិករ ណែនាំផ្សព្វផ្សាយអំពីបច្ចេកទេស ការអនុវត្តកសិកម្មល្អ និងការផ្ដល់ហិរញ្ញប្បទានដល់ប្រជាកសិករតាមគ្រប់រូបភាពសំដៅដល់ការបង្កើតកសិដ្ឋានថ្មីៗ ព្រមទាំងគាំទ្រនិងពង្រីកទំហំផលិតកម្មស្បៀងដែលឆាប់ផ្ដល់ផល។ល។
- ជំរុញការចិញ្ចឹមសត្វ ធានាការផ្គត់ផ្គង់សាច់និងផលិតផលសត្វ សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ដោយត្រូវរៀបចំយុទ្ធនាការបំផុសដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ឱ្យបង្កើនការចិញ្ចឹមសត្វដែលមានវដ្តផលិតកម្មខ្លី និងដោះស្រាយបានទាន់ពេលវេលាចំពោះបញ្ហាសន្តិសុខស្បៀង។

៤.៥២- ក្រសួងធនធានទឹកនិងឧតុនិយម នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- កែលម្អការគ្រប់គ្រងរដ្ឋបាលនិងការអភិវឌ្ឍធនធានមនុស្ស
- គ្រប់គ្រងនិងការអភិវឌ្ឍធនធានទឹកនិងការអនុវត្តអនុត្តរភាពប្រព័ន្ធធារាសាស្ត្រ
- គ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត និងព័ត៌មានស្ដីពីធនធានទឹកនិងឧតុនិយម
- ការពារនិងការអភិរក្សធនធានទឹក។

**ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ**

៤.៥៣- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា នឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២១-២០២៥ ដើម្បីបន្តជំរុញនិងខិតខំប្រឹងប្រែងអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនិងទទួលបានជោគជ័យក្នុងបេសកកម្មចូលរួមចំណែកសម្រេចឱ្យបាននូវការអភិវឌ្ឍនិងការគ្រប់គ្រងប្រកបដោយចីរភាពនៃធនធានទឹកនិងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ក្នុងនោះមានទិសដៅអាទិភាពជាយុទ្ធសាស្ត្រចំនួន៦ រួមមាន (១)ការលើកកម្ពស់ប្រសិទ្ធភាពលើការងារសម្របសម្រួល (២)ការពង្រឹងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូ (៣)ការពង្រឹងស្ថាប័ននិងធនធានមនុស្ស (៤)ការសិក្សាស្រាវជ្រាវ ការរៀបចំនិងការអនុវត្តគម្រោង (៥)ការលើកកម្ពស់ការយល់ដឹងនិងការផ្សព្វផ្សាយ និង(៦) ការពិនិត្យតាមដាននិងការវាយតម្លៃ។

### ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

៤.៥៤- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ "ការគ្រប់គ្រងផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា" និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយស្តីពីការផ្គត់ផ្គង់ទឹកស្អាត
- បន្តពង្រឹងវឌ្ឍនភាពអង្គភាពរដ្ឋាករទឹកសាធារណៈ
- ពង្រឹងការគ្រប់គ្រងទិន្នន័យនិងស្ថិតិវិស័យទឹកស្អាត
- លើកកម្ពស់សមត្ថភាពបច្ចេកទេសនិងការគ្រប់គ្រងគុណភាពទឹក។

### ភូមិមួយផលិតផលមួយ

៤.៥៥- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ជំរុញនិងលើកកម្ពស់ការអនុវត្តការងារ ដោយការផ្លាស់ប្តូរឥរិយាបថតាមបែបគន្លងថ្មីក្នុងបរិបទការរាតត្បាតជំងឺកូវីដ-១៩ ដើម្បីសម្រួលការអនុវត្តការងារឱ្យបានរលូននិងមានប្រសិទ្ធភាព
- ការងារលើកកម្ពស់ស្តង់ដាផលិតផល ត្រូវពន្យារពេលទៅឆ្នាំ២០២៣ ក្រោមហេតុផលនៃវិបត្តិនៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងដោយសារថវិកាប្រចាំឆ្នាំត្រូវបានកាត់បន្ថយ
- ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រការងារជំរុញចលនាភូមិមួយផលិតផលមួយ ៥ឆ្នាំលើកទី១ ២០១៩-២០២៣
- រៀបចំវិធានវាយតម្លៃគុណភាពផលិតផលខ្មែរ ក្នុងបរិបទភូមិមួយផលិតផលមួយ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

## ៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព

៤.៥៦- ក្រសួងបរិស្ថាន នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ថែរក្សានិងលើកកម្ពស់តម្លៃអេកូឡូស៊ីនិងវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ
- លើកកម្ពស់ការចូលរួមការងារនិងការគាំទ្រពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងអភិរក្សតំបន់ការពារធម្មជាតិ
- អភិវឌ្ឍគំនិតច្នៃប្រឌិតថ្មីៗក្នុងការអភិរក្សនិងការអភិវឌ្ឍ រួមទាំងបង្កើតឱកាសសម្រាប់ចីរភាពវិស័យអេកូទេសចរណ៍និងយន្តការហិរញ្ញប្បទាន
- ផ្ដល់នូវព័ត៌មានពាក់ព័ន្ធជាក់លាក់និងទាន់ពេលវេលា សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព
- ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិនិងសហការក្នុងភាពជាដៃគូជាមួយនឹងទីភ្នាក់ងាររាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិរក្ស(អង្គការអភិរក្ស) និងដៃគូអភិវឌ្ឍ
- ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីលុបបំបាត់ភាពអណាធិបតេយ្យក្នុងតំបន់ទាំងនោះ លុបបំបាត់ការធ្វើអាជីវកម្មធនធានធម្មជាតិខុសច្បាប់ និងត្រួតពិនិត្យការទន្ទ្រានដីដើម្បីប្រើប្រាស់ និងកាន់កាប់ព្រៃឈើខុសច្បាប់
- ការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ទាំងនៅដែនគោកនិងដែនសមុទ្រ ដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅទាំងពេលបច្ចុប្បន្ននិងទៅអនាគត។ ក្រសួងបរិស្ថានបន្តពង្រឹងកិច្ចការពារគុណភាពបរិស្ថាននិងអភិរក្សធនធានធម្មជាតិឱ្យមានចីរភាពក្នុងប្រព័ន្ធអេកូឡូស៊ី ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ជាពិសេសការចូលរួមរបស់សហគមន៍នៅមូលដ្ឋាន វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ពង្រឹងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ ដើម្បីធានាការប្រើប្រាស់ធនធានធម្មជាតិ សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពនិងជំរុញការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដែលនឹងជួយដល់ការថែរក្សាបរិស្ថាននិងធនធានធម្មជាតិ
- ធ្វើការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល
- រៀបចំយុទ្ធសាស្ត្របង្កើនគម្របព្រៃឈើឡើងវិញតាមរយៈការដាំឈើឡើងវិញ
- ពង្រឹងការគ្រប់គ្រងខ្សែក្រវាត់បៃតងតាមរយៈការពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- បង្កើនសមត្ថភាពនៃការអភិរក្សនិងការការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ
- កំណត់សកម្មភាពអាទិភាពតាមដាននិងត្រួតពិនិត្យគុណភាពទឹក ខ្យល់សាធារណៈនៅតំបន់ងាយរងការបំពុល
- កំណត់ប្រភពបំពុលជាគោលដៅអាទិភាព ក្នុងការចុះត្រួតពិនិត្យ ពង្រឹងការអនុវត្តច្បាប់និងការតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន
- កំណត់សកម្មភាពអាទិភាព ពង្រឹងការគ្រប់គ្រងសំរាម សំណល់រឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បន្តការសិក្សានិងប្រមូលទិន្នន័យបុរាណស្ថាន បេតិកភណ្ឌវប្បធម៌ និងផូស៊ីល ដែលមានសក្តានុពលទាំងក្នុងទាំងក្រៅតំបន់ការពារធម្មជាតិ និងពិនិត្យលទ្ធភាពស្នើសុំបង្កើតជាតំបន់បេតិកភណ្ឌធម្មជាតិនិងវប្បធម៌
- បន្តអភិវឌ្ឍមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិរក្សកេសរកុល សុខ អាន ភ្នំគូលែន

៤.៥៧- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- កសាងឯកសារលិខិតបទដ្ឋានគតិយុត្តបំពេញដល់ដំណើរការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងធ្វើការផ្សព្វផ្សាយច្បាប់ ឯកសារលិខិតបទដ្ឋានគតិយុត្តដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ថ្នាក់
- កសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនៅថ្នាក់ជាតិ និងរៀបចំគោលការណ៍ណែនាំ ធ្វើឱ្យប្រសើរឡើងនូវផែនការត្រៀមបម្រុងឆ្លើយតបគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ និងអនុវត្តសាកល្បងនៅខេត្តគោលដៅមួយចំនួន
- ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុសម្រាប់វិស័យគ្រប់គ្រងគ្រោះមហន្តរាយ និងណែនាំ គាំទ្រ ដល់ការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បង្កើតឧបករណ៍ប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយ និងវិធីសាស្ត្រអនុវត្តការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ ព្រមទាំងស្រាវជ្រាវដាក់ចេញយុទ្ធ-សាស្ត្រនៃផែនការសកម្មភាពសម្រាប់ការគ្រប់គ្រងហានិភ័យអាកាសធាតុនិងគ្រោះមហន្តរាយ។

៤.៥៨- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តជួសជុលនិងអភិរក្សសំណង់បុរាណ ដូចជាប្រាសាទបុរាណ ព្រះវិហារបុរាណ ស្ពានបុរាណ និងសំណង់បុរាណផ្សេងៗដទៃទៀត
- បន្តជួសជុលនិងអភិរក្សវត្ថុបុរាណវត្ថុសិល្បៈ/និងវត្ថុជាតិពន្ធសាស្ត្រ ចុះបញ្ជីវត្ថុបុរាណវត្ថុ/សិល្បៈនិងវត្ថុជាតិពន្ធសាស្ត្រ បញ្ចូលទិន្នន័យវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធសាស្ត្រទៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋាន និងទាមទារវត្ថុបុរាណខ្មែរដែលកំពុងកាន់កាប់ដោយខុសច្បាប់យកត្រឡប់មកវិញ
- បន្តរៀបចំស្នើសុំចុះបេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រកម្ពុជា ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ ស្មារតីចងចាំពិភពលោក និងបណ្ដាញទីក្រុងដែលមានភាពច្នៃប្រឌិតរបស់អង្គការយូណេស្កូ
- បន្តយកចិត្តទុកដាក់និងសហការជាមួយសហគមន៍ក្នុងការបណ្ដុះបណ្ដាលនិងរៀបចំការសម្ដែងសិល្បៈរួមគ្នា ព្រមទាំងបន្តពង្រឹងការថែរក្សាវប្បធម៌របស់សហគមន៍ ពិសេសសហគមន៍ជនជាតិដើមភាគតិច។

## ៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

៤.៥៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗ ដូចខាងក្រោម៖

- ជំរុញការអនុវត្តផែនការចុះបញ្ជីអចលនវត្ថុឱ្យបាន៩៦% នៅឆ្នាំ២០២២ និងឈានទៅសម្រេច១០០% នៅឆ្នាំ២០២៣ នៃចំនួនក្បាលដីប៉ាន់ស្មានសរុប៧លានក្បាលដី
- ជំរុញការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាពឱ្យបានចំនួន១០ សហគមន៍ ក្នុងមួយឆ្នាំ
- ជំរុញការចុះបញ្ជីដីរដ្ឋដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ចដែលនៅសេសសល់ចំនួន៧០ ក្រុមហ៊ុន និងដីរដ្ឋផ្សេងទៀត
- ជំរុញបញ្ចប់ការកសាងផែនទីព្រំប្រទល់រដ្ឋបាល ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងផែនទីប្រើប្រាស់ដី
- បន្តកៀរគរវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធដើម្បីធ្វើការវិនិយោគលើការសាងសង់លំនៅឋានតម្លៃសមរម្យលក់ឬជួលជូនប្រជាពលរដ្ឋមានប្រាក់ចំណូលមធ្យមនិងប្រាក់ចំណូលទាប និងលំនៅឋានបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់ផ្តល់ជូនគ្រួសារ ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ
- បន្តសហការជាមួយរដ្ឋបាលខេត្តក្នុងការស្វែងរកដីសម្រាប់ចែកជូនប្រជាពលរដ្ឋក្រីក្រគ្មានដី និងខ្វះដី និងអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ សម្រាប់សាងសង់លំនៅឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ
- ជំរុញការរៀបចំការងារចុះបញ្ជីក្រុមហ៊ុននិងរូបវន្តបុគ្គល ព្រមទាំងសេវាកម្មផ្សេងៗទៀតតាមប្រព័ន្ធព័ត៌មានវិទ្យា
- បន្តរៀបចំឯកសារគតិយុត្តនិងបទប្បញ្ញត្តិបច្ចេកទេសមួយចំនួនដែលពាក់ព័ន្ធដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីសំណង់។

## ៦.៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

៤.៦០- ក្រសួងបរិស្ថាន នឹងបន្តអនុវត្តសកម្មភាពអាទិភាពសំខាន់ៗដូចខាងក្រោម៖

- ធានាសង្គតិភាពលើការរៀបចំអាទិភាពគោលនយោបាយ ផែនការ និងកម្មវិធីនិរន្តរភាពរបស់ជាតិ និងការបន្ស៊ីអាទិភាពគោលនយោបាយ ផែនការ និងកម្មវិធី ជាមួយលិខិតូបករណ៍ គោលនយោបាយថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដែលកម្ពុជាបានចូលជាភាគីសមាជិក
- ជំរុញការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ការកសាងធនធានមនុស្ស ការលើកកម្ពស់ការយល់ដឹង ការប្រើប្រាស់បច្ចេកវិទ្យាបៃតងនិងបច្ចេកវិទ្យានុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ដើម្បីគាំទ្រការអភិវឌ្ឍដោយចីរភាព

- ពង្រឹងនិងកែលម្អគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីបង្កើនការចូលរួមចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះនិងប្រសិទ្ធភាពថាមពលរបស់កម្ពុជា
- ជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងបង្កលក្ខណៈងាយស្រួលសម្រាប់វឌ្ឍនភាពនៃការកសាងសង្គមមួយដែលបញ្ចេញកាបូនតិច រួមទាំងទាក់ទាញវិស័យឯកជនក្នុងការវិនិយោគដែលវៃឆ្លាតខាងអាកាសធាតុ
- បង្កើនការវិភាជថវិកាជាតិសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ធានានិរន្តរភាពមុខងារនិងតួនាទីពេញលេញរបស់ធនធានជីវៈចម្រុះ ជីវសុវត្ថិភាព និងប្រព័ន្ធអេកូឡូស៊ី រួមទាំងអនុវត្តយន្តការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ី។

# ជំពូកទី៥

# តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ

៥.១- ជំពូកនេះ បង្ហាញអំពីតម្រូវការធនធានសម្រាប់ការវិនិយោគ ដើម្បីសម្រេចបានទិសដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ សម្រាប់រយៈពេលពាក់កណ្ដាលអាណត្តិទៀតដែលនៅសល់របស់ផែនការ។

៥.២- ចំពោះបញ្ហាប្រឈមមួយចំនួនដែលកើតឡើងដោយសារការីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកាត់បន្ថយការចំណាយមួយចំនួន រួមទាំងចំណាយវិនិយោគផងដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩នៅកម្ពុជា ជាពិសេសការទិញនិងចាក់វ៉ាក់សាំងដល់ប្រជាជននិងព្យាបាលអ្នកជំងឺកូវីដ-១៩។ លើសពីនេះទៀត ចំណូលពីពន្ធក៏មានធ្លាក់ចុះដោយសារអាជីវកម្មមួយចំនួនធំត្រូវបានផ្អាកដំណើរការ។

៥.៣- សម្រាប់រយៈពេលពាក់កណ្ដាលអាណត្តិទៀតដែលនៅសល់របស់ផ.យ.អ.ជ. រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវការទុនវិនិយោគមូលធនសរុបចំនួន២៧ ៨៧១លានដុល្លារអាម៉េរិក សមមូល១១៣ ១៥៦ពាន់លានរៀល ដែលក្នុងនោះ៖

- វិនិយោគមូលធននៃវិស័យសាធារណៈ មានចំនួន៧ ៧០៦,៥លានដុល្លារអាម៉េរិក សមមូល ៣១ ២៨៨ពាន់លានរៀល ប្រមាណ២៧,៧%នៃទុនវិនិយោគសរុប
- វិនិយោគមូលធនរបស់វិស័យឯកជន មានចំនួន២០ ១៦៥,៥លានដុល្លារអាម៉េរិក សមមូល ៨១ ៨៧១ពាន់លានរៀល ប្រមាណ៧២,៣%នៃទុនវិនិយោគសរុប។

**តារាង៥.១ : ការវិនិយោគមូលធនចាំបាច់ ដើម្បីសម្រេចបានកំណើនផ.ស.ស.ដែលបានគ្រោងទុក និងធនធានដែលអាចមានសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគចាំបាច់**

(គិតជាលានដុល្លារអាម៉េរិក)

| ប្រភពហិរញ្ញប្បទាន | ២០២១/ កក្កដា ២០២១ | ២០២២ | ២០២៣ | សរុប កក្កដា ២០២១-២០២៣ |
|---|---|---|---|---|
| វិនិយោគមូលធនសរុប | ១០ ១៥៨/ ៥ ០៧៩ | ១០ ៨៦៧ | ១១ ៩២៥ | ២៧ ៨៧១ |
| • វិនិយោគសាធារណៈ | ២ ៩៥៣/ ១ ៤៧៦,៥ | ២ ៩៦៨ | ៣ ២៦២ | ៧ ៧០៦,៥ |
| • វិនិយោគឯកជន | ៧ ២០៥/ ៣៦០២,៥ | ៧ ៨៩៩ | ៨ ៦៦៤ | ២០ ១៦៥,៥ |

ប្រភព : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ខែសីហា ឆ្នាំ២០២១)

សម្គាល់ : អត្រាប្តូរប្រាក់១ដុល្លារអាម៉េរិកស្មើនឹង៤ ០៦៥រៀល

៥.៤- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍនានា ជាពិសេសដៃគូអភិវឌ្ឍដែលជាទូទៅផ្តល់កិច្ចគាំទ្រដល់ការអភិវឌ្ឍនៅកម្ពុជា រួមមានជំនួយបច្ចេកទេស សម្ភារៈ និងហិរញ្ញវត្ថុជាដើម។ ដោយសារការធ្លាក់ចុះនៃហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ជាពិសេសហិរញ្ញប្បទានឥតសំណង តួនាទីរបស់វិស័យឯកជនត្រូវបានទទួលស្គាល់កាន់តែទូលាយនិងដើរតួនាទីជាហិរញ្ញប្បទានសាធារណៈក្នុងស្រុក។

៥.៥- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តការពង្រឹងនិងការធ្វើឱ្យប្រសើរឡើងនូវសង្គតិភាពរវាងការរៀបចំផែនការ រួមទាំងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជាមួយនឹងការអនុវត្តចំណាយវិនិយោគសាធារណៈ ក៏ដូចជាហិរញ្ញប្បទានសហប្រតិបត្តិនានា តាមរយៈការអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដើម្បីធានាឱ្យមានការបន្សុីគ្នា ការផ្សារភ្ជាប់រវាងផែនការនិងថវិកានឹងត្រូវធ្វើឡើងរវាងការរៀបចំផែនការ( ដាក់ចេញនៅក្នុងផ.យ.អ.ជ. និងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.) បីឆ្នាំរំកិល ដែលទទួលខុសត្រូវដោយក្រសួងផែនការ ) ជាមួយនឹងចំណូលនិងការរៀបចំថវិកាវិនិយោគ( ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា ដែលធ្វើឡើងដោយក្រសួង ស្ថាប័ន និងទទួលខុសត្រូវដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ )។

៥.៦- រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តពង្រីកនូវវិសាលភាពនិងការប្រើប្រាស់នូវភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ក្នុងការផ្តល់តម្រូវការវិនិយោគ ដោយមានការយកចិត្តទុកដាក់ទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ ការប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ចូលរួមចំណែកក្នុងការកាត់បន្ថយនូវសម្ពាធលើធនធានមូលធន និងអាចទទួលបានការចូលរួមពីវិស័យឯកជនក្នុងការផ្តល់នូវសេវាសាធារណៈ ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍។

៥.៧- រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនល្បឿននៃកិច្ចខិតខំប្រឹងប្រែងក្នុងការរួមបញ្ចូលគ្នានៃដំណើរការក.វ.ស. បីឆ្នាំរំកិល និងការរៀបចំថវិកាវិនិយោគនៅក្នុងរង្វង់នៃផែនការយុទ្ធសាស្ត្រថវិកា( ស្ថិតក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ )។

៥.៨- រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងផែនការ នឹងបន្តពង្រឹងគុណភាពរបស់ក.វ.ស. បីឆ្នាំរំកិល ដែលជាឧបករណ៍ក្នុងការអនុវត្តអាទិភាពគោលនយោបាយក្នុងផ.យ.អ.ជ.។ កិច្ចការនេះនឹងជួយធានាថា តម្រូវការចំណាយចរន្តបន្ថែមនៃគម្រោងដែលបានស្នើឡើង ត្រូវបានយកចិត្តទុកដាក់ទៅលើថវិកាប្រចាំឆ្នាំ ហើយគម្រោងដែលបានបញ្ចូលទៅក្នុងក.វ.ស. បីឆ្នាំរំកិល ត្រូវបានចាត់ទុកជាគម្រោងអាទិភាពយ៉ាងច្បាស់លាស់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នត្រូវធានាថាកម្មវិធីនិងគម្រោងទាំងអស់ដែលដាក់បញ្ចូលនៅក្នុងក.វ.ស. បីឆ្នាំរំកិល នឹងត្រូវបានយកមកពិចារណាក្នុងការផ្តល់ហិរញ្ញប្បទាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ តាមរយៈក្រុមប្រឹក្សា

អភិវឌ្ឍន៍កម្ពុជានិងក្រសួង ស្ថាប័នត្រូវធានាថាសកម្មភាពកៀរគរធនធាន ត្រូវផ្ដោតទៅលើការស្វែងរកហិរញ្ញប្បទានសម្រាប់គាំទ្រដល់កម្មវិធីនិងគម្រោងទាំងនោះដែលមានក្នុងក.វ.ស. បីឆ្នាំរំកិល។

# ជំពូកទី៦

# ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ១- សេចក្តីផ្តើម

៦.១- ផ.យ.អ.ជ. ២០១៩-២០២៣ បានបញ្ជាក់ពីសារៈសំខាន់នៃការបង្កើតឱ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយ ដើម្បីអ្នកធ្វើគោលនយោបាយអាចវាស់វែងពីវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍នានា។ ផ.យ.អ.ជ. ២០១៩-២០២៣ បានបង្ហាញពីក្របខ័ណ្ឌលទ្ធផលដែលជាគោលការណ៍នៃខ្សែច្រវាក់លទ្ធផលមួយសម្រាប់វាយតម្លៃទំនាក់ទំនងរវាងធាតុចូល ធាតុចេញ លទ្ធផល និងឥទ្ធិពល។ ផ.យ.អ.ជ. ២០១៩-២០២៣ មានសូចនាករស្នូលនិងសូចនាករបន្ថែមសម្រាប់វាស់វែងវឌ្ឍនភាពការសម្រេចបានគោលដៅគោលនយោបាយនានា ដែលបញ្ជាក់ឱ្យឃើញថាក្របខ័ណ្ឌលទ្ធផលបង្កើតបានជាមូលដ្ឋានគ្រឹះមួយសម្រាប់បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជាទាំងមូល។ សូចនាករស្នូលនិងសូចនាករបន្ថែមដែលមាននៅក្នុងផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃវឌ្ឍនភាពឬសមិទ្ធផលតាមវិស័យ។

៦.២- របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣នេះ បានបង្ហាញអំពីតម្រូវការនិងការពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្សសម្រាប់អនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រកបដោយចីរភាព និងបញ្ជាក់ថាការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយ គឺជាដំណើរការដ៏វែងមួយដែលតម្រូវឱ្យមានការប្តេជ្ញាចិត្តនិងការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍនានា។

## ២- សមិទ្ធផល

៦.៣- **កំណែទម្រង់អភិបាលកិច្ច** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងសម្រេចបានវឌ្ឍនភាពល្អក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងការអនុវត្តថវិកាកម្មវិធីដែលបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ផ្សារភ្ជាប់គោលនយោបាយជាមួយនឹងការវិភាជថវិកា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានលើកកម្ពស់ការរៀបចំសូចនាករតាមដានរួមគ្នា ដែលជាឧបករណ៍មួយសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់តាមដានវឌ្ឍនភាពធៀបនឹងគោលដៅតាមវិស័យ។

៦.៤- **ការគ្រប់គ្រងព័ត៌មាន** ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានបង្កើតឡើងនៅតាមក្រសួង ស្ថាប័នមួយចំនួន ដូចជាក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងកសិកម្ម រុក្ខា

ប្រមាញ់ និងនេសាទ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័ន ដែលជាផ្នែកមួយនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្រសួងមហាផ្ទៃ បាននិងកំពុងពង្រឹងសមត្ថភាពទាក់ទឹងនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅថ្នាក់ក្រោមជាតិបន្តិចម្តងៗផងដែរ។ ប្រព័ន្ធព័ត៌មានទាំងនេះ បង្ហាញពីវឌ្ឍនភាពល្អលើការប្រមូលនិងការគ្រប់គ្រងទិន្នន័យ ដែលគាំទ្រដល់ផ្នែករដ្ឋបាលនិងការរៀបចំគោលនយោបាយ។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានជួយអ្នករៀបចំផែនការតាមដានសូចនាករសំខាន់ៗ សម្រាប់តាមដានវឌ្ឍនភាពធៀបនឹងគោលដៅតាមវិស័យ។

៦.៥- **ការប្រមូលទិន្នន័យ** ក្រសួងផែនការបានផ្តល់ប្រភពទិន្នន័យធំៗមួយចំនួនតាមពេលកំណត់ដែលជួយឱ្យអ្នករៀបចំផែនការក្នុងការវាយតម្លៃវឌ្ឍនភាពរយៈពេលវែង។ ទិន្នន័យទាំងនេះ រួមមានជំរឿនប្រជាជនដែលរៀបចំឡើងរៀងរាល់១០ឆ្នាំ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ដែលរៀបចំឡើងរៀងរាល់២ឆ្នាំ អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាដែលរៀបចំឡើងរៀងរាល់៤ឆ្នាំ និងទិន្នន័យឃុំ សង្កាត់ ទិន្នន័យគ្រួសារក្រីក្រនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាពិសេសបានរៀបចំបង្កើតក្របខ័ណ្ឌសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ និងរបាយការណ៍វិភាគស៊ីជម្រៅមួយចំនួនទៀត សម្រាប់តាមដានពីវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣។

៦.៦- **សមត្ថភាពស្ថាប័ននិងធនធានមនុស្ស** ក្រសួងផែនការ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍ ជាពិសេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន និងមន្ត្រីផែនការនៅថ្នាក់ក្រោមជាតិ។

## ៣- បញ្ហាប្រឈម

៦.៧- **ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ** វឌ្ឍនភាពមួយចំនួនសម្រេចបាននៅក្នុងវិស័យមួយចំនួនក្នុងការប្រមូលនិងរាយការណ៍ទិន្នន័យ ប៉ុន្តែមិនទាន់បានប្រមូលផ្តុំគ្នាតែមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជាទាំងមូល ដោយសារក្រសួង ស្ថាប័នប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា ដែលមិនត្រូវបានណែនាំដោយគោលការណ៍រួម វិធីសាស្ត្របន្ថែម និងការប្រើប្រាស់ពាក្យបច្ចេកទេសដូចគ្នានៅឡើយ។

៦.៨- **ការផ្តល់អាទិភាពដល់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ** ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃមិនទាន់ត្រូវបានផ្តល់ជាអាទិភាពនៅតាមក្រសួង ស្ថាប័ន និងមិនទាន់មានការវិភាជថវិកាគ្រប់គ្រាន់សម្រាប់ការងារនេះនៅឡើយ។ ការយល់ដឹងរបស់មន្ត្រីនៅតាមក្រសួង ស្ថាប័នមួយចំនួននៅមានកម្រិតទាក់ទងនឹងការគ្រប់គ្រងដោយផ្អែកលើលទ្ធផល ក្របខ័ណ្ឌលទ្ធផលនិងការអនុវត្តការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

## ៤- ជំហានបន្ទាប់

៦.៩- រាជរដ្ឋាភិបាលកម្ពុជា នឹងរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិមួយ ដើម្បីបំពេញបន្ថែមលើប្រព័ន្ធស្ថិតិជាតិនានា ដូចជាជំរឿនប្រជាជន ជំរឿនកសិកម្ម អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា និងអង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាជាដើម រួមទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅតាមវិស័យ ដូចជាវិស័យអប់រំនិងសុខាភិបាលជាដើម។ ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិនេះ នឹងធានានូវគុណភាពនិងភាពអាចជឿទុកចិត្តរបស់ទិន្នន័យដែលប្រមូលបាន និងផ្សព្វផ្សាយត្រឹមត្រូវតាមស្តង់ដា និងលើកកម្ពស់ការផ្លាស់ប្តូរទិន្នន័យនិងព័ត៌មានតាមវិស័យបានទូលំទូលាយនិងមានតម្លាភាព។

៦.១០- រាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវពន្លឿនការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិដែលផ្សារភ្ជាប់ក្របខ័ណ្ឌលទ្ធផលជាមួយថវិកាកម្មវិធី។ ការផ្សារភ្ជាប់នេះ នឹងជួយដល់អ្នករៀបចំផែនការនិងអ្នករៀបចំគោលនយោបាយ ធ្វើការវិភាគផលចំណេញផ្នែកសេដ្ឋកិច្ចនិងលើការវិនិយោគកាន់តែបានប្រសើរ។

៦.១១- រាជរដ្ឋាភិបាលកម្ពុជា នឹងធានាចីរភាពក្នុងការវិភាជថវិកានិងការកៀរគរថវិកានិងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍនានាសម្រាប់គាំទ្រការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

៦.១២- រាជរដ្ឋាភិបាលកម្ពុជា នឹងពង្រឹងសមត្ថភាពមន្ត្រីនៅគ្រប់ក្រសួង ស្ថាប័ន បន្ថែមទៀតទាក់ទងនឹងការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជាពិសេសការវិភាគនិងបកស្រាយទិន្នន័យ។

# ជំពូកទី៧

# សេចក្ដីសន្និដ្ឋាន

៧.១- រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានវឌ្ឍនភាពជាច្រើនសម្រាប់ការអនុវត្តពាក់កណ្ដាលអាណត្តិនៃការអនុវត្តផ.យ.អ.ជ.២០១៩-២០២៣ ក្នុងផ្នែកសំខាន់ៗរបស់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ទោះបីរាជរដ្ឋាភិបាលត្រូវប្រឈម ដោះស្រាយ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ។ ការសម្រេចបានសមិទ្ធផលទាំងនេះ គឺដោយសារការដឹកនាំដ៏ឆ្លាតវៃនិងគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល និងភាពជាដៃគូក្នុងការវិនិយោគនិងអភិវឌ្ឍរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ព្រមទាំងការវិនិយោគរបស់វិស័យឯកជន។

៧.២- របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្តផ.យ.អ.ជ. ២០១៩-២០២៣ នេះ បានបញ្ជាក់ពីការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលសម្របសម្រួលនិងលើកកម្ពស់ប្រសិទ្ធភាព ភាពសក្តិសិទ្ធិ ចីរភាពនៃដំណើរការអភិវឌ្ឍនិងសមិទ្ធផលនានា។ របាយការណ៍នេះក៏បានបង្ហាញអំពីការយកចិត្តទុកដាក់ក្នុងការអនុវត្តអាទិភាពតាមវិស័យដើម្បីចូលរួមសម្រេចបានការងារអាទិភាពនានាដែលមានតាមមុំទាំងបួនរបស់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤(ការអភិវឌ្ឍធនធានមនុស្ស ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជននិងការងារ និងការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន)។

៧.៣- របាយការណ៍នេះ ក៏បានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយមួយដែលផ្តល់ជាការតម្រង់ទិសសម្រាប់ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍន៍នានា រួមមានគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា គោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម គោលនយោបាយជាតិមុខរបរ គោលនយោបាយជាតិប្រជាជន និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ជាដើម។

៧.៤- របាយការណ៍នេះបានទទួលស្គាល់ថារាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល និងវិស័យឯកជននឹងប្រឈមមុខរួមគ្នាជាមួយបញ្ហាប្រឈមដែលកំពុងកើតមាន ជាពិសេសការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងដំណើរការនៃការអភិវឌ្ឍប្រទេសជាតិ។ បរិបទអភិវឌ្ឍន៍សកល តំបន់ និងក្នុងស្រុកកាន់តែមានលក្ខណៈស្មុគស្មាញ តម្រូវឱ្យមានការពង្រីកការវិនិយោគដែលកាន់តែមានប្រសិទ្ធភាព ភាពសក្តិសិទ្ធិ និងចីរភាព។

៧.៥- របាយការណ៍នេះ បានបង្ហាញអំពីសមិទ្ធផលជាច្រើននៅក្នុងការកសាងសមត្ថភាព ប៉ុន្តែត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចបានគម្លាតសមត្ថភាពទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សម្រាប់ចូលរួមចំណែកក្នុងការសម្រេចបានអាទិភាពជាតិ។

៧.៦- និន្នាការនៃការអភិវឌ្ឍ បង្ហាញអំពីតម្រូវការពង្រីកនិងពន្លឿនការងារលើការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ការអនុវត្តផ.យ.អ.ជ. រួមជាមួយការប្រែប្រួលនៃបរិបទអភិវឌ្ឍន៍ តម្រូវឱ្យយកចិត្តទុកដាក់លើក្របខ័ណ្ឌលទ្ធផល ដែលអាចពង្រឹងនិងពង្រីកបានតាមរយៈការបង្កើតទំនាក់ទំនងច្បាស់លាស់រវាងក្របខ័ណ្ឌលទ្ធផលនិងកំណែទម្រង់ថវិកាកម្មវិធី។ ការផ្សារភ្ជាប់ធាតុចូលទៅនឹងលទ្ធផលនិងឥទ្ធិពល មានសារៈសំខាន់សម្រាប់វិភាគផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់ការវិនិយោគសាធារណៈ។

៧.៧- សម្រាប់ពាក់កណ្ដាលអាណត្តិពីរឆ្នាំកន្លះដែលនៅសល់របស់ផ.យ.អ.ជ. ២០១៩-២០២៣ ការសម្រេចបាននូវសមិទ្ធផលដ៏រឹងមាំទៅតាមកាលបរិច្ឆេទកំណត់ ក៏ដូចជាការដោះស្រាយបញ្ហាប្រឈមនានានៅក្នុងទិដ្ឋភាពនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងប្រទេស ក្នុងតំបន់និងក្នុងសកលលោក គឺមានសារៈសំខាន់ណាស់សម្រាប់ប្រទេសជាតិនិងប្រជាជន។ កម្ពុជានឹងត្រូវរៀបចំការអភិវឌ្ឍប្រភពធនធានថ្មីៗ ក៏ដូចជាការពិចារណាទៅលើការកៀរគរចំណូលក្នុងស្រុក សម្រាប់ផ្ដល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍជាតិ និងការរក្សាបាននូវវឌ្ឍនភាពសេដ្ឋកិច្ច សង្គមដែលសម្រេចបានកន្លងមក និងឈានទៅសម្រេចបាននូវគោលដៅអាទិភាពជាតិនិងចំណុចដៅនានាដែលមានចែងក្នុងផ.យ.អ.ជ. ២០១៩-២០២៣។

UNDP

UNFPA